នេះជាការវាយបញ្ចូលក្នុងកុំព្យូទ័ររបស់ខ្ញុំបាន ថៃ ម៉ុនឆាយ ជាធម្មទានៗ

# ជីវិតសន្តិភាព



# ជីវិតសន្តិភាព

## ដោយ

## ភិក្ខុធម្មបាល ទៀវ ជុំ


បោះពុម្ពផ្សាយដោយ

**គណធម្មទាន**

ព.ស ២៥១៤ គ.ស ១៩៧០



អ្នកនិពន្ធរក្សាសិទ្ធិ



**បោះពុម្ពសាឡើងវិញ គ.ស២០០១**

# អារម្ភកថា

សម័យនេះ ប្រទេសបានទទួលស្គាល់ព្រះពុទ្ធសាសនា តាមផ្លូវច្បាប់ផង តាមផ្លូវឃោសនាផង តាមផ្លូវប្រពៃណីនិយមផង។ តែពុទ្ធសាសនិកក្នុងប្រទេសយើង មានសេចក្តីចេះដឹងវិជ្ជាខាងពុទ្ធសាសនានៅពុំទាន់គ្រប់គ្រាន់សម្រាប់ដឹកនាំវិញ្ញាណនៃអាត្មា ឲ្យមានសន្តិភាពតាមគោលបំណងនៃព្រះពុទ្ធសាសនាឡើយ។ ដូច្នេះព្រោះអ្វី? ព្រោះយុវជន-យុវនារីរបស់ជាតិ បានធ្វើខ្លួនឲ្យទៅក្រៅឃ្លាតឆ្ងាយចាកវត្តដែលជាមជ្ឈមណ្ឌលអប់រំនៃ សីលធម៌ខាងផ្លូវចិត្តរបស់ជាតិស្ទើរតែរាល់ទីកន្លែង។ ការឆ្ងាយវត្ត ឆ្ងាយការអប់រំសីលធម៌ខាងផ្លូវចិត្តនៃយុវជីវិតទាំងឡាយរបស់ជាតិនោះមិនមែនកើតមានឡើងឯងៗទេ គឺកើតឡើងដោយការរស់នៅរបស់មនុស្សមានការទាក់ទងជាមួយនឹងសេដ្ឋកិច្ច ដែលចេះតែមានដំណើរប្រែប្រួលយ៉ាងលឿនរហ័សព្រោះតែមនុស្សម្នាក់ៗ ត្រូវការលើកឋានៈជីវភាពនៃខ្លួនឲ្យខ្ពស់ជាង ដែលធ្លាប់មានមកអំពីដើម ទើបជាឧបសគ្គដល់មនុស្សជំនាន់ក្រោយ ដែលខ្លួនគេបានធ្លាក់ទៅជានុយនៃសេចក្តីប្រាថ្នាខាងវិជ្ជាជីវៈច្រើនជាងចិត្តវិជ្ជា ដូចដែលធ្លាប់កើតមានឡើងក្នុងពិភពលោកខាងលិចនោះឯង។

យើងធ្លាប់បានរាប់អានពុទ្ធសាសនាមកអស់កាលយូរអង្វែង ហើយឃើញថាការរាប់អាននេះវាជារបស់ធម្មតា។ យើងគួរនាំគ្នាវិលត្រឡប់ទៅស្វែងរកទ្រព្យសម្បត្តិឲ្យបានយ៉ាងច្រើន ដើម្បីស៊ីចាយឲ្យបានសប្បាយម្តងវិញ នេះជាគំនិតត្រូវមួយដែរ តែមិនស្មើនឹងគំនិតដែលរកធម៌ផង រកទ្រព្យផងទេ ព្រោះសេចក្តីរីកចំរើនខាងសំភារៈដោយមិនមានរីកចំរើនខាងធម្មៈ ឬខាងចិត្តវិញ្ញាណនោះវាពុំបានឲ្យសេចក្តីសុខពិតប្រាកដជាស្ថាពរឡើយ។

ដូច្នេះ ទើបយើងមានការចាំបាច់ត្រូវសិក្សាវិជ្ជាពុទ្ធសាសនាឲ្យមានតុល្យភាពជាមួយនឹងវិជ្ជាសេដ្ឋកិច្ច និងវិជ្ជាវិទ្យាសាស្ត្រ ឬវិជ្ជាទាំងឡាយដទៃទៀតដែលប្រទេសជាតិរបស់យើងត្រូវការ។ ការសិក្សាវិជ្ជាខាងផ្លូវលោកនិងវិជ្ជាខាងផ្លូវធម៌ឲ្យបានគូនឹងគ្នាដូចនេះ គឺជាវិធីមួយដែលធ្វើមនុស្សយើងឲ្យមានសេចក្តី

រីកចំរើនទាំងផ្លូវសំភារៈទាំងផ្លូវចិត្តយ៉ាងល្អប្រសើរ។ ពុទ្ធសាស្ត្រជាមួយនឹងវិទ្យាសាស្ត្រទាំងពីរនេះជាធម្មជាតុមិនអាចទំនាស់ទំនើសដល់គ្នានឹងគ្នាទេ ។ យើងកាន់តែចេះដឹងវិទ្យាសាស្ត្រច្រើនដល់ថ្នាក់ណា គំនិតយើងក៏កាន់តែយល់ស្គាល់វិជ្ជាពុទ្ធសាសនាយ៉ាងច្រើនដល់ថ្នាក់នោះ។

ពុទ្ធធម៌ណា ដែលយើងមិនទាន់ចូលចិត្ត ឬ ចូលចិត្តពុំទាន់បានច្បាស់លាស់យើងត្រូវចាំទុកក្នុងចិត្ត យើងព្យាយាមគិតពិចារណាលុះត្រាចូលចិត្តបាន ។ ចំណែកយុវពុទ្ធសាសនិក ប្រសិនបើបានចេះដឹងរឿងបំពេញសេចក្តីល្អ លះបង់សេចក្តីអាក្រក់ និងរឿងសំអាតចិត្តឲ្យបរិសុទ្ធល្អមសមគួរហើយ កុំភ្លេចផ្សាយមេត្តាចិត្ត កុំភ្លេចអត់ធន់ កុំភ្លេចឲ្យអភ័យទោសដល់អ្នកដទៃ ជាពិសេសគឺគួរតំកល់ខ្លួននៅក្នុងសីលធម៌ ឲ្យដូចជាមាតាបិតាទាំងឡាយបានធ្វើដល់កូនរបស់ខ្លួននោះឡើយ។

ចំណែកពុទ្ធធម៌ក្នុងចំណុចណា ដែលយើងគិតចូលចិត្តហើយ បានល្បងពិសោធន៍មើលឃើញថាមានហេតុផលសមគួរ ល្អមដោយវិចារណញ្ញាណរបស់យើងហើយ យើងត្រូវថែរក្សារបស់មានតំលៃនេះទុកក្នុងចិត្តកុំឲ្យភ្លេចព្រោះការចេះដឹងពុទ្ធធម៌ នឹងនាំឲ្យខ្លួនយើងរួចផុតចាកភយន្តរាយទាំងពួង មានសេចក្តីសុខស្ងប់ប្រកបដោយគុណតំលៃ ច្រើនជាងសេចក្តីសុខដែលបានមកចាកការស្វែងរកសេចក្តីភ្លើតភ្លើនក្នុងលោកិយវិស័យ។

ការស្គាល់ព្រះពុទ្ធសាសនា គឺជាសំគាល់មួយសំរាប់ដាស់តឿនចិត្ត ឲ្យគិតដល់វឌ្ឍនធម៌ សីលធម៌ មនុស្សជាតិនិងប្រទេសជាតិដែលជាទីនៅអាស្រ័យជានិច្ច ប្រែថាចេះស្រឡាញ់ជាតិ ចេះការពារជាតិមិនឲ្យធ្លាក់ចុះក្នុងទំនៀមទំលាប់បរជាតិទាំងឡាយខ្លះ ក្នុងពិភពលោកខាងលិច ដែលមានលក្ខណៈមិនមោះសមជាមួយនឹងប្រទេស ជាមួយនឹងឧបនិស្ស័យនៃជាតិរបស់យើង។ គឺខ្លួនយើងម្នាក់ៗ ត្រូវព្យាយាមរៀនយកចំណេះវិជ្ជាល្អៗ អំពីលោកខាងលិចតែមិនភ្លេចនូវសីលធម៌ និងវឌ្ឍធម៌របស់ជាតិ ដែលបានធ្វើឲ្យយើងរស់នៅក្នុងសេចក្តីស្ងប់ មិនមានការបៀតបៀនគ្នាឯង មិនមានការសង្កត់សង្កិនជាតិដទៃ ពេញចិត្តរស់នៅក្នុងសភាពធម្មតារបស់ខ្លួន។

កាលណាយើងមានពុទ្ធធម៌នៅក្នុងចិត្តគ្រប់ពេលវេលា យើងនឹងរស់នៅក្នុងទីណាក៏បានស្រួល ហើយនឹងជាមនុស្សចេះតែមានគេរាប់អាន់ ។ ដូចនេះព្រោះអ្វី? ព្រោះមានពុទ្ធភាសិតថា ៖

**សុខំ យាវ ជរា សីលំ** សីលនាំមកនូវសេចក្ដីសុខលុះដល់ចាស់ជរា។

**សុខា សទ្ធា បតិដ្ឋិតា** សទ្ធាដែលមានតំណាំងយ៉ាងមាំនាំមកនូវសេចក្ដីសុខ។

**សុខោ បញ្ញាយ បដិលាភោ** ការមានបញ្ញានាំមកនូវសេចក្ដីសុខ។

**បាបានំ អករណំ សុខំ** ការមិនធ្វើនូវបាបទាំងឡាយនាំមកនូវសេចក្ដីសុខ។

សៀវនេះ ខ្ញុំឲ្យឈ្មោះថា "**ជីវិតសន្តិភាព**" ប្រែថា "**សេចក្ដីស្ងប់នៃជីវិត**"។ ដូចម្ដេចទើបខ្ញុំកាន់យកជីវិតសន្តិភាពជាឈ្មោះ ព្រោះខ្ញុំចង់មានបំណងឲ្យពុទ្ធសាសនិកទាំងឡាយ ជាពិសេសគឺពុទ្ធសាសនិកក្នុងប្រទេសយើង មានជីវិតរស់នៅប្រកបដោយសេចក្ដីសុខស្ងប់ ដែលគេទាំងអស់គ្នាប្រហែលចង់បានបើមិនច្រើនក៏តិចដែរ។

នៅទីបំផុតនេះ ខ្ញុំសូមឧទ្ទិសផលនៃការសរសេរសៀវភៅនេះ ថ្វាយចំពោះសម្ដេចព្រះមហាក្សត្រិយានីជាព្រះមាតាជាតិ និងសម្ដេចឧបយុវរាជនរោត្តមសីហនុជាព្រះប្រមុខរដ្ឋខ្មែរ ដោយអំណាចកុសលនេះ សូមឲ្យព្រះអង្គទ្រង់បានប្រកបដោយជោគជ័យក្នុងព្រះរាជបេសកកម្មគ្រប់យ៉ាង សមតាមព្រះរាជបំណងនិងព្រះឧត្តមគតិរបស់ព្រះអង្គ កុំគប្បីមានឃ្លាងឃ្លាតឡើយ។

ជូនចំពោះប្រជាពលរដ្ឋខ្មែរ និងប្រជាពលលោក សូមបានសំរេចនូវសុខសន្តិភាព អស់កាលជានិរន្តន៍ទៅហោង។

**ភ្នំពេញ**

**លង្កាព្រះកុសុមារាម**

នៅថ្ងៃទី ១០ ខែ កុម្ភៈ ឆ្នាំ ១៩៧០

**ភិក្ខុធម្មបាល ខៀវ ជុំ**

# វាចារបស់ខ្ញុំ

ខ្ញុំព្រះករុណា ខ្ញុំបាទសូមថ្វាយបង្គំព្រះពុទ្ធ ព្រះធម៌ ព្រះអង្គជាទីពឹងដ៏ខ្ពង់ខ្ពស់បំផុតក្នុងលោក និងបងប្អូនជនរួមជាតិទាំងអស់ ដោយហេតុមានសេចក្តីជ្រះថ្លានិងព្រះពុទ្ធសាសនា ដែលជាសាសនាប្រដៅមនុស្សឲ្យមាននៅមេត្តាធម៌ ករុណាធម៌ ចំពោះសត្វលោកទាំងអស់ ក៏បានញុាំងចិត្តរបស់ខ្ញុំឲ្យមាននៅសេចក្តីព្យាយាមខ្លាំងក្លា ដើម្បីវាយនូវអត្ថបទជាច្រើនកន្លងមកហើយ ហើយនេះជាការព្យាយាមដោយចិត្តជ្រះថ្លាផលដែរ។

ដោយសេចក្តីជ្រះថ្លានិង ដោយចិត្តគោរពគុណធម៌ព្រះពុទ្ធ និងសាវ័ករបស់ព្រះអង្គទាំងអស់ ក៏សូមឧទិសកុសលទាំងនេះជូនដល់ ធម្មបាល **ខៀវ ជុំ** សូមលោកបានរួចទុក្ខចាកទុក្ខទាំងពួង និងសូមជូនបុណ្យកុសលចំពោះ លោកគ្រូជាម្ចាស់ **ម៉ុត សាវឌ្ឍ** សូមឲ្យលោកមានសុខភាពល្អបរិបូណ៌ដើម្បីបំពេញសេចក្តី ល្អតរាងទៅ និងសូមឧទិសកុសលដល់ មាតាបិតាខ្ញុំបាទឪពុក **ថៃ គីមឈាត** ម្តាយ **ផាត់ ឡេង** និងបងប្អូនរបស់ខ្ញុំ និងមិត្តទាំងអស់គ្នា សូមបាននូវសេចក្តីសុខ សេចក្តីចំរើនគ្រប់វេលាពេល។

**ភ្នំពេញ**

ថ្ងៃទី ២៨ ខែ កុម្ភៈ ព.ស ២៥៥៦

**ថៃ ម៉ុន ឆាយ**

□□□

# ទំព័រពិសេស

**ព្រះពុទ្ធគឺជានរណា?** គឺជាបុគ្គលមានភាពបរិសុទ្ធ. ភាពស្ងប់. ភាពភ្លឺស្វាងក្នុងជីវិត។ អ្នកអានអាចស្គាល់បានដោយពាក្យដែលស្តីអំពីពុទ្ធប្រវត្តិក្នុងសៀវភៅនោះ។

**ព្រះធម៌គឺជាអ្វី?** គឺជាធាតុសំរាប់ធ្វើអ្នកប្រតិបត្តិឲ្យកើតបានជាមនុស្ស. ធ្វើមនុស្សសាមញ្ញឲ្យទៅជាអរិយមនុស្ស. លុះត្រាបានសំរេចជាពុទ្ធមនុស្សក្នុងទីបំផុត។ អ្នកអានអាចស្គាល់បានដោយពាក្យដែលស្តីអំពីធម៌ក្នុងសៀវភៅនេះ។

**ព្រះសង្ឃគឺជាមនុស្សពួកណា?** គឺជាបុគ្គលដែលខំប្រឹងអនុវត្តនូវជីវិតរបស់ខ្លួនឲ្យមានភាពបរិសុទ្ធ. ភាពស្ងប់. ភាពភ្លឺស្វាង. ដូចគ្នានឹងជីវិតព្រះពុទ្ធហ្នឹងឯង។ អ្នកអានអាចស្គាល់បាន ដោយពាក្យដែលស្តីអំពី **លោកុត្តចិត្ត** ឬ **លោកុត្តរធម៌** ដែលមានចែងក្នុងសៀវភៅនេះផងដែរ។

†††

# បនទី ១

# ជីវប្បវត្តិនៃព្រះសម្ពុទ្ធ

១- មហាសត្វសិទ្ធត្ថៈ ជាព្រះឱរសរបស់ព្រះចៅសុទ្ធោទនៈនិងព្រះនាងមហាមាយា ក្សត្រគ្រប់គ្រងសក្កជនបទនៃប្រជាជតិអរិយកៈ ក្នុងរយៈកាលជិត ២៦០០ឆ្នាំកន្លងទៅ។ សក្កជនបទនេះ ឋិតនៅក្នុងភាគខាងលើនៃប្រទេសឥណ្ឌា ជិតហិមាល័យបព៌ត ឋិតនៅក្នុងអាណាខេត្តហិមពាន្ត (ព្រំដែននេប៉ាល)។

២- ព្រះមហាសត្វបានប្រសូតនាឧទ្យានលុម្ពិនីវ័ន ខាងក្រោមម្លប់ឈើឈ្មោះសាលៈ ក្នុងថ្ងៃ ១៥កើត ខែវិសាខ គិតរយៈកាលបាន ៨០ឆ្នាំមុនពុទ្ធសករាជ។

៣- ព្រះនាងមហាមាយាប្រសូតព្រះឱរសហើយ រស់នៅបាន ៧ថ្ងៃក៏ទីវង្គត(អស់ព្រះជន្មាយុ)។ ព្រះនាងបជាបតិគោតមី ជាម្តាយមីងទ្រង់បានទទួលអភិបាលព្រះអង្គតមក។

៤- មានទំនាយថា ៖ បើមហាសត្វសិទ្ធត្ថៈ រស់នៅក្នុងឃរាវាសវិស័យ នឹងបានជាចក្រពត្តិរាជ មានអំណាចទូទៅលើបរិមណ្ឌល មានទីបំផុតនៃមហាសមុទ្រទាំង ៤ ជាព្រំដែន។ បើនឹងចេញសាងផ្នួស នឹងបានជាសាស្តាឯកក្នុងលោកមិនមានសាស្តាណាដទៃ មានគុណវុឌ្ឍិប្រៀបផ្ទឹមបាន

៥- ព្រះរាជបិតាទ្រង់ជ្រាបនូវគតិក្នុងអនាគតនៃព្រះឱរសដូចនេះ តាមការទស្សន៍ទាយរបស់ពួកព្រាហ្មណ៍ ព្រះអង្គទ្រង់មានបារម្ភជានិច្ចចំពោះភ័ព្វវាសនាទ្រង់ផ្នួសនៃព្រះឱរស ជាភ័ព្វវាសនាដែលព្រះអង្គមិនពេញព្រះទ័យ ទើបទ្រង់ចងព្រះរាជបុត្រដោយសេចក្តីសប្បាយភ្លើតភ្លើនផ្សេងៗ ជាមួយនឹងការបង្ខាំងមិនឲ្យឃើញរឿងទុក្ខ រឿងកង្វល់ដែលជាវត្ថុធាតុតែងមានជាធម្មតាសម្រាប់មនុស្សសត្វក្នុងសកលលោក។

៦- កាលមហាសត្វសិទ្ធត្ថៈទ្រង់ចំរើនវ័យ មានព្រះជន្មាយុ ១៦ឆ្នាំក៏ត្រូវ

បានគេនាំយកព្រះនាងយសោធរា ព្រះរាជធីតានៃក្សត្រកោលិយវង្ស សឹងជាប់ជាព្រះញាតិរបស់ព្រះអង្គ មកអភិសេកជាព្រះជាយា។ មហាក្សត្រសោយសុខសម្បត្តិតាមប្រពៃណីលោក លុះព្រះជន្មបាន ២៩វស្សា ទ្រង់មានព្រះឱរសមួយព្រះអង្គទ្រង់ព្រះនាម "រាហុលកុមារ" ។

៧- ខាងក្រោយសម្រេចព្រះពោធិញ្ញាណ ព្រះអង្គទ្រង់មានតម្រាស់ថា "ពេលដែលយើងមានអាយុនៅក្នុងយុវវ័យ មានសក់ខ្មៅព្រីក មានសាច់ម៉ដ្ឋផង់មានសម្បុរថ្លាស្រស់...... ខណៈដែលមាតាបិតារបស់យើងមិនពេញព្រះទ័យនឹងផ្នួសរបស់យើង ព្រះអង្គកំពុងកន្ទក់កន្ទេញប្រាស់ប្រាល់ មានព្រះភ័ក្ត្រជោកសើមទៅដោយទឹកនេត្រា ទ្រង់កន្សែង ទ្រង់រាព្រះហស្តជាមួយនឹងព្រះរាជបន្ទូលថា ៖ "កុំ កុំ" យើងបានដាក់កេសានិងមស្សុហើយជាស្រេច ព្រមជាមួយគ្នានេះយើងក៏បានស្លៀកពាក់ដោយសំពត់មានពណ៌លឿង (កាសាវពស្ត្រ) យើងបាននាំជីវិតរបស់យើងឲ្យដល់ទៅផ្លូវប្រតិបត្តិមួយ ដែលអ្នកផងបានស្គាល់ថា ជាជនមិនមានផ្ទះ "ប្រែថា យើងចេញចាកភាពជាមនុស្សមានផ្ទះទៅកាន់ភាពជាមនុស្សប្រាសចាកផ្ទះ ដើម្បីស្វែងរកនូវទីបំផុតនៃទុក្ខ" ។

៨- ក្នុងការស្វែងរកសម្មាសម្ពោធិញ្ញាណ ជាដំបូងព្រះអង្គទ្រង់ចារិកនទៅជួបនឹងគណាចារ្យនានា ដែលក្នុងសម័យនោះខ្លួនគេម្នាក់ៗសុទ្ធតែមានលទ្ធិមួយៗ សំរាប់ផ្សាយល័ខគោលនៃទ្រឹស្តី ដល់ជនណាដែលសូមរៀនអំពីគេ។ ព្រះអង្គទ្រង់បានសាកល្បងរៀនយកនូវទ្រឹស្តីក្នុងលទ្ធិនោះៗ ហើយទ្រង់ធ្វើការពិសោធន៍យ៉ាងដិតដល់លទ្ធផលក្នុងរឿងទាំងអស់នោះគឺមិនបានរួច ផុតចាកទុក្ខ។ បន្ទាប់មក ទើបទ្រង់ចារិកទៅក្នុងមគធជនបទ រហូតលុះដល់តំបន់ឧរុវេលាសេនានិគម ដែលសព្វថ្ងៃនេះហៅថា "ពុទ្ធគយា" ទ្រង់ស្នាក់អាស្រ័យក្នុងទីនោះ ហើយទ្រង់បំពេញទុក្ករកិរិយាយ៉ាងខ្លាំងក្លាបំផុត លទ្ធផលក្នុងរឿងនេះ គឺទ្រង់បានត្រឹមតែដឹងថា ៖ *"ទុក្ខវេទនានោះ វាក៏មានកម្លាំងខ្លាំងក្លាត្រឹមតែប៉ុណ្ណោះ វាមិនមានកម្លាំងខ្លាំងក្លាជាងនេះទៅទៀតទេ នេះក៏វាមិនមែនជាផ្លូវត្រូវសម្រាប់ជីវិតសន្តិភាពឡើយ" ។*

៩- លុះទ្រង់សន្និដ្ឋានដូចនេះហើយ ទើបទ្រង់ផ្លាស់កម្មវិធី គឺទ្រង់ត្រឡប់

សោយអាហារដើម្បីជួសជុលកម្លាំងរូបកាយ ឲ្យបានរឹងពឹងមាំមួនដូចប្រក្រតីវិញ។ តមក ទ្រង់ផ្តើមធ្វើវត្តប្រតិបត្តិតាមកម្មវិធីកែប្រែថ្មី គឺហ្វឹកហាត់ចិត្តឲ្យសម្លឹងមើលចុះក្នុងអារម្មណ៍តែមួយ ដែលគេបានស្គាល់គ្រប់គ្នាថាជាកម្មដ្ឋាននុ៎ះឯង។ ក្នុងទីបំផុតនៃសេចក្តីព្យាយាមនេះ ព្រះអង្គក៏បានត្រាស់ដឹងសម្មាសម្ពោធិញ្ញាណ នាក្រោមម្លប់ឈើមួយមានឈ្មោះថា "អស្សត្ថព្រឹក្ស" នៅជិតមាត់ស្ទឹងនេរញ្ជរា ក្នុងព្រះជន្មបាន ៣៥ ព្រះវស្សា គិតពីថ្ងៃចេញបព្វជ្ជារហូតលុះដល់ថ្ងៃបានត្រាស់ដឹងជាវេលា ៦ឆ្នាំគត់។

១០- ទ្រង់គង់ពិចារណា ឈានទៅខាងក្រោមម្លប់នៃមហាពោធិ ក្នុងរាត្រីនោះទ្រង់បានឰចក្ខុញ្ញាណ ប្រែថា ៖ មានសេចក្តីដឹងយ៉ាងទូលំទូលាយ ដូចមានភ្នែកទិព្វ ទ្រង់រលឹកឃើញនូវអតីតជាតិរបស់ព្រះអង្គនិងសត្វទាំងឡាយ ជាពិសេសគឺទ្រង់ដឹងថា ៖ សត្វទាំងឡាយមាការកើតរលត់មានសុខ-ទុក្ខ-ល្អ-អាក្រក់... ផ្សេងៗគ្នាដោយអំណាចនៃ "កម្ម"។ ព្រះអង្គទ្រង់ត្រាស់ដឹងនូវមគ្គទាំងឡាយ គឺផ្លូវមានអង្គ ៨ ប្រាការ ជាផ្លូវដឹកនាំមនុស្សឲ្យដល់នូវភាពជាអរិយៈ ជាផ្លូវដឹកនាំសត្វឲ្យដល់នៅទីបំផុតនៃទុក្ខទាំងពួងយ៉ាងពិតប្រាកដ។

១១- ព្រះបរមសាស្តាចារ្យទ្រង់ត្រាស់ដឹងត្រូវដោយព្រះអង្គឯង ទ្រង់ស្រាវជ្រាវឃើញនូវសេចក្តីពិតព្រមទាំងទ្រង់ធ្វើនូវសេចក្តីបញ្ជាក់ តាមសេចក្តីពិតថា ៖ *សាកលចក្រវាឡនេះស្ថិតនៅខាងក្រោមអំណាចនៃកម្ម បុគ្គលម្នាក់ៗនឹងត្រូវមានចំណែកក្នុងការទទួលផលអំពី* ***កាយកម្ម វចីកម្ម មនោកម្ម ។*** *សត្វទាំងឡាយរមែងត្រូវធ្វើកម្មជានិច្ច ជាកម្មល្អក៏មាន ជាកម្មអាក្រក់ក៏មាន លុះដល់បញ្ញាជាគ្រឿងរំលាយនូវកិលេស ដែលជាគ្រឿងចងភ្ជាប់នូវសត្វឲ្យជាប់ជំពាក់ជាមួយនឹង "វដ្តសង្សារ" ទើបអាចស្វែងរកផ្លូវចេញចាកទុក្ខបាន។*

១២- ក្រោយពីព្រះអង្គទ្រង់សោយវិមុត្តិសុខ គឺសុខកើតអំពីការរួចផុតស្រឡះចាកកិលេសាសវៈ និងផលនៃកម្មអស់រយៈកាល ៧ ថ្ងៃ។ ព្រះអង្គទ្រង់រំពឹងគិតក្នុងព្រះទ័យថា ៖ នឹងមិនសំដែងធម៌ដែលទ្រង់រកឃើញ ដើម្បីឲ្យបានជាពន្លឺនៃវិញ្ញាណរបស់មនុស្សលោកឡើយ។ ដូចនេះ ព្រោះអ្វី? ព្រោះទ្រង់យល់ឃើញថា ៖ ធម៌នេះមានជម្រៅជាអតិបរមា សត្វទាំងឡាយដែលកំពុង

ត្រេកអរក្នុងកាមសុខមិនងាយនឹងយល់តាមបានឡើយ។

១៣- កាលទ្រង់ពិចារណាឃើញសេចក្តីទុក្ខលំបាករបស់សត្វលោកកាន់តែច្រើនឡើង ព្រះទ័យព្រះអង្គក៏កាន់តែមានមេត្តាករុណាដល់សត្វទាំងឡាយយ៉ាងខ្លាំងក្លា ក្នុងទីបំផុត ព្រះអង្គទ្រង់កាត់ព្រះទ័យប្រកាសធម៌ដែលទ្រង់បានត្រាស់ដឹងប្រោសសត្វលោកក្នុងពេលនោះទៅ។

១៤- ព្រះអង្គទ្រង់ចារិកចាកតំបន់ឧរុវេលាសេនានិគម ទៅកាន់ព្រៃឥសីបតនមិគទាយវ័ន នាដែនពារាណសី (ក្នុងបច្ចុប្បន្នហៅថាសារនាថ) នៅក្នុងទីនោះ ព្រះអង្គទ្រង់សំដែងធម៌ដល់បញ្ចវគ្គីយ៍ទាំង ៥ រូប ដែលធ្លាប់បានបំរើព្រះអង្គ ក្នុងគ្រាបំពេញទុក្ករកិរិយា។ ព្រះធម្មទេសនានេះ ក្រោយមកត្រូវបានឲ្យឈ្មោះថា "**ធម្មចក្រ**" ឬ "**ធម្មចក្កប្បវត្តនសូត្រ**" ក្នុងសូត្រនេះព្រះអង្គទ្រង់បានវែកញែក សម្តែងឲ្យឃើញនូវផ្លូវឆ្វេងផុតនិងផ្លូវស្តាំផុត ដែលគេនៅចេះចាំបានគ្រប់គ្នាថា "**កាមសុខល្លិកានុយោគ និង អត្តកិលមថានុយោគ**" គឺ "**កាមសុខល្លិកានុយោគ**" ជាផ្លូវស្តាំផុត "**អត្តកិលមថានុយោគ**" ជាផ្លូវឆ្វេងផុត។ ព្រះអង្គទ្រង់បញ្ជាក់ព្រមទាំងណែនាំថា ផ្លូវទាំងពីរនេះ ផ្លូវទៅមិនដល់ (កាមសុខល្លិកានិយោគ" ផ្លូវទៅហួស (អត្តកិលមថានុយោគ) ផ្លូវនេះបព្វជិតក្នុងព្រះពុទ្ធសាសនាមិនត្រូវសេពគប់មិនត្រូវដើរតាមឡើយ។ នៅចន្លោះផ្លូវទាំងពីរនេះ មានផ្លូវមួយទៀតឈ្មោះ "**មជ្ឈិមាបដិបទា**" ដែលសម្តែងឡើង ដោយព្រះសម្មាសម្ពុទ្ធដូចគ្នាដែរ *ផ្លូវនេះបានដល់អរិយមគ្គប្រកបដោយអង្គ ៨ប្រការ មានសម្មាទិដ្ឋិ បញ្ញាឃើញអរិយសច្ចៈ ៤ ជាដើម ដែលនៅក្នុងពេលជាមួយគ្នានោះ ព្រះអង្គទ្រង់សំដែងអំពីអរិយសច្ចៈ ៤ ប្រោសបញ្ចវគ្គីយ៍ឥសីទាំង ៥ រូបផងដែរ។*

១៥- ព្រធម្មទេសនារបស់ព្រះអង្គដែលទ្រង៉ាបានសំដែងអំពីអរិយសច្ចៈ ៤ នោះគឺ "**ទុក្ខ**" ទ្រង់បញ្ជាក់ថាអ្វីៗទាំងអស់ រស់នៅបានដោយលំបាក ដោយធន់ទ្រាំ។ **សមុទយៈ** ហេតុឲ្យកើតទុក្ខកើតព្រួយ ទ្រង់បញ្ជាក់ថា សេចក្តីទុក្ខសេចក្តីព្រួយនោះកើតមកអំពីហេតុមួយ ដែលមាននៅក្នុងវិញ្ញាណនៃសត្វទាំងឡាយ ដែលវាចេះតែវាតពង្រីកនូវចំណង់ទៅលើធម្មជាតុនិងវត្ថុធាតុទាំងឡាយមិនមានឈប់ឈរ។ **និរោធៈ** ទ្រង់បញ្ជាក់ថា ដើម្បីដកចេញឲ្យអស់នូវសេចក្តី

ទុក្ខ ត្រូវរលក់នូវហេតុនៃទុក្ខត្រូវប្រព្រឹត្តតាមអង្គមគ្គទាំង ៨ ឬដើរតាមផ្លូវប្រកប ដោយអង្គ ៨ ប្រការ មានសម្មាទិដ្ឋិជាដើម។

១៦- ព្រះបរមសាស្តា ទ្រង់ប្រកាសសាសនាចារិកនិមន្តទៅក្នុងដែននិង ជនបទនានា ក្នុងភាគលើនៃប្រទេសឥណ្ឌា គិតជាវេលាបាន ៤៥ឆ្នាំ។

១៧- ក្នុងពេលនោះ តណាចារ្យទាំងឡាយកើតមានសេចក្តីច្រណែន ឬស្យាដល់ព្រះអង្គ ដែលប្រជាជនទូទៅនិយមស្រឡាញ់រាប់អាន។ អាចារ្យទាំង ឡាយនោះបានព្យាយាមធ្វើឃាតព្រះអង្គជានិច្ច។ បុគ្គលដែលព្យាយាមធ្វើឃាត ព្រះអង្គដោយចេញមុខជាក់ស្តែងជាងគេ គឺព្រះទេវទត្តដែលជាប់ជាព្រះញាតិ របស់ព្រះអង្គតែសេចក្តីព្យាយាមរបស់បុគ្គលទាំងអស់នោះ ពុំបានសម្រេច ឡើយ។

១៨- ក្នុងពេលជាខាងក្រោយ នៃការឆាន់បច្ឆិមបិណ្ឌបាតទានរបស់នាយ ចុន្ទជាបុត្តនៃជាងមាសហើយព្រឹកឡើងជាថ្ងៃ ១៥ កើតខែវិសាខ ព្រះបរម សាស្តាទ្រង់រំលត់ខន្ធបរិនិព្វាន ក្នុងនគរកុសិនារា នាក្រោមម្លប់ឈើសាលៈ ជា សួនរបស់មល្លក្សត្ររួមព្រះជន្មាយុបាន ៨០ វស្សា។

១៩- ការបរិនិព្វានរបស់ព្រះបរមសាស្តា បានជាកម្មវត្ថុជាទីសោកស្តាយ របស់សាកលជនយ៉ាងខ្លាំង រកអ្វីប្រៀបផ្ទឹមពុំបាន ដោយគេទាំងឡាយមាន គំនិតថាប្រទីបនៃសាកលពិភព ដែលមានពន្លឺធំធេងមិនមានទីបំផុត ដែល សាកលសត្វធ្លាក់បានទទួលពន្លឺនឹងមិនកើតមានទៀតទេ ក្នុងរយៈកាលដែល យើងទាំងឡាយកំពុងរស់នៅនេះ។

២០- ព្រះសាស្តានៃយើង ទោះណាជាព្រះអង្គបរិនិព្វានមានរយៈកាល កន្លងទៅ ២៥១៤ ឆ្នាំហើយ តែពាក្យឱវាទរបស់ព្រះអង្គ ពុំបានបរិនិព្វានទៅជា មួយ ពុំបានចាស់ជរាទ្រុឌទ្រោមដូចវត្ថុធាតុទាំងឡាយដទៃឡើយ។ សាសនោ វាទនេះ បានរីកចំរើនសាយភាយទូទៅក្នុងពិភពលោក ដោយអាស្រ័យជំនឿនៃ ពុទ្ធមាមកៈគ្រប់ជាតិសាសន៍និងបញ្ញាដ៏មានគុណភាពខ្ពស់ នៃពុទ្ធសាវកទាំង ឡាយ។

□□□

# បទទី ២

# ពុទ្ធសាសនាជាអ្វី ?

**ក- ពុទ្ធសាសនាបានដល់ពាក្យឱវាទ ពាក្យបង្រៀនអំពីសេចក្ដីពិត** គឺបង្រៀនអំពីសេចក្ដីពិតដ៏ប្រសើរ ៤ ប្រការហៅថា "**អរិយសច្ចៈ" គឺទុក្ខ ហេតុនៃទុក្ខ សេចក្ដីរលត់ទុក្ខ ផ្លូវដើរឲ្យដល់សេចក្ដីរលត់ទុក្ខ** ដែលព្រះគោត្តមបរមគ្រូបានត្រាស់ដឹងកាលអំពី ២៥១៤ ឆ្នាំកន្លងទៅ ។

**ខ- ពុទ្ធសាសនាបានដល់ពាក្យបង្រៀន ឲ្យបំពេញសេចក្ដីល្អ លះបង់សេចក្ដីអាក្រក់ និងការធ្វើចិត្តឲ្យបរិសុទ្ធផុតចាកកិលេសទាំងពួង។** ដើម្បីឲ្យបានសំរេចនូវបញ្ញាជាន់ខ្ពស់បំផុត គេទាំងឡាយត្រូវខំប្រឹងរៀនឲ្យស្គាល់នូវសេចក្ដីពិត ឃើញតាមនូវសេចក្ដីពិតក្នុងដំណើរប្រព្រឹត្តទៅរបស់ជីវិត ដែលជាធម្មធាតុធ្វើឲ្យរួចចាកទុក្ខទាំងឡាយបានលុះដល់និព្វាន សឹងជាចំណុចគូសដៅចុងក្រោយបង្អស់នៃពុទ្ធសាសនិកជនទាំងពួង។

**គ- ពុទ្ធសាសនាសំដែងអំពីបន្ទាត់នៃផ្លូវប្រតិបត្តិរបស់ជីវិត** ជាកម្មវិធីបង្ហាញការប្រព្រឹត្ត ដើម្បីឲ្យរួចចាកសេចក្ដីកង្វល់របស់ជីវិត ដោយដឹកនាំឲ្យរក្សាសីលបានដល់ការសង្រួម ឬការប្រុងប្រយ័ត្នកាយនិងវាចា កុំឲ្យធ្លាក់ចុះទៅក្នុងអកុសលកម្មនានាជាដំបូង។ បន្ទាប់មក ដឹកនាំឲ្យអប់រំចិត្តឲ្យទៅជាធាតុមានសេចក្ដីនឹងន (សមាធិចិត្ត) ។ ចុងក្រោយបង្អស់ ដឹកនាំឲ្យរៀនពិចារណាសង្ខារធម៌តាមផ្លូវវិបស្សនាដើម្បីឲ្យកើតបញ្ញាជាន់ខ្ពស់ សម្រាប់ស្គាល់នូវសេចក្ដីពិតតាមសភាវៈនៃធម្មជាតិ។ របៀនទាំងឡាយនេះ អាចធ្វើអ្នករៀនឲ្យបានដល់សេចក្ដីសុខស្ងប់ទៀងទាត់មិនមានការវិលវល់ត្រឡប់ត្រឡិន គឺនិព្វានហ្នឹងឯង។

កាលបើធៀបពុទ្ធសាសនាជាមួយនឹងសាសនាទាំងឡាយដទៃ គេនឹងបានឃើញយ៉ាងច្បាស់ថា ៖ *ពុទ្ធសាសនាជាពាក្យបង្រៀនឲ្យចេះដឹង ស្គាល់*

*សេចក្ដីពិតដោយបញ្ញា បង្រៀនឲ្យចូលចិត្តជ្រួតជ្រាបជ្រៅជ្រះប្រកបដោយលក្ខណៈ ដែលលោកហៅថាច្បាស់លាស់ជាក់លាក់ដល់សភាវៈពិតទាំងឡាយរបស់ជីវិត ដែលកំពុងមាននៅក្នុងបច្ចុប្បន្ននេះ។* សាសនាទាំងឡាយដទៃៗគេប្រើជំនឿជាធំ គេបង្រៀនសាសនិករបស់គេឲ្យទទួលស្គាល់សារភាព (កំហុស) ចំពោះព្រះអាទិទេពរបស់ខ្លួន គេបញ្ជាក់ថាធ្វើយ៉ាងនេះរួចចាកទោស។ ខ្ទុះ[១] ទាំងឡាយបានទៅជាមនុស្សស្អាតបរិសុទ្ធក្នុងទីបំផុតនៃជីវិត នឹងបានទៅកើតក្នុងឋានសួគ៌ជាមួយនឹងព្រះអាទិទេពរបស់ខ្លួន។

ជំនឿនេះនាំឲ្យមនុស្សយើងគោរពកោតខ្លាចព្រះអាទិទេព ខំថ្វាយបង្គំព្រះអង្គជានិច្ច ដើម្បីឲ្យខ្លួនបានល្អ បានទៅកើតឋានសួគ៌ ។ វិធីនេះឃើញថាងាយ ព្រោះសេចក្ដីល្អបរិសុទ្ធនៅលើព្រះ ស្រេចហើយនឹងព្រះលោកប្រទាន តែជាជំនឿមិនប្រកបដោយហេតុផលឡើយ ។ *ពុទ្ធសាសនាបង្រៀនមនុស្សរាល់រូបឲ្យប្រើបញ្ញារបស់ខ្លួនពិចារណា រកឲ្យឃើញនូវសេចក្ដីពិត ប្រកបដោយហេតុផលមិនឲ្យពឹង ផ្អែកលើជំនួយខាងក្រៅឡើយ។*

**ពុទ្ធសាសនា** មិនអើពើដល់រឿងមានឬមិនមាននៃព្រះអាទិទេពទេ មិនឃើញថាវិញ្ញាណរបស់មនុស្សម្នាក់ៗមានសេចក្ដីទៀងទាត់ជាស្ថាពរ មិនមានកង្វល់ក្នុងគំនិតដល់រឿងអ្នកណាសាងពិភពលោក មិនខ្វីរវល់គិតគូរដល់ព្រឹត្តិកម្មទីបំផុតនៃពិភពលោកដែលនឹងត្រូវប្រែប្រួលទៅយ៉ាងណាៗ ។ *តែពុទ្ធសាសនាយកចិត្តទុកដាក់គន់គិតណាស់ តែអំពីសេចក្ដីមិនទៀងទាត់របស់ជីវិត អំពីសាកលលោកមានការផ្លាស់ប្ដូររឿយៗ* មិនមានឈប់ឈរកើតហើយរលត់ទៅ រលត់ហើយកើតឡើងទៀតអស់កាលជាប់មិនដាច់ ដោយអំណាចក្រសែនៃហេតុនិងផល ដ៏ជាធម្មធាតុអាស្រ័យនូវគ្នានឹងគ្នាយ៉ាងជិតស្និទ្ធមិនអាចនឹងញែកចេញបាន។ ព្រោះថាអ្វីៗទាំងអស់មិនធ្លាប់មានផលមួយកើតឡើងពីរដងតៗគ្នា ដោយប្រាសចាកហេតុមិនមានរបស់ណាមួយ តាំងនៅបានដោយមិនមានការផ្លាស់ប្ដូរ មិនមានវត្ថុណាមួយជារបស់ពិតទៀងទាត់ ឥតមានសេចក្ដី

(១) ខ្ទុះ ជានាមការកនាម ប្រើជំនួសអ្នកខុស ដែលជាការកនាម។

ប្រែប្រួលឡើយ។ របស់ទាំងឡាយដែលគេមើលឃើញគ្រប់គ្នាតាមធម្មតានេះ សុទ្ធតែរបស់មិនទៀងជាទុក្ខ មិនមានខ្លួនមិនមានប្រាណ។ សត្វលោកទាំងអស់បិតនៅ ក្រោមអំណាចនៃកម្ម ប្រែថារស់នៅក្រោមច្បាប់នៃការដែលមានហេតុហើយរមែងមានផលដ៏ជាក់ច្បាស់នៃធម្មជាតិនេះតែម្តង។

របស់ទាំងឡាយដែលជាផលកើតមកអំពីហេតុ ព្រះតថាគតទ្រង់ត្រាស់ដល់ហេតុនៃរបស់ទាំងឡាយនោះផង ទ្រង់ត្រាស់ដល់ហេតុនៃសេចក្តីរលត់នៃរបស់ទាំងឡាយនោះផង (កាលណាហេតុទាំងឡាយរលត់) ទុក្ខដែលជាផលកើតមកអំពីហេតុទាំងឡាយ គឺអវិជ្ជា តណ្ហា... (ទុក្ខសមុទ័យ) ក៏រលត់ទុក្ខនិរោធៈ ដែលជាផលកើតមកអំពីមគ្គ ក៏កើតមានឡើងក្នុងពេលនោះដែរ។

សាកលលោកជាមួយនឹងជីវិតទាំងឡាយក្នុងសាកលលោក រមែងតែងវិលវល់ទៅតាមសង្សារវដ្ត វិលវល់ទៅតាមវង់នៃសេចក្តីស្លាប់ហើយកើត កើតហើយស្លាប់។ សត្វលោកទាំងឡាយស្លាប់ចោលគ្នា ហើយត្រឡប់កើតជាថ្មីទៀតក្នុងភពផ្សេងៗជំនួបដែលខ្លួនគេម្នាក់ៗ បានបាត់បង់ទៅបានត្រឡប់មកមានវិញ ព្រមគ្នានេះសេចក្តីសុខ ទុក្ខក៏មានឡើងទៀតដែរ។ សេចក្តីសុខទុក្ខរបស់សត្វរមែងមានទំហំតំណូចមិនស្មើទេ ព្រោះធម្មធាតុនេះវាប្រព្រឹត្តទៅតាមអំណាចរបស់កម្ម ដែលសត្វកសាងមានតិចមានច្រើន។

មនុស្សយើងកើតឡើងមានលក្ខណៈយ៉ាងណា លក្ខណៈនោះមិនមែនមានឡើងឯងៗទេ គឺមានមកក្រោមការចាត់ចែងរបស់កម្មនៃមនុស្សម្នាក់ៗ។ របៀបចាត់ចែងរបស់កម្មនោះ ធម្មធាតុនោះវាចាត់ចែងដាច់មុខក៏មាន វាចាត់ចែងរួមគ្នាក៏មាន។ អតីតកម្មចាត់ចែងជាតិ ភព បច្ចុប្បន្នចាត់ចែងឋានៈជីវភាព។ អតីតកម្មនិងបច្ចុប្បន្នកម្មជាបច្ច័យដល់អានគតកម្ម កម្មបីយ៉ាងនេះ មានការទាក់ទងដល់គ្នាដែលភាសាពុទ្ធសាសនាយើងលោកហៅថា "**កម្មវដ្ត**" ។ កម្មដែលសត្វបានធ្វើហើយក្នុងអតីតកាល ជាកម្មអាក្រក់ក្តី ជាកម្មល្អក្តី មិនមាននរណាអាចកែបានទេកម្មនេះនឹងបញ្ជូនផលដល់ម្ចាស់កម្ម តាមវិថីរបស់វាជាពិតប្រាកដ លុះដល់ហេតុផលដែលជាជំនួសនៃកម្មនោះ បានផុតរលត់អស់ក្នុងបច្ចុប្បន្នជាតិនេះ ឬក្នុងអានាគតជាតិ ទើបកម្មនេះឈប់លែងឲ្យផល ។

អនាគតកម្មរបស់សត្វទាំងឡាយមិនមាននរណាមើលឃើញច្បាស់ លាស់ទេ ការមើលមិនឃើញច្បាស់លាស់ ប្រែថាធ្វើឲ្យត្រូវចំៗឥតមានខុសោះមិនកើត តែបច្ចុប្បន្នកម្ម ជាកម្មដែលមនុស្សយើងមើលឃើញច្បាសលាស់ ថាវាពិតជាយ៉ាងនេះ វាពិតជាយ៉ាងនោះ។ ដូចនេះការទទួលខុសត្រូវនិងការសម្រេចចិត្តសាងកម្មអ្វីៗ ឬធ្វើការអ្វីៗក្នុងបច្ចុប្បន្ននេះឲ្យកើតផលប្រយោជន៍ដល់ខ្លួន ទើបជាភារៈនៃបុគ្គលម្នាក់ៗ ត្រូវអារកាត់ដោយវិចារណញ្ញាណរបស់ខ្លួន។

ពំនោលខាងលើនេះ បញ្ជាក់សេចក្ដីឲ្យយើងឃើញថា ៖ **ពុទ្ធសាសនាបានដាក់រឿងជតាកម្ម "ជោគវាសនា" របស់មនុស្សនៅក្នុងកណ្ដាប់ដៃរបស់ខ្លួនឯង គឺមនុស្សម្នាក់ៗត្រូវទទួលខុសត្រូវចំពោះជោគវាសនារបស់ខ្លួន។** ដោយន័យថា : មនុស្សទាំងឡាយមានសមត្ថភាពនៅក្នុងខ្លួនរបស់ខ្លួន សម្រាប់ទាញបំបែរព្រហ្មលិខិតឲ្យវិលទៅតាមបំណងនៃអាត្មា ។ គេទាំងឡាយអាចទាត់ចោលនូវសេចក្ដីអាក្រក់ (បាប) បំពេញនូវសេចក្ដីល្អ (បុណ្យ) ជាពិសសគឺគេអាចធ្វើចិត្តឲ្យបរិសុទ្ធស្អាតចាក លោភៈ ទោសៈ មោហៈ គេអាចសាងកម្មល្អៗសម្រាប់ខ្លួនរបស់គេបន្តិចម្ដងៗតាមលំដាប់។ កម្មល្អនេះនឹងនាំខ្លួនរបស់គេឲ្យដល់នូវសេចក្ដីផុតទុក្ខ ឬគេអាចនឹងប្រើនូវសមត្ថភាពរបស់ខ្លួនដែលកើតអំពីកម្មល្អនេះ ប្រានចោលនូវសេចក្ដីអាក្រក់ទាំងឡាយក៏បាន។ ដោយអាស្រ័យសេចក្ដីព្យាយាមល្អដែលគេបានធ្វើអស់កាលជាប់មិនដាច់ សេចក្ដីទុក្ខក៏អស់ទៅ ការអន្ទោលកើតស្លាប់ក៏សូន្យត្រឹមប៉ុណ្ណេះ ឥតមានសេសសល់ឡើយ។

ដូចដែលបាននិយាយមកហើយនេះ យើងអាចធ្វើសេចក្ដីបញ្ជាក់បានថា៖ **ពុទ្ធសាសនារបស់យើងត្រូវរាប់ថាជានស្សនវជ្ជាស្ដីដោយកម្ម** (ការងារ) មិនមែនជាសាសនាបង្រៀនមនុស្សឲ្យរស់នៅផ្សងព្រេង ឬឲ្យប្រគល់ខ្លួនទៅលើធម្មជាតុដែលហៅថា "**ជោគវាសនា**" ឬឲ្យពង្វិលខ្លួនទៅតាមហេតុការណ៍ជុំវិញជីវិតដោយមិនមានការតស៊ូនោះទេ ។ ពុទ្ធសាសនា ជាសាសនាទំនុកបំរុងមនុស្សឲ្យរស់នៅក្នុងសេចក្ដីថ្លៃថ្នូរ ទាំងខាងសំភារៈ ទាំងខាងសីលធម៌ តែជាសាសនាជឿនលឿនទៅខាងអប់រំគុណសម្បត្តិរបស់ជីវិត ដើម្បីរំដោះទុក្ខ

របស់សត្វទាំងឡាយក្នុងលោកនេះ ច្រើនជាងអប់រំមនុស្សឲ្យស្រវឹងវិមវាមនៅក្នុងភព។ ជាពិសេសចាងនេះទៅទៀត គឺបង្រៀនឲ្យមនុស្សហ្វឹកហាត់ប្រើចិត្តមេត្តាករុណា ស្រឡាញ់រាប់រកមនុស្ស បន់ស្រន់ក្នុងចិត្តឲ្យអស់ទុក្ខអស់ព្រួយដល់មនុស្សទូទៅក្នុងពិភពលោកដោយមិនមានកំណត់ព្រំដែន មិនមានបរិមាណ ។ បង្រៀនឲ្យមនុស្សធ្វើចិត្តរបស់ខ្លួនឲ្យមានព្រហ្មវិហារធម៌ទូលំទូលាយ ឃើញចិត្តឃើញអធ្យាស្រ័យគ្នា មានបំណងល្អចំពោះមិត្តរួមលោកជាមួយគ្នា។

ព្រះសម្មាសម្ពុទ្ធទ្រង់តាំងព្រះទ័យមេត្តាករុណាចំពោះសត្វលោក ទ្រង់ណែនាំឲ្យគេទាំងឡាយធ្វើចិត្តឲ្យល្អបរិសុទ្ធ ចាកសព្វកេលិសា ដែលជាគ្រឿងធ្វើសន្តានចិត្តឲ្យសៅហ្មង។

រឿងនេះបើយើងពិចារណាមើលជុំវិញព្រះទ័យរបស់ព្រះអង្គ យើងនឹងឃើញថាព្រះសម្មាសម្ពុទ្ធទ្រង់ដឹកនាំយើងឲ្យទំលាយចោលនូវកំហុស ដែលឃើញថា អត្តាជារបស់ខ្លួន ឲ្យព្យាយាមអប់រំចិត្តដើម្បីយកសម្មាធិធម៌ ឲ្យរស់នៅក្នុងសេចក្ដីបរិសុទ្ធឲ្យលះបង់សេចក្ដីអាក្រក់ ឲ្យបំពេញសេចក្ដីល្អរឿយៗ ដើម្បីប្រានចិត្តឲ្យចូលទៅដល់បញ្ញាជាន់ខ្ពស់ ដែលជាបញ្ញាវិសេសសម្រាប់ធ្វើឲ្យខ្លួននៃមនុស្សម្នាក់ៗ បានចាក់ធ្លុះនូវអរិយសច្ចធម៌ក្នុងទីបំផុត នេះឯងគឺជាព្រះពុទ្ធសាសនា។

□

□ □

# បទទី ៣

# សាសនាជាអ្វី?

## What is religion?

ពុទ្ធសាសនាជាអ្វី? អ្នកអាចបានដឹងខ្លះហើយ ដើម្បីឲ្យកាន់តែមានពន្លឺក្នុងវិញ្ញាណរបស់ខ្លួនច្រើនឡើងទៀត ក្នុងពេលជាមួយគ្នានេះ សូមអ្នកអានមេត្តាសិក្សាជាមួយនឹងខ្ញុំ អំពីពាក្យថា "សាសនាគឺជាអ្វី?" ម្តងទៀត។ "សាសនា" តាមស័ព្ទប្រែថា "ពាក្យបង្រៀន" "ពាក្យឱវាទ" "ការអប់រំ" "ការដឹកនាំល្អ" ។ល។ ពាក្យបកប្រែប៉ុណ្ណោះជាដើម មិនសូវជាបានសេចក្តីងាយរៀន ងាយចូលចិត្តប៉ុន្មានទេ ដូចនេះទើបត្រូវរកពាក្យដែលមានន័យ ជានិយាម មកវែកញែកបំបែកបំភ្លឺពាក្យថា "សាសនា" ដូចមានតទៅនេះ ៖

សាស្ត្រចារ្យ **ម៉ៃរ៍ម៉ែន** បាននិយាយសៀវភៅរបស់លោកឈ្មោះ Aphilosophy of religion ថា "**សាសនា**" *គឺជាខ្សែចំណងមួយសម្រាប់ចងភ្ជាប់សត្វលោកជាមួយនឹងវត្ថុសក្តិសិទ្ធិដ៏មានតម្លៃខ្ពង់ខ្ពស់បំផុត ជាសេចក្តីស្មោះត្រង់ស្វាមីភ័ក្តិចំពោះអំណាចមួយ ឬ អំណាចច្រើនដែលមាននៅក្នុងពិភពលោក ជាការបន្ថែមនូវគុណតម្លៃថ្មី និងរក្សាទុកនូវគុណតម្លៃចាស់ ជាការសំដែងឲ្យអ្នកផងឃើញច្បាស់នូវសេចក្តីសមរម្យខាងសេចក្តីសម្ពន្ធ័ និងសេចក្តីស្វាមីភ័ក្តិ ទោះជាដោយពិធិកម្មប្រកបទៅដោយគ្រឿងគង្វាយក្តី ដោយសំដែងចេញនូវឥរិយាបថទន់ភ្លន់ចំពោះវត្ថុសក្តិសិទ្ធិនោះៗក្តី។*

សាស្ត្រាចារ្យសីលធម៌ម្នាក់ទៀតបាននិយាយថា "**សាសនា**" *គឺជាធម្មរូបជាគ្រឿងឧបករណ៍សម្រាប់គ្រប់គ្រងមនុស្សឲ្យរស់នៅក្នុងសន្តិសុខ ឲ្យរស់នៅក្នុងបែបភាពសមសួនជាមនុស្ស។* សាស្ត្រាចារ្យជាប្រមុខនៃសាសនាទាំង

ឡាយ មានសេចក្ដីឃើញដូចពោលមកនេះ ទើបរៀបចំកម្មវិធីប្រព្រឹត្តទុកមក ដោយឲ្យមនុស្សប្រតិបត្តិមនុស្សធម៌ ដើម្បីឲ្យខ្លួននៃមនុស្សម្នាក់ៗ មាន លក្ខណៈនៃសត្វតិរច្ឆាន។

មតិទាំងពីរនេះមានទីដៅខុសគ្នា មតិទី១ ប្រកាន់យកអំណាចលើឋាន សួគ៌អំណាចនៃព្រះអាទិទេពតាមជំនឿរបស់ប្រជាជាតិ ក្នុងប្រទេសនៃលោក ខាងលិច។ សេចក្ដីជឿនិងសេចក្ដីស្វាមីភក្ដិចំពោះអំណាចខ្ពង់ខ្ពស់ គឺជាធម្ម ធាតុមួយដែលគេលើកតម្កើងទុកជាល័ខគោលដ៏សំខាន់របស់គេក្នុងរឿងគោរព ។ ទស្សនៈដូចនេះបានត្រូវគ្នាជាមួយនឹងទស្សនៈនៃមនុស្សក្នុងបូរាណសម័យ ដែលមានជំនឿក្នុងល័ខគោលនៃសាសនាធម្មជាតិទាំងឡាយ តែខុសគ្នាអំពី ទស្សនៈនៃមនុស្សសម័យថ្មី ដែលមានជំនឿក្នុងសាសនាបច្ចុប្បន្នឬសាសនា មានហេតុផល។ មតិទី២ បានប្រកាន់យកសីលធម៌ថា ជាធម្មជាតុធ្វើមនុស្សឲ្យ មានលក្ខណៈខុសប្លែកអំពីសត្វតិរច្ឆានជាសំខាន់ ដោយធ្វើសេចក្ដីបញ្ជាក់ថា នេះគឺជារឿងរបស់មនុស្ស គឺថាមនុស្សយើងម្នាក់ៗ ប្រសិនបើរស់នៅដោយ ប្រាសចាកសីលធម៌នៃសាសនាហើយ ក៏ប្រែបានថាមិនសមនឹងទទួលយក នាមថាជាមនុស្ស។ ដូចនេះព្រោះអ្វី? ព្រោះពាក្យថា "**មនុស្ស**" ប្រែជាសេចក្ដីថា "**បុគ្គលមានចិត្តខ្ពស់**" សំខាន់ជាងនេះទៅទៀត ជីវិតណាដែលរស់នៅក្នុង សង្គម ប្រកបដោយសេចក្ដីសុខស្ងប់ ជីវិតនោះអ្នកប្រាជ្ញខាងសីលធម៌លោកឲ្យ ឈ្មោះថា "**ជីវិតមនុស្ស**"។

សូមអ្នកអានរៀនពាក្យថា "**សាសនា**" ជាមួយនឹងខ្ញុំដើម្បីឲ្យបានយល់ ន័យរបស់ពាក្យនេះ ដោយច្បាស់លាស់ដូចមានតទៅ។

អ្នកប្រាជ្ញសីលធម៌ម្នាក់ទៀត បានមានមតិថា សាសនាគឺជាធម្មជាតុគ្រង រក្សាសត្វលោកឲ្យឋិតនៅក្នុងសេចក្ដីសុខ-ចំរើន។ *ចំណែកអ្នកប្រាជ្ញខាងផ្នែក នេះជាច្រើនរូបទៀត លោកមានយោបល់ថា ការបង្រៀនមនុស្សឲ្យស្រឡាញ់ សេចក្ដីយុត្តិធម៌សេចក្ដីត្រូវការនូវរបស់ផ្សេងៗតាមផ្លូវត្រូវ សេចក្ដីស្នេហារក្នុង មេត្តាធម៌ ការអាណិតដល់សត្វ ដែលបានទទួលសេចក្ដីទុក្ខ ការធ្វើជំនួយដល់*

*មនុស្សទន់ខ្សោយ ការមិនមានសេចក្តីច្រណែនឬស្យាព្យាបាទ ការតាំងចិត្តធ្វើល្អដល់មនុស្សដោយមិនមានកំណត់ព្រំដែន ការស្ងួនរក្សាពាក្យសច្ចៈ ការទម្លាប់និយាយតែពាក្យពិត ការមិនធ្វើឲ្យអ្នកដទៃកើតសេចក្តីក្តៅក្រហាយ ការស្រឡាញ់មនុស្សដទៃស្មើនឹងខ្លួននៃអាត្មា ការព្យាយាមធ្វើឲ្យខ្លួនបានឈ្នះនូវសេចក្តីត្រូវការតាមផ្លូវកាយ វាចាចិត្តរបស់ខ្លួន ការស្រឡាញ់ចេះដឹង ការមានចិត្តរឹងពឹងក្នុងមុខងារដែលត្រូវធ្វើ ការមានចិត្តក្លាហានក្នុងនាទីដែលត្រូវការពារនុវយុត្តិធម៌ ការមិនមានអគតិធម៌នៅក្នុងចិត្តវិញ្ញាណ នេះគឺជា* ***សាសនា*** *។*

ទស្សនវិទូឈ្មោះ **ករូតេ** ម្នាក់ឯងមានទស្សនថា ៖ *សាសនារបស់មនុស្សលោកទូទៅ គឺមនុស្សធម៌និងយុត្តិធម៌ ។* បុគ្គលដដែលនេះបានធ្វើសេចក្តីបញ្ជាក់ថា *ធម៌ទាំងពីរប្រការនេះ គឺជាល័ខគោលសំខាន់ សម្រាប់ធ្វើឲ្យជីវិតមនុស្សក្នុងសង្គមដើរទៅដល់សន្តិភាពជាស្ថាពរ។*

អ្នកប្រាជ្ញទាំងឡាយខ្លះទៀត លោកមានសេចក្តីយល់ឃើញថា *សាសនាគឺជាប្រភពនៃធម្មចរិយា ជាប្រភពនៃទំនៀមទំលាប់ប្រពៃណីដ៏ល្អទាំងឡាយ ជាធម្មធាតុសម្រាប់លត់នូវកំដៅ ជាមធ្មធាតុសម្រាប់បង្កើតនូវភាពត្រជាក់ ជាបទបញ្ញត្តិប្រកបដោយបែបផែនសម្រាប់ឲ្យមនុស្សប្រតិបត្តិនូវមនុស្សធម៌ ជាធម្មតាធ្វើឲ្យមនុស្សឃ្លាតចេញចាកភាពនៃអនារ្យជននិងសត្វតិរច្ឆាន ជាធម្មធាតុបង្រៀនឲ្យមនុស្សស្រឡាញ់គោរពរាប់អានគ្នា លុះត្រាឋិតនៅក្នុងឋានៈជាភាតរភាព ជាធម្មធាតុធ្វើឲ្យមនុស្សមានយោបល់ស្របគ្នាជាផ្លូវមួយរហូតដល់មាន សាមគ្គីភាពខាងផ្លូវគំនិត។ ខ្ពស់ជាងនេះទៅទៀត គឺបង្រៀនឲ្យមនុស្សមានមនោសញ្ចេតនាប្រកបដោយសេចក្តីក្លាហានហ៊ានលះបង់នូវអ្វីៗទាំងអស់ ជាជីវិតជាសាច់ឈាម ។ល។ ដើម្បីបូជានូវធម្មចិរយា ដែលជាសម្បត្តិនៃសាសនាទាំងឡាយ។*

កាលណាយើងបានចូលចិត្តន័យនិងទីដៅ របស់សាសនា ដូចខ្ញុំបានសរសេរមកដោយសង្ខេបនេះហើយ គំនិតរបស់យើងនឹងបានធូរក្នុងការពិចារណាអំពីរឿងសាសនាតទៅក្នុងខាងមុខ។ ជាពិសេសគឺវិជ្ជាសាសនាដែលយើងបានរៀនមកជាមួយគ្នាប៉ុណ្ណោះនេះ ជាវិជ្ជាតិចតួចស្តួចស្តើងណាស់។ ដូច

នេះព្រោះអ្វី? ព្រោះថាសេចក្តីចេះដឹងរបស់យើងមានបរិមាណមិនដល់ទាំងមួយភាគរយផង តែវិញ្ញាណយើងបានប្រែភាពខុសធម្មតាខ្លះហើយ គឺវិញ្ញាណនេះបានជួបនូវពាក្យថា "**សន្តិភាព**" ឬ "**សន្តិសុខ**" ដែលជាទីដៅសំខាន់របស់សាសនាទាំងឡាយខ្លះហើយ។ ប្រសិនបើយើងខំប្រឹងគិតគួរពិចារណារឿយៗលើសេចក្តីចេះដឹងបន្តិចបន្តួចនេះរាល់ៗពេលជាប់មិនដាច់ យើងប្រាកដជានឹងមានពន្លឺក្នុងគំនិតមួយភាគថ្មីទៀត ថែមទៅលើពន្លឺចាស់ដែលមាននៅក្នុងវិញ្ញាណរបស់យើងក្នុងកាលមុន ។ ក្នុងកាលណាពន្លឺនេះកាន់តែរីកធំឡើង ក្នុងកាលនោះចិត្តរបស់យើងអាចនឹងធ្វើនូវសេចក្តីសំរេចមួយបានយ៉ាងច្បាស់ ថាចំណុចទីដៅចុងក្រោយបង្អស់នៃពាក្យបង្រៀនរបស់សាសនាទាំងឡាយ គឺធ្វើឲ្យមនុស្សរស់នៅក្នុងសន្តិភាព ឬនឹងនិយាយម្យ៉ាងទៀតថា "**សន្តិភាព**" *គឺជាទីដៅរបស់សាសនាទាំងឡាយ* ដូច្នេះវិញក៏បាន។

"**សន្តិភាព**" តាមស័ព្ទប្រែថា "**សេចក្តីស្ងប់**" ពាក្យនេះជានាម ជាពាក្យកណ្តាលៗ ។ ប្រសិនបើយកពាក្យនេះទៅភ្ជាប់ជាមួយនឹងពាក្យដទៃឬរឿងដទៃ ពាក្យនេះក៏ក្លាយទៅជាពាក្យគុណដោយកាត់ "ភាព" ឬ "សេចក្តី" ចេញសល់នៅតែពាក្យ "សន្តិ" ឬ "ស្ងប់" ឧទាហរណ៍ កាយសន្តិ វាចាសន្តិ ចិត្តសន្តិ ឬកាយស្ងប់ វាចាស្ងប់ ចិត្តស្ងប់ ស្រុកស្ងប់ ប្រទេសស្ងប់ ។ល។ ជានាមឧទាហរណ៍ សេចក្តីស្ងប់របស់កាយ សេចក្តីស្ងប់របស់ប្រទេស សេចក្តីស្ងប់របស់ចិត្ត ឬសេចក្តីស្ងប់របស់ពិភពលោក ឬសន្តិភាពនៃពិភពលោក ។ល។ "សន្តិភាព" តាមពាក្យនិយាយធម្មតាថា *សេចក្តីសុខសាន្តត្រាណសម្បូណ៌សប្បាយ* ។

□ □
□

# បទទី ៤

# សន្តិភាពគឺជាអ្វី ?

តាមផ្លូវសាសនា "**សេចក្តីស្ងប់**" ក្នុងទ្វារកាយ វាចា ចិត្ត ដោយកការមិនប្រព្រឹត្តកន្លងនូវសិក្ខាបទរបស់សីល ស្រុកប្រទេសមិនមានចោរលួចប្លន់ ប្រជាពលរដ្ឋធ្វើការរកស៊ីប្រកបដោយសេចក្តីសុខចំរើន សមណៈជីព្រាហ្មទាំងឡាយមានខ្លួនតម្កល់នៅក្នុងសីលធម៌ ប្រជាជាតិទាំងឡាយប្រកាន់យកមនុស្សធម៌ខាងផ្លូវចិត្តជាធំជាងផ្លូវសម្ភារៈ ។ល។ ដូចនេះ លោកថា ប្រទេសជាតិមានសន្តិភាព។

ពាក្យថា "**សន្តិភាព**" គឺជាពាក្យមានន័យផ្ទុយអំពីពាក្យថា "**សង្គ្រាម**" ជាពាក្យនាម សម្រាប់ប្រើជាមួយនឹងពាក្យនាមទាំងឡាយដូចប្រទេសសន្តិភាព លោកសន្តិភាព សាសនាសន្តិភាព នយោបាយសន្តិភាព គំនិតសន្តិភាព ដូចសន្តិធម៌ សន្តិបទ សន្តិជន សន្តិបុគ្គល សន្តិភាវៈ ។ល។ ដូច្នេះ ពាក្យថា "សន្តិភាព" ទើបត្រូវដោយកដល់ភាពស្ងប់ ភាពសុខសាន្ត ភាពមិនមានសង្គ្រាម មិនមានជម្លោះ ។ល។ ឬបើនឹងនិយាយជាកាលក៏គឺបានដល់កាលវេលាដែលប្រាសចាកសង្គ្រាមនុ៎ះឯង។

"**សន្តិភាព**" គឺជាដៅនៃសាសនាទាំងឡាយ ជាពិសេសគឺពុទ្ធសាសនារបស់យើងតែម្តង ព្រោះពុទ្ធសាសនាហាមមិនឲ្យធ្វើសង្គ្រាមគ្រប់កាលវេលាគ្រប់មធ្យោបាយ ព្រោះសង្គ្រាមនោះវាជារឿងនៃសញ្ចាតិញ្ញាណរបស់មនុស្សផ្នែកទំលាយបំផ្លិចបំផ្លាញ។ ចំណែកសន្តិភាពវាជារឿងនៃមនោសញ្ចេតនាប្រកបទៅដោយមនុស្សធម៌ វាជាធាតុនាំឲ្យរីកដុះដាលចំរុងចំរើនទាំងខាងផ្លូវចិត្ត ទាំងខាងផ្លូវសំភារៈដែលជារបស់ចាំបាច់ដល់ជីវិតមនុស្ស វាជាធាតុប្រមូល

មកនូវសេចក្តីសុខក្សេមក្សាន្ត ជាធាតុផ្ទុយអំពីសង្គ្រាមដែលជាប្រភពនៃទុក្ខទោស គ្រោះថ្នាក់យ៉ាងពិតប្រាកដមួយរយភាគរយ។ សង្គ្រាមមិនត្រឹមតែឲ្យទុក្ខព្រួយប៉ុណ្ណោះទេ គឺវាជាធាតុញុាំងមនុស្សភាពឲ្យក្លាយទៅសត្វព្រៃ ដូចក្នុងអតីត វាជារបស់មិនសមគួរដល់មនុស្សដែលជាសត្វស្រុក ឬជាសត្វមានចិត្តខ្ពស់នាំគ្នាគិតនាំគ្នាធ្វើឡើយ ។ ជាពិសេសជាងនេះទៅទៀត គឺវាគ្មានទំនងគ្មានសមគួរដល់មនុស្សឬប្រជាជាតិដែលអួតអាងថាខ្លួន ឬប្រជាជាតិរបស់ខ្លួនមានសេចក្តីជឿនលឿនដោយអារ្យធម៌ ដែលលោកមានបំណងចង់ឲ្យមនុស្សមានសន្តិភាព ចង់កំចាត់ចោលឲ្យអស់នូវសញ្ជាតិញ្ញាណនៃសត្វព្រៃ ដើម្បីឲ្យមនុស្សទាំងឡាយដែលទស្សនវិទូទាំងឡាយ មានរូស្សូនិងប្លាតូជាដើមហៅថា ″សត្វស្រុក″ បានរស់នៅក្នុងសេចក្តីសុខស្ងប់ ឲ្យសមតាមឈ្មោះថាសត្វស្រុកដែលត្រូវតែមានលក្ខណៈខុសប្លែកអំពី សត្វព្រៃនុ៎ះឯង។

□ □

□

# បទទី ៥

# សាសនាបង្រៀនអំពីសន្តិភាពដូចម្តេចខ្លះ?

សន្តិភាពតាមទស្សនៈនៃសាសនាទាំងឡាយដ៏សំខាន់ៗ របស់ពិភពលោកបានឲ្យមេរៀនស្រដៀងៗគ្នា មានសេចក្តីប្រកបដោយខ្លឹមសារប្រហែលៗគ្នា ខុសគ្នាតែកម្មវិធីសំរាប់បង្រៀន មានជ្រៅ មានរាក់ មានទូលាយ មានចង្អៀតឆ្ងាយជាងគ្នាប៉ុណ្ណោះ។ ក្នុងទីនេះ ខ្ញុំសូមមិនសរសេរអីពីអ្វីៗ ដែលអ្នកអានមិនមានបំណងចង់ដឹងជាបន្ទាន់ឡើយ ខ្ញុំនឹងសរសេរឲ្យចំចំណុជនៃសំណួរថា ៖ *សាសនាបង្រៀនអំពីសន្តិភាពនោះមានដូចម្តេចខ្លះ? ចម្លើយបង្រៀន មិនឲ្យសម្លាប់មនុស្សមានជីវិត មិនឲ្យលួចទ្រព្យមានម្ចាស់កាន់កាប់ មិនឲ្យក្បត់សេចក្តីស្នេហានៃបុរសស្ត្រី មិនឲ្យនិយាយសំដីខុសការណ៍ពិត មិនឲ្យសេពគ្រឿងញៀនទាំងឡាយដែលធ្វើឲ្យជីវិតបាត់បង់សីលធម៌ ។ល។ នេះគឺជាសិក្ខាបទរបស់សីលក្នុងពុទ្ធសាសនា។* ចូរអ្នកកុំសម្លាប់គេ កុំលួចទ្រព្យសម្បត្តិគេ កុំលួចស្នេហាប្រពន្ធគេនឹងប្តីគេ ។ល។ នេះសិក្ខាបទក្នុងបញ្ញត្តិ ១០ ប្រការនៃសាសនាគ្រឹស្ត។ ក្នុងសាសនាគ្រឹស្តដែលបានបង្រៀនថា ៖ បើគេទះកំផ្លៀងរបស់អ្នកខាងស្តាំ ចូរងាកកំផ្លៀងខាងឆ្វេងរបស់អ្នកទៅឲ្យគេទៀត បើគេលួចអាវក្រៅរបស់អ្នក ចូរដោះអាវក្នុងរបស់អ្នកទៅឲ្យគេទៀត ចូរឲ្យពរដល់មនុស្សដែលជេរអ្នក ចូរធ្វើគុណដល់មនុស្សដែលស្អប់ខ្ពើមអ្នក បើអ្នកឲ្យអភ័យដល់មនុស្សទាំងឡាយ ព្រះជាម្ចាស់ព្រះអង្គនឹងឲ្យអភ័យដល់អ្នកវិញដែរ បើអ្នកមិនឲ្យអភ័យដល់មនុស្សទាំងឡាយ ព្រះជាម្ចាស់ក៏នឹងមិនឲ្យអភ័យដល់អ្នកដូចគ្នាដែរ ។ល។ ក្នុងសាសនាឥស្លាម ព្រះមូហាម៉ុត (មហាម៉ុត) បានបង្រៀនថាផ្លូវនៃបុណ្យកុសលមានតែមួយ គឺផ្សាយចិត្តមេត្តាករុណាដល់អ្នកដទៃ ធ្វើសេចក្តីសុខសប្បាយឲ្យកើតមានដល់អ្នកដទៃគ្រប់ទិសទី។ ចំពោះមេត្តាធម៌ក្នុងសាសនាឥស្លាមនេះ ក្រោយមកបានក្លាយទៅជាអមេត្តាធម៌ឬហិង្សាធម៌ទៅ

វិញ។ ដើម្បីឲ្យអ្នកអានបានយល់អំពីការប្រែប្រួលនេះ ខ្ញុំសូមបញ្ជាក់ថា ការប្រែត្រឡប់អំពីមេត្តាធម៌មកជាហិង្សាធម៌វិញរបស់សាសនានេះ មិនមានធាតុអ្វីដទៃក្រៅអំពីធាតុគឺធន់ទ្រាំពុំបាននឹងអំពើព្យាបាទ ដែលកើតអំពីប័ក្សពួកនៃអ្នកស្អប់ខ្ពើម ដែលចេះតែសង្កត់សង្កិនហួសវិស័យឲ្យទ្រាំបាន។ ដោយអាស្រ័យហេតុដូចពោលមក ទើបសាសនិកក្នុងសាសនានេះផ្លាស់ចិត្ត ចាប់អាវុធការពារ ហើយមានពេលខ្លះពួកគេបានជ្រុលដៃរហូតដល់ហួសព្រំដែននៃការពារ ចូលទៅក្នុងក្របខ័ណ្ឌនៃការវាយលុករុករានពួកដទៃទៀតផង។ តែយ៉ាងណាក៏ដោយ រឿងច្បាំងកាប់ចាក់នេះវាមិនមែនជាបទបញ្ញានៃសាសនាទេ គឺជាបទបញ្ញារបស់សាសនិកទាំងឡាយ ជាពិសេសគឺបុគ្គលដែលជាប្រមុខរបស់សាសនាម្នាក់ៗ។ បើនិយាយឲ្យបានខ្លីជាងនេះទៅទៀត យើងត្រូវនិយាយថា *"ច្បាំងកាប់ចាក់សម្លាប់គ្នា វាមាននៅក្នុងចិត្តរបស់មនុស្ស វាមិនមែននៅក្នុងចិត្តរបស់សាសនាទេ"* ។ ដូចនេះព្រោះអ្វី? ព្រោះសាសនាបង្រៀនឲ្យលះបង់ លោភៈ ទោសៈ មោហៈ ។ ដូចម្ដេចទើបបង្រៀនយ៉ាងនេះ? ព្រោះកិលេសទាំងបីនេះ វាធ្វើឲ្យមនុស្សចង់បានឥតរបប ឲ្យស្អប់ខ្ពើមគ្នាគ្មានរើសមុខ ឲ្យវង្វេងភ័ន្តច្រឡំភ្លេចភាពជាមនុស្សដូចគ្នាអស់រលីង។ គឺវាទាំងពីរនេះហើយ ដែលជាប្រភពនៃចម្បាំងនៃជម្លោះគ្រប់យ៉ាង។ កាលណាយើងដាក់គំនិតរបស់យើងនៅក្នុងយុត្តិធម៌ហើយ យើងពិចារណាមើលជុំវិញរឿងរបស់សាសនាឥស្លាមរឿយៗទៅ យើងនឹងឃើញថា ប្រសិនបើមិនមានហេតុការណ៍កកើតឡើងដូចបាននិយាយក្នុងខាងលើកនេះទេ ការទាក់ទាញចិត្តសាសនិកឲ្យប្រឆាំងនឹងសន្តិភាព និងមេត្តាធម៌ក៏ពុំអាចកើតមានឡើងបានដែរ។ ដូចនេះព្រោះអ្វី? ព្រោះក្នុងសាសនាឥស្លាមក៏មានពាក្យបង្រៀនអំពីសន្តិភាពនៃជីវិត និងមេត្តាចិត្តច្រើនណាស់ដែរ។

អ្នកអានទាំងលាយ សូមពិចារណាជាថ្មីទៀតជាមួយនឹងខ្ញុំ អំពីសន្តិភាពនៃជីវិតនិងមេត្តាចិត្ត តាមផ្លូវសាសនា ជាពិសេសគឺពុទ្ធសាសនារបស់យើង ដែលខ្ញុំនឹងស្រង់យកសេចក្ដីក្នុងព្រះសូត្រមួយមកសរសេរដូចមានតទៅក្នុងបទខាងមុខ។

# បទទី ៦

# ខ្សែបន្ទាត់នៃសន្តិភាពរបស់ពុទ្ធសាសនា

ជាមនុស្សជាតិត្រូវមានសេចក្តីក្លាហានចំពោះនាទី ត្រូវមានស្មារតីស្មោះត្រង់ចំពោះមុខការ ត្រូវជាបុគ្គលរស់នៅដោយគេស្តីថាងាយ ត្រូវជាអ្នកមានចិត្តទន់ភ្លន់ត្រូវជាអ្នកលះបង់នូវសេចក្តីប្រកាន់ ត្រូវជាអ្នកមានសេចក្តីសន្តោស ត្រូវជាអ្នករស់នៅឲ្យគេចិញ្ចឹមងាយនឹងរើសអើងចំពោះបច្ច័យជាគ្រឿង ធ្វើឲ្យជីវិតប្រព្រឹត្តទៅបាន មិនប្រព្រឹត្តនូវកម្មគួរដល់ការរិះគន់របស់អ្នកដទៃ ហើយគប្បីផ្សាយរឿយៗនូវមេត្តាករុណា... ចិត្តទៅក្នុងសត្វលោកថា ៖

សូមសត្វទាំងឡាយ ចូរនាំគ្នារស់នៅដោយមិនមានពៀរ ដោយមានសេចក្តីសុខសប្បាយ ដោយមិនមានទុក្ខគ្រោះថ្នាក់ ដោយមិនមានធម៌ព្យាបាទ ដោយចេះថែរក្សាខ្លួនឲ្យបានសេចក្តីសុខចំរើនគ្រប់ៗអាត្មា ទាំងសត្វមនុស្ស សត្វទេព សត្វរូបព្រហ្ម សត្វអសញ្ញី សត្វអរូបព្រហ្ម សត្វនរក សត្វប្រេត សត្វអសុរកាយ សត្វតិរច្ឆានប្រភេទធំ ប្រភេទតូច ប្រភេទមានជើងច្រើន ប្រភេទមាន ជើងតិច ប្រភេទមានស្លាប ប្រភេទមិនមានស្លាប ប្រភេទមើលឃើញ ប្រភេទមើលមិនឃើញ ប្រភេទនៅជិត ប្រភេទនៅឆ្ងាយ ប្រភេទកើតទៀត ប្រភេទមិនត្រូវកើតទៀត ប្រភេទកំពុងរកភពកើតទៀត ។ល។ កាលណាសត្វទាំងឡាយ បានរស់នៅក្នុងសេចក្តីសុខស្ងប់គ្រប់អាត្មាហើយ សូមទុកដាក់ខ្លួនជាភាតរភាពដល់គ្នានឹងគ្នា កុំប្រព្រឹត្តនូវបទសង្កត់សង្កិនគ្នា កុំនិយាយពាក្យអាក្រក់អំពីគ្នាទាំងក្នុងទីចំពោះមុខ ទាំងក្នុងទីកំបាំងមុខ កុំបង្កើតនូវសេចក្តីទុក្ខឲ្យដល់គ្នានឹងគ្នា កុំមានចិត្តស្អប់ខ្ពើមគ្នា កុំមានចិត្តចង្អៀតចង្អល់ដល់គ្នានឹងគ្នា។

មានតាបិតាទាំងឡាយចិញ្ចឹមកូន ទំនុកបំរុងកូនដែលកើតចេញអំពីដើមទ្រូងរបស់ខ្លួន ឲ្យរស់នៅប្រកបដោយសេចក្តីសុខ រហូតដល់ហ៊ានលះបង់ជីវិត

ដើម្បីការពារនូវគ្រោះថ្នាក់ ដែលនឹងត្រូវកើតមានដល់វត្ថុជាទីស្រឡាញ់នេះ យ៉ាងណាមិញមនុស្សលោកម្នាក់ៗ ប្រសិនណាបើមានចិត្តស្រឡាញ់សន្តិភាពរបស់ជីវិតនៃខ្លួន គប្បីបង្កបង្កើតនូវមេត្តាធម៌ ឲ្យមានក្នុងចិត្តរបស់ខ្លួនជាមួយនឹងការផ្សាយនូវមេត្តាធម៌នេះដល់សត្វទាំងឡាយ ដោយឥតមានកំណត់ព្រំដែន ឥតមានកំណត់ជាតិសាសន៍ដើម្បីការពារនូវសន្តិភាពរបស់ជីវិត ទាំងឡាយយ៉ាងនោះដែរ។ នេះគឺជាព្រះសូត្រមួយឈ្មោះថា "**មេត្តសូត្រ**" ដែលមានសម្តែងអំពីការផ្សាយមេត្តាចិត្តដូចបានពោលមកហើយ ព្រមទាំងមានសេចក្តីបញ្ជាក់ចាបន្ថែមថា ៖ បុគ្គលដែលនឹងហាត់រៀនចម្រើនមេត្តាចិត្តនោះ ជាដំបូងគប្បីធ្វើដល់ចិត្តខ្លួនឯង ជាបន្ទាប់គប្បីធ្វើដល់មនុស្សដែលខ្លួនស្រឡាញ់ ជាទីបំផុតគប្បីធ្វើដល់មនុស្សដែលខ្លួនស្អប់ រហូតដល់ធ្វើជាទូទៅដោយមិនមានប្រមាណដល់ទីកន្លែង គឺធ្វើដល់សាកលលោកទាំងអស់ គ្រប់ទិសនៃសាកលលោកទាំងឡាយដែលយើងបានស្គាល់ថា ៖ ខាងលើ ខាងក្រោម ខាងកើត ខាងលិច ខាងត្បូង ខាងជើង ។ល។ ជាមួយនឹងសម្លេងបន់ស្រន់ថា ៖ សូមអ្នកទាំងឡាយកុំមានចិត្តពៀរដល់គ្នានឹងគ្នា កុំតាំងចិត្តជាសត្រូវ ដល់គ្នានឹងគ្នា ។ល។ គប្បីផ្សាយមេត្តាចិត្តបែបនេះគ្រប់ឥរិយាបថ ដេក ដើរ ឈរ អង្គុយ ។ល។

ព្រះសម្មាសម្ពុទ្ធទ្រង់ត្រាស់បន្ថែមជាចុងក្រោយបង្អស់ នៃមេត្តាធម៌នេះថា ៖ "**លោកោ បត្ថម្ភិកា មេត្តា**" មេត្តាធម៌នេះជាធម្មជាតុមួយ ជួយគាំទ្រសត្វលោកនិងពិភពលោកជាមួយនឹងធម៌ដទៃទៀត ដែលគេប្រតិបត្តិដើម្បីសន្តិភាពរបស់ជីវិត។

ប្រសិនបើវាស្រង់យកធម្មៈផ្សេងៗ របស់សាសនានានាជាពិសេសគឺពុទ្ធសាសនារបស់យើង មកសរសេរអំពីរឿងដែលទាក់ទងដល់សន្តិភាពនោះ ឃើញថាហួសសេចក្តីត្រូវការដែលបានគ្រោងទុកក្នុងសៀវភៅនេះ ។ អ្នកអាចទាំងឡាយគប្បីកត់សំគាល់ថា ពាក្យសរសេរប៉ុណ្ណោះក៏ជាពាក្យមានបរិមាណសមគួរ ល្មមឲ្យយើងមើលឃើញមុខងាររបស់សាសនាទាំងឡាយមិនមានអ្វី

ដទៃក្រៅអំពីធ្វើឲ្យមនុស្សឲ្យអស់ទុក្ខព្រួយ ឲ្យមានសុខសន្តិភាពសម្រាប់ជីវិតដែលមនុស្សទាំងឡាយមានការចងចាំតាមផ្លូវគំនិតអស់កាលជានិច្ចនុ៎ះឯង។

តាមពាក្យបង្រៀនរបស់ **សាសនា** ដែលខ្ញុំបាននិយាយមកហើយនោះ គេទាំងឡាយអាចនឹងស្តាប់បានថា **សាសនា** មានសេចក្តីប្រាថ្នានឹងធ្វើមនុស្សឲ្យដល់នូវសេចក្តីសុខសន្តិភាពមែន សំដាប់នេះត្រូវពិតមិនខុសទេ។ ដូចនេះព្រោះអ្វី? ព្រោះសន្តិភាពពុំមែនកើតមានអំពីសម្ភារៈតែម្យ៉ាងទេ គឺប្រាកដជាកើតមកអំពីចិត្តមេត្តាករុណារបស់មនុស្សផងដែរ ឬបើយើងចង់និយាយថា កើតមកអំពីចិត្តល្អរបស់មនុស្សផងដែរ ក៏រិតតែត្រូវហើយងាយស្តាប់ផងទៀត។ ចំពោះរឿងនេះ ប្រវត្តិសាស្ត្រនៃពិភពលោក ក៏បានប្រាប់យើងយ៉ាងច្បាស់មកហើយថា ៖ សេចក្តីសុខក្សេមក្សាន្តដែលជាកំពូលនៃសេចក្តីប្រាថ្នារបស់មនុស្សនោះ គឺសន្តិភាពរបស់ជីវិត។ ប្រវត្តិនេះបានធ្វើសេចក្តីបន្ថែមថា ៖ ក្នុងសម័យណាមានសង្គ្រាមកើតឡើងក្នុងសម័យនោះអ្នកនៅក្នុងអាណាចខេត្ត របស់សង្គ្រាមអស់សន្តិភាប។ ក្នុងសម័យណាសង្គ្រាមរលត់ ក្នុងសម័យនោះមនុស្សមានសន្តិភាព សម័យសង្គ្រាមកើត ម្តងៗជាសម័យដែលមនុស្សបិតនៅក្នុងខ្ទង់សូន្យគ្រប់ៗអាត្មា ជាអាទិសូន្យទ្រព្យ សូន្យជីវិត សូន្យប្រពន្ធ សូន្យកូន សូន្យសីលធម៌។ លើសនេះទៅទៀត *គឺមិនមែនបិននៅតែលើខ្ទង់សូន្យប៉ុណ្ណោះទេ គឺបិតនៅលើខ្ទង់កើតផង ជាអាទិគឺកើតមានទណ្ឌកម្មដោយមិនមានកំហុស កើតទារុណកម្មដ៏សាហាវដល់ខ្លួន កើតរោគចិត្ត កើតរោគប្រែប្រួលស្មារតី កើតចិត្តក្បត់ផ្សេងៗ។* សំណួននិងកំណើតដូចបានរៀបរាប់មកដោយសង្ខេបនេះ មិនមានមនុស្សណាម្នាក់ត្រូវការទេ ហើយក៏មិនមានមនុស្សណាម្នាក់បង្កើតដែរ ក្រៅតែអំពីមនុស្សដែលនិយមសង្គ្រាមប៉ុន្មាននាក់ប៉ុណ្ណោះ។

□ □

□

# បទទី ៧

# ពុទ្ធធម៌

**ពុទ្ធោវាទមបីយ៉ាងគឺ ÷**

១- លះបង់សេចក្តីអាក្រក់

២- បំពេញសេចក្តីល្អ

៣- សំអាតចិត្តឲ្យបរិសុទ្ធ។

គេធ្វើយ៉ាងណាហៅថាលះបង់សេចក្តីអាក្រក់? គេឈប់ប្រព្រឹត្តធ្វើការនូវការទាំងឡាយ ដែលធ្វើឲ្យអ្នកដទៃបានទទួលរងទុក្ខទោស រងគ្រោះថ្នាក់ មានការសម្លាប់ជាដើម។

គេធ្វើយ៉ាងណាហៅថាបំពេញសេចក្តីល្អ? គេប្រព្រឹត្តធ្វើនូវការទាំងឡាយដែលធ្វើឲ្យអ្នកដទៃបានទទួលនូវសេចក្តីសុខ សេចក្តីចំរើន មានការជួយស្រង់មនុស្សលង់ទឹកជាដើម។

គេធ្វើយ៉ាងណាហៅថាសំអាតចិត្តឲ្យបរិសុទ្ធ? គេខំប្រព្រឹត្តធ្វើចិត្តរបស់គេឲ្យកិលេសដែលមានឈ្មោះថាលោភៈ ទោសៈ មោហៈ មានកម្លាំងខ្សោយចុះតាមលំដាប់ រហូតដល់ផុតរលត់ចាកសន្តានក្នុងទីបំផុត ។ ព្រោះអ្វី? ព្រោះថាការឈប់ធ្វើបាបដល់មនុស្សទាំងឡាយ វាជាឈ្មោះនៃការលះបង់សេចក្តីអាក្រក់ ការធ្វើល្អដល់មនុស្សទាំងឡាយ វាជាឈ្មោះនៃបុណ្យ ការធ្វើឲ្យស្រាលឬឲ្យអស់នូវលោភៈ ទោសៈ មោហៈ វាជាឈ្មោះនៃចិត្តបរិសុទ្ធ។ ឧទាហរណ៍ការមិនសម្លាប់សត្វទន្សាយ ដែលមានជើងទាក់ជាប់ដោយស្នៀឈ្មោះថាមិនធ្វើបាប។ ការដោះលែងនូវសត្វទន្សាយ រូបដដែលនេះឈ្មោះថាធ្វើបុណ្យ ។ ការបួងសួងបន់ស្រន់ក្នុងចិត្តសូមកុំឲ្យសត្វទន្សាយទាក់ជើងជាប់ដោយស្នៀ ជាថ្មីទៀត ឈ្មោះថាធ្វើចិត្តឲ្យបរិសុទ្ធ។

**សប្បុរិសបញ្ញត្តិ ៣ យ៉ាងគឺ ÷**

១- ធ្វើអំណោយដល់អ្នកដទៃដោយទ្រព្យរបស់ខ្លួន

២- សាងផ្នួសអស់រយៈកាលមួយក្នុងជីវិតរបស់ខ្លួន

៣- គោរពប្រតិបត្តិមាតាបិតាឲ្យរស់នៅជាសុខ។

**គេធ្វើកម្មយ៉ាងណាហៅថា ទាន**? ការជួយរំដោះមនុស្សឲ្យអស់សេចក្តីទុក្ខព្រួយ ដោយលះបង់ប្រយោជន៍ផ្ទាល់ខ្លួនសាងផ្លូវ ថ្នល់ ស្ពាន សាលាស្នាក់ សាលារៀន សាលាព្យាបាលរោគ វត្ត អារាម គ្រឿងបរិភោគ សំពត់ យាន គ្រឿងសំអាង គ្រឿងក្រអូប គ្រឿងបំភ្លឺ ។ល។ លើសនេះទៅទៀត គេឆ្លៀតឱកាសដាក់បាត្រភិក្ខុសង្ឃ ធ្វើបុណ្យតាមប្រពៃណី ធ្វើបុណ្យសង្គ្រោះអ្នកមានគ្រោះថ្នាក់ ។ល។ ដែលប្រជាជាតិខ្មែរយើងទំលាប់ធ្វើមកហើយ ដើម្បីឧទ្ទិសផលដល់បុព្វបុរសផង ដើម្បីរក្សានូវសាមគ្គីភាពនៃគ្នានឹងគ្នាផង ទាំងអស់នេះហៅថា "**ទាន**" ។

**គេធ្វើកម្មយ៉ាងណាហៅថាសាងផ្នួស** ?

ការរក្សាសីល ៥ ចាំសីល ៨ សីល ១០ សីល ៤ ដោយមានកំណត់កាល ឬមិនមានកំណត់កាល នៅស្រុកឬនៅព្រៃ ជាបព្វជិតឬជាគ្រហស្ថ។ លើសនេះទៅទៀត គេតាំងចិត្តបូជាជីវិតនិងរូបកាយចំពោះសេចក្តីយុត្តិធម៌ គឺគេមិនធ្វើនូវអ្វីៗទាំងអស់ ដែលជាទំនាស់ដល់សេចក្តីយុត្តិធម៌ ទាំងអស់នេះហៅថា "**សាងផ្នួស**" ។

គេធ្វើកម្មយ៉ាងណាហៅថាគោរពប្រតិបត្តិមាតាបិតាល្អ? ការចិញ្ចឹមដោយបច្ច័យ៤ (គ្រឿងស៊ី គ្រឿងស្លៀកពាក់ គ្រឿងឱសថ) ការបំរើដោយកម្លាំងកាយកម្លាំងសំដី កម្លាំងចិត្ត កម្លាំងបញ្ញា ការរក្សាទុកនូវប្រពៃណីល្អរបស់ត្រកូល ការធ្វើតាមបទបញ្ជាយ៉ាងខ្ជាប់ខ្លួន ការធ្វើទក្ខិណានុប្បទានឧទ្ទិសផលជូនវិញ្ញាណចថ្មីទាំងអស់នេះហៅថា គោរពប្រតិបត្តិល្អចំពោះមាតាបិតា។

**អរិយសច្ចៈ ៤ គឺ ÷**

១- ទុក្ខ

២- ហេតុនៃទុក្ខ

៣- សេចក្ដីរលត់ទុក្ខ

៤- ផ្លូវដើរទៅកាន់សេចក្ដីរលត់ទុក្ខ។

ទុក្ខគឺជាអ្វី? ជីវិតរបស់សត្វទាំងឡាយ តាំងអំពីកើតមករហូតដល់ស្លាប់ ជាទុក្ខ ព្រោះអ្វី? ព្រោះទ្រាំកើត ទ្រាំចាស់ទ្រាំឈឺ ទ្រាំស្លាប់ ខំប្រឹងសោក ខំប្រឹងយំ ខំប្រឹងខឹង ខំប្រឹងទ្រាំសេចក្ដីស្អុះស្អាប់តានតឹង ខឹប្រឹងប្រាថ្នាជានេះជានោះ ខំប្រឹងមិនប្រាថ្នាជានេះជានោះ ខំប្រឹងធន់ទ្រាំនូវសេចក្ដីមិនសំរេច ខំប្រឹងសប្បាយនឹងសេចក្ដីសម្រេច ខំប្រឹងស្អប់ ខំប្រឹងស្រឡាញ់ ខំប្រឹងសើច ខំប្រឹងរាំ ខំប្រឹងច្រៀង ខំប្រឹងឈ្លោះ ខំប្រឹងច្បាំង ខំប្រឹងស៊ី ខំប្រឹងផឹក ខំប្រឹងប្រកាន់ខ្លួនប្រាណ ។ល។ ទាំងអស់នេះហៅថា "**ទុក្ខសច្ចៈ**" ។

**ហេតុនៃទុក្ខគឺជាអ្វី?** បំណងទាំងឡាយដែលមាននៅក្នុងសន្ដានរបស់សត្វជា ធម្មជាតិរុញច្រានឲ្យចូលទៅក្នុងភាពធន់ទ្រាំ (ទុក្ខ) ចំណង់ (តណ្ហា) នេះវាជាធាតុតាក់តែងឡើងនូវទុក្ខគ្រប់ប្រការ ព្រោះធាតុនេះវាធ្វើឲ្យមនុស្សសត្វចង់សប្បាយក្នុងរូប សម្លេង ក្លិន រស់និងផ្សព្វ (កាមតណ្ហា) ចង់កើតជានេះជានោះ ចង់កើតជានេះជានោះ មិនចង់បានបុណ្យស័ក្ដិ មិនចង់បានកេរ្ដិ៍ឈ្មោះ មិនចង់បានអំនួត (វិភវតណ្ហា) ។ល។ ចំណង់ទាំងឡាយនេះ កើតមកអំពីវិជ្ជាគឺសេចក្ដីមិនដឹង មិនស្គាល់ គឺមិនយល់ថារបស់ទាំងឡាយ ដែលខ្លួនចង់បាន និងមិនចង់បាននោះ មិនស្គាល់ គឺមិនយល់ថារបស់ទាំងឡាយ ដែលខ្លួនចង់បាន និងមិនចង់បាននោះ ជាធម្មជាតិឋិតនៅក្នុងភាពប្រែប្រួល (អនិច្ចំ) ភាពធន់ទ្រាំ (ទុក្ខំ) ភាពពុកផុយសោះសូន្យ (អនត្តា) ទាំងអស់នេះហៅថា "**ហេតុនៃទុក្ខ**"។

សេចក្ដីរលត់ទុក្ខគឺជាអ្វី? កិលេសទាំងឡាយមានលោភៈ ទោសៈ មោហៈ ជាដើម ដែលគេបានធ្វើឲ្យមានកម្លាំងខ្សោយចុះបន្តិចម្ដងៗតាមលំដាប់ចិត្តរបស់គេប្រែជាមានអំណាចលើកិលេស ការមើលឃើញនូវប្រយោជន៍ផ្ទាល់

ខ្លួនក៏នឹងថយចុះ ការឃើញចិត្តអធ្យាស្រ័យរបស់អ្នកដទៃនឹងរីកចំរើនឡើង សេចក្តីរីករាយ (បីតិ) និងសេចក្តីស្ងប់ (សន្តិ) នឹងកើតមានរឿយៗ ។ កាលណាមានសេចក្តីស្ងប់ក្នុងសន្តាន កាលនោះបញ្ញាក៏មានពន្លឺវិសេសវិសាលឬបញ្ញាជាន់ខ្ពស់ គឺបញ្ញាសម្រាប់ដឹងស្គាល់នូវសភាវៈទាំងឡាយរបស់ធម្មជាតិតាមសេចក្តីពិត ក៏កើតមានឡើងដែរ។ ក្នុងទីបំផុតនៃកំណើតរបស់បញ្ញានេះ សេចក្តីស្ងប់យ៉ាងប្រណីតក៏កើតមានឡើងជាបន្តបន្ទាប់គ្នា។ ក្នុងខណៈនោះ ចំណង់ទាំងឡាយ កំណាន់ទាំងឡាយក៏រលត់ព្រមៗគ្នា កំណើតអន្ទោលនៃសត្វទាំងឡាយក៏ចប់ត្រឹមប៉ុណ្ណោះ នេះឯងហៅថា "**និរោធសច្ចៈ**" ។

## ផ្លូវដើរទៅកាន់សេចក្តីរលត់ទុក្ខគឺជាអ្វី ?

គឺមគ្គមានអង្គ ៨ ប្រការ ៖

១- ធម្មទិដ្ឋិ ឃើញត្រូវតាមសេចក្តីពិត
២- សម្មាសង្កប្បៈ ត្រិះរិះតាមសេចក្តីពិត
៣- សម្មាវាចា និយាយត្រូវតាមសេចក្តីពិត
៤- សម្មាកម្មន្តៈ ធ្វើការត្រូវមានសេចក្តីពិត
៥- សម្មាអាជិវៈ ចិញ្ចឹមជីវិតត្រូវតាមសេចក្តីពិត
៦- សម្មាវាយាមៈ ព្យាយាមត្រូវតាមសេចក្តីពិត
៧- សម្មាសតិ មានស្មារតីត្រូវតាមសេចក្តីពិត
៨- សម្មាសមាធិ តម្កល់ចិត្តត្រូវតាមសេចក្តីពិត។

ទាំងអស់នេះហៅថា "**មគ្គសច្ចៈ**" ។

## និព្វាន

និព្វានគឺជាទីដៅចុងក្រោយបង្អស់នៃពុទ្ធសាសនិកជន ជាបរមសុខក្នុងទីបំផុតនៃអ្នកប្រព្រឹត្តធម៌ ជាធម្មជាតិមិនមានសំណោះសំនូន្យ តាមដែលអ្នកខ្លះដៅស្មាននោះទេ។ ជាសេចក្តីសំរេចដែលលោកទុកដូចជាត្រួយនៃសេចក្តី

ព្យាយាមអប់រំចិត្តឲ្យផុតចាកសេចក្តីលោភ សេចក្តីខឹង សេចក្តីវង្វេងព្រមជាមួយនឹងសេចក្តីសៅហ្មងទាំងឡាយដទៃទៀត ដែលមាននៅក្នុងសន្តានរបស់សត្វទាំងឡាយ។ ជាភាពមិនមានទុក្ខ មិនមានអន្ទោលនៃកំណើត ជាភាពរបស់ចិត្តដែលបានសំរេចនូវសេចក្តីបរិសុទ្ធ ជាលក្ខណៈនៃចិត្តដែលបានដល់នូវសេចក្តីស្ងប់យ៉ាងខ្ពស់ យ៉ាងបរិបូណ៌មិនមានកម្លាំងអ្វីមកធ្វើឲ្យកំរើកញាប់ញ័របាន។ ជាក្របខ័ណ្ឌនៃភូមិធម៌ជាន់ខ្ពស់របស់ចិត្ត ជាភាពនៃសេចក្តីសម្រេចនូវគោលបំណងជាខាងចុងបំផុតរបស់ជីវិតដែលបានវិវត្តន៍មកអំពីថ្នាក់ទាបបំផុត រហូតដល់ថ្នាក់ខ្ពស់បំផុតសឹងមនុស្សទាំងឡាយកំពុងវិវត្តន៍មកអំពីថ្នាក់ទាប បំផុតរហូតដល់ថ្នាក់ខ្ពស់បំផុតសឹងមនុស្សទាំងឡាយកំពុងឋិតនៅក្នុងការវិវត្តន៍ នេះគ្រប់ៗអាត្មា ។ និព្វានក្នុងន័យថា ៖ *ជាភាពសោះសូន្យឬជាភាពរលត់នោះ ន័យនេះប្រែថា ៖ រលត់លោភៈ ទោសៈ មោហៈ អស់ជាតិ ជរា ព្យាធិ មរណៈ និងទុក្ខទាំងឡាយដែលជាធម្មធាតុមាននៅប្រចាំវដ្តសង្សារ សំរាប់ជីវិតអន្ទោលប៉ុណ្ណោះឯង។*

## ច្បាប់អនត្តា

ទោះណាជាបញ្ញារបស់មនុស្សមានច្រើនឡើង តាមការរីកចំរើននៃវិទ្យាសាស្ត្រយ៉ាងណាក៏ដោយ ក៏នៅតែមានអ្នកមានជំនឿថា ៖ កំណើតមនុស្សជារបស់មានឡើងឯងៗ មិនមានទាក់ទងជាមួយនឹងហេតុផល កំណើងទាំងឡាយនេះ ពេលស្លាប់ក៏សូន្យស្លាយរលាយទៅ។ ក្នុងសាសនាគ្រីស្ត គេមានជំនឿថា ៖ ព្រះជាម្ចាស់នៃសួគ៌ទ្រង់បង្កើតមនុស្ស ឲ្យមានរូបរាងដូចគ្នានឹងព្រះអង្គ ប្រែថា ប្រសើរជាងរូបសត្វតិរច្ឆានទាំងឡាយ ព្រោះរូបមនុស្សប្រកបដោយវិញ្ញាណ ដែលមានភាពទៀងទាត់មិនចេះស្លាប់។ ចំណែកសត្វទាំងឡាយដទៃគេបដិសេធថាមិនមានវិញ្ញាណ មានតែជីវិតដែលព្រះទ្រង់ប្រទានឲ្យប៉ុណ្ណោះ។ ពួកអ្នកដែលមានជំនឿថាកំណើតមនុស្សមានឡើងឯងៗ ពួកនេះគិតតែអំពីធ្វើយ៉ាងណាឲ្យជីវិតរបស់ខ្លួនបានសប្បាយ មិនខ្វីរវល់គិតគូរអំពីបុណ្យបាបគុណទោសអាក្រក់ល្អឡើយ។ ពួកដែលមានជំនឿក្នុងព្រះអាទិទេព ក៏គិតតែគោរព

ផ្គាប់ផ្គុនព្រះអង្គដើម្បីឲ្យខ្លួនបានទៅកើតក្នុងឋានសួគ៌ ទោះណាជាមានឋាននរក ក៏គេមិនខ្វីខ្លាច ព្រោះគេមានសង្ឃឹមថា ៖ ព្រះជាម្ចាស់នៃសួគ៌នឹងទ្រង់អត់ទោសឲ្យគេ ប្រសិនបើគេមិនព្រមទទួលកំហុស ព្រមធ្វើសេចក្តីអង្វររលន់តួចំពោះព្រះអង្គ។

ក្នុងរឿងនេះ ព្រះសម្មាសម្ពុទ្ធរបស់យើងទាំងឡាយ ទ្រង់មានព្រះយោបល់ផ្សេងអំពីសាសនាទាំងឡាយដទៃ ព្រះអង្គទ្រង់យល់ថា ៖ មនុស្សកើតឡើងដោយខ្លួនឯង លក្ខណៈកំណើតក្នុងបច្ចុប្បន្ននេះមានដូចម្តេចខ្លះ វាមានបច្ច័យមកអំពីកម្មចាស់ក្នុងអតីតៈ ហើយកម្មក្នុងបច្ចុប្បន្ននេះនឹងជាធម្មធាតុតាក់តែងនូវជាតិភពរបស់គេក្នុងអានគតកាល។

កំណើតអន្ទោលនេះ ទោះណាជាពួកព្រហ្មបានស្គាល់តាំងអំពីមុនពុទ្ធកាលក៏ដោយ តែសំគាល់នេះគេពុំបានធ្វើអត្ថាធិប្បាយបញ្ជាក់ចុងដើម នៃហេតុនេះឲ្យច្បាស់លាស់សោះឡើយ។ ច្បាប់របស់កម្មនិងកំណើតអន្ទោលរបស់សត្វទាំងឡាយ ក្នុងសាកលលោកទាំងអស់ ជាធម្មធាតុដែលព្រះសម្មាសម្ពុទ្ធទ្រង់ស្រាវជ្រាវឃើញ។ ព្រះអង្គទ្រង់ជាសាស្តាដំបូងដែលបានស្គាល់ថា សត្វទាំងឡាយនិងសាកលលោកទាំងអស់ឋិតនៅក្រោមអំណាចរបស់កម្ម (គឺច្បាប់នៃភាវដែលមានហេតុត្រូវមានផល) ច្បាប់នេះពុំមាននរណាម្នាក់ជៀសរួចឡើយ ហើយព្រះហេតុដែលមនុស្សយើងជាសត្វមានកំណើតដោយខ្លួនឯង គេទាំងឡាយទើបទទួលខុសត្រូវខ្លួនឯង។ លក្ខណៈនៃកំណើតក្នុងបច្ចុប្បន្ននេះមានដូចម្តេចខ្លះ វាមានបច្ច័យមកអំពីកម្មចាស់ក្នុងអតីតៈ ហើយកម្មក្នុងបច្ចុប្បន្ននេះនឹងជាធម្មធាតុចាត់ចែងជាភពរបស់គេក្នុងអនាគតកាល។ គេអាចនឹងបានសំរេចនូវបញ្ញាជាន់ខ្ពស់ គេអាចនឹងរួចផុតចាកសេចក្តីទុក្ខនិងកំណើតអន្ទោលដោយសេចក្តីព្យាយាមក្នុងខ្លួនរបស់គេ។

ព្រះសម្មាសម្ពុទ្ធមិនត្រឹមតែត្រាស់ដឹងនូវច្បាប់របស់កម្ម តែមួយមុខប៉ុណ្ណោះទេខ្ពស់ជាងនេះទៅទៀត គឺព្រះអង្គទ្រង់ស្គាល់ច្បាស់ថា សាកលលោកនិងសព្វជីវិតជាធាតុមានសេចក្តីមិនទៀង ជាធាតុមានសេចក្តីទុក្ខ ជាធាតុមានសេចក្តីបែកស្លាយរលាយសូន្យ ។ ដូច្នេះ ទើបពិភពលោកទទួលស្គាល់ថា ព្រះ

អង្គជាសាស្តាដំបូងនិងជាសាស្តាតែមួយគត់ ដែលមានយោបល់ថា ៖ ខន្ធ ៥ គឺរូប សញ្ញា សង្ខារ វិញ្ញាណ ដែលយើងស្គាល់ថាជាអត្តានេះ ការណ៍ពិត ធម្មធាតុនេះវាត្រឹមតែជាផលនៃអាយតនៈ ៦ គឺភ្នែក ត្រចៀក ច្រមុះ អណ្តាត កាយ ចិត្ត តុបតែងឡើង ផ្លាស់ប្តូរទៅរឿយៗមិនមានទីបំផុត។ វាមិនមានខន្ធណាមួយ ដែលមនុស្សយើងអាចនឹងធ្វើនូវសេចក្តីបំភ្លឺថា ជាអត្តានេះឡើយ។ សត្វទាំងឡាយមានជំនាប់ដោយខន្ធ ៥ នេះ ព្រោះអវិជ្ជា ប្រែថាដឹងមិនដល់នូវសេចក្តីពិតរបស់ជីវិត និងតណ្ហាសេចក្តីប្រាថ្នាក្នុងការមារម្មណ៍) ធម្មធាតុនេះ វាធ្វើឲ្យមនុស្សសត្វចង់មាន ចង់កើត មិនចង់កើត គឺថាបើមិនមានកាមតណ្ហា (សេចក្តីប្រាថ្នាក្នុងកាមារម្មណ៍) ក៏គង់មានភវតណ្ហា (ការចង់បានជានេះជានោះ) ឬវិភវតណ្ហា (ការមិនចង់បានជានេះជានោះ)។ បើនឹងនិយាយមួយបែបទៀតថា ព្រោះអវិជ្ជានិងតណ្ហាទើបសត្វទាំងឡាយមានសំគាល់ខុស មានគំនិតខុសក្នុងន័យថា ៖ មានអត្តាជាធម្មជាតិសោយអារម្មណ៍តាមអាយតនៈទាំង ៦ ដូចជារូប៉ះខ្ទប់នឹងភ្នែក យើងសំគាល់ថាយើងជាអ្នកឃើញ ដែលពិតនោះលោកថា ៖ គំហើញនេះ កើតឡើយដោយអាស្រ័យភ្នែកជាអាយតនៈខាងក្នុង ១ រូបជាអាយតនៈខាងក្រៅ ១ ធម្មជាតិទាំងពីរនេះពានពារគ្នា ទើបកើតបានជាដំណឹងខាងផ្លូវភ្នែកនេះឡើង ដែលគម្ពីរអភិធម្មឲ្យឈ្មោះថា "**ចក្ខុវិញ្ញាណ**" ។ បើតាមន័យនេះ គំហើយក្តី កម្លិនក្តី ។ល។ ធម្មធាតុទាំងនេះ អាចកើតឡើយបានដោយអាស្រ័យរបស់ទាំង ៣ នេះ (ភ្នែក រូប វិញ្ញាណ) ជួបជុំគ្នាទើបកើតឡើងបាន ។ល។ តែគំនិតរបស់យើង ប្រែជាដៅស្មានថា អត្តា (យើង) ជាអ្នកឃើញរូប ជាអ្នកដឹងក្លិន ជាអ្នកដឹងរស ជាអ្នកដឹងសម្ផស្ស ជាអ្នកដឹងធម្មារណ៍ ដែលមិនមែនជាសេចក្តីពិតដូចនេះទៅវិញ។

ច្បាប់ស្តីដោយ អនត្តា របស់ព្រះសម្មាសម្ពុទ្ធ ជាច្បាប់មានសេចក្តីពិតជាទីបំផុត ដែលពុំធ្លាប់មានមកក្នុងសាសនាទាំងឡាយដទៃ ជាកំពូលនៃយោបល់របស់ព្រះអង្គ។ ពុទ្ធយោបល់នេះ មានពន្លឺឲ្យសត្វទាំងឡាយឃើញច្បាស់នៃសេចក្តីពិតរបស់ **កម្ម** និង **កំណើតអន្ទោល** មួយអន្លើដោយអរិយសច្ចៈ (ទុក្ខៈ សមុទយៈ និរោធៈ មគ្គ) ដែលជាធម្មចក្រនៃពុទ្ធសាសនារបស់យើង។

ច្បាប់នៃសេចក្តីពិតស្តីដោយអនត្តានេះ ជាធម្មធាតុកើតឡើយដោយការស្រាវជ្រាវប្រកបដោយព្រះគំនិតយ៉ាងខ្ពស់ និងយ៉ាងជ្រៅជាទីបំផុត ហើយកំពូលនៃសម្រាវជម្រាវនេះ មិនមែនជារបស់មានមកសម្រាប់ឃោសនាអួតចេះអួតដឹងទេ គឺជាកម្មវិធីប្រសើររបស់ជីវិតអ្នកប្រតិបត្តិធម៌ ក្នុងបំណងឲ្យខ្លួននិងមនុស្សសត្វទាំងឡាយលះបង់នូវកំហុសនៃគំនិតថា ៖ នៅក្នុងរូបកាយមានអត្តាដ៏ទៀងទាត់នុ៎ះឯង។

# ព្រះសម្មាសម្ពុទ្ធ ទ្រង់ស្រាវជ្រាវរកឃើញសេចក្តី

# ពិតស្តីដោយអនត្តានោះយ៉ាងដូចម្តេច ?

ក្នុងពេលត្រាស់ដឹងរបស់ព្រះអង្គក្រោមដើមពោធិព្រឹក្ស ព្រះអរហន្តសម្ពុទ្ធទ្រង់ស្គាល់ច្បាស់ ដោយព្រះពោធិញ្ញាណថា ៖ របស់ដែលគេស្គាល់ថាជាធម្មជាតិទាំងអស់ ទាំងមនុស្សទាំងសាកលលោកសុទ្ធតែនៅក្នុងវិស័យនៃការផ្លាស់ប្តូរកើតរលត់រឿយៗអស់កាលជាប់មិនដាច់ មិនមានរបស់អ្វីឋិតនៅក្រៅច្បាប់នៃការវិវត្តន៍នេះរហូតដល់ពីរពេលបានទេ គឺត្រូវមានគ្រប់ពេល (នាទី ម៉ោង ថ្ងៃ យប់...)។ បើនឹងនិយាយមួយបែបទៀតថា ៖ ហេតុផលនៃធម្មជាតិឋិតនៅក្នុងចលនាប្រែប្រួលដូច្នេះវិញក៏បាន។ ព្រោះព្រះសម្មាសម្ពុទ្ធទ្រង់បញ្ជាក់បន្ថែមក្នុងរឿងនេះថា ៖ របស់ទាំងឡាយដែលគេមើលឃើញ ហើយកំណត់សំគាល់ថាជាផលនោះ ក៏មិនមែនកើតឡើងដោយឥតហេតុទេ គឺត្រូវអាស្រ័យហេតុទើបកើតឡើងបាន តែហេតុនោះទៀតសោតក៏មិនអាចតាំងនៅក្នុងភាពពិតប្រាកដបានទេ ហេតុដំបូងរមែងងាករេចូលទៅកាន់ភាពលក្ខណៈផ្សេងទៀត តែរបស់ទាំងនេះវាតែងអាស្រ័យដូចគ្នានឹងគ្នា ជាហេតុជាផលជាប់គ្នារដឹកដូចកាំច្រវាក់ គឺហេតុផ្លាស់ភាពមកជាផល ផលផ្លាស់ភាពមកជាហេតុ ឧទាហរណ៍កើតជាហេតុ ស្លាប់ជាផល ស្លាប់ជាហេតុ កើតជាផល។ ដូចនេះព្រោះអ្វី? ព្រោះហេតុនិងផលជាធម្មធាតុប្តូរភាពប្តូរទីគ្នាដូចកាំច្រវាក់នុ៎ះឯង។ នៅក្នុងរឿងនេះ ពាក្យធម្មតាក៏មាននិយាយគ្នាថា ៖ "សេចក្តីស្លាប់មកអំពីសេចក្តីកើត សេចក្តីកើតមកអំពីសេចក្តីស្លាប់" ពាក្យនេះជាពាក្យនិយាយដែលម្ចាស់ពាក្យមិនទាន់បានជាគិតឲ្យជ្រៅជ្រះទេ តែពាក្យនេះបានចូលទៅក្នុងហេតុផលនៃសេចក្តីត្រឹមត្រូវហើយ ព្រោះអ្វី? ព្រោះមេសូធ្យនៃបដិសមុប្បទបានបញ្ជាក់ថា អវិជ្ជាជាហេតុរបស់សង្ខារ សង្ខារជាផលរបស់អវិជ្ជា សង្ខារជាហេតុរបស់វិញ្ញាណ ជាផលរបស់សង្ខារ ។ល។ ការវិវត្តន៍របស់ធម្មជាតិដូចបាននិយាយមកនេះឯង ទើបត្រូវមានឈ្មោះថា ហេតុនិងផលពុំអាចតាំងនៅក្នុងភាពច្បាស់

លាស់ ឬពុំអាចតាំងនៅក្នុងភាពមួយ ក្នុងលក្ខណៈមួយដោយមិនមានប្តូរទីប្តូរភាពគ្នានោះបានឡើយ។ ដូច្នេះហើយ បានជាព្រះសម្មាសម្ពុទ្ធទ្រង់ត្រាស់ថា ព្រោះមានហេតុហ្នឹងឯង ទើបត្រូវមានផលគឺអនិច្ចំ ទុក្ខំ អនត្តា ពុទ្ធតម្រាស់នេះ បើសិនជាយើងយកមកបកស្រាយនៅក្នុងក្របខ័ណ្ឌនៃត្រៃលក្ខណ៍នោះ ។ យើងត្រូវនិយាយថាអនិច្ចំជាហេតុរបស់ទុក្ខំ ទុក្ខំជាផលរបស់អនិច្ចំ ទុក្ខជាហេតុរបស់អនត្តា អនត្តាជាផលនៃទុក្ខំ អនត្តាជាផលរបស់អនិច្ចំ អនិច្ចំជាផលរបស់អនត្តា ។ល។ ប្រទាក់ប្រតោងគ្នាមិនមានទីបំផុត ដែលពុទ្ធសាសនាយកការប្រទាក់ក្រតោគ្នានៃធម្មជាតិនេះមកឲ្យឈ្មោះថា ៖ "**កំណើតអន្ទោល**" ឬ "**សង្សារវដ្ត**" ។

សភាពរបស់ជីវិតគឺសេចក្តីមិនទៀង សេចក្តីទុក្ខនិងភាពមិនមានអត្តាហ្នឹងឯងប្រសិនបើយើងពិចារណាដល់រឿងនេះរឿយៗ ចិត្តរបស់យើងក៏នឹងឃ្លាតចេញឆ្ងាយចាកការប្រកាន់មាំក្នុងអត្តា។ ការសង្រួម ការឃាត់ខាំងចិត្តនិងការពិចារណាឃើញសភាពពិតរបស់ជីវិត រមែងនាំខ្លួនយើងទៅកាន់ធម៌ថ្នាក់ខ្ពស់សំរាប់ចិត្តនៃសត្វទាំងឡាយ។ សេចក្តីសន្តោសក្នុងជីវិត និងអធ្យាស្រ័យមេត្តាករុណាចំពោះសត្វក្នុងសាកលលោកនឹងកើតមានឡើង។ មនុស្សទាំងឡាយមានទុក្ខព្រោះសង្ខារមិនទៀងព្រោះហេតុដូចនេះ ការបណ្តែតបណ្តោយចិត្តឲ្យស្រវឹងនឹងសេចក្តីសុខសប្បាយទាំងឡាយ វាជាធាតុមួយអាចធ្វើឲ្យយើងភ្លាត់ធ្លាក់ចុះ ទៅក្នុងសេចក្តីទុក្ខវិញជាមិនខានព្រោះសេចក្តីសុខក៏ជារបស់មិនទៀងដូចរបស់ទាំងឡាយដទៃ ដែលយើងត្រូវលះបង់ចោលទើបនឹងបានដល់ទីបំផុតនៃទុក្ខ។

## កម្មនិងកំណើតអន្ទោល

ចាកអរិយសច្ចៈ៤ យើងបានស្គាល់ថា ៖ តណ្ហា៣ ជាហេតុឲ្យមានកំណើតអន្ទោល ចំណង់ជាហេតុឲ្យគំនិតវង្វេងជំពាក់ទាក់ទិននៅក្នុងជីវិត តែជាកម្មជាធម្មធាតុ ឲ្យកើតថ្មី ក្នុងខណៈដែលជីវិតត្រូវរលត់នោះ មិនប្រាកដថាមានរបស់ណាមួយអាចធ្វើចលនាទៅកាន់កំណើតថ្មីទេ ប៉ុន្តែកំណើតថ្មីនេះចូលមក

កាន់ជីវិតដោយចម្រាននៃតណ្ហានិងកម្មរបស់បុគ្គល ដែលត្រូវស្លាប់ ដែលប្រើពុំទាន់អស់ ដែលសល់នៅក្នុងជីវិតអន្តោលនោះ និងជាធម្មធាតុចូលមក តុបតែងកំណើតថ្មី។ ព្រឹត្តិកម្មនៃធម្មជាតិក្នុងរឿងនេះ មានឧបមាដូចបុគ្គលនាំយកទៀនមួយដើម ដែលកំពុងត្រូវឆេះមានពន្លឺយ៉ាងស្វាងស្វៃ ទៅអុជទៀនមួយដើមដទៃទៀតឲ្យឆេះមានពន្លឺដូចគ្នាឡើង យ៉ាងណាមិញ កំណើតនៃជីវិតចាស់និងកំណើតនៃជីវិតថ្មី ក៏មានការទាក់ទងគ្នាយ៉ាងនោះដែរ។

ម្យ៉ាងទៀត មនុស្សម្នាក់ៗមានខ្លួនជាបច្ច័យរបស់កម្ម មនុស្សជាអ្នកសាងកម្មទាំងបច្ចុប្បន្នទាំងអនាគត មនុស្សជានាយនៃជោគជាតារាសីរបស់ខ្លួន ខ្លួនម្នាក់ៗអាចនឹងសាងកម្មក្នុងអនាគតឲ្យល្អជាងកម្មក្នុងបច្ចុប្បន្នបានដូច ពុទ្ធភាសិតក្នុងគម្ពីរធម្មបទថា ៖ *"ធ្វើបាបខ្លួនឯង នឹងមានសេចក្ដីសៅហ្មងខ្លួនឯង មិនធ្វើបាបដោយខ្លួនឯង នឹងបានសេចក្ដីបរិសុទ្ធខ្លួនឯង សេចក្ដីសៅហ្មងនិងសេចក្ដីបរិសុទ្ធ កើតមកតែអំពីខ្លួនឯង ពុំមែនកើតមកអំពីអ្នកដទៃឡើយ"* ។

កម្មដែលបុគ្គលធ្វើតែម្នាក់ឯង តែកម្មទាំងឡាយនោះវាអាចនិងឲ្យផលរាលដល់អ្នកដទៃផងក៏មានដែរ ព្រោះកម្មដែលគេធ្វើនោះ វេលាឲ្យផលនឹងឲ្យតាមព្រឹត្តិហេតុនិងវត្ថុធាតុដែលមាននៅជុំវិញនៃជីវិត។ ដោយអាស្រ័យហេតុនេះ ទើបគេឃើញសេចក្ដីទុក្ខរបស់គ្រួសារ របស់ញាតិមិត្ត របស់ប្រជាជាតិនៃបុគ្គលអ្នកធ្វើកម្មអាក្រក់ជារឿយៗ ។ ដូច្នេះប្រសិនបើព្រឹត្តិហេតុនិងវត្ថុធាតុជុំវិញមិនមាន កម្មក៏ពុំមានឲ្យផលដែរ ។ ចំពោះរឿងនេះ យើងអាចនឹងធ្វើនូវសេចក្ដីសន្និដ្ឋានថា ៖ កម្មនឹងអាចឲ្យផលទៅលើអ្នកសាងតែម្យ៉ាងក៏មាន អាចនឹងឲ្យផលរាលដាលទៅលើ អ្នកដទៃរស់នៅជិតឬរស់នៅជាមួយក៏មាន។

ច្បាប់នៃ កម្ម ប្រសិនបើយើងចង់និយាយឲ្យបានងាយស្ដាប់នោះ យើងត្រូវធ្វើសំណួរថា ៖ មនុស្សទាំងឡាយដូចម្ដេចទើបមានលក្ខណៈផ្លែកផ្សេងគ្នា? លក្ខណៈទាំងឡាយនេះកើតមានឡើងព្រោះអាស្រ័យអ្វី? ចំពោះសំណួរនេះ ចម្លើយរបស់សាសនាព្រាហ្មណ៍ គ្រឹស្ត ឥស្លាម ថា ៖ លក្ខណៈទាំងឡាយរបស់មនុស្សសត្វទាំងល្អទាំងអាក្រក់ មានឡើងដោយព្រះអាទិទេពទ្រង់បង្កើត ។ ឆម្លើយរបស់សាសនាព្រះពុទ្ធថា ៖ លក្ខណៈទាំងឡាយនៃរូបកាយរបស់

មនុស្សមាន កំម៉ៅ សំណា កំពស់ ទំនាប សំគម ទំហាត់ តំណូច ទំហំ កង្វាក់ កង្វិន តម្លង់ គំនឿ កំបុត កំបាក់។ នៃចិត្តវិញ្ញាណមានឆម្លួត សម្ពឹក កម្លៅ កម្លាច ចម្លាត ចំណេះ ដំណឹង ។ល។ និងសម្បទាផ្សេងៗច្រើនយ៉ាងទៀតមានមកអំពីមនុស្សបង្កើត ដែលប្រែថាកម្មឬបុណ្យបាប ដែលមនុស្សម្នាក់ៗបានធ្វើក្នុងបច្ចុប្បន្នក្តី អតីតក្តី អនាគតក្តី កម្មទាំងឡាយនេះជារបស់នៃមនុស្សអ្នកសាងមនុស្សត្រូវមានខ្លួនជាមត៌តរបស់កម្ម មានកម្មជាកំណើត មានកម្មជាញាតិមិត្រមានកម្មជាទីពឹង...។ ដែលយើងធ្លាប់ចេះចាំគ្រប់គ្នាថា ធ្វើល្អបានល្អ ធ្វើអាក្រក់បានអាក្រក់ហ្នឹងឯង ។ អ្នកអានទាំងឡាយសូមពិចារណារឿងកម្មនេះតាមសំណួរនិងចំលើយដែលខ្ញុំបានសរសេរមកដោយសង្ខេបនេះ ហើយសូមធ្វើនូវសេចក្តីចូលចិត្តដោយខ្លួនឯងចុះ។ ប្រសិនបើមិនយល់សូមមេត្តាមើលរឿងកម្មនេះឡើងវិញក្នុងសៀវភៅឈ្មោះ "**ពុទ្ធវិទ្យារឿងបុណ្យបាប**" ដែលខ្ញុំបានសរសេរ ហើយដែលគេបានបោះពុម្ពផ្សាយហើយ។

## បដិច្ចសមុប្បាទ

លក្ខខណ្ឌនៃបដិច្ចសមុប្បាទ ជាធម្មធាតុសំខាន់បំផុតក្នុងព្រះពុទ្ធសាសនា ជាលក្ខខណ្ឌដែលព្រះសម្មាសម្ពុទ្ធទ្រង់អធិប្បាយដល់ដើមហេតុនៃទុក្ខ និងដំណើរប្រព្រឹត្តទៅនៃធម្មជាតិទាំងឡាយ ជាចម្លើយនៃបញ្ហាជីវិតរបស់មនុស្សក្នុងសាកលលោក។

បដិច្ចសមុប្បាទនេះ មានលក្ខខណ្ឌ១២ប្រការ សម្រាប់អធិប្បាយបំភ្លឺនូវសាហេតុនៃសេចក្តីទុក្ខ។ អ្នកសិក្សាទាំងឡាយណា មានពន្លឺក្នុងបដិច្ចសមុប្បាទនេះអ្នកសិក្សានោះឈ្មោះថា បានទទួលនូវកូនសោនៃគំនិតមួយយ៉ាងសំខាន់សម្រាប់ចាក់ទ្វារនាំវិញ្ញាណរបស់ខ្លួន ចូលទៅនៅក្នុងផ្ទះគឺអរិយមគ្គអរិយផលទាំងឡាយ។ ដើម្បីចូលចិត្តនូវអរិយសច្ចៈ គេត្រូវបំពេញសមាធិប្រតិបត្តិតាមមគ្គទាំង ៨ ជាពិសេសគឺពិចារណា ឲ្យយល់សេចក្តីនៃអង្គបដិច្ចសមុប្បាទទាំងឡាយនេះ។

## អង្គនៃបដិច្ចសមុប្បាទ ១២ គឺ ÷

ព្រោះ អវិជ្ជា ជាបច្ច័យ មានសង្ខារ
ព្រោះ សង្ខារ ជាបច្ច័យ មានវិញ្ញាណ
ព្រោះ វិញ្ញាណ ជាបច្ច័យ មាននាមរូប
ព្រោះ នាមរូប ជាបច្ច័យ មានសឡាយតនៈ
ព្រោះ សឡាយតនៈ ជាបច្ច័យ មានផស្សៈ
ព្រោះ ផស្សៈ ជាបច្ច័យ មានវេទនា
ព្រោះ វេទនា ជាបច្ច័យ មានតណ្ហា
ព្រោះ តណ្ហា ជាបច្ច័យ មានឧបាទាន
ព្រោះ ឧបាទាន ជាបច្ច័យ មានភព
ព្រោះ ភព ជាបច្ច័យ មានជាតិ
ព្រោះ ជាតិ ជាច្ច័យ មានជរាមរណៈសោកបរិទេវទុក្ខទោមនស្សឧបាយាសៈ។

ដើម្បីចូលចិត្តងាយ សូមមេត្តាពិចារណាធម៌នេះ ដោយចាប់ផ្តើមអំពីបទខាងចុងស្រាវដេញទៅរកបទខាងដើម ដែលហៅថា បដិលោមតាមសេចក្តីអធិប្បាយបំភ្លឺរបស់ខ្ញុំ មានដូចតទៅនេះ ៖

សត្វលោកទាំងឡាយ កាលណាមានកំណើតហើយនឹងមានចំណាស់ជម្ងឺនិងសម្លាប់ (សេចក្តីស្លាប់) នៅក្នុងទីបំផុត។ ព្រះបរមសាស្តាទ្រង់មានតម្រាស់ថា ជីវិតទាំងពួងជាទុក្ខព្រោះមានជរាមរណៈ ដែលមានជាតិជាហេតុ។

ជាតិប្រៀបបាននឹងរូបភាពមួយៗនៃភាពយន្ត ដែលមានចលនាដូរផ្លាស់រឿយៗឬប្រៀបបាននឹងជំនួបនៃពេលវេលា ដែលមានចលនាវិលទៅវិលមកនៅក្នុងវង់នៃដំណើរអន្ទោល ដែលយើងគួរកត់សំគាល់នូវជំនួបនេះថា ថ្ងៃវិលមកដល់យប់ យប់វិលមកដល់ថ្ងៃ ការវិលរបស់កាលដែលបិតនៅក្នុងជំនួបបែបនេះ លោកហៅថា "**ការអន្ទោលនៃពេលវេលា**" ។ ជីវិតរបស់សត្វទាំងឡាយដែលវិលអំពីកើតទៅដល់ស្លាប់ វិលអំពីស្លាប់ទៅដល់កើត ការវិលរបស់ជីវិត

ដែលបិតនៅក្នុងវង់នៃការអន្ទោលជាតិ គឺវិលនៅក្នុងភាពដដែលៗបែបនេះ លោកហៅថា "**សង្សារវដ្ដ**" ។

ជាតិមាន ព្រោះភព ភាពក្នុងទីនេះ សំដៅទៅលើសាកលលោកធាតុទូទៅ ចាអាកាសធាតុផង ជាបឋវីធាតុផង ជាអាបោធាតុផង ជាតេជោធាតុផង ជាវាយោធាតុផង ដែលភាសាធម្មតានិយាយាថា ៖ ឋានមនុស្ស ឋានទេវតា ឋានឥន្ទ ឋានព្រហ្ម ឋានអរូបព្រហ្ម ឋានអសញ្ញីសត្វ ឋានព្រះអាទិត្យ ឋានព្រះច័ន្ទ ឋានព្រះសុក្រ ឋានព្រះសៅរ៍ ឋានព្រះអង្គារ ឋានព្រះពុធ ឋានព្រះហស្បតិ៍ ឋានព្រះរាហូ ឋានព្រះកេត ឋានផ្កាយទាំងឡាយ ចំណាំង ពន្លឺ ភាពត្រជាក់ កំដៅ កាល ថ្ងៃ យប់ រដូវ បន្លាស់ ជំនួប ។ល។ ទាំងអស់នេះហើយជាធម្មជាតិធ្វើឲ្យមានឡើងនូវកំណើតនៃជីវិតទាំងឡាយក្នុងសាកលលោក។

**ភពមាន ព្រោះឧបាទាន** ដែលយើងធ្លាប់ចេះចាំគ្រប់គ្នាថា កំណាន់យ៉ាងស្អិតដែលជីវិតអន្ទោលបាន ប្រកាន់យកអស់កាលជានិច្ចក្នុងរបស់ដែលតែងតែប្រែប្រួល ទៅតាមសភាវៈនៃធម្មជាតិ។

**ឧបាទានមាន ព្រោះតណ្ហា** ដែលអ្នកអានទាំងឡាយធ្លាប់ស្គាល់គ្រប់គ្នាហើយ។ ដើម្បីជាពន្លឺដល់អ្នកអានខ្លះទៀត សូមធ្វើសេចក្ដីបកស្រាយអំពីតណ្ហា ៣យ៉ាង ដែលមានឈ្មោះថា **កាមតណ្ហា ភវតណ្ហា វិភវតណ្ហា** ដូចមានខាងក្រោមនេះ ៖

កាមតណ្ហា សេចក្ដីប្រាថ្នាក្នុងកាម កាមក្នុងទីនេះសំដៅយករូប សម្លេង ក្លិន រស ផស្សៈទាំងឡាយណាដែលជាទីស្រឡាញ់ពេញចិត្ត ឬ ជាទីត្រេកអរនៃសត្វទាំងឡាយ។ ចំណែករូប សម្លេង ក្លិន រស ផស្សទាំងឡាយដែលមិនជាទីស្រឡាញ់ ជាទីប្រាថ្នារបស់សត្វទាំងឡាយ លោកពុំឲ្យឈ្មោះថាកាមឡើយ។ ដើម្បីងាយយល់ សូមមេត្តាគិតថា ៖ រូប សម្លេង ក្លិន រស ផស្សដែលជាទីស្រឡាញ់ ជាទីប្រាថ្នារបស់សត្វទាំងឡាយនោះ មិនមែនជារូប សម្លេង ក្លិន រស ផស្សអ្វីដទៃក្រៅអំពីរូប សម្លេង ក្លិន រស សផ្សរបស់បុរសនិងស្ត្រីទាំងពីរនេះឡើយ។ មេត្តានឹកថា ៖ ព្រះអរហន្តទាំងឡាយ ដែលមានចិត្តរួចស្រឡះចាក

កាមទាំងឡាយហើយ ក៏គង់តែលោកនៅប្រើរូប សម្លេង ក្លិន រស ផស្សទាំងឡាយដែលមិនមែនជាកាមដូចជារូបកុដិសាលា សម្លេងខ្យល់ ក្លិនផ្កា រស អាហារនិងសម្ផស្សនៃស្បង់ចីពរជាដើម ប្រែថា លោកប្រើប្រាស់របស់គ្រប់យ៉ាងជាបច្ច័យរបស់ជីវិត មិនប្រើជាកាមរបស់ជីវិតឡើយ។ ដូច្នេះ រូប សម្លេង ក្លិន រស និង ផស្សដែលកំណត់ឲ្យឈ្មោះជាកាមនោះ គឺលោកសំដៅយករូប ... បុរសស្ត្រីព្រោះរូបទាំងពីរប្រភេទនេះជាវត្ថុធាតុញ៉ាំងចិត្តនៃសត្វលោកឲ្យតម្រេកកើតសេចក្តីប្រាថ្នាទាំងសងខាង។ **ភវតណ្ហា** ប្រាថ្នាចង់បាន ប្រែថាចង់បានធំ ចង់បានខ្ពស់ ចង់បានទ្រព្យ ចង់បានយសស័ក្តិ ចង់មានអំណាច ចង់បានសម្ញើច ចង់មានតម្លៃ ចង់បានកេរ្តិ៍ឈ្មោះល្អ។ល។ **វិភវតណ្ហា** ប្រាថ្នាមិនឲ្យជួបមិនឲ្យឃើញ មិនឲ្យដឹងមិនឲ្យឮនូវអ្វីៗទាំងអស់ដែលខ្លួនកតសំគាល់ថាមិនល្អ។

**តណ្ហាមាន ព្រោះវេទនា** ត្រង់ចំណុចនេះងាយចូលចិត្តទេ។ តាមធម្មតាយើងធ្លាប់ដឹងគ្រប់គ្នាថា ៖ វត្ថុធាតុណាឲ្យសេចក្តីសុខដល់យើង យើងចង់បានវត្ថុធាតុនោះ ដែលឲ្យសុខច្រើន ចង់បានច្រើន ដែលឲ្យសុខតិច ចង់បានតិច។

**វេទនាមាន ព្រោះផស្ស** ពីព្រោះតែមានការទង្គិចគ្នារវាងអាយតនៈខាងក្នុង ភ្នែក ត្រចៀក ច្រមុះ អណ្តាត កាយនិងចិត្ត និងអាយតនៈខាងក្រៅ រូបារម្មណ៍ សទ្ទារម្មណ៍ គន្ធារម្មណ៍ រសារម្មណ៍ ផោដ្ឋព្វារម្មណ៍និងធម្មារម្មណ៍។

អាយតនៈខាងក្នុង៦ នឹងធ្វើការតាមប្រក្រតីបាណ ត្រូវអាស្រ័យជាមួយនឹងវិញ្ញាណ។ ព្រះសម្មាសម្ពុទ្ធទ្រង់មានព្រះតម្រាស់ថា វិញ្ញាណជាធាតុមានក្នុងទីទូទៅមិនមែនជារបស់សម្រាប់មនុស្សណា សត្វណា ដើមឈើណាមួយៗទេ។ ធាតុនេះរមែងតែងមានចលនាប្រាកដឡើង រាល់តែពេលដែលអាយតនៈខាងក្នុងទង្គិចនឹងអាយតនៈខាងក្រៅ។ ក្រោយអំពីវត្ថុធាតុទាំងពីរនេះបានទង្គិចគ្នាហើយ ទើបកើតមានចក្ខុវិញ្ញាណ សោតវិញ្ញាណ ឃានវិញ្ញាណ កាយវិញ្ញាណ និងមនោវិញ្ញាណ។ វិញ្ញាណទាំងឡាយនេះមានការកើតរលត់

រឿយៗ មិនមែនជាធាតុឋិតនៅក្នុងលក្ខណៈស្ថិតស្ថេរជាស្ថាពរឡើយ។

**ផស្សមាន ព្រោះអាយតនៈ** ដូចដែលខ្ញុំបានសរសេរមកហើយ ដោយចំណុចនេះមានសេចក្ដីមិនសូវជាបិបាកយល់ប៉ុន្មាន អ្នកអានទាំងឡាយ សូមគ្រាន់តែពិចារណាតាមសេចក្ដីខ្លីៗនេះ ក៏អាចនឹងចូលចិត្តបានហើយ

អាយតនៈមាន ព្រោះនាមរូប បទមួយនេះទៀត ក៏មានសេចក្ដីរាក់ងាយនឹងពិចារណាដែរ ព្រោះអ្វី? ព្រោះថាបើគ្មានរូបគ្មាននាម ក៏ពុំអាចនឹងមានភ្នែក ត្រចៀក ច្រមុះ អណ្ដាត កាយនិតចិត្តបានដែរ ។

**នាមរូបមាន ព្រោះវិញ្ញាណ** ក្នុងចំណុចនេះហើយគ្រាន់តែច្រើនគំនិតប្រកបដោយវិចារណញ្ញាណរឿយៗទៅ យើងគង់នឹងយល់ជាមិនខាន ព្រោះរូបកាយនៃមនុស្សក្ដី នៃដើមឈើក្ដី វាមានលក្ខណៈឆ្លែកៗ ។ លក្ខណៈទាំងឡាយនៃរូបមានលក្ខណៈខ្លះល្អ មានលក្ខណៈខ្លះអាក្រក់ ទាំងល្អទាំងអាក្រក់ សុទ្ធតែមានរបស់អាថ៌កំបាំង ដែលជាងគំនូរយ៉ាងជំនាញក៏ពុំអាចគូរឲ្យបានមួយរយភាគរយឡើយ។ មិនតែប៉ុណ្ណោះទេ របស់ដែលមាននៅក្នុងរូបកាយនិងលើរូបកាយទាំងមូល សុទ្ធសឹងតែរបស់មានន័យ សម្រាប់មកស្រាយនូវបំណងនៃធម្មជាតិដែលបង្កើតរូបនេះបានទាំងអស់ ជាអាទិសក់មានមកសម្រាប់អ្វី រោមមកមានសម្រាប់អ្វី ធ្មេញមានមកសម្រាប់អ្វី ស្បែកមានមកសម្រាប់អ្វី ... បើតាមន័យនេះ អ្នកសាងរូបត្រូវជាអ្នកមានចំណេះវិជ្ជាយ៉ាងខ្ពស់ និងមានការពិសោធន៍ក្នុងសំណង់នេះយ៉ាងច្រើនផងទើបអាចធ្វើបាន។ អ្នកនោះគឺនរណា មិនគឺវិញ្ញាណនោះទេឬ? ព្រោះវិញ្ញាណយើងក៏ធ្លាប់ស្គាល់ថា ជាធាតុមួយមានសេចក្ដីចេះដឹងនៅក្នុងខ្លួនរបស់វា ។

**វិញ្ញាណមាន ព្រោះសង្ខារ** សង្ខារក្នុងទីនេះពុទ្ធសាសនាដៅយកសេចក្ដីនឹកគិត ដែលជាផលរបស់កម្ម ដែលសត្វធ្វើដោយចេតនា (កាយកម្ម វចិកម្ម មនោកម្ម) ។ ដូច្នេះ ចេតនា (សង្ខារ) ដែលកើតអំពីកម្មទាំងឡាយនោះហើយ ដែលជាបច្ច័យឲ្យមានវិញ្ញាណ។ វិញ្ញាណក្នុងជីវិតបច្ចុប្បន្ន គឺជាវិញ្ញាណរបស់កម្មចាស់ ដែលសត្វបានធ្វើក្នុងអតីតកាល ។ ប្រែថាវិញ្ញាណសត្វ ថ្ងៃនេះដែល

យើងសន្មតហៅថា វិញ្ញាណថ្មីនោះ គឺជាធាតុកើតអំពីកម្មចាស់ (អតីតវិញ្ញាណ) ឬបើនឹងនិយាយមួយបែបទៀតថា ៖ វិញ្ញាណចាស់ជាបច្ច័យ ឲ្យកើតវិញ្ញាណថ្មីដូច្នេះវិញក៏មាន ។

**សង្ខារមាន ព្រោះអវិជ្ជា** ក្នុងចំណុចនេះអ្នកអានគប្បីយល់ថា ៖ ការមិនស្គាល់នូវសេចក្ដីពិតតាមសភាវៈនៃធម្មជាតិ មិនស្គាល់នូវអរិយសច្ចៈ៤ មិនស្គាល់ច្បាស់នូវកម្ម មិនស្គាល់ត្រៃលក្ខណ៍និងមិនស្គាល់បដិច្ចសមុប្បាទ។ ការមិនស្គាល់នូវធម្មធាតុទាំងឡាយនេះ ជាហេតុឲ្យទំហើទាំងអស់របស់មនុស្សនៅក្រោមអំណាចនៃចេតនាដែលមានកំហុស។ កាលណាសត្វទាំងឡាយមានកំហុសនៅក្នុងចេតនា ចំណង់ទាំងឡាយរបស់មនុស្សក៏មានកំហុសតគ្នា។ គេទាំងឡាយរមែងចង់កើតជានេះជានោះ មិនចេះនឿយណាយធុញទ្រាន់ ដោយអាស្រ័យសេចក្ដីល្ងង់ដែលធាតុបង្កើតនូវកំហុសចេតនា ដែលយើងធ្លាប់ហៅថាសង្ខារហ្នឹងឯង។ អវិជ្ជាគឺជាបឋមហេតុនៃទុក្ខទាំងឡាយ ប្រសិនបើមនុស្សយើងកំចាត់អវិជ្ជាចោលបានហើយនាំគ្នាធ្វើបុណ្យ ឈប់ធ្វើបាប ព្រមជាមួយគ្នានេះ នាំគ្នាសំអាតចិត្តឲ្យអស់មន្ទិលគឺលោភៈ ទោសៈ មោហៈ នោះយើងនឹងបានសម្រេចនូវបញ្ញាខ្ពស់ខ្ពស់និងនិព្វានដែលជាទីបំផុតនៃទុក្ខទាំងឡាយ ជាមិនខានឡើយ ។

ព្រះសម្មាសម្ពុទ្ធទ្រង់ត្រាស់ដឹងនូវច្បាប់នៃសេចក្ដីមិនទៀង នៃទុក្ខ នៃអនត្តា របស់សត្វលោក ៗ ជាមួយគ្នានេះ ព្រះអង្គទ្រង់ធ្វើការស្រាវជ្រាវឃើញច្បាប់នៃកម្មដែលជាច្បាប់របស់ធម្មជាតិ បានសេចក្ដីពិតយ៉ាងបរិសុទ្ធ ជាធម្មធាតុមានអំណាចលើសកលលោក។ ដូច្នេះ ទើបទ្រង់បានអ្នកប្រាជ្ញទាំងឡាយទទួលស្គាល់ព្រះអង្គថា ជាទស្សនវិទូជាន់ខ្ពស់បំផុត ដោយថ្វាយព្រះនាមថា ‶លោកវិទូ″ ដែលយើងទាំងឡាយធ្លាប់ស្គាល់គ្រប់គ្នា ។

# បទទី ៨

# ការប្រតិបត្តិធម៌

ទោះណាជាព្រះពុទ្ធសាសនា ជាសាសនារបស់រដ្ឋ តាមដែលមានចែងក្នុងច្បាប់រដ្ឋធម្មនុញ្ញនៃរដ្ឋាណាចក្រក៏ដោយ ប្រជាជាតិខ្មែរយើងក៏គង់ពុំមែនជាពុទ្ធសាសនិកទាំងអស់ទេ ដូចនេះព្រោះអ្វី? ព្រោះរដ្ឋធម្មនុញ្ញបានអនុញ្ញាតឲ្យប្រជាពលរដ្ឋរាល់រូប មានសិទ្ធិជ្រើសរើសយកសាសនាណាមួយ មកធ្វើជាសាសនាសំរាប់ជីវិតរបស់ខ្លួន តាមសេចក្ដីពេញចិត្ត។ ដូចនេះ ឃើញថា ៖ បំណងរបស់រដ្ឋក្នុងរឿងនេះ មិនមានប្រាថ្នាអ្វីក្រៅអំពីឲ្យប្រជាពលរដ្ឋមានសេរីភាពយ៉ាងទូលំទូលាយដូច្នេះក៏ដោយ ប្រជាជាតិភាគច្រើនរបស់យើង ហាក់ដូចជាពុំសូវចាប់ចិត្តស្រឡាញ់រាប់អាន សាសនាទាំងឡាយដទៃប៉ុន្មានទេ ដែលមានខ្លះបន្តិចបន្តួចនោះ *ច្រើនជាអ្នកប្រាថ្នាប្រយោជន៍ក្នុងផ្លូវបច្ចុប្បន្ន មិនមែនជាអ្នកស្រឡាញ់រាប់អានប្រកបដោយចិត្តជាសីលធម៌តាមផ្លូវសាសនាឡើយ។*

បុគ្គលទាំងឡាយជាពុទ្ធសាសនិក ដែលធ្លាប់បានប្រតិបត្តិធម៌ក្នុងព្រះពុទ្ធសាសនាមកហើយ មិនមានបញ្ហាអ្វីចោទក្នុងរឿងនេះទេ។ ប៉ុន្តែបុគ្គលទាំងឡាយណា ដែលមិនមែនជាសាសនិក ហើយមានចិត្តចង់ប្រតិបត្តិធម៌របស់ពុទ្ធសាសនាក៏អាចនឹងប្រតិបត្តិបានគ្មានលំបាកទេ ម្នាក់ៗគ្រាន់តែតាំងចិត្តរំពឹងគិតដល់សេចក្ដីបរិសុទ្ធរបស់ព្រះពុទ្ធ ព្រះធម៌និងព្រះសង្ឃ ហើយចម្លងយកសេចក្ដីបរិសុទ្ធទាំងឡាយនោះដោយចិត្តរបស់ខ្លួន ប្រែថាធ្វើចិត្តរបស់ខ្លួនឲ្យមានសេចក្ដីបរិសុទ្ធដូចព្រះពុទ្ធព្រះធម៌និងព្រះសង្ឃ ហើយនាំគ្នាប្រតិបត្តិតាមធម៌ទាំងឡាយដែលព្រះសម្មាសម្ពុទ្ធទ្រង់សំដែង ក៏ជាការស្រេចត្រឹមប៉ុណ្ណោះឯង។

ពាក្យថា ៖ **ប្រតិបត្តិធម៌** បានដល់ការធ្វើតាមធម៌ មិនមែនរៀនធម៌និងចេះចាំធម៌ទេ ។ ដើម្បីឲ្យអ្នកអានទាំងឡាយបានភ្លឺក្នុងរឿងប្រតិបត្តិធម៌នេះ ខ្ញុំសូមបញ្ជាក់ថា ធម៌មាន ៣ ប្រការគឺ ៖

១- បរិយត្តិធម៌

២- បដិបត្តិធម៌

៣- បដិវេធធម៌

• **<u>បរិយត្តិធម៌</u>** : បាលដល់ធម៌ដែលនៅក្នុងថ្នាក់ជារបៀននៅឡើយ គឺធម៌ដែលអ្នកសិក្សាកើតបានជាសេចក្ដីចេះចាំនៅក្នុងចិត្ត នឹកឃើញសូត្ររួច ។ល។ ឬបើនឹងនិយាយមួយបែបទៀតថា ធម៌ដែលនៅជាបទបញ្ញាឬធម្មបញ្ញា ដែលអ្នកសិក្សាទាំងឡាយចាំបានថា : ព្រះសម្មាសម្ពុទ្ធទ្រង់បង្គាប់ឲ្យធ្វើទាន យ៉ាងនេះ ធ្វើសីលយ៉ាងនេះ ធ្វើភាវនាយ៉ាងនេះ ។ល។

• **<u>បដិបត្តិធម៌</u>** : បានដល់ធម៌ដែលអ្នកប្រតិបត្តិ បានអនុវត្តនូវចំណាំចំណេះនិងសំណូធ្យរបស់ខ្លួនឲ្យមានជាការងារ ជាករណីយ៍ ជាសេចក្ដីប្រតិបត្តិ ។ល។ ឬបើនឹងនិយាយឲ្យបានខ្លីជាងនេះថា ធម៌ដែលអ្នកប្រតិបត្តិបានអនុវត្ត នូវសេចក្ដីចេះដឹង នូវបទបញ្ញាឲ្យទៅជាមុខការមុខងាររបស់ខ្លួន ។ល។ ដូច្នេះ ទៅវិញក៏បាន ។

• **<u>បដិវេធធម៌</u>** : បានដល់ធម៌ដែលជាផលរបស់ធម៌ចាំនិងធម៌អនុវត្តនុ៎ះឯង។ ដើម្បីឲ្យអ្នកអានទាំងឡាយមានពន្លឺក្នុងរឿងនេះ កាន់តែច្រើនឡើងទៀត ខ្ញុំសូមលើកយកមាតិកានៃធម៌ខ្លះដែលជាគោលក្នុងរឿងប្រតិបត្តិនេះ មក សរសេរមានដូចតទៅ ៖

## សប្បុរិសបញ្ញត្តិ

១- ទាន : ការបរិច្ចាគទ្រព្យសម្បត្តិរបស់ខ្លួននៃបុគ្គលម្នាក់ៗ ដល់បុគ្គលគួរដល់ការសង្គ្រោះ និងបុគ្គលគួរដល់ការបូជា។ បុគ្គលដែលគួរដល់ការសង្គ្រោះមានជាអាទិ៍ បុគ្គលក្រដាច់ដាប បុគ្គលអនាថា បុគ្គលដែលមានគ្រោះថ្នាក់ដោយធម្មជាតិ (ដីកម្រើក ស្រុត បាក់... ទឹកលិច ភ្លើងឆេះ ខ្យល់ព្យុះ) បុគ្គលដែលមានគ្រោះថ្នាក់ដោយចរាចរ ។ល។ បុគ្គលដែលគួរដល់ការបូជា មានជាអាទិ៍មាតាបិតា គ្រូអាចារ្យ សមណព្រាហ្មណ៍នេះជាបុគ្គលាធិដ្ឋាន។ល។

ប្រទេសជាតិ សាសនា អង្គការមនុស្សធម៌ នេះជាធម្មាធិដ្ឋាន ។ល។ មានទាំងឡាយនេះអ្នកមានបំណងនឹងឆ្លងចាកទុក្ខក្នុងសង្សារវដ្ដ គប្បីបំពេញឲ្យបាន *ព្រោះធម៌នេះមិនត្រឹមតែជាសប្បុរិសបញ្ញត្តិទេ គឺជាទានបារមីទៀតផង* ។

**២- បព្វជ្ជា** : ការកាន់យកផ្នួស ជាភិក្ខុ ភិក្ខុនី សាមណេរ សិក្ខមានា សាមណេរី តាបស ឥសី ដូនជី ។ល។ នេះជាផ្នួសជាន់ខ្ពស់-កណ្ដាល។ អ្នកកាន់សីលឧបោសថ (សីល ៨) នេះជាផ្នួសថ្នាក់ទាប។ ផ្នួសទាំងឡាយនេះ បុគ្គលអ្នកឃើញភ័យក្នុសង្សារវដ្ដ គប្បីឆ្លៀតរកពេលឱកាសណាមួយបំពេញផ្នួសនេះឲ្យបាន *ព្រោះធម៌នេះមិនត្រឹមតែជាសប្បុរិសបញ្ញត្តិទេ គឺជានេក្ខម្មបារមីទៀតផង* ។

**៣- មាតាបិតុបដ្ឋាន** : ការគោរពប្រតិបត្តិដោយកិច្ច មានបំរើនិងចិញ្ចឹមថែទាំជាដើម និងការលំអុតលំអោនចិត្តស្ដាប់ឱវាទមាតាបិតា ជាធម៌មួយមានគុណភាពយ៉ាងខ្ពស់ គឺបុគ្គលអ្នកឃើញភ័យក្នុងសង្សារវដ្ដគប្បីឆ្លៀតបំពេញឲ្យបាន *ព្រោះធម៌នេះមិត្រឹមតែជាសប្បុរិសបញ្ញត្តិ ជាភូមិនៃសប្បុរសប៉ុណ្ណោះទេ គឺជាមេត្តាបារមីផងទៀត* ។

## ព្រហ្មវិហារ ៤

អ្វីជាព្រហ្មវិហារធម៌ "ធម៌ជាជំរកដ៏ប្រសើររបស់ចិត្ត" ឬ "ធម៌ជាលំនៅដ៏ខ្ពង់ខ្ពស់របស់ចិត្ត" ឈ្មោះថា "**ព្រហ្មវិហារធម៌**" ដោយន័យថា : *ធម៌សំរាប់ធ្វើចិត្តរបស់មនុស្សឲ្យបានល្អ ឬធ្វើមនុស្សឲ្យមានចិត្តមនុស្សពេញលក្ខណៈ ឬធ្វើមនុស្សឲ្យមានចិត្តខ្ពស់ជាងសត្វតិរច្ឆាន ។ល។* ធម៌នេះពុទ្ធសាសនាចែកចេញជា ៤ យ៉ាងគឺ ៖

**១- មេត្តា** : រៀនធ្វើចិត្តឲ្យស្រឡាញ់រាប់អានមនុស្សនៅគំនិតបន់ស្រន់ថា សូមឲ្យមនុស្សទាំងឡាយឋិតនៅក្នុងសេចក្ដីសុខអស់កាលជានិរន្តរ៍។

**២- ករុណា** : រៀនធ្វើចិត្តឲ្យអាណិតអាសូរមនុស្សមានទុក្ខនៅក្នុងគំនិតអំពាវនាវថា : សូមឲ្យមនុស្សទាំងឡាយរួចចាកទុក្ខដែលកំពុងមាន។

**៣- មុទិតា** : រៀនធ្វើឲ្យសប្បាយរីករាយជាមួយនឹងមនុស្សទាំងឡាយ ដែលបានប្រកបដោយសេចក្តីសុខចំរើនច្រើនជាងខ្លួន។

**៤- ឧបេក្ខា** : រៀនធ្វើចិត្តឲ្យឃើញតាមចលនាប្រែប្រួលរបស់មនុស្សទាំងឡាយ ប្រែថារៀនរួមសុខរួមទុក្ខជាមួយនឹងមនុស្សគ្នាឯង ។

ដែលថា "**រៀនស្រឡាញ់រាប់អានគ្នា**" គឺរៀនគិតថា : មនុស្សដូចគ្នាត្រូវតែស្រឡាញ់រាប់អានគ្នា នៅក្នុងគំនិតបន់ស្រន់ថា *សូមមិត្តមនុស្សទាំងឡាយបានឋិតនៅក្នុងសេចក្តីសុខដែលកំពុងមាន កុំគប្បីមានទុក្ខអ្វីមកបៀតបៀនបានឡើយ* ។

ដែលថា "**រៀនអាណិតអាសូរគ្នា**" គឺរៀនគិតថា មនុស្សដូចគ្នាត្រូវចេះអាណិតអាសូរគ្នាក្នុងពេលមានទុក្ខ មានគ្រោះថ្នាក់ ប្រកបដោយគំនិតអំពាវនាវបន់ស្រន់ថា : *សូមមិត្តមនុស្សទាំងឡាយ រួចចាកទុក្ខគ្រោះថ្នាក់ដែលកំពុងត្រូវរង កុំគប្បីអាក់ខានឡើយ* ។

ដែលថា "**រៀនសប្បាយរីករាយជាមួយគ្នា**" គឺរៀនគិតថា មនុស្សដូចគ្នាត្រូវចេះសប្បាយរីករាយជាមួយគ្នា ក្នុងពេលដែលម្នាក់ៗត្រូវបានឡើងបុណ្យស័ក្តិ ឬត្រូវបានលាភទាំងឡាយមានទ្រព្យសម្បត្តិ និងកេរ្តិ៍ឈ្មោះល្អជាដើម នៅក្នុងគំនិតបន់ស្រន់ថា : *សូមមិត្តមនុស្សទាំងឡាយរស់នៅជោគវាសនាដ៏ខ្ពស់ខ្ពស់ថ្មីនេះអស់កាលយាវជីវី កុំគប្បីមានឧបសគ្គអ្វីមកធ្វើឲ្យធ្លាក់ចុះបានឡើយ* ។

ដែលថា "**រៀនធ្វើចិត្តឲ្យឃើញតាមចលនាប្រែប្រួលរបស់ជីវិត**" គឺរៀនឲ្យឃើញថា ជិវិតរបស់មនុស្សទាំងឡាយឋិតនៅក្នុងចលនាប្រែប្រួលរបស់ធម្មជាតិ គឺអនិច្ចំ ទុក្ខំ អនត្តា។ ដូច្នេះ *អាត្មាអញត្រូវតែខិតខំពង្រឹងចិត្តឲ្យងាករេទៅតាមចលនាទាំងឡាយនេះ គឺធ្វើយ៉ាងណាឲ្យជីវិតរបស់អញឋិតនៅជាមួយនឹងសេចក្តីទុក្ខព្រួយរបស់មនុស្សទាំងឡាយ នៅក្នុងឧត្តមគតិនៃគំនិតថា យើងជាមនុស្សផងគ្នា យើងត្រូវរស់នៅក្នុងសេចក្តីសុខទុក្ខផងគ្នា អស់កាលជានិរន្តរ៍*។

ខ្ញុំសូមបញ្ជាក់ថា : ព្រហ្មវិហារធម៌ទាំង ៤ នេះប្រសិនបើអ្នកចំរើនធ្វើឲ្យកើតក្នុងចិត្តបានមិនគ្រប់ទាំង៤ ឬដឹកនាំចិត្តនៃអាត្មាឲ្យចូលទៅជ្រកនៅក្នុងធម៌នេះមិនបានគ្រប់ទាំង៤ទេនោះ អ្នកចំរើនឈ្មោះថា ពុំទាន់មានព្រហ្មវិហារធម៌នៅឡើយទេ។ ដូចនេះព្រោះអ្វី? ព្រោះអ្នកមានព្រហ្មវិហារមិនទាន់បានធ្វើចិត្តរបស់ខ្លួនឲ្យជ្រកនៅគ្រប់ថ្នាក់នៃព្រហ្មវិហារ ជាពិសេសគឺពុំបានបានប្រានចិត្តឲ្យចូលទៅក្នុងព្រហ្មវិហារថ្នាក់ខ្ពស់បំផុត ដែលពុទ្ធសាសនាឲ្យឈ្មោះថា "**ឧបេក្ខាព្រហ្មវិហារ**" ។ ឧទាហរណ៍គេមានចិត្តមេត្តាមនុស្សចង់ឲ្យនៅក្នុងសេចក្ដីសុខហើយ តែគេពុំទាន់មានចិត្តអាណិតមនុស្សដែលធ្លាក់ខ្លួនចូលទៅក្នុងសេចក្ដីទុក្ខ ឬកំពុងរងគ្រោះថ្នាក់គេមានចិត្តអាណិតមនុស្សកំពុងមានទុក្ខហើយ តែគេពុំទាន់មានចិត្តជួយសប្បាយមនុស្សដែលបានទទួលសេចក្ដិសុខចំរើនជាងខ្លួនរបស់គេ ឬមានជោគជ័យលើខ្លួនរបស់គេ ដោយសម្បត្តិទាំងឡាយមានយសស័ក្តិជាដើម គេមានធម៌មេត្តា ករុណា មុទិតាទាំង ៣ នេះគ្រប់គ្រាន់ហើយ តែគេពុំទាន់មានឧបេក្ខាចិត្ត គឺចិត្តដែលតាមគយគន់មើលនូវស្ថានភាពនៃជីវិតទាំងឡាយ ដែលចេះតែមានការផ្លាស់ប្តូរម្តងសុខម្តងទុក្ខជានិច្ច ។ល។ ខ្វះការផ្លាស់ចិត្តរបស់ខ្លួនឲ្យវិលទៅតាមស្ថានភាពនៃជីវិតទាំងឡាយ គឺដំបូងរៀនធ្វើចិត្តឲ្យមាមេត្តាដល់មនុស្សទាំងឡាយ លុះមនុស្សទាំងឡាយដែលខ្លួនមេត្តានោះមានទុក្ខ រៀនធ្វើចិត្តឲ្យមានករុណាដល់មនុស្សទាំងឡាយនោះដោយអំពាវនាបន់ស្រន់ក្នុងចិត្ត *សូមឲ្យគេទាំងឡាយរួចផុតចាកទុក្ខ លុះមនុស្សមានទុក្ខទាំងឡាយ បានរួចចាកទុក្ខ បានទទួលនូវសេចក្ដីសុខចំរើនជាងខ្លួន រៀនធ្វើចិត្តឲ្យមានមុទិតាដល់មនុស្សទាំងឡាយដដែលនោះជាថ្មីទៀត ដោយជួយអរជួយសប្បាយចំពោះជោគវាសនាគេទាំងឡាយ លុះមនុស្សទាំងឡាយដែលខ្លួនមានចិត្ត មេត្តា ករុណា មុទិតានោះ មានខ្លួនធ្លាក់ចុះក្នុងសេចក្ដីទុក្ខរហូតកែពុំបាន រៀនធ្វើចិត្តឲ្យមានឧបេក្ខាទៅលើមនុស្សទាំងឡាយ នោះក្នុងទីបំផុតដោយជួយកាន់ទុក្ខកាន់ ព្រួយជាមួយនឹងគេទាំងឡាយរហូតទៅ។ ដោយន័យថាមិនធ្វើចិត្តរបស់ខ្លួនឲ្យសប្បាយរីករាយ នៅលើសេចក្ដីទុក្ខព្រួយរបស់អ្នកដទៃ* ។ នេះជាសេចក្ដីបកស្រាយរបស់ព្រហ្មវិហារធម៌តាមធម្មតា។

ប្រសិនបើបកស្រាយឲ្យខ្ពស់ជាងនេះ ឧបេក្ខាបានដល់ចិត្តដែលមើលឃើញមនុស្សសត្វនិងពិភពលោក តាមសេចក្តីពិតរបស់ធម្មជាតិ ដែលមានចែងក្នុងបរមត្ថធម៌ដោយពុទ្ធសាសនា គឺក្នុងខ្លួននៃមនុស្សម្នាក់ៗមានត្រឹមតែខន្ធ អាយតនៈ ធាតុ ឥន្ទ្រីយ៍ សច្ចៈ បដិច្ចសមុប្បាទប៉ុណ្ណោះ មិនមានអ្វីក្រៅអំពីរបស់ទាំងឡាយនេះទេ ។ ពាក្យថា មនុស្ស សត្វ ទេព ព្រហ្ម យក្ស មារ អសុរ គន្ធព្វ ប្រេត នរក អសុរកាយ។ល។ នោះគ្រាន់តែជាភាសាដែលសន្មតឡើងដើម្បីនិយាយគ្នាឲ្យកើតជាសេចក្តីស្តាប់បាន ដែលលោកឲ្យឈ្មោះភាសាបែបនេះថាជាភាសាបញ្ញត្តិ ពុំមែនជាភាសាសបរមត្ថឡើង។ កាលណាបើចិត្តនៃមនុស្សទាំងឡាយមានឧបេក្ខាព្រហ្មវិហារ ដែលខ្ញុំបកស្រាយថា មើលឃើញមនុស្សតាមសភាវពិតនៃធម្មជាតិ ដែលពុទ្ធសាសនាឲ្យឈ្មោះថា "**សភាវសច្ចៈ**" នោះហើយ សភាវសច្ចៈនេះក៏ជាបច្ច័យឲ្យកើតបានជាស្ពាននៃគំនិតមួយទៀត ដែលលោកឲ្យឈ្មោះថា "**បរមត្ថសច្ចៈ**" បរមត្ថសច្ចៈនឹងបានជាស្ពាននៃគំនិតមួយទៀត ដែលលោកឲ្យឈ្មោះថា "អរិយសច្ចៈ" អរិយសច្ចៈធម្មធាតុនេះនឹងបានជាស្ពាននៃសច្ចៈជាទីបំផុតដែលមានឈ្មោះថា "និព្វានសច្ចៈ" នុ៎ះឯង។

**ឧបេក្ខាព្រហ្មវិហារ** ជាធម៌ធ្វើឲ្យបុគ្គលមើលឃើញមនុស្សលោកនៅក្នុងលក្ខណៈដូចគ្នា ដូចបាននិយាយមកហើយនេះ ប្រសិនណាបើបុគ្គលណាចំរើនបានហើយ បុគ្គលនោះនឹងអស់មានប្រកាន់ជាតិសាសន៍ អម្បូរ ពូជ ត្រកូល គោត្ត វណ្ណៈ ពណ៌សម្បុរ ខ្លួនប្រាណ ទ្រព្យសម្បត្តិ យសស័ក្តិ ។ល។ ទៀតហើយ។ ការមិនប្រកាន់របស់មនុស្សទាំងឡាយនេះ នឹងបានជាបច្ច័យមួយយ៉ាងសំខាន់សម្រាប់ធ្វើឲ្យមនុស្សទាំងឡាយក្នុងទីបលោកចេះស្រឡាញ់ គ្នា ចេះអាណិគ្នា ចេះជួយសប្បាយគ្នា ចេះជួយកាន់ទុក្ខគ្នាអស់កាលជានិច្ច។

ព្រះសម្មាសម្ពុទ្ធព្រមទាំងព្រះសាវកទាំងឡាយ លោកមានព្រះហឫទ័យប្រកបដោយព្រហ្មវិហារគ្រប់ទាំង ៤ នេះ ទើបលោកមិនមានការប្រកាន់ជាតិ

សាសន៍។ល។ អ្នកព្រហ្មវិហារទាំងឡាយ មិនត្រឹមតែមានចិត្តមិនប្រកាន់ប៉ុណ្ណោះទេ គឺមានចិត្តជាអ្នកបំរើ ជាអ្នកទំនុកបំរុងអ្នកដទៃទៀតផង។ ដូច្នេះ ទើបព្រះសម្មាសម្ពុទ្ធទ្រង់ឲ្យឈ្មោះធម៌នេះថា "ព្រហ្មវិហារ" ប្រែថា "ធម៌ជាជម្រកដ៏ប្រសើររបស់ចិត្ត" ឬ "*ធម៌ជាលំនៅចិត្តរបស់បុគ្គលអ្នកស្វែងរកសន្តិភាព*" ។

□ □

□

## អធិដ្ឋានធម៌ ៤

ធម៌ដែលគួរបង្កើតនិងគួរតម្កល់ទុកក្នុងចិត្ត ៤ យ៉ាងគឺ ៖

១- បញ្ញា : សេចក្តីចេះដឹងខាងផ្លូវលោកផ្លូវធម៌ ដែលលោកទុកដាក់ថាជាពន្លឺរបស់ជីវិត សម្រាប់ឆ្លុះមើលបញ្ហាលោកនឹងបញ្ហាធម៌ ដើម្បីដឹងនាំជីវិតឲ្យរស់នៅក្នុងផ្លូវត្រូវក្នុងលោកនេះ និងលោកខាងមុខ ជាពិសេសគឺធ្វើជីវិតប្រព្រឹត្តទៅដល់ទីបំផុតនៃទុក្ខ ដោយប្រតិបត្តិតាមមគ្គមានអង្គ៨ ប្រការមានសម្មាទិដ្ឋិជាដើម។

**២- សច្ចៈ** : សេចក្តីពិត បានដល់ភាពពិតដែលមានលក្ខណៈផ្ទុយអំពីភាពមិនពិត។ សច្ចៈនេះលោកចែកចេញជា ៦ យ៉ាងគឺ : **វចីសច្ចៈ** ភាពពិតនៃពាក្យសំដី **សម្មតិសច្ចៈ** ភាពពិតនៃបរមត្ថធម៌ **អរិយសច្ចៈ** ភាពពិតនៃសច្ចៈធម៌ ៤ **និព្វានសច្ចៈ** ភាពពិតនៃនិព្វាន។ សច្ចធម៌នេះជាធម៌ គឺបុគ្គលគប្បីកំណត់ទុកក្នុងចិត្ត ហើយប្រព្រឹត្តនូវវចីសុចរិតគ្រប់ពេលវេលា ដើម្បីចម្លងនូវជីវិតរបស់ខ្លួនទៅដល់ទីបំផុតនៃទុក្ខ។

**៣- ចាគៈ** : ការលះបង់ បានដល់ការចំណាយទ្រព្យរបស់ខ្លួនធ្វើអំណោយដល់អ្នកដទៃ ដោយសង្គ្រោះឬដោយបូជា ដោយសង្គ្រោះដូចជាដាក់ទានដល់មនុស្សក្រខ្សត់ មនុស្សអនាថា មនុស្សមានគ្រោះថ្នាក់... ដោយបូជាដូចជាចិញ្ចឹមមាតាបិតាគ្រូអាចារ្យ សាងវត្ត សាងថ្នល់ សាងស្ពាន សាងសាលា... ដើម្បីសម្រាលទុក្ខដល់មនុស្សទាំងឡាយ ដែលមានកំណើតរួមប្រទេស រួមលោកជាមួយនឹងខ្លួន ក្នុងបំណងធ្វើឲ្យជីវិតអស់ទុក្ខក្នុងទីបំផុត។

**៤- ឧបសមៈ** : សេចក្តីស្ងប់ បានដល់ការធ្វើចិត្តឲ្យស្ងប់ស្ងៀម ឲ្យអស់ភ័យ ឲ្យអស់កង្វល់ក្នុងអារម្មណ៍ទាំងឡាយ ដែលជាធាតុធ្វើចិត្តឲ្យអណ្តែតអណ្តូង ឲ្យត្រាច់ទៅដោយមិនមានទីដៅ គឺមិនបណ្តោយឲ្យកិលេសគ្រឿងសៅហ្មងគ្របសង្កត់ជិះជាន់។ កាលណាចិត្តមិនមានកិលេសជិះជាន់ ចិត្តក៏បានតាំងនៅក្នុងភាពស្ងប់បញ្ញាជាន់ខ្ពស់ គឺបញ្ញាសម្រាប់ឃើញនូវអរិយសច្ចៈ ក៏កើតមាននៅក្នុងពេល នុ៎ះឯងដែរ។

# បទទី ៩

# លោកិយធម៌

លោកិយធម៌ បានដល់ធម៌សម្រាប់មនុស្សក្នុងសកលលោក ឬធម៌ទាំងឡាយដែលមនុស្សលោកប្រតិបត្តិ ដើម្បីជាប្រយោជន៍របស់ខ្លួននៅក្នុងត្រៃលោក។ ពុទ្ធសាសនាបានចែកធម៌នេះទៅជា ៣យ៉ាង ដោយកំណត់យកតាមការត្រាច់ទៅនៃចិត្តដែលមានឈ្មោះថា **កាមាវចរៈ រូបាវចរៈ អរូបាវចរៈ** ។ *ធម្មធាតុទាំង៣យ៉ាងនេះចំពោះកាមាវចរៈ ជាធាតុដែលលោកបញ្ជាក់ថាប្រព្រឹត្តទៅបានទាំងកុសលទាំងអកុសល*។ ចំណែករូបាវចរៈ និងអរូបាវចរៈលោកសង្គ្រោះចូលក្នុងពួកធម៌ជាកុសលតែម្យ៉ាង ។ ចិត្តជាកាមាវចរៈមាន ៥៤ គឺ ៖

១- អកុសលចិត្ត ១២

២- អហេតុកចិត្ត ១៨

៣- សោភណចិត្ត ២៤។

**អកុសលចិត្ត ១២** លោកចែកជាលោភមូល ៨ ទោសមូល ២ មោហមូល ២។ **លោភមូល ៨** លោករាប់ដូចនេះ :

ក- សោមនស្ស សហគត ទិដ្ឋិគត សម្បយុត្ត អសង្ខារិកៈ

ខ- សោមនស្ស សហគត ទិដ្ឋិគត សម្បយុត្ត សសង្ខារិកៈ

ឃ- សោមនស្ស សហគត ទិដ្ឋិគត វិប្បយុត្ត អសង្ខារិកៈ

គ- សោមនស្ស សហគត ទិដ្ឋិគត វិប្បយុត្ត សសង្ខារិកៈ

ង- ឧបេក្ខា សហគត ទិដ្ឋិគត សម្បយុត្ត អសង្ខារិកៈ

ច- ឧបេក្ខា សហគត ទិដ្ឋិគត សម្បយុត្ត សសង្ខារិកៈ

ឆ- ឧបេក្ខា សហគត ទិដ្ឋិគត វិប្បយុត្ត អសង្ខារិកៈ

ជ- ឧបេក្ខា សហគត ទិដ្ឋិគត វិប្បយុត្ត សសង្ខារិកៈ។

**ទោសមូល ២** លោករាប់ដូចជា :

ក- ទោមនស្ស សហគត បដិឃសម្បយុត្ត អសង្ខារិកៈ

ខ- ទោមនស្ស សហគត បដិឃសម្បយុត្ត សសង្ខារិកៈ

**មោហមូល ២** លោករាប់ដូចនេះ :

ក- ឧបេក្ខា សហគត ឧទ្ធច្ចសម្បយុត្តៈ

ខ- ឧបេក្ខា សហគត វិចិកិច្ឆាសម្បយុត្តៈ។

**អហេតុកចិត្ត ១៨** លោកចែកជាអកុសលវិបាក ៧ កុសលវិបាក ៨ អហេតុកកិរិយា ៣ ។ **អកុសលវិបាក ៧** លោករាប់ដូចនេះ :

ក- ឧបេក្ខា សហគត ចក្ខុវិញ្ញាណៈ

ខ- ឧបេក្ខា សហគត សោតវិញ្ញាណៈ

គ- ឧបេក្ខា សហគត ឃានវិញ្ញាណៈ

ឃ- ឧបេក្ខា សហគត ជិវ្ហាវិញ្ញាណៈ

ង- ទុក្ខ សហគត កាយវិញ្ញាណៈ

ច- ឧបេក្ខា សហគត សម្បដិច្ឆន្នៈ

ឆ- ឧបេក្ខា សហគត សន្តីរណៈ

**កុសលវិបាក ៨** លោករាប់ដូចនេះ :

ក- ឧបេក្ខា សហគត ចក្ខុវិញ្ញាណៈ

ខ- ឧបេក្ខា សហគត សោតវិញ្ញាណៈ

គ- ឧបេក្ខា សហគត ឃានវិញ្ញាណៈ

ឃ- ឧបេក្ខា សហគត ជិវ្ហាវិញ្ញាណៈ

ង- សុខ សហគត កាយវិញ្ញាណៈ

ច- ឧបេក្ខា សហគត សម្បដិច្ឆន្នៈ

ឆ- សោមនស្ស សហគត សន្តីរណៈ

ជ- ឧបេក្ខា សហគត សន្តីរណៈ។

**អហេតុកកិរិយា ៣** លោករាប់ដូចនេះ :

ក- ឧបេក្ខា សហគត បញ្ចទ្វារាវជ្ជនៈ

ខ- ឧបេក្ខា សហគត មនោទ្វារាវជ្ជនៈ

គ- សោមនស្ស សហគត ហសិតុប្បាទ។

**សោភណចិត្ត ២៤** លោកចែកជា មហាកុសលចិត្ត ៨ មហាវិបាកចិត្ត៨ មហាកិរិយាចិត្ត ៨ ។ មហាកុសលចិត្ត ៨ លោករាប់ដូចនេះ :

ក- សោមនស្ស សហគត ញាណសម្បយុត្ត អសង្ខារិកៈ

ខ- សោមនស្ស សហគត ញាណសម្បយុត្ត សសង្ខារិកៈ

គ- សោមនស្ស សហគត ញាណវិប្បយុត្ត អសង្ខារិកៈ

ឃ- សោមនស្ស សហគត ញាណវិប្បយុត្ត សសង្ខារិកៈ

ង- ឧបេក្ខា សហគត ញាណសម្បយុត្ត អសង្ខារិកៈ

ច- ឧបេក្ខា សហគត ញាណសម្បយុត្ត សសង្ខារិកៈ

ឆ- ឧបេក្ខា សហគត ញាណវិប្បយុត្ត អសង្ខារិកៈ

ជ- ឧបេក្ខា សហគត ញាណវិប្បយុត្ត សសង្ខារិកៈ។

**មហាវិបាកចិត្ត ៨** លោករាប់ដូចនេះ :

ក- សោមនស្ស សហគត ញាណសម្បយុត្ត អសង្ខារិកៈ

ខ- សោមនស្ស សហគត ញាណសម្បយុត្ត សសង្ខារិកៈ

គ- សោមនស្ស សហគត ញាណវិប្បយុត្ត អសង្ខារិកៈ

ឃ- សោមនស្ស សហគត ញាណវិប្បយុត្ត សសង្ខារិកៈ

ង-ឧបេក្ខា សហគត ញានសម្បយុត្ត អសង្ខារិកៈ

ច-ឧបេក្ខា សហគត ញានសម្បយុត្ត សសង្ខារិកៈ

ឆ-ឧបេក្ខា សហគត ញានវិប្បយុត្ត អសង្ខារិកៈ

ជ-ឧបេក្ខា សហគត ញានវិប្បយុត្ត សសង្ខារិកៈ។

**មហាកិរិយាចិត្ត ៨** លោករាប់ដូចនេះ :

ក- សោមនស្ស សហគត ញាណសម្បយុត្ត អសង្ខារិកៈ

ខ- សោមនស្ស សហគត ញាណសម្បយុត្ត សសង្ខារិកៈ

គ- សោមនស្ស សហគត ញាណវិប្បយុត្ត អសង្ខារិកៈ

ឃ- សោមនស្ស សហគត ញាណវិប្បយុត្ត សសង្ខារិកៈ

ង- ឧបេក្ខា សហគត ញាណសម្បយុត្ត អសង្ខារិកៈ

ច- ឧបេក្ខា សហគត ញាណសម្បយុត្ត សសង្ខារិកៈ

ឆ- ឧបេក្ខា សហគត ញាណវិប្បយុត្ត អសង្ខារិកៈ

ជ- ឧបេក្ខា សហគត ញាណវិប្បយុត្ត សសង្ខារិកៈ។

**រូបាវចរចិត្ត ១៥** លោកចែកជា រូបាវចរកុសលចិត្ត ៥ រូបាវចរវិបាកចិត្ត ៥ រូបាវចរកិរិយា ៥។ **រូបាវចរកុសលចិត្ត ៥** លោករាប់ដូចនេះ :

ក- វិតក្កវិចារបិតីសុខេកគ្គតា សហិតំ បឋមជ្ឈានរូបាវចរកុសលចិត្តំ

ខ- វិចារបីតិសុខេកគ្គតា សហិតំ ទុតិយជ្ឈានរូបាវចរកុសលចិត្តំ

គ- បីតិសុខេកគ្គតា សហិតំ តតិយជ្ឈានរូបាវចរកុសលចិត្តំ

ឃ- សុខេកគ្គតា សហិតំ ចតុត្ថជ្ឈានរូបាវចរកុសលចិត្តំ

ង- ឧបេក្ខេកគ្គតា សហិតំ បញ្ចមជ្ឈានរូបាវចរកុសលចិត្តំ។

**រូបាវចរវិបាកចិត្ត ៥** លោករាប់ដូចដូចនេះ :

ក- វិត្តកវិចារបីតិសុខេកគ្គតា សហិតំ បឋមជ្ឈានរូបាវចរវិបាកចិត្តំ

ខ- វិចារបីតិសុខេកគ្គតា សហិតំ ទុតិយជ្ឈានរូបាវចរកិរិយាចិត្តំ

គ- បីតិសុខេកគ្គតា សហិតំ គតិយជ្ឈានរូបាវចរកិរិយាចិត្តំ

ឃ- សុខេកគ្គតា សហិតំ ចតុត្ថជ្ឈានរូបាវចរកិរិយាចិត្តំ

ង- ឧបេក្ខាកគ្គតា សហិតំ បញ្ចមជ្ឈានរូបាវចរកិរិយាចិត្តំ។

**អរូបាវចរចិត្ត ១២** លោកចែកជា អរូបាវចរកុសលចិត្ត ៤ អរូបាវចរវិបាកចិត្ត ៤ អរូបាវចរកិរិយាចិត្ត ៤។ **អរូបាវចរកុសលចិត្ត ៤** លោករាប់ដូចនេះ :

ក- អាកាសានញ្ចាយតនៈ

ខ- វិញ្ញានញ្ចាយតនៈ

គ- អាកិញ្ចញ្ញាយតនៈ

ឃ- នេវសញ្ញានាសញ្ញាយតនៈ។

**អរូបាវចរវិបាកចិត្ត ៤** លោករាប់ដូចនេះ :

ក- អាកាសានញ្ចាយតនៈ

ខ- វិញ្ញាណញ្ចាយតនៈ

គ- អាកិញ្ចញ្ញាយតនៈ

ឃ- នេវសញ្ញានាសញ្ញាយតនៈ។

**អរូបាវចរកិរិយាចិត្ត ៤** លោករាប់ដូចនេះ :

ក- អាពាសានញ្ចាយតនៈ

ខ- វិញ្ញាណញ្ចាយតនៈ

គ- អាកិញ្ចញ្ញាយតនៈ

ឃ- នេវសញ្ញានាសញ្ញាយតនៈ។

**មហាកុសលឲ្យសម្រេចកិច្ច ៤ យ៉ាងគឺ : បដិសន្ធិ ភវង្គ ចុតិ តទាលម្ពណៈ ២** មហាកុសលនេះជាធម្មធាតុតាក់តែងជាតិ ភព សម្បត្តិ ជាធាតុឲ្យនូវកំណើត មហាវិបាកជាតួបដិសន្ធិ ជាធម្មធាតុសោយនូវសម្បត្តិ ។ មហាកិរិយាលោកទុកដូចស្នាមត្រា ជាពិសេសមហាកិរិយានេះមាននៅតែក្នុងសន្តានព្រះអរហន្តទាំងឡាយ។ ចំណែកបុគ្គលក្រៅអំពីនេះ ពុំមានមហាកិរិយានេះទេ។ រូបាវចរកុសលវិបាកជាតួបដិសន្ធិ ជាធម្មធាតុសោយនូវសម្បត្តិ ។ រូបាវចរកុសលនិងរូបាវចរកិរិយាដូចគ្នា ផ្សេងគ្នាតែទីកើតគឺ *រូបាវចរកុសលកើតក្នុងសន្តានបុថុជ្ជននិងសេក្ខបុគ្គល* ចំណែក *រូបាវចរកិរិយា កើតក្នុងសន្តានព្រះខីណាស្រពតែមួយពួកប៉ុណ្ណោះ។* អរូបាវចរកុសល ជាធម្មធាតុតាក់តែងជាតិ ភព សម្បត្តិ ជាធម្មធាតុដឹកនាំឲ្យមានបដិសន្ធិ អរូបាវចរវិបាកជាតួបដិសន្ធិ ជាធម្មធាតុសោយនូវសម្បត្តិ។ ចំណែក *អរូបាវចរកិរិយា និងអរូបាវចរកុសលលោកថាដូចគ្នាមិនមានប្លែកគ្នាទេ* សេចក្តីឧបមានៃរបស់ទាំងពីរនេះ លោកថាដូចតួត្រានិងស្នាមរបស់ត្រា ឬដូចស្រមោលដែលមាននៅក្នុងរឿងមហាកុសល

និងមហាកិរិយានោះដែរ ខុសគ្នាតែទីកើត គឺ *អរូបាវចរកុសលកើតក្នុងសន្តាន បុថុជ្ជននិងសេក្ខបុគ្គល ចំណែកអរូបាវចរកិរិយាកើតក្នុងសន្តាននៃព្រះខីណាស្រពតែមួយពួកប៉ុណ្ណោះ។*

កុសលធម៌ទាំងឡាយនេះ ជាធម្មធាតុដឹកនាំសត្វទាំងឡាយឲ្យកើតក្នុងលោកទាំង ៣ ទើបត្រូវបានឲ្យឈ្មោះថា "**លោកិយធម**" ។ ម្យ៉ាងវិញទៀត សម្បទាបច្ចុប្បន្ន ៤ យ៉ាង និងសម្បទាបរលោក ៤ យ៉ាង ដែលខ្ញុំនឹងសរសេរនៅក្នុងបទខាងមុខ ក៏ត្រូវបានឲ្យឈ្មោះថា "**លោកិយធម៌**" ដែរ ។

□ □
□

# បទទី ១០

# លោកុត្តរធម៌

*ធម៌សម្រាប់ចម្លងសត្វទាំងឡាយចេញចាក* លោកហៅថា "**លោកុត្តរធម៌**" ធម៌នេះបើនិយាយដោយឈ្មោះនៃលោកុត្តរកុសលចិត្តមាន ៨ ឬ ៤០។ លោកុត្តរកុសលចិត្ត ដែលលោកចែកចា ៨ គឺ មគ្គ ៤ ផល ៤ ។

**មគ្គ ៤** លោករាប់ដូចនេះ :

ក- សោតាបត្តិមគ្គចិត្ត

ខ- សកិទាគាមិមគ្គចិត្ត

គ- អនាគាមិមគ្គចិត្ត

ឃ- អរហត្តមគ្គចិត្ត

**ផល ៤** លោករាប់ដូចនេះ :

ក- សោតាបត្តិផលចិត្ត

ខ- សកិទាគាមិផលចិត្ត

គ- អនាគាមិផលចិត្ត

ឃ- អរហត្តផលចិត្ត។

*លោកុត្តរចិត្តដែលលោកចែកជាមគ្គ ២០ ផល ២០ ។*

**មគ្គ ២០** លោក រាប់ដូចនេះ :

ក- វិតក្កវិចារបីតិសុខេកគ្គតា សហិតំ បឋមជ្ឈានសោតាបត្តិមគ្គចិត្តំ

ខ- វិចារបីតិសុខេកគ្គតា សហិតំ ទុតិយជ្ឈានសោតាបត្តិមគ្គចិត្តំ

គ- បីតិសុខេកគ្គតា សហិតំ តតិយជ្ឈានសោតាបត្តិមគ្គចិត្តំ

ឃ- សុខេកគ្គតា សហិតំ ចតុត្ថជ្ឈាន សោតាបត្តិមគ្គចិត្តំ

ង- ឧបេក្ខេកគ្គតា សហិតំ បញ្ចមជ្ឈាន សោតាបត្តិមគ្គចិត្តំ

ច- វិតក្កវិចារបីតិសុខេកគ្គតា សហិតំ បឋមជ្ឈាន សកិទាគាមិមគ្គចិត្តំ

ឆ- វិចារបីតិសុខេកគ្គតា សហិតំ ទុតិយជ្ឈាន សកិទាគាមិមគ្គចិត្តំ

ជ- បីតិសុខេកគ្គតា សហិតំ តតិយជ្ឈាន សកិទាគាមិមគ្គចិត្តំ

ឈ- សុខេកគ្គតា សហិតំ ចតុត្ថជ្ឈាន សកិទាគាមិមគ្គចិត្តំ

ញ- ឧបេក្ខាកគ្គតា សហិតំ បញ្ចមជ្ឈាន សកិទាគាមិនមគ្គចិត្តំ

ដ- វិតក្កវិចារបីតិសុខេកគ្គតា សហិតំ បឋមជ្ឈាន អនាគាមិមគ្គចិត្តំ

ឋ- វិចារបីតិសុខេកគ្គតា សហិតំ ទុតិយជ្ឈាន អនាគាមិមគ្គចិត្តំ

ឌ- បីតិសុខេកគ្គតា សហិតំ តតិយជ្ឈាន អានាគាមិមគ្គចិត្តំ

ឍ- សុខេកគ្គតា សហិតំ ចតុត្ថជ្ឈាន អានាគាមិមគ្គចិត្តំ

ណ- ឧបេក្ខាកគ្គតា សហិតំ បញ្ចមជ្ឈាន អានាគាមិមគ្គចិត្តំ

ត- វិតក្កវិចារបីតិសុខេកគ្គតា សហិតំ បឋមជ្ឈាន អរហន្តមគ្គចិត្តំ

ថ- វិចារបីតិសុខេកគ្គតា សហិតំ ទុតិយជ្ឈាន អរហន្តមគ្គចិត្តំ

ទ- បីតិសុខេកគ្គតា សហិតំ តតិយជ្ឈាន អរហត្តមគ្គចិត្តំ

ធ- សុខេកគ្គតា សហិតំ ចតុត្ថមជ្ឈាន អរហត្តមគ្គចិត្តំ

ន- ឧបេក្ខេកគ្គតា សហិតំ បញ្ចមជ្ឈាន អរហត្តមគ្គចិត្តំ។

**ផល ២០** លោករាប់ដូចនេះ :

ក- វិតក្កវិចារបីតិសុខេកគ្គតា សហិតំ បឋមជ្ឈាន សោតាបត្តិផលចិត្តំ

ខ- វិចារបីតិសុខេកគ្គតា សហិតំ ទុតិយជ្ឈាន សោតាបត្តិផលចិត្តំ

គ- បីតិសុខេកគ្គតា សហិតំ តតិយជ្ឈាន សោតាបត្តិផលចិត្តំ

ឃ- សុខេកគ្គតា សហិតំ ចតុត្ថជ្ឈាន សោតាបត្តិផលចិត្តំ

ង- ឧបេក្ខេកគ្គតា សហិតំ បញ្ចមជ្ឈាន សោតាបត្តិផលចិត្តំ

ច- វិតក្កវិចារបីតិសុខេកគ្គតា សហិតំ បឋមជ្ឈាន សកិទាគាមិផលចិត្តំ

ឆ- វិចារបីតិសុខេកគ្គតា សហិតំ តតិយជ្ឈាន សកិទាគាមិផលចិត្តំ

ឈ- សុខេកគ្គតា សហិតំ ចតុត្ថជ្ឈាន សកិទាគាមិផលចិត្តំ

ញ- ឧបេក្ខេកគ្គតា សហិតំ បញ្ចមជ្ឈាន សកិតាគាមិផលចិត្តំ

ដ- វិតក្កវិចារបីតិសុខេកគ្គតា សហិតំ បឋមជ្ឈាន អនាគាមិផលចិត្តំ

ឋ- វិចារបីតិសុខេកគ្គតា សហិតំ ទុតិយជ្ឈាន អនាគាមិផលចិត្តំ

ឌ- បីតិសុខេកគ្គតា សហិតំ គតិយជ្ឈាន អនាគាមិផលចិត្តំ

ឍ- សុខេកគ្គតា សហិតំ ចតុត្ថជ្ឈាន អនាគាមិផលចិត្តំ

ណ- ឧបេក្ខេកគ្គតា សហិតំ បញ្ចមជ្ឈាន អនាគាមិនផលចិត្តំ

ត- វិតក្កវិចារបីតិសុខេកគ្គតា សហិតំ បឋមជ្ឈាន អរហត្តផលចិត្តំ

ថ- វិចារបីតិសុខេកគ្គតា សហិតំ ទុតិយជ្ឈាន អរហត្តផលចិត្តំ

ទ- បីតិសុខេកគ្គតា សហិតំ តតិយជ្ឈាន អរហត្តផលចិត្តំ

ធ- សុខេកគ្គតា សហិតំ ចតុត្ថជ្ឈាន អរហត្តផលចិត្តំ

ន- ឧបេក្ខេកគ្គតា សហិតំ បញ្ចមជ្ឈាន អរហត្តផលចិត្តំ។

*កុសលចិត្តទាំងឡាយ ជាកាមាវចរត្តី រូបាវចរត្តី អរូបាវចរត្តី* ដែលខ្ញុំបានសរសេរហើយក្នុងបទទី ៩ មួយអន្លើដោយលោកុត្តរកុសលចិត្តទាំងឡាយដែលខ្ញុំសរសេរក្នុងបទទី ១០ នេះមិនមានពាក្យប្រែទេ ។ ដូចនេះ ព្រោះអ្វី? ព្រោះខ្ញុំយល់ឃើញថា ពាក្យបាលីទាំងឡាយនេះ អ្នកសិក្សាគង់ស្តាប់សេចក្តីបានមិនខានដោយពាក្យទាំងអស់នេះអ្នកសិក្សាក្នុងពុទ្ធសាសនា ធ្លាប់និយាយគ្នាជាបាលីមកហើយ។ ឆ្លៀតឱកាសនេះ ខ្ញុំសូមបញ្ជាក់ថា *លោកុត្តរចិត្តមិនមានលោកុត្តរកិរិយាទេ គឺមានតែលោកុត្តរកុសលចិត្ត និងលោកុត្តរវិបាកចិត្តតែពីរប៉ុណ្ណោះ*ឯង ។

មនុស្សកើតមកក្នុងលោកមានបញ្ញាផ្សេងគ្នា ស្រេចហើយនឹងបុណ្យកុសលដែលមនុស្សម្នាក់ៗសាងមកក្នុងអតីតជាតិ និងបច្ចុប្បន្នជាតិ ប្រែថាមានការរៀន ការស្តាប់ក្នុងជាតិមុន ឬ ក្នុងជាតិនេះតិចច្រើនជាងគ្នា។ បញ្ញារបស់មនុស្សបុថុជ្ជនដែលកើតដោយការស្តាប់ ការរៀនអំពីអ្នកដទៃ បានស្តាប់អរិយសច្ចធម៌ដោយសារអ្នកដទៃពន្យល់ ហើយប្រឹងគិតប្រឹងពិចារណាតាមពាក្យពន្យល់នោះ លុះត្រាបានយល់បានភ្លឺខ្លះ តែយោបល់របស់គេក្នុងរឿងនេះលោកឲ្យឈ្មោះ "**លោកិយធម៌**" ។ ចំណែកការឃើញដោយបញ្ញារបស់ខ្លួនដែលពុទ្ធសាសនាឲ្យឈ្មោះថា "**ត្រាស់ដឹង**" ឬ "**ចាក់ធ្លុះ**" នូវអរិយសច្ចធម៌នោះលោកឲ្យឈ្មោះថា "**លោកុត្តរធម៌**" បានដល់ មគ្គ ៤ ផល ៤ និងនិព្វាន១ ។ បុគ្គលដែលបានសម្រេចនូវមគ្គ ៤ ផល ៤ លោកហៅថា "**អរិយបុគ្គល**" ព្រះអរិយបុគ្គលទាំងឡាយ លោកលះបង់នូវធម៌ជាគ្រឿងចង់រឹតសត្វឲ្យជាប់នៅក្នុង

ជីវិតអន្ទោល ឬ ធម៌ជាគ្រឿងចងភ្ជាប់សត្វឲ្យនៅក្នុងភព ធម៌នេះពុទ្ធសាសនាឲ្យឈ្មោះថា "**<u>សំយោជនធម៌</u>**" *សំយោជនៈមាន ១០ ប្រការ លោកចែកជា២ពួក គឺសំយោជនៈយ៉ាងទាប ៥ ប្រការ យ៉ាងខ្ពស់ ៥ប្រការ។* **យ៉ាងទាប ៥ យ៉ាង** លោករាប់ដូចនេះ :

**១- សក្កាយទិដ្ឋិ** : ឃើញខ្លួនថាជារបស់ខ្លួន

**២- វិចិកិច្ឆា** : សេចក្តីសង្ស័យ

**៣- សីលព្វត្តបរាមាស** : មានជំនឿក្នុងវត្ថុស័ក្តិសិទ្ធិនិងអំពីកម្មនានា

**៤- កាមរាគៈ** : មានតម្រេកក្នុងកាម

**៥- បដិឃៈ** : មានសេចក្តីព្យាបាទ។

**យ៉ាងខ្ពស់ ៥** យ៉ាងលោករាប់ដូចនេះ :

**១- រូបរាគៈ** : ពេញចិត្តក្នុងរូប

**២- អរូបរាគៈ** : ពេញចិត្តក្នុងសុខវេទនាឬពេញចិត្តក្នុងអរូប

**៣- មានៈ** : មានកំណាន់ក្នុងរបស់ទាំងឡាយ

**៤- ឧទ្ធច្ចៈ** : មានគំនិតអណ្តែតអណ្តូង

**៥- អវិជ្ជា** : មានសេចក្តីមិនដឹងក្នុងអរិយសច្ចៈ ៤ ។

**អរិយបុគ្គលលោកចែកជា ៤ គូ រួមទាំងនិព្វាន ១ ផងជា ៥ គឺ ÷**

១- សោតាបត្តិមគ្គនិងសោតាបត្តិផល

២- សកិទាគាមិមគ្គ និង សកិទាគាមិផល

៣- អនាគាមិមគ្គ និង អនាគាមិផល

៤- អរហត្តមគ្គ និងអរហត្តផល

៥- និព្វាន។

**ក- សោតាបត្តិមគ្គ និងសោតាបត្តិផល** លះសំយោជនៈបាន ៣ គឺ ៖ សក្កាយទិដ្ឋិ វិចិកិច្ឆា សីលព្វត្តបរាមាស។ *ព្រះសោតាបុគ្គលលោកមិនធ្វើអភិដ្ឋាន ៦ គឺ : មិនធ្វើអនន្តរិយកម្ម៥ និងមិនមានជំនឿក្នុងសាសនាទាំងឡាយ*

*ដទៃ។ លោកមិនទៅកើតក្នុងអបាយទាំងឡាយ ៤ ។ មានកំណើតជាមនុស្ស យ៉ាងច្រើនបំផុតត្រឹម ៧ ដង ។*

**ខ- សកិទាគាមិមគ្គ និងសកិទាគាមិផល** លះសំយោជនៈ ៣ ដូចគ្នានឹងព្រះសោតា *តែលោកមានរាគៈ ទោសៈ មោហៈ ស្តើងជាងព្រះសោតា។ លោកត្រូវមានកំណើតជាមនុស្សទៀតត្រឹមតែម្តង ក្នុងទីបំផុតនៃជីវិតក្នុងលោកនៃមនុស្សនេះលោកត្រូវបានទៅកើតក្នុងឋានព្រហ្ម ឈ្មោះសុទ្ធាវាស ហើយបានសម្រេចព្រះនិព្វានក្នុងទីនោះស្រេចតែម្តង។*

**គ- អនាគាមិមគ្គ និងអនាគាមិផល** លះសំយោជនៈបាន ៥ គឺ ៖ សក្កាយទិដ្ឋិ វិចិកិច្ឆា សីលព្វតួបរាមាស កាមរាគៈ បដិឃៈ។ *ព្រះអានាគាមិបុគ្គលលោកត្រូវមានកំណើតជាមនុស្សទៀតត្រឹមតែម្តង លុះដល់ទីបំផុតនៃជីវិតក្នុងលោកនេះ លោកត្រូវបានទៅកើតក្នុងឋានព្រហ្មឈ្មោះសុទ្ធាវាស ហើយសម្រេចព្រះនិព្វានក្នុងទីនោះតែម្តង ។*

**ឃ- អរហត្តមគ្គ និងអរហត្តផល** លោកលះសំយោជនៈបានទាំងអស់ *លុះដល់ទីបំផុតនៃជីវិតក្នុងលោកនេះ លោកបានសម្រេចនិព្វានប្រែថា លោកមិនមានជីវិតអន្ទោលទៀតឡើយ។* ព្រះអរហន្តទាំងឡាយ លោកមិនមានសេចក្តីស្អប់ស្រឡាញ់ មិនមានមនោសញ្ចេតនាជាកាមតណ្ហា មិនមានគ្រឿងសៅហ្មងទាំងឡាយដែលមនុស្សលោកនៅមាន តែលោកក៏នៅមានមនោសញ្ចេតនាខាងឈឺចាប់ខ្លះដែរ លោកមានអាយុប្រហែលៗនឹងមនុស្សធម្មតា លោកមានអារម្មណ៍ជាឧបេក្ខាលោកមានវិញ្ញាណភ្លឺស្វាងរុងរឿង លោកមានព្រះទ័យស្អាតបរិសុទ្ធ មានជីវិតស្ងប់ មានអភិនិហារស្គាល់ចិត្តថ្លើមរបស់មនុស្សសត្វ មានញាណរលឹកជាតិទាំងឡាយក្នុងអតីតកាលបាន លោកមើលឃើញសេចក្តីស្លាប់កើតរបស់សត្វទាំងឡាយ លោកដឹងច្បាស់ថាកម្មនិងអាសវៈទាំងឡាយរបសខ្លួន បានត្រូវរលាយសសបសូន្យអស់ដោយមិនមានសេសសល់។

**ង- និព្វាន** និព្វានលោកចែកជា ២គឺ ៖ *១ និព្វានដែលសត្វបានសម្រេចក្នុងជីវិតបច្ចុប្បន្ន (សឧបាទិសេសនិព្វាន)* សំដៅសេចក្តីថា មគ្គចិត្តនិងផលចិត្ត

របស់ព្រះអរហន្ត ដែលសោយនូវវិមុត្តិសុខនុ៎ះឯង។ *២ និព្វាន ដែលព្រះអរហន្ត ត្រូវបានក្នុងពេលអស់ជីវិត (អនុបាទិសេសនិព្វាន)* ប្រែថា និព្វានដោយអស់ខន្ធ ៥ នៃប្រះអរហន្តទាំងឡាយ ។

និព្វានមានពាក្យជាវេវចនៈ ៧ ប្រការគឺ ៖

**១- បធនិមធនោ** បន្ទោរបង់នូវសេចក្តីស្រវឹង

**២- បិបាសវិនយោ** នាំចេញនូវសេចក្តីស្រេកឃ្លាន

**៣- អាលយសមុគ្ឃាតោ** ដកចេញនូវសេចក្តីអាល័យ

**៤- វដ្ដុបច្ឆេទោ** កាត់ផ្តាច់នូវជីវិតអន្ទោល

**៥- តណ្ហាក្ខយោ** សូន្យអស់តណ្ហា

**៦- វិរាគោ** សូន្យអស់នៃធាតុជាគ្រឿងតម្រេក

**៧- និរោធោ** រលត់ដោយមិនមានសេសសល់។

ក្រៅអំពីគុណធម៌ទាំង ៧ យ៉ាងនេះ ពាក្យថា "និព្វាន" លោកដៅដល់សេចក្តីរលត់នៃកងទុក្ខទាំងអស់ បានដល់សេចក្តីរលត់នៃជាតិ នៃជរា នៃព្យាធិ នៃមរណៈ នៃសេចក្តីសោកនៃសេចក្តីខ្សឹកខ្សួល នៃសេចក្តីត្អូញត្អែរ នៃសេចក្តីខំប្រឹង (ទុក្ខ) នៃសេចក្តីគួចចិត្ត នៃសេចក្តីតឹងទ្រូង ។ល។ នៅក្នុងសុត្តន្តបិដកមានពុទ្ធឧទានអំពីរឿងនិព្វានថា : "ម្នាលភិក្ខុទាំងឡាយ! អាយតនៈជាធម្មធាតុនៅមាន នាទីនោះមិនមានដី ទឹក ភ្លើង ខ្យល់ឡើយ នាទីនោះមិនមានអាកាស មិនមានវិញ្ញាណ មិនមានអ្វីៗទាំងអស់ លោកនេះក៏មិនមែន លោកទាំងឡាយដទៃណាៗក៏មិនមែន មិនមានទាំងព្រះអាទិត្យ មិនមានទាំងព្រះចន្ទ។ ភិក្ខុទាំងឡាយ! ក្នុងអាយតនៈនោះ មិនមានការមក មិនមានការទៅ មិនមានការតាំងនៅ មិនមានការសូន្យបាត់ មិនមានការកើតថ្មី អាយតនៈនោះជាធម្មធាតុប្រាសចាកលំនៅប្រាសចាកទីតាំង ប្រាសចាកទំរើទាំងឡាយ ប្រាសចាកកំណាន់ទាំងអស់ នេះឯងជាទីបំផុតនៃទុក្ខ" ។

នៅក្នុងសុត្តនបិដកដដែលនេះ ព្រះសម្មាសម្ពុទ្ធទ្រង់សំដែងអំពីរឿងនិព្វានមួយបែបទៀតមានដូចនេះ : "ម្នាលភិក្ខុទាំងឡាយ! សេចក្តីតក់ស្លុតញាប់

ញ៉័រ រមែងកើតមានដល់បុគ្គលណាដែលមានតំណាន់ សម្រាប់បុគ្គលណាដែល មិនមានតំណាន់រមែងមិនមានសេចក្ដីតក់ស្លុតញាប់ញ៉័រ ក្នុងទីនោះរមែងមាន សេចក្ដីស្ងប់ ក្នុងទីណាដែលមានសេចក្ដីស្ងប់ ក្នុងទីនោះរមែងមិនមានសេចក្ដី លំអៀង ក្នុងទីណាដែល មិនមានសេចក្ដីលំអៀង ក្នុងទីនោះរមែងមានការទៅ ការមក កាលណាមិនមានការទៅការមក ក៏រមែងមិនមានការសូន្យនិងការកើត ក្នុងទីណាមិនមានការសូន្យនិងការកើត ក្នុងទីនោះក៏រមែងមិនមានជាកន្លែង នោះ ឬមិនមាននូវអ្វីៗទាំងអស់ នៅក្នុងចន្លោះនៃការសូន្យនិងការកើតនោះ នេះឯងហៅថា "**សេចក្ដីរលត់ទុក្ខ**" ។

"**និព្វាន**" ដែលខ្ញុំសរសេរមកនេះ បើសរុបសេចក្ដីនៅ អ្នកអានទាំងឡាយ នឹងបានឃើញ : បំណងរបស់ព្រះពុទ្ធសាសនា គឺចង់ឲ្យមនុស្សទាំងឡាយរួច ផុតចាកទុក្ខទាំងអស់ ដោយព្យាយាមរំលត់ឲ្យអស់នូវហេតុនៃទុក្ខមិនឲ្យមាន សេសសល់ នេះឯងគឺជារង្វាន់មានគុណភាពខ្ពស់បំផុត ដែលព្រះសម្មាសម្ពុទ្ធ ទ្រង់ប្រទានដល់បុគ្គលអ្នកមានជំនឿក្នុងធម្មៈរបស់ព្រះអង្គ ។

អ្នកអានទាំងឡាយ ប្រសិនបើចង់បានសម្រេចនូវលោកុត្តរធម៌នេះ គប្បី តាំងសេចក្ដីព្យាយាមប្រតិបត្តិធម៌តាមអង្គមគ្គទាំង ៨ ឲ្យបានយ៉ាងទៀងទាត់ យ៉ាងតឹងរឹងៗ កាលណាយើងធ្វើបានតាមសេចក្ដីណែនាំនេះ បណ្ឌិតទាំង ឡាយក្នុងសាសនាលោកមានយោបល់ថានឹងបានដូចនេះ :

១- បុគ្គលបុថុជ្ជនទាំងឡាយ បើបានប្រតិបត្តិតាមមគ្គ ៨ អស់កាលជា និច្ចនោះ រយៈកាលនៃការប្រតិបត្តិត្រឹម ៧ឆ្នាំ ឬ ៦ឆ្នាំ ៥ឆ្នាំ ៤ឆ្នាំ ២ឆ្នាំ ១ឆ្នាំ ឬ ៧-៦-៥-៤-៣-២-១ខែ កន្លះខែ ឬត្រឹមតែ ៧ថ្ងៃប៉ុណ្ណោះក៏អាចធ្វើឲ្យគេ បាន សម្រេចផល ២ប្រការគឺ ៖

១- បាននិព្វានក្នុងជាតិនេះ ប្រសិនបើកិលេសនៅមានច្រើន មិនអាចនឹង បាននិព្វានក្នុងជាតិនេះ ក៏គង់មានកំណើតក្នុងជាតិនេះមិន ទាបជាងកំណើត

មនុស្ស ឬអាចនឹងបានសម្រេចនូវមគ្គណាមួយក្នុងបណ្ដាលមគ្គទាំងឡាយ ៤។

២- បើធ្វើមរណកាល ក្នុងពេលបានសម្រេចសោតាបន្នៈហើយ ក៏នឹងកើតជាមនុស្សទៀតត្រឹមតែ ៧ ដងប៉ុណ្ណោះ ។

៣- ធ្វើមរណកាល ក្នុងពេលសម្រេចសកិទាគាមីហើយ នឹងមានកំណើតក្នុងលោកនេះត្រឹមតែម្ដង។

៤- បើធ្វើមរណកាល ក្នុងពេលសម្រេចអនាគាមីហើយ នឹងមិនមានកំណើតក្នុងលោកនេះទៀត គឺនឹងបានទៅកើតក្នុងឋានសួគ៌ជាន់សុទ្ធាវាស ហើយបាននិព្វានក្នុងទីនោះតែម្ដង។

៥- បុគ្គលដែលមានបញ្ញាច្រើន អាចបានសម្រេចមគ្គ ៣ ខាងដើមជាបន្តបន្ទាប់គ្នាមួយម្ដងៗ រហូតដល់មគ្គទី ៤ ក្នុងបច្ចុប្បន្នជាតិនេះ អាចនឹងបានជាព្រះអរហន្តសោយនូវវិមុត្តិសុខយ៉ាងស្ងប់របស់និព្វាន។

៦- បុគ្គលដែលអស់ជីវិត ក្នុងពេលបានអរហត្តផលហើយ មានខន្ធ ៥ រលត់អស់ដោយមិនមានសេសសល់ មានទុក្ខទាំងឡាយដែលសត្វត្រូវសោយសូន្យអស់ មានជីវិតអន្ទោលរលត់អស់ មានសង្ខតធម៌សម្រាប់ពង្វិលសត្វឲ្យអន្ទោលក្នុងភពរបស់ហើយ នេះឯងគឺជាសេចក្ដីសម្រេចយ៉ាងខ្ពស់បំផុត ដែលកើតឡើងអំពីការប្រតិបត្តិធម៌នៃពុទ្ធសាសនា ដែលព្រះសម្មាសម្ពុទ្ធទ្រង់ប្រកាសឲ្យប្រើតាំងអំពី ២៥១៣ ឆ្នាំកន្លងមកហើយ។

អ្នកអានទាំងឡាយ! ខ្ញុំបានសរសេរអំពីជីវិតសន្តិភាពដែលត្រូវកើតមានឡើងដោយធម្មៈនៃពុទ្ធសាសនាចប់ដោយសង្ខេបប៉ុណ្ណោះហើយ។ ដទៃអំពីនេះ ខ្ញុំនឹងសរសេរអំពីបញ្ហាជីវិតសន្តិភាព ដែលមានជាប់ទាក់ទងជាមួយនឹងព្រះពុទ្ធសាសនាដោយចែកបញ្ហាទាំងឡាយនេះជាបទៗ ដើម្បីឲ្យអ្នកសិក្សាអំពីជីវិតសន្តិភាពងាយយល់ ងាយចេះចាំដូចមានតទៅ។

□□□

# បទទី ១០

# ពុទ្ធសាសនាហួសសម័យហើយឬ?

សំនួរនេះអាចធ្វើឲ្យទង្គិចចផ្ទត់គំនិតនៃអ្នកអាន ចំពោះត្រង់ចំណុចខ្លះ ដែលកំពុងកើតមានក្នុងសង្គមយុវជនអ្នកសិក្សាវិជ្ជាសម័យថ្មី ព្រមជាមួយនឹង សេចក្ដីភ្ញាក់ផ្អើលរបស់ពុទ្ធសាសនិកពួកខ្លះ ដែលបានឃើញទ្រឹស្ដីនៃពួក m.R.a. សព្វថ្ងៃនេះ។ នៅក្នុងទ្រឹស្ដីនោះ ពួកគេបានលើកយក *សច្ចៈ បរិសុទ្ធ ចាគៈ មេត្តា* មកធ្វើអត្ថាធិប្បាយវែកញែកហើយបញ្ជាក់ថា *មនុស្សលោកអាច រួមរស់នៅជាមួយគ្នាបានប្រសិនបើទាំងអស់គ្នាសុខចិត្តព្រមកាន់ធម៌ទាំងឡាយ ៤ នេះទាំងអស់គ្នា ។* ក្នុងទីបំផុត ពួកណោះបានលើកយកការស្វែងរកសេចក្ដី ខុសត្រូវតាមផ្លូវច្បាប់ ទាំងផ្នែកគតិលោកនិងផ្នែកគតិធម៌ថាជាធំបំផុត ហើយ បានទាត់ចោលនូវការចាប់កំហុសចំពោះរូបមនុស្ស ព្រះទាំងបានលើកលែង ប្រកាន់ជាតិ ត្រកូល វណ្ណៈ ឋានៈ ពណ៌សម្បុរ ។ល។ មកធ្វើជាឧត្តមគតិរបស់ គេ។ កាលណាលិទ្ធិ m.R.a. បានប្រកាសនូវគោលបំណងនិងឧត្តមគតិដូចនេះ នាំឲ្យយើងមានសេចក្ដីសង្ស័យកើតឡើងថា ព្រះពុទ្ធសាសនារបស់យើងបាន កន្លងសម័យទៅហើយឬ ? ព្រឹត្តិការណ៍នេះធ្វើឲ្យនិស្សិត និស្សិតក្នុងវិទ្យាល័យ និងសាកលវិទ្យាល័យ មួយអន្លើដោយពុទ្ធសាសនិកពួកខ្លះ អស់ជំនឿក្នុងលំអ នៃពុទ្ធសាសនារបស់យើង ហើយងាកទៅចូលលទ្ធិដទៃៗ ដើម្បីជ្រកកោនពឹង អាស្រ័យ ដោយសេចក្ដីសំគាល់ត្រឹមតែថាលទ្ធិនេះ ថ្មីជាងលទ្ធិរបស់ខ្លួន។ ក្រៅ អំពីនេះ មានជនមួយចំនួនទៀតដែលនៅពុំទាន់ចូលចិត្តជ្រៅទូលាយ ក្នុងអត្ថ ន័យដ៏សុខុមនៃពុទ្ធសាសនារបស់ខ្លួននោះ ក៏ជាហេតុមួយទៀតបូកជាមួយនឹង ហេតុខាងលើ ដែលនាំឲ្យគេចូលចិត្តថា ព្រះពុទ្ធសាសនាមិនប្លែកផ្សេងអ្វីអំពី សាសនាទាំងឡាយដទៃ ក្នុងចំណុចមួយដែលព្រះសម្មាសម្ពុទ្ធរបស់យើងទ្រង់ សំដែងថា "**ធ្វើល្អបានល្អ ធ្វើអាក្រក់បានអាក្រក់**" ព្រោះភាសិតនេះមានទូទៅ គ្រប់សាសនា ពួកយើងគ្រាន់តែជ្រើសរើសសេចក្ដីល្អឲ្យបានច្រើន លះបង់

សេចក្ដីអាក្រក់ឲ្យអស់ ពួកយើងរួមរស់នៅជាមួយគ្នា ស្រឡាញ់គ្នា ទុកដាក់គ្នាក្នុងឋានៈជាបងប្អូនក៏ជាការស្រេច ហើយត្រឹមត្រូវតាមបំណងនៃសាសនាទាំងអស់នោះហើយ។

ការណ៍ពិត វត្ថុបំណងនៃរាល់ៗសាសនា មានសេចក្ដីប្រាថ្នាឲ្យមនុស្សធ្វើសេចក្ដីល្អ ឲ្យមនុស្សរួមរស់នៅផងគ្នា ឲ្យមនុស្សស្រឡាញ់គ្នាមែន តែទំហំរបស់មនុស្សត្រឹមប៉ុណ្ណោះនេះ មិនអាចនឹងធ្វើឲ្យមនុស្សរួចផុតចាកទុក្ខទាំងអស់បានឡើយយ៉ាងគាប់ប្រសើរណាស់ ក៏បានត្រឹមតែនាំឲ្យមនុស្សទៅកាន់ស្ថានសួគ៌ប៉ុណ្ណោះ ពុំមែនបានរួចផុតចាកការវិលកើតវិលស្លាប់ មិនមែនទាន់ទៅជាផ្លូវប្រតិបត្តិដើម្បីនិព្វានឡើយ។ នៅក្នុងលោកនេះ មិនមានសាសនាណាមួយបានសំដែងចេញនូវមគ្គមានអង្គ ៨ ឬសំដែងចេញនូវលោកុត្តរធម៌ទាំងឡាយទេ លើកលែងតែព្រះពុទ្ធសាសនារបស់យើងមួយប៉ុណ្ណោះ។ ទ្រឹស្ដីដ៏ខ្ពស់ខ្ពស់នៃពុទ្ធសាសនាមានកំពស់និងជំរៅចាងសាសនាទាំងឡាយឯទៀត អ្នកអានបើមានបំណងនឹងញុំាងជំនឿរបស់ខ្លួនឲ្យកើតមានឡើងក្នុងទ្រឹស្ដីនេះ ត្រូវធ្វើការសិក្សាស្រាវជ្រាវតាមមគ្រាពុទ្ធសាសនាឲ្យបានយ៉ាងច្រើន។ តែកុំភ្លេចថា មុននឹងធ្វើការសិក្សាស្រាវជ្រាវ ត្រូវដាក់ខ្លួនឲ្យជាមនុស្សកណ្ដាលរបស់លទ្ធិវិទ្យាសាស្ត្រនិងលទ្ធីសាសនាទាំងឡាយសិន។ បើមិនដូច្នេះទេការសិក្សាស្រាវជ្រាវរបស់យើងនឹងពើបប្រទះនូវការទាល់ច្រកជាមិនខាន ព្រោះជំរាវរបស់យើងស្ថិតនៅលើមូលដ្ឋាននៃអរូបធាតុជាច្រើន សឹងផ្ទុយពីសាសនាទាំងឡាយនិងវិទ្យាសាស្ត្រគ្រប់ប្រភេទ ដែលមានជំរាវរបស់គេផ្អែកទៅលើរូបធាតុដោយភាគច្រើន។

ចំពោះបញ្ហាដូចនេះ មិនមែនមានតែក្នុងសម័យនេះទេ សូម្បីក្នុងសម័យពុទ្ធកាល ក៏គង់មានគេមិនជឿធម្មទេសនានៃព្រះសម្មាសម្ពុទ្ធរបស់យើងដែរ។ ក្នុងបាយាសិសូត្រនៃសម្បិមនិកាយ មាននិយាយអំពីស្ដេចបាយាសិ ដែលមានយោបល់ថា : មិនមានលោកដទៃ មិនមានដំណើតកើតឡើងឯងៗ គឺមិនមានករឧបត្តិក្នុងទេវលោក ព្រហ្មលោក មិនមានកម្មល្អ មិនមានកម្មអាក្រក់ ។ល។ ព្រះកុមារកស្សបត្ថេរៈ បានព្យាយាមធ្វើអត្ថាធិប្បាយពន្យល់ស្ដេចបាយាសិ តាម

បញ្ញារបស់លោក ដោយប្រើវិធីប្រៀបធៀបច្រើនបែបច្រើនប្រការក្នុងទីបំផុត ស្ដេចអង្គនេះក៏យល់ព្រមផ្លាស់គំនិតរបស់ព្រះអង្គតាមយោបល់ ព្រះមហាថេរវិញ ហើយសូមចូលបួសជាភិក្ខុក្នុងពុទ្ធសាសនា។ បាយាសិសូត្រមានសេចក្ដីគួរអានស្ដាប់ណាស់ព្រោះស្ដេចបាយាសិ ដែលគេទុកជាជើងខាងវិទ្យាសាស្ត្រក្នុងជំនាន់នោះ ព្រះអង្គទ្រង់បានធ្វើការពិសោធន៍ក្នុងសរីរាង្គនៃមនុស្សជាច្រើនលើកច្រើនគ្រា ដើម្បីចង់ដឹងថា ក្នុងរូបកាយរបស់មនុស្សមានវិញ្ញាណឬមិនមានទេ។ អ្នកវិទ្យាសាស្ត្ររូបនេះមានលក្ខណការខុសគ្នានឹងអ្នកវិទ្យាសាស្ត្រក្នុងសម័យបច្ចុប្បន្ន ព្រោះព្រះអង្គបានយកមនុស្សទាំងរស់មកធ្វើជាគ្រឿងពិសោធន៍សាកល្បង។ ចំណែកអ្នកវិទ្យាសាស្ត្របច្ចុប្បន្នសម័យគេយកសត្វសុនខ ឆ្មា ទន្សាយ ។ល។ មកធ្វើការពិសោធន៍នៅក្នុងបន្ទប់ល្បងពិសោធ។ ក្នុងសម័យបរមាណូនេះគង់នៅមានមនុស្សជាច្រើនចំនួនទៀត ដែលមិនមានជំនឿក្នុសច្ចធម៌ដូចស្ដេចបាយាសិ។ ពួកអស់ទាំងនេះសុទ្ធតែមិនមានជំនឿក្នុងធម្មៈនៃពុទ្ធសាសនា មិនមានសេចក្ដីគោរពរាប់អានព្រះពុទ្ធសាសនា ដែលជាលទ្ធិនៃជាតិរបស់ខ្លួន។ យុវជនពួកខ្លះដកខ្លួនថយចេញឆ្ងាយពីរបបសង្គមដ៏ល្អរបស់ជាតិ មានចិត្តរវើរវាយដើរហើរទៅរាប់អានរបបសង្គមដទៃដោយមិនមានសេចក្ដីពិចារណាជ្រើសរើសតាមផ្លូវប្រាជ្ញាញាណ ព្រោះជឿតាមពាក្យឃោសនារបស់គេថា របបសង្គមនោះជារបស់ថ្មី ជារបស់ល្អ ដែលមនុស្សជាតិគេនិយមនៅក្នុងលោកនេះដោយភាគច្រើន។ ពួកអស់ទាំងនោះហើយ ដែលខ្ញុំចង់សួរថា : តើព្រះពុទ្ធសាសនារបស់យើងកន្លងសម័យហើយឬ ?

មុននឹងតបបញ្ហានេះ ជាដំបូង យើងត្រូវពិចារណាមើលថា : មនុស្សសម័យនេះបានឃើញលោកក្នុងទស្សនៈនៃវិទ្យាសាស្ត្រ បានឃើញការស្រាវជ្រាវថ្មីៗយ៉ាងម៉េចខ្លះ។ ជាលំដាប់ទី ២ យើងគួរត្រួតពិនិត្យមើលថា តើធម្មៈនៃពុទ្ធសាសនាមានទំនាស់នឹងគោលការណ៍វិទ្យាសាស្ត្រដែរឬទេ? ហើយក្នុងលំដាប់ចុងក្រោយបំផុត យើងគួរពិចារណាដល់ទស្សនៈរបស់ព្រះពុទ្ធសាសនាត្រង់ចំណុចមួយដែលទាក់ទងជាមួយនឹងជីវិតមនុស្ស និងធម្មៈរបស់ព្រះសម្មាសម្ពុទ្ធថា តើអាចឲ្យអត្ថាធិប្បាយយ៉ាងច្បាស់លាស់ក្នុងបញ្ហានានា ដែលទាក់

ទងជាមួយនឹងជីវិតទាំងឡាយយ៉ាងណាខ្លះ? ព្រោះត្រង់ចំណុចនេះ ខាងវិទ្យាសាស្រ្តមិនអាចឆ្លើយបានច្បាស់លាស់ឡើយ។

មនុស្សសម័យថ្មី បានទទួលការសិក្សាខាងវិទ្យាសាស្រ្តយ៉ាងល្អ ចេះប្រើសេចក្តីសង្កេតពិនិត្យប្រកបដោយបញ្ញាយ៉ាងស្រួលស្រាល់ ត្រឹមត្រូវតាមកម្មវិធីនៃវិទ្យាសាស្រ្ត ។ ការស្រាវជ្រាវបែបថ្មី បណ្តាលឲ្យគេលះបង់នូវជំនឿចាស់និងកំណាន់ចាស់បានយ៉ាងងាយ គេមានជំនឿតែក្នុងវត្ថុធាតុដែលគេអាចពិសោធន៍បានតែក្នុងបន្ទប់ពិសោធន៍វិទ្យាសាស្រ្ត ឬគេមានជំនឿតែលើវត្ថុណាដែលរាប់ចូលថាជារបស់ពិត មិនមានទំនាស់នឹងល័ខការនៃវិទ្យាសាស្រ្ត។ ជនសម័យនេះ គេមិនជឿថាមានខ្មោចបិសាចព្រោះគេមិនដែលឃើញខ្មោចដែលភ្នែករបស់គេ ព្រោះខ្មោចជាវត្ថុធាតុដែលគេថតរូបវាមិនបាន វិញ្ញាណក៏មិនមានអ្នកណាឃើញប្រាកដក្នុងទីណាមួយ ។ យោបល់ថា : មនុស្សយើងមានវិញ្ញាណនៅប្រចាំខ្លួន ឬវិញ្ញាណមាននៅប្រចាំជាប់ជានិច្ចក្នុងសាកលពិភពដែលកើតមកអំពីសេចក្តីយល់ឃើញនៃសាសនាទាំងឡាយ មានសាសនាហិណ្ឌូជាដើមនោះ ។ អ្នកចេះដឹងខាងវិទ្យាសាស្រ្តខ្លះ និងអ្នកល្ងង់ជ្រុលហួសពេកខ្លះ មិនយល់ថាជំនឿនេះ នាំឲ្យចំរើនខាងផ្លូវវិទ្យាសាស្រ្តនិងផ្លូវសង្គមវិវត្តឡើយ។

ខាងវិជ្ជាពេទ្យក្នុង ៥០ឆ្នាំកន្លងមកហើយនេះ គេបានប្តូរទស្សនៈរបស់មនុស្សក្នុងរឿងទាក់ទងជាមួយនឹងសាកលលោកបានយ៉ាងច្រើន។ ក្រៅអំពីនេះ ការចំរើនដុះដាលខាងវិទ្យាសាស្រ្ត បានធ្វើឲ្យសេដ្ឋកិច្ចគ្រប់ប្រទេសក្នុងពិភពលោក មាការផ្លាស់ប្តូររូបយ៉ាងសំបើម អារ្យធម៌សម័យនេះពោរពេញទៅដោយសេចក្តីសប្បាយរីករាយយ៉ាងត្រកាល។ គ្រប់ប្រទេស មានរោងចក្រតូចធំធ្វើផលិតផលវត្ថុធាតុបានតាមត្រូវការ រោងចក្រមួយៗ អាចធ្វើការបានគ្រប់រយៈពេល ២៤ម៉ោង ប្រើកម្លាំងមនុស្សតិចផលិតវត្ថុបានច្រើន ជាហេតុឲ្យជីវិតមនុស្សមានសេចក្តីសប្បាយកាន់តែច្រើនឡើង មានអនាម័យក៏កាន់តែល្អឡើងតាមលំដាប់។ ព្រមជាមួយគ្នានេះ ជីវិតមនុស្សក៏ចេះតែមានតម្លៃច្រើនឡើងទៀត ជាហេតុឲ្យគេខំប្រឹងធ្វើការច្រើនជាងដើម ដើម្បីយកកម្រៃមកដំឡើង

កំពស់នៃជីវភាព។ រាល់ថ្ងៃៗ គេខំប្រឹងធ្វើការ ដើម្បីយកប្រាក់មកទិញគ្រឿងឧបភោគបរិភោគ ទិញទីលំនៅ ទំនុកបំរុងសេចក្ដីសប្បាយ បំរើសេចក្ដីសុខក្សេមក្សាន្តរបស់គេ ធ្វើឲ្យខ្លួនគេមានអំណាចសក្ដិសិទ្ធិក្នុងលទ្ធិភោគសម្បត្តិនោះ។ សឹងហៅតាមសព្ទវប្បធម៌ថា "**វឌ្ឍនធម៌ខាងវត្ថុធាតុ**" ដូច្នេះ លោកទស្សនៈរបស់មនុស្សសម័យនេះ ទើបគួរហៅថា "ពិភពលោកនៃវត្ថុនិយម" ។

ទស្សនៈនៃវត្ថុនិយមសម័យនេះ មានសេចក្ដីដៅថា : "វត្ថុធាតុក្នុងសាកលលោក ក្លាយទៅជាគ្រឿងចក្រធំៗ មនុស្សជាតិមួយរូបៗ បានក្លាយខ្លួនទៅជាគ្រឿងចក្រតូចៗ ដែលកើតឡើងដោយថាមពលបរមាណូ។ ថាមពលបរមាណូនេះវាផ្គុំគ្នាកើតបានជារូបធាតុ រូបធាតុវាតែងផ្លាស់ប្ដូរទៅតាមអំណាចនិងការវិវត្តន៍នៃកម្មជាតិ (Naturitie evolution) មនុស្សយើងដោះខ្លួនអំពីទុក្ខមិនទាន់រួច ការតស៊ូដើម្បីរស់នៅមិនមានទីដៅណាមួយទៀតក្រៅអំពីនេះ មិនមានវត្ថុបំណងច្បាស់លាស់នៅខាងចុង។ សេចក្ដីស្លាប់របស់សត្វទាំងឡាយត្រឹមតែជាសភាវៈនៃការស្លាយរបស់ធាតុគីមីអស់ទាំងនោះ ដែលជាការធម្មតា មិនមានអ្នកណាម្នាក់អាចធ្វើឲ្យវត្ថុធាតុទាំងឡាយតាំងនៅជាប្រក្រតី បានឡើយ។

ទស្សនៈវត្ថុនិយមនៃជនខ្លះថា : រូបមនុស្សយើងជារោងការ ឧស្សាហកម្មសំរាប់ផលិតវត្ថុគីមីច្រើនយ៉ាង វត្ថុគីមីអស់ទាំងនោះវាតែងឆក់ស្រូបគ្នាទៅវិញទៅមកបណ្ដាលឲ្យចំណែកអវយវៈនានាធ្វើការបានជាប្រក្រតី។ ប្រសិនបើមានសេចក្ដីវិបត្តិប្រែប្រួលកើតឡើងក្នុងរូបកាយរបស់យើង ត្រង់ចំណែកណាមួយ រូបកាយយើងក៏ទៅជាឈឺចាប់ទ្រុឌទ្រោមចុះ ក្នុងទីបំផុតយើងក៏ត្រូវស្លាប់ព្រោះតែរូបកាយមិនមានសមត្ថភាពបកប្រែធាតុទាំងឡាយបានដូចធម្មតា ឬមិនមានជំនួយអំពីធាតុខាងក្រៅចូលមកធ្វើការជំនួសនោះឯង។

ដូច្នេះបើអ្នកប្រាជ្ញវិទ្យាសាស្ត្រ មានសមត្ថភាពអាចផលិតវត្ថុធាតុនានាដែលជាចាំបាច់សម្រាប់ស្ងួនគ្រងជីវិតមនុស្ស មានតុល្យភាពដ៏សមគួរហើយជីវិតរបស់មនុស្សយើងក៏អាចរស់នៅបានយូរតទៅទៀត ដោយមិនមានកំណត់

សេចក្ដីស្លាប់សឹងបណ្ដាលមកអំពីធាតុអស់ទាំងនោះក៏ផុតរលត់អស់ទៅ ពុំមានសេសសល់នៅក្នុងរូបកាយរបស់យើងឡើយ ។

អ្នកវត្ថុនិយមសម័យនេះ បានទាយទុកថា ក្នុងអនាគតកាល មនុស្សជាតិនឹងមានជោគជ័យលើសេចក្ដីចាស់ឈឺស្លាប់ ដោយសំអាងដល់វិជ្ជាពេទ្យក្នុងបច្ចុប្បន្នដែលកាន់តែពូកែឡើងៗ គឺគេមានសមត្ថភាពធ្វើហ័រម៉ូន (Hormone) ឡើយបានតាមតម្រាវិទ្យាសាស្រ្ត សម្រាប់ប្រើព្យាបាលជម្ងឺក្នុងរូបកាយរបស់មនុស្ស ។ ឱសថថ្មីៗនេះ អាចព្យបាលជម្ងឺឆ្លងបានយ៉ាងឆុតឆាប់ជាងពីដើម ចាប់តាំងពីមានឱសថចាក់បង្ការជម្ងឺ ចាប់តាងពីបានរៀបចំសុខភាពអនាម័យរបស់មនុស្សតាមរបៀបថ្មីកាលណាមក គេអាចការពារជម្ងឺ[១] ឆ្លងបានជាច្រើនឆ្នាំមកហើយដែរ។ ជម្ងឺចុះរាក ជម្ងឺពិលក្ដៅ ជម្ងឺអុត ។ល។ មិនសូវកើតមានក្នុងប្រទេសហើយទេ ឃើញថាសម័យនេះយើងកំចាត់រោគតាមតម្រាពែទ្យ[២] បានយ៉ាងល្អ សេចក្ដីទុក្ខក្នុងរូបកាយរបស់យើងក៏បានធូរស្រាលច្រើនហើយ។ តែជាអកុសលរបស់យើង សេចក្ដីទុក្ខដែលប្រព្រឹត្តទៅក្នុងចិត្តពុំបានស្រាកស្រាន្តទេ។ ការស្រេវខ្លាច ការព្រួយបារម្ភការរួញរា បណ្ដាលមកពីស្ថានភាពបច្ចុប្បន្នកំញើញគំរាមគ្នាតាមផ្លូវចម្បាំង ការទាំងអស់នេះវិទ្យាសាស្រ្តខាងពែទ្យមិនមានឱសថសម្រាប់ព្យាបាលទេ។ ពួកយើងមនុស្សជាតិ ត្រូវឈមមុខតស៊ូនឹងគ្រោះកាច ដែលកើតមកពីកម្លាំងចិត្តប្រកបដោយលោភៈ មោហៈ ទោសៈរបស់មនុស្សរាល់ៗថ្ងៃ សូម្បីវិទ្យាសាស្រ្តចំរើនដុះដាលដល់ថ្នាក់ណាក៏មិនអាចកែបញ្ហានេះ ជូនមនុស្សលោកបានឡើយ។

កាលណាយើងងាកទៅមើល សេចក្ដីចំរើនដុះដាលនៃវិទ្យាសាស្រ្តខាងផ្នែករូបនិយម យើងបានឃើញថាក្នុងរយៈពេល ២០ឆ្នាំកន្លងមកនេះ វិជ្ជាផ្នែកនេះបានដើរយ៉ាងលឿនជាងវិទ្យាសាស្រ្តសាខាដទៃៗ ។ គេបានស្រាវជ្រាវរកឃើញរលកវិទ្យុ វិទ្យុទូរទស្សន៍ (Television) រ៉ាដារ៍ (Radar) វិទ្យុសកម្ម ព្រម

(១) "ជម្ងឺ" ពាក្យធម្មតា ពាក្យវេយ្យករណ៍ថា "ជម្ងឺ" មកអំពីកិរិយាសព្ទថា "ឈឺ"។

(២) "ពែទ្យ" ជាពាក្យវេយ្យាករណ៍ដែលផ្លាស់ស្រៈអេជាស្រៈអែ ពាក្យក្នុងវចនានុក្រមថា "ពេទ្យ"

មួយអន្លើដោយអំណាចនៃរ៉ែធាតុនានា។

ក្នុងទស្សនៈរបស់វិទ្យាសាស្ត្ររូបនិយមសម័យថ្មី គេឃើញថា សាកលចក្រវាឡប្រកបដោយបរមាណូច្រើនយ៉ាង ក្នុងយ៉ាងមួយៗប្រកបដោយប្រូត្រូន និងអ៊ីឡេក្រូន វត្ថុទាំងអស់នេះ សុទ្ធតែមានចលនាញ័រកម្រើកឆាបឆក់នូវគ្នានឹងគ្នាជាហេតុឲ្យវត្ថុធាតុគ្រប់បែបដូរផ្លាស់រូបបាន អស់កាលជាប់មិនដាច់ ដោយមិនមានរូបធាតុណាមួយដែលនៅស្ងប់ស្ងៀម មិនប្រែប្រួលឡើយក្នុងរាល់ៗខណៈ។

ដូច្នេះឃើញថា អ្នកវិទ្យាសាស្ត្រព្រមទទួលស្គាល់និងព្រមដាក់ជំនឿរបស់ខ្លួនទៅលើទ្រឹស្តីព្រះសម្មាសម្ពុទ្ធរបស់យើង ត្រង់ចំណុចថា : សាកលចក្រវាឡជារបស់ដែលត្រូវរចនាតាក់តែងដោយធម្មជាតិ (ជាសង្ខារ) មិនទៀង ជាទុក្ខនិងមិនមែនជាខ្លួនប្រាណ (អនិច្ចំ ទុក្ខំ អនត្តា) ម៉្យាងទៀតមានពុទ្ធវចនៈមួយបទដែលស្តីថាវត្ថុខាងក្រៅ (គឺសាកលចក្រវាឡ) មនុស្សយើងអាចដឹងបានដោយអាស្រ័យអាយតនៈខាងក្នុង ៦ អាយតនៈខាងក្រៅ ៦ ជានាមរូបប៉ុណ្ណោះ។ ក្រៅអំពីនេះយើងមិនអាចដឹងបានឡើយ។ ពុទ្ធវចនៈនេះ ខាងវិទ្យាសាស្ត្រ ទើបតែនឹងចូលចិត្ត គឺអ្នកវិទ្យាសាស្ត្របានពិចារណាស្រាវជ្រាវឃើញហើយយល់ថាគ្រឿងវិទ្យាសាស្ត្រនិងរូបធាតុនានាដែលបានរកឃើញថ្មីនេះ ជាគ្រឿងជំនួយធ្វើឲ្យអាយតនៈទាំង៥ (ភ្នែក ត្រចៀក ច្រមុះ អណ្តាត កាយ) មានទំហំរីកទូលាយជាងដើម។ កម្លាំងវិទ្យាសាស្ត្រត្រឹមប៉ុណ្ណោះ ធ្វើឲ្យយើងមើលឃើញសាកលចក្រវាឡត្រឹមតែចំណែកតូច ប្រហែលដូចជាយើងមើលឃើញពិភពលោកតាមប្រហោងមួយយ៉ាងតូចប៉ុណ្ណោះ។ យើងស្គាល់ពិភពលោក ឃើញពិភពលោកនៅក្នុងការមានកំណត់ព្រំដែន។ ដូចនេះព្រោះអ្វី មិនមែនព្រោះយើងស្គាល់បានដោយអាស្រ័យអាយតនៈទាំងប្រាំនោះទេឬ?

អ្នកប្រាជ្ញភូមិសាស្ត្រគ្រប់សម័យបាននិយាយថា : សាកលចក្រវាឡមានច្រើនណាស់ ដែលយើងពុំអាចនឹងមើលឃើញដោយអាស្រ័យអាយតនៈធម្មតា។ តែទោះជាយ៉ាងណាក៏ដោយ អ្នកវិទ្យាសាស្ត្របច្ចុប្បន្នបានរកឃើញនូវក្រសែរលកដែលមាននៅក្នុងសាកលចក្រវាឡខ្លះហើយ ហើយបានយកមក

ប្រើប្រាស់ធ្វើប្រយោជន៍ឲ្យមនុស្សលោក ដោយរៀបចំប្រើគ្រឿងវិទ្យាសាស្ត្រតាមបែបសម័យ ឲ្យកាន់តែបានផលច្រើនឡើង ដូចគ្រឿងចុលទូរទស្សន៍ (Electron microscope) គ្រឿងឆ្លុះនេះអាចពង្រីករូបអតិសុខុមប្រាណ ឲ្យរីកធំឡើងជាងប្រក្រតីរាប់រយពាន់ភាគ គេប្រើគ្រឿងទូរទស្សន៍ (Telescope) វិទ្យុទូរទស្សន៍និងរ៉ាដារ៍សម្រាប់មើលកន្លែងឆ្ងាយៗដែលកម្លាំងភ្នែកធម្មតាមើលមិនឃើញ បានចម្ងាយច្រើនរយច្រើនពាន់គីឡូវម៉ែត្រ។ យើងប្រើគ្រឿងវិទ្យុទទួលសម្លេង វិទ្យុទូរស័ព្ទ និងគ្រឿងចាប់សម្លេង (Electronic sound detector) សម្រាប់ពង្រីកសៀងឲ្យធំ ដើម្បីស្តាប់ឲ្យច្បាស់។ ដោយអាស្រ័យគ្រឿងវិទ្យាសាស្ត្រនេះ យើងអាចស្តាប់សម្លេងត្រីនៅក្នុងផ្ទៃបាតសមុទ្រយ៉ាងជ្រៅបាន តែយើងពុំដឹងបកប្រែភាសារបស់វាទេ ។ វិទ្យាសាស្ត្រចេះធ្វើកញ្ចែមួយបែប ឲ្យមានសម្លេងអណ្តែតឡើងខ្ពស់ មនុស្សយើងពុំឮទេតែសត្វសុនខវាអាចស្តាប់ឮយ៉ាងច្បាស់។ មានសត្វច្រើនយ៉ាងទៀតដែលមានភ្នែក ត្រចៀក ច្រមុះ វៃជាងមនុស្សយើងច្រើនភាគរយ។ សត្វពួកនេះវាអាចមើលឃើញរូបតូចៗ និងរូបដែលនៅក្នុងទីឆ្ងាយៗ វាស្តាប់ឮសម្លេងដែលមានសូរតិចៗ និងសម្លេងដែលលាន់ឮក្នុងទីឆ្ងាយៗ ច្រមុះវាស្រង់ក្លិនបានឆ្ងាយជាងមនុស្សយើងច្រើនណាស់ ។ មានសត្វច្រើនប្រភេទទៀត ដែលវាមានសមត្ថភាពអាចដឹងមុន នូវហេតុការណ៍ដែលនឹងត្រូវកើត ត្រូវមានឡើង។ ការដឹងនោះទៀត វាមិនមែនដឹងក្នុងពេលភ្លាមៗទេ គឺវាដឹងហេតុភេទអាក្រក់ល្អ មុនកើតឡើងជាច្រើនៗថ្ងៃ ថានឹងមានអន្តរាយឬមានលាភដល់ខ្លួនរបស់វា។ ដូចជាសត្វកណ្តុរ វាលោតចុះទៅក្នុងទឹកមុនទូកត្រូវលិច ស្រមោចវារត់រកដីទួលខ្ពស់ធ្វើសំបុកមុនភ្លៀងធ្លាក់ សត្វបក្សីខ្លះវាចេះធ្វើសំបុកលើមែកឈើដោយស្មានកំពស់ឲ្យត្រូវមុនទឹកឡើង លិច ។ សរុបសេចក្តីបានថា : សត្វទាំងអស់នេះ វាដឹងសេចក្តីពិត (Reality) ជាងមនុស្សយើងទៅទៀត ។ អ្នកវិទ្យាសាស្ត្រមានសេចក្តីសង្ស័យចំពោះរឿងនេះ ហើយខំប្រឹងសិក្សាស្រាវជ្រាវទៅទៀត ដើម្បីធ្វើឲ្យមនុស្សយើងមើលឃើញសេចក្តីពិត បានឆ្ងាយជាងដែលធ្លាប់ឃើញមកហើយ ដោយអាស្រ័យអាយតនៈធម្មតា។

តែបញ្ហាទាំងឡាយនេះ គេពុំទាន់បានស្រាយរួចនៅឡើយទេ សព្វថ្ងៃអ្នកវិទ្យាសាស្ត្រកំពុងព្យាយាមធ្វើការពិសោធន៍កម្លាំងចិត្ត ដើម្បីចង់ដឹងថា មនុស្សខ្លះដែលធ្វើជាគ្រូទាយក្តី មនុស្សខ្លះដែលអាចដឹងសេចក្តីពិតជាងមនុស្សធម្មតាក្តី ។ ជនទាំងឡាយនេះ អាចប្រើកម្លាំងចិត្តរបស់គេទៅសង្កត់សង្កិនជនដទៃឲ្យលុះក្នុងអំណាចរបស់ខ្លួន អាចមើលឃើញហេតុការណ៍ក្នុងអតីតនិងអនាគតបាន។ អ្នកវិបស្សនាខ្លះ បានធ្វើសមាធិចិត្តហើយពិចារណាឃើញហេតុផលនៃសេចក្តីពិតខុសជនធម្មតា។ ព្រះសម្មាសម្ពុទ្ធរបស់យើង ទ្រង់បង្រៀនសមាធិដែលព្រះអង្គបានពិសោធមក ហើយឲ្យពុទ្ធបរិស័ទត្រាស់ដឹងនូវសេចក្តីពិតបាន។ ជនជាតិបស្ចឹមប្រទេសខ្លះ មានសមត្ថភាពវិនិច្ឆ័យជម្ងឺបាន ទោះជាបុគ្គលមានជម្ងឺនោះមានលំនៅ នៅឆ្ងាយពីគ្នារាប់រយគីឡូម៉ែត្រ គឺគេអាចមើលឃើញជីវិតក្នុងអតីតនៃអ្នកមានជម្ងឺ។

វិទ្យាសាស្ត្រមានផលយ៉ាងម៉េចខ្លះ? មានផលធ្វើឲ្យយើងរស់នៅងាយស្រួលមានសេចក្តីសប្បាយច្រើន យើងអាចហោះបានលឿនជាងសម្លេង បើកកុប៉ាល់ក្រោមទឹកសមុទ្របាន បររថភ្លើងក្រោមដីបាន រថយន្តក៏អាចបើកបរកាត់ភ្នំកាត់ទន្លេបាន វិទ្យុទូរទស្សន៍ធ្វើឲ្យយើងមើលឃើញឆ្ងាយធ្លុះធ្លាយកំពែងក្រាស់ៗបានឃើញតាំងពីប្រទេសយើងដល់ប្រទេសគេឆ្ងាយៗ វិទ្យុទូរស័ព្ទ ធ្វើឲ្យយើងនិយាយឆ្លើយឆ្លងគ្នាបានរាប់ទាំងពាន់ៗគីឡូម៉ែត្រ សូម្បីតែនៅក្នុងយន្តហោះ កប៉ាល់រថភ្លើង។ល។ ដែលកំពុងបើកបរយ៉ាងលឿន ក៏អាចនិយាយប្រាស្រ័យគ្នាបានដែរ។

*តែគ្រឿងវិទ្យាសាស្ត្រទាំងអស់នេះ ដែលគួរឲ្យយើងមានសេចក្តីព្រួយបារម្ភជាទីបំផុតទៅវិញនោះ គឺការកសាងបុមអាតូមិក និងបុមអ៊ីដ្រូហ្សែន។ អំណាចអាតូមិកប្រើឲ្យជាប្រយោជន៍ដល់សង្គមមនុស្សបានផលយ៉ាង ប្រសើរកអ្វីប្រៀបពុំបាន តែគេក៏អាចយកទៅប្រើប្រហារមនុស្ស ប្រល័យចក្រវាឡយ៉ាងអាក្រក់រកអ្វីប្រៀបមិនបានដូចគ្នាដែរ។ វិទ្យាសាស្ត្រអាចប្រើជាមហាកុសលសម្រាប់តំឡើងជោគវសានារបស់មនុស្សក៏បាន អាចប្រើជាមហាអកុសលសម្រាប់ទំលាយពិភពនៃមនុស្សក៏បានប្រសិនបើអ្នកវិទ្យាសាស្ត្រ មិន*

*មានសិលធម៌ មិនមានវឌ្ឍធម៌ខាងផ្លូវចិត្តជួយគាំទ្រផងទេ។*

វិទ្យាសាស្ត្រពុំអាចឲ្យផលខាងផ្លូវសីលធម៌ណាមួយឡើយ ពុំបានធ្វើមនុស្សឲ្យរួចផុតចាកទុក្ខទាំងអស់ តាមតម្រាយផ្លូវរបស់ខ្លួន ពុំបានធ្វើប្រាប់គោលបំណងរបស់ជីវិតឲ្យមានហេតុផល ល្មមជាទីពេញចិត្តសព្វគ្រប់ឡើយ។ បញ្ហារឿងជីវិតដូចមានតទៅនេះក៏ពុំអាចឆ្លើយបាន មនុស្សយើងមកអំពីណា? មនុស្សយើងស្លាប់ហើយទៅនៅឯណា? ខ្លួនយើងគ្រប់គ្នាគឺជាអ្វី? មនុស្សផ្សេងគ្នាព្រោះហេតុអ្វី? សេចក្តីទុក្ខព្រួយរបស់យើងកើតមកពីអ្វី? ចំណុចសំខាន់បំផុត គឺវិទ្យាសាស្ត្រ មិនអាចធ្វើមនុស្សឲ្យបានសេចក្តីសុខយ៉ាងស្ងប់ មិនអាចធ្វើឲ្យមនុស្សដល់នូវទីបំផុតនៃទុក្ខអស់កាលជានិរន្តន៍បាន ដូចនេះព្រោះអ្វី? ព្រោះវិទ្យាសាស្ត្រមានមុខការបំរើមនុស្សតែខាងវត្ថុ គឺបំរើចំពោះរូបកាយមនុស្ស ពុំបានបំរើចិត្តវិញ្ញាណរបស់មនុស្សឡើយ។ ដូច្នេះ ការសិក្សាខាងផ្លូវពុទ្ធសាសនា ទើបជាការចាំបាច់នៃយុវជនរបស់យើង ព្រោះធម្មៈនៃពុទ្ធសាសនាជានាមធាតុ សម្រាប់ធ្វើចិត្តមនុស្សឲ្យស្ងប់ សុខ ឬ នឹងនិយាយថា ព្រះពុទ្ធសាសនាមានមុខការបំរើមនុស្សខាងអវត្ថុ គឺបំរើចិត្តវិញ្ញាណរបស់មនុស្សដូច្នេះវិញក៏បាន។ ពុទ្ធសាសនានិងវិទ្យាសាស្ត្រជាសាស្ត្រ មានគោលការណ៍ត្រូវគ្នាត្រង់ចំណុចមកប្រែធម្មជាតិ យកមកប្រើឲ្យជាផលប្រយោជន៍នៃសេចក្តីសុខចំរើនរបស់មនុស្ស ឬ បើនឹងស្តីមួយបែបទៀតថា *ពុទ្ធសាសនាក៏គឺវិទ្យាសាស្ត្រ វិទ្យាសាស្ត្រក៏គឺពុទ្ធសាសនសាស្ត្រដូច្នេះវិញក៏បាន ព្រោះសាស្ត្រទាំងពីរនេះមានឧត្តមគតិត្រូវគ្នា បង្រៀនមនុស្សឲ្យស្គាល់ធម្មជាតិ បកស្រាយធម្មជាតិ ធ្វើការជាមួយធម្មជាតិ រស់នៅជាមួយធម្មជាតិ ស្លាប់ជាមួយធម្មជាតិ កើតជាមួយធម្មជាតិ។ល។* ជាពិសេស គឺសាស្ត្រទាំងពីរនេះ មានឧត្តមគតិស្របគ្នាថា "*សេចក្តីចំរើនរបស់មនុស្សកើតមកពីធ្វើការងារ មិនមែនកើតមកពីឋានសួគ៌ប្រសិទ្ធទេ*" ចំពោះការបកប្រែរូបធាតុ ពុទ្ធសាសនានិងវិទ្យាសាស្ត្រ បានធ្វើការមានតុល្យភាពស្មើគ្នាហើយ តែចំពោះការបកប្រែអរូបធាតុ វិទ្យាសាស្ត្របានធ្វើការមានតុល្យភាពពុំទាន់ស្មើនឹងពុទ្ធសាសនារបស់យើងទេ។

យុវជនដែលចង់ធ្វើឲ្យជីវិតខុសស្ងប់ គប្បីឆ្លៀតឱកាសសិក្សាសាស្ត្រទាំង

ពីរនេះព្រមៗ គ្នាដរាបណាយើងចេះដឹងវិទ្យាសាស្ត្រកាន់តែច្រើន ដរាបនោះយើងក៏កាន់តែចូលចិត្តធម្មៈនៃពុទ្ធសាសនាច្បាស់លាស់ឡើងដែរ។ ដរាបណាយើងចេះដឹងធម្មៈនៃពុទ្ធសាសនាកាន់តែច្រើន ដរាបនោះគំនិតរបស់យើង ក៏កាន់តែមានពន្លឺក្នុងវិទ្យាសាស្ត្រច្រើនឡើងដែរ។ ក្នុងកាលណាពិភពលោកស្រុះស្រួលព្រមព្រៀងគ្នា យកសាស្ត្រទាំងពីរនេះមកដោះស្រាយបញ្ហាជីវិតរបស់មនុស្ស ដោយធ្វើតុល្យការឲ្យមានចំណែកស្មើគ្នា ក្នុងកាលនោះពិភពលោកនិងជីវិតទាំងឡាយនឹងបានដល់នូវសន្តិភាពជាស្ថាពរមិនខានឡើយ។

ក្នុងកាល ២៥១៣ ឆ្នាំកន្លងទៅ ព្រះសម្មាសម្ពុទ្ធទ្រង់បានត្រាស់ដឹងនូវត្រៃលក្ខណ៍ សឹងជាលក្ខណៈប្រចាំសត្វលោកទាំងមូល គឺជាលក្ខណៈប្រចាំរបស់រូបធាតុនិងអរូបធាតុទាំងអស់។ "**ត្រៃលក្ខណ៍**" មានន័យថា "កំណត់សំគាលនូវការវិវត្តន៍នៃធម្មជាតិ ៣ យ៉ាង" (១) កំណត់សំគាល់ដោយចលនាប្រែប្រួលដូរផ្លាស់ហៅថា "**អនិច្ចំ**" (២) កំណត់សំគាលដោយចលនាទល់ធន់ទ្រាំហៅថា "**ទុក្ខំ**" (៣) កំណត់សំគាល់ដោយចលនាស្លាយប្រាណបែកធ្លាយខ្លួនហៅថា "**អនត្តា**" ។

ចំណែកអ្នកវិទ្យាសាស្ត្រសម័យបច្ចុប្បន្ន ទើបនឹងរកឃើញថា សាកលចក្រវាឡប្រកបដោយបរមាណូ មានអេឡេកត្រុង មានចលនាញ័រកម្រើករាល់វេលា មានការស្រូបឆក់នូវគ្នានឹងគ្នា បណ្តាលឲ្យវត្ថុធាតុទាំងឡាយប្រែប្រួលដោយឥតមានទីបំផុត សឹងត្រូវគ្នានឹងសេចក្តីត្រាស់ដឹងរបស់ព្រះសម្មាសម្ពុទ្ធរបស់យើងក្នុងសម័យនោះទាំងអស់។

ប្រការមួយទៀត ព្រះសម្មាសម្ពុទ្ធបានរកឃើញនូវកម្លាំងនៃកម្មនិងការវិលវល់កើតស្លាប់សត្វលោក ព្រះអង្គបានធ្វើសេចក្តីបញ្ជាក់ថា វត្ថុធាតុណាកើតឡើងអំពីហេតុ វត្ថុធាតុនោះរមែងមានផលហេតុមួយៗជាធម្មធាតុមានកំរិតព្រំដែន ផលមួយៗគឺជាធម្មមានកំរិតព្រំដែនយ៉ាងទៀតទាត់ដូចគ្នា។ អ្នកណាធ្វើល្អនឹងបានល្អ អ្នកណាធ្វើអាក្រក់នឹងបានអាក្រក់ នេះគឺជាហេតុផលដ៏ទៀងទាត់នៃពុទ្ធសាសនា។ ចលនានៃលោកន័រតុន ក៏បានធ្វើសេចក្តីបញ្ជាក់ថា

រាល់ៗតែកិរិយានឹងមានប្រតិកិរិយាផ្ទុយគ្នាហើយប៉ុនគ្នា (To every action there is an equal and opposite Reaction) ចលនានេះ ខាងព្រះពុទ្ធមិនមែនប្រើត្រឹមខាងវិទ្យាសាស្ត្ររូបនិយមប៉ុណ្ណោះទេ តែប្រើបាននៅក្នុងផ្លូវសីលធម៌ផងហើយជារបស់សម្រាប់សត្វលោកគ្រប់គ្នាផង ។ ពុទ្ធសាសនាបញ្ជាក់ថាផលកម្មក្នុងជីវិតនេះ នឹងទៅជាកម្មផលក្នុងជីវិតខាងមុខ ដោយដៅឲ្យឃើញថាកម្មប្រៀបដូចស្ពានសម្រាប់ភ្ជាប់ជីវិតមួយ ទៅជីវិតមួយទៀត គឺបច្ចុប្បន្នកម្មគឺជាធាតុមានមកអំពីអតីតកម្ម អតីតកម្មជាធាតុទៅពីបច្ចុប្បន្នកម្ម

តួយ៉ាងទាំងឡាយដែលបានលើកមកនិយាយនេះ ដើម្បីសម្តែងឲ្យឃើញថាធម្មនៃពុទ្ធសាសនាមិនមានទំនាស់នឹងវិទ្យាសាស្ត្រទេ ឬ នឹងពោលមួយបែបទៀតថាពុទ្ធសាសនាជាសាសនាវិទ្យាសាស្ត្រក៏បាន ព្រោះសាសនានេះ បានរៀបចំឲ្យមានធម្មៈឡើង ដោយអាស្រ័យការពិសោធន៍នៃធម្មជាតិរបស់ព្រះពុទ្ធបរមគ្រូ ដែលគេបានស្គាល់គ្រប់គ្នាមកហើយ។

ព្រះពុទ្ធសាសនាមិនហួសសម័យទេ ព្រះពុទ្ធសាសនាឲ្យអត្ថាធិប្បាយយ៉ាងច្បាស់លាស់ក្នុងបញ្ហាធម្មជាតិ ដែលមានទាក់ទងជាមួយនឹងជីវិតទាំងអស់ ខ្ពស់ជាងនេះទៀត ពុទ្ធសាសនាបានសម្តែងចេញនូវមគ្គមានអង្គ៨ ប្រការជាផ្លូវនាំសត្វលោកទៅកាន់ត្រើយផុតទុក្ខគឺនិព្វាន ជាបញ្ហាដែលវិទ្យាសាស្ត្រឆ្លើយមិនរួចហើយដែលប្រជាជនក្នុងពិភពលោកកំពុងចាប់អារម្មណ៍យ៉ាងខ្លាំងបំផុត។

សរុបពាក្យក្នុងពុទ្ធសាសនា ក្នុងបញ្ហាដែលវិទ្យាសាស្ត្រមិនអាចឆ្លើយបានមានដូចនេះ : *យើងទាំងអស់គ្នាប្រព្រឹត្តទៅតាមកម្មដែលខ្លួនយើងបានធ្វើ ពិភពលោកប្រព្រឹត្តទៅតាមកម្មដែលចាត់ចែងឡើងដោយសង្ខារ ទាំងខ្លួនយើងទាំងពិភពលោកដើរតាមក្រោយកម្ម យើងមិនមានអត្តាប្រាណខ្លួនទៀតទាត់ យើងមិនមានវិញ្ញាណខ្ជាប់ខ្លួន ខ្លួនយើងត្រឹមតែជាផលរបស់កម្ម ជីវិតរបស់យើងត្រឹមតែជាសភាពពួតផ្គុំនៃធម្មជាតិ សឹងប្រកបដោយកម្មរាល់ៗជីវិត សភាពនៃជីវិតមានការទាក់ទងគ្នានៅក្នុងសង្សារវដ្ត ជាមនុស្សខ្លះ ជាសត្វខ្លះ ឬជាអ្វីខ្លះតាមផលរបស់កម្មសេចក្តីកើតសេចក្តីស្លាប់និងការសាងភពថ្មី វាជា*

*អការៈនៃក្រសែរបស់ជីវិត រាល់ៗជីវិតសឹងមានចលនាប្រែប្រួលអស់កាលជានិរន្តន៍ លុះពេលណាអស់កម្ម គឺមិនមានឧបាទានក្ខន្ធ មិនមានអវិជ្ជា មិនមានតណ្ហា ដែលសុទ្ធតែជាហេតុរបស់កម្មនិងជាហេតុឲ្យកើតសំណង់នៃវិញ្ញាណ កាលណាវិញ្ញាណរលត់អស់ក្រសែនៃជីវិតដាច់កាំនៃសង្សារវដ្តមិនមាន សេសសល់ នាមរូបក៏សូន្យបាត់ទៅដូចរលកទឹកត្រូវខ្ទប់ច្រាំង ហ្នឹងឯងគឺសម្រេចព្រះនិព្វាន។*

បញ្ហាចុងបំផុតដែលចោទថា មនុស្សយើងហេតុដូចម្ដេចទើបមិនដូចគ្នា បញ្ហានេះខាងវិទ្យាសាស្ត្រឆ្លើយមិនច្បាស់ តែព្រះពុទ្ធសាសនាឆ្លើយបានយ៉ាងច្បាស់ប្រកបដោយហេតុផលល្មមឲ្យយើងពិចារណាបាន គឺមនុស្សយើងផ្សេងគ្នាដោយ "**កម្ម**" ។ ក្នុងអភិណ្ហបច្ចវេក្ខណធម្មសូត្រ ព្រះសម្ពុទ្ធទ្រង់បានគូសបញ្ជាក់ថា "*មនុស្សមានកម្មជារបស់ខ្លួន មនុស្សជាទាយាទនៃកម្ម មនុស្សមានកម្មជាប្រភពនៃកំណើត មានកម្មជាវង្សត្រកូល មានកម្មជាទីរលឹកជាទីសង្ឃឹម*" មនុស្សសាងកម្មមិនដូចគ្នា ទើបមានលក្ខណៈមិនដូចគ្នា សូម្បីមនុស្សមានលក្ខណៈនៃកំណើតលក្ខណៈនៃជីវភាពផ្សេងគ្នាយ៉ាងណាក៏ដោយ តែមនុស្សទាំងអស់ក៏ដូចជាបងប្អូនបង្កើតនឹងគ្នា ព្រោះត្រូវរងទុក្ខទោសគ្រោះថ្នាក់ដូចគ្នា មានត្រៃលក្ខណ៍ប្រចាំខ្លួនដូចគ្នា ប្រព្រឹត្តទៅតាមអំណាចនៃកម្មដែលខ្លួនបានសាងដូចគ្នា មានថ្ងៃណាមួយខាងចុងបំផុតនៃជោគវាសនា មនុស្សគ្រប់គ្នានឹងបានឃើញសេចក្ដីពិតក្នុងអរិយសច្ចៈ ៤ នេះឯងគឺការសម្រេចព្រះនិព្វាន។

វិទ្យាសាស្ត្រមិនមានទាក់ទងខាងផ្លូវចិត្ត មិនអាចធ្វើឲ្យសត្វលោកដល់នូវទីបំផុតនៃសេចក្ដីទុក្ខ គឺនិព្វានបានទេ ។ តែវិទ្យាសាស្ត្រក៏មានគុណលើមនុស្សខាងវត្ថុក្នុងបច្ចុប្បន្នកាលជាអនេក ប្រសិនបើគេប្រើវត្ថុនៃវិទ្យាសាស្ត្រនៅក្នុងសប្បុរិសធម៌គឺគេយកធម្មៈរបស់ព្រះពុទ្ធបរមគ្រូទៅប្រើ ជាមួយនឹងវិញ្ញាណនៃមនុស្សទាំងអស់ដែលជាអ្នកបានរកឃើញនូវវត្ថុវិទ្យាសាស្ត្រ និងជាអ្នកប្រើប្រាស់វត្ថុវិទ្យាសាស្ត្រ ។

□□□

# បទទី ១២

# បញ្ហាវិលកើតវិលស្លាប់

ទោះជាយើងដឹងដោយអាស្រ័យគម្ពីរទាំងឡាយថា : ក្នុងពុទ្ធសម័យ មានមនុស្សទាំងបុរសទាំងស្ត្រីជាច្រើន បានសម្រេចជាព្រះហរន្ត បានដល់នូវនិព្វាននោះក៏ដោយ បញ្ហាកើតស្លាប់ក៏នៅតែមានក្នុងគ្រានោះ ។ សព្វថ្ងៃនេះ គេមិនបានដឹងច្បាស់ថា មានអរហន្តនៅក្នុងពិភពលោកត្រង់ភូមិភាគណាមួយឲ្យប្រាកដសោះឡើយ។ ដូច្នេះបញ្ហាកម្មនិងបញ្ហាកើតស្លាប់ ទើបទៅជាចំណុចសំខាន់របស់ព្រះពុទ្ធសាសនា។ ពុទ្ធសាសនិកទាំងឡាយមានជំនឿថា មនុស្សយើងកើតមកមានលក្ខណៈយ៉ាងណាៗ ស្រេចហើយតែកម្មដែលខ្លួនបានសាង ព្រោះសេចក្ដីល្ងង់ខ្លៅដឹងមិនដល់នូវសេចក្ដីពិតក្នុងសង្ខារដែលមិនទៀង ជាទុក្ខ និងជាអនត្តា ទើបភ័ន្តច្រឡំគំនិតនាំគ្នាធ្វើកម្ម សេចក្ដីខ្លៅល្ងង់នាំឲ្យឃើញខុសថា ខ្លួនទៀង ខ្លួនសុខ ខ្លួនមានអត្តា។ សេចក្ដីឃើញខុសនេះ ធ្វើឲ្យកើតតណ្ហា ឧបាទាន បណ្ដាលឲ្យមាន លោភៈ ទោសៈ មោហៈ សឹងសុទ្ធជាដើមហេតុនៃកម្ម កម្មនាំឲ្យយើងកើត នាំឲ្យយើងត្រឡប់ទៅកាន់ជីវិតថ្មីទៀត កាលណាយើងបានសងបំណុលកម្មអស់ យើងបានជំរះចិត្តឲ្យបរិសុទ្ធចាកកិលេសទាំងពួង គឺបានទម្លាយចោលនូវដើមហេតុរបស់កម្មឲ្យអស់ទៅ ហើយយើងមិនបានធ្វើកម្មទៅជាថ្មីទៀត កាលនោះយើងក៏បានដល់ទៅទីបំផុតនៃទុក្ខ។

ច្បាប់របស់កម្មនិងការអន្ទោលកើតស្លាប់ ជាសភាវៈតែមួយមិនអាចញែកចេញពីគ្នាបានទេ បើយើងជឿកម្ម យើងក៏ត្រូវជឿការអន្ទោលកើតស្លាប់ផង។ ពុទ្ធសាសនិកទាំងឡាយមិនចាំបាច់ ត្រូវយកច្បាប់នៃសេចក្ដីពិតខាងវិទ្យាសាស្ត្រមកបញ្ជាក់លើធម្មៈរបស់ព្រះបរមសាស្ត្ចារ្យ និងមិនចាំបាច់ត្រូវយកសេចក្ដីពិសោធន៍ខាងវិទ្យាសាស្ត្រមកពិសោធទៀតទេ ព្រោះពុទ្ធធម៌ទាំងមូលសុទ្ធតែមានមូលដ្ឋាននៃសេចក្ដីពិត សឹងព្រះអង្គត្រាស់ដឹងដោយសម្មសម្ពោធិញ្ញាណ ធម្មឱវាទរបស់ព្រះអង្គបានប្រតិស្ថាននៅលើល័ខគោលនៃ

"**អនិច្ចំ ទុក្ខំ អនត្តា**" ព្រមជាមួយគ្នានេះព្រះអង្គទ្រង់បានប្រមូលនូវគ្រប់រូបវត្ថុ និងអរូបវត្ថុ ដែលទ្រង់រកឃើញដោយសេចក្ដីត្រាស់ដឹងរបស់ព្រះអង្គ រួមចូលក្នុងអរិយសច្ចៈ ៤ គឺ "**ទុក្ខៈ សមុទយៈ និរោធៈ មគ្គៈ**" និង "**បដិច្ចសមុប្បាទ**" ដែលរាប់ថាជាសុទ្ធឱវាទរបស់ព្រះអង្គ។

ព្រះពុទ្ធបរមគ្រូនិងសាវកព្រះអង្គ បានត្រាស់ដឹងនូវសេចក្ដីពិត ដោយបានដើរតាមអរិយមគ្គមានអង្គ ៨ បានរួចផុតចាកទុកក្ខដោយកម្លាំងញាណ ឆ្លុះមើលឃើញច្បាស់ក្នុងអត្តភាពត្រង់ៗតែម្យ៉ាង។ តែជនក្នុងបស្ចិមប្រទេស តែងស្វែងរកសេចក្ដីពិតតាមកម្មវិធីច្រើនយ៉ាង ដោយការសង្កេតនិងការល្បងពិសោធតាមវិទ្យាសាស្ត្រដោយវិធីវាស់ចំនួនតាមគណិតសាស្ត្រ មានការប្រើគ្រឿងចក្រ គ្រឿងឧបករណ៍ទាំងឡាយ។ វិធីរកសេចក្ដីពិតតាមរបៀបនេះ ជាវិធីនាំឲ្យមានការយឺតយូរ តែអាចឲ្យសេចក្ដីចំរើនយ៉ាងច្រើនក្នុងផ្នែកការពេទ្យ គីមី និងវិទ្យាសាស្ត្ររូបនិយម។

វិទ្យាសាស្ត្របានផលិតគ្រឿងឧបករណ៍នានា ដើម្បីជួយធ្វើឲ្យអាយតនៈរបស់យើងវៃឆ្លាតឡើង តែធ្វើបានត្រឹមតែពង្រីកអាយតនៈធម្មតាឲ្យទូលាយឡើងលើសប្រក្រតីប៉ុណ្ណោះ ហួសទៅខាងក្រៅព្រំដែននៃអាណាខែត្រ ដែលអ្នកវិទ្យាសាស្ត្រពង្រីកនោះ យើងមិនអាចប្រើកម្លាំងអ្វីឲ្យដឹងបានទេ។ មនុស្សយើងដឹងសេចក្ដីពិតនៅក្នុងកំរិតព្រំដែន គឺអាចមើលឃើញសាកលលោកបានដោយចំពោះ ដោយចំណែកដែលវិទ្យាសាស្ត្របានពង្រីកអាណាខែត្រអាយតនៈ ឲ្យទូលាយឡើង នុ៎ះឯង។

អ្នកវិទ្យាសាស្ត្រកំពុងយកចិត្តទុកដាក់ថា : ខ្លួននឹងអាចធ្វើឲ្យអាយតនៈទាំងអស់ មានគុណភាពមោះមុតស្រួចស្រាល់ឡើយដរាប ដល់ធ្វើឲ្យមនុស្សដឹងសេចក្ដីពិតបានច្រើនជាងដែលបានដឹងដោយគ្រឿងឧបករណ៍វិទ្យា សាស្ត្រសព្វថ្ងៃនេះ ។ តែនឹងបានសម្រេចឬមិនបានសម្រេចនោះ មានតែអនាគតកាលទេទើបទាយត្រូវ ដោយការរាវរកស្មាននិងការសង្ស័យក្នុងទំហើររបស់ខ្លួននោះហើយ ទើបអ្នកវិទ្យាសាស្ត្រខ្លះងាកត្រឡប់មកយកចិត្តទុកដាក់ខាងចិត្តសាត្រ

វិញ។

ការណ៍ពិតដែលថា : មានមនុស្សសាមញ្ញមានភ្នែកទិព្វ អាចមើលឃើញរបស់ទាំងឡាយដែលមិនបាននៅចំពោះមុខអាយតនៈនោះ ក៏ល្មមយកមកធ្វើជាសេចក្តីបញ្ជាក់បានថា : មនុស្សយើងអាចនឹងឃើញសេចក្តីពិតបានដោយកម្មវិធីដទៃ ក្រៅពីមនោសញ្ចេតនាខាងអាយតនៈ ។

អ្នកប្រាជ្ញមួយពួកទៀត បានរកឃើញភាពប្រាកដជាក់ស្តែងនៃចិត្ត ដែលកើតមានឡើងតាមមនោសញ្ចេតនា ដោយអាស្រ័យការល្បងពិសោធខាងសង្កត់ចិត្ត ឬប្រមូលផ្តុំចិត្ត ហើយបានធ្វើការបញ្ជាក់តាមសេចក្តីពិតថា ដោយអាស្រ័យអំណាចនៃការប្រមូលពូតផ្តុះចិត្ត (សមាធិចិត្ត) មនុស្សយើងអាចរករលឹកឃើញហេតុការណ៍ទាំងឡាយ តាំងពីមានវ័យនៅក្មេងបាត់អស់ទៅហើយជាថ្មីម្តងទៀត។ សព្វថ្ងៃនេះខាងពេទ្យក៏បានប្រើវិធីប្រមូលផ្តុំចិត្ត ឬសង្កត់ចិត្តដោយចាក់ថ្នាំឲ្យមនុស្សមានជម្ងឺដេកលក់ ដើម្បីធ្វើការរាវរកអាការៈរោគក្នុងរូបកាយ វិធីនេះគេច្រើនធ្វើចំពោះរោគ ដែលមានទាក់ទងខាងផ្លូវចិត្ត។

ក្រៅអំពីនេះ អ្នកវិទ្យាសាស្ត្រ បានល្បងពិសោធ (Aggression) រឿងរលឹកឃើញហេតុការណ៍ទៅខាងក្រោយនៃមនុស្ស បានតាមរយៈអាយុកាល គេបានរកឃើញថា : ដោយអាស្រ័យអំណាចនៃការប្រមូលពូតផ្តុំចិត្ត និងការសង្កត់ចិត្តឲ្យនៅក្នុងអារម្មណ៍តែមួយ មនុស្សយើងអាចអន្ទងទាញគំនិតក្នុងវ័យក្មេងៗ ឲ្យត្រឡប់មកវិញម្តងទៀតបាន គេអាចសរសេរឈ្មោះរបស់គេក្នុងវ័យ ១០០ឆ្នាំ ៦ឆ្នាំរហូតដល់អាយុ ៣ឆ្នាំបាន តែតួអក្សរដែលគេសរសេរនោះមិនប្រាកដជាតួអ្វីៗឡើយ។

ដូច្នេះ ទើបឃើញថាចិត្តសាស្ត្របច្ចុប្បន្ន បានល្បងពិសោធន៍ឃើញថា មនុស្សមិនមែនមានត្រឹមតែចិត្តសម្រាប់គិតនឹកធម្មតាប៉ុណ្ណោះទេ គឺនៅមានចិត្តមួយចំណែកទៀត ដែលអាចដឹងបានដូចគ្នា តែមិនប្រាកដដោយភាព។ ចិត្តនេះធ្លាប់បានសន្សំអារម្មណ៍ និងចេះចាំហេតុការណ៍ទាំងឡាយតាំងតែពីកើតមក អស់រយៈកាលយ៉ាងវែងទៀតផង។

ដោយសំអាងលើពន្លឺនៃចិត្តសាស្រ្តបច្ចុប្បន្ននេះ អ្នកវិទ្យាសាស្រ្តគួរតែធ្វើសេចក្តីចូលចិត្តដល់គំនិតនៃពុទ្ធសាសនាក្នុងរឿងអន្ទោលកើតស្លាប់ កុំគប្បីសង្ស័យឡើយ។ ចិត្តចំណែកមួយដែលចេះដឹង ស្គាល់អារម្មណ៍បានដោយមិនប្រាកដដោយភាពនោះមិនមែនមាននាទីត្រឹមតែសន្សំសេចក្តីចេះចាំរឿងរ៉ាវ អំពីវ័យក្មេងៗប៉ុណ្ណោះទេ។ ចិត្តភាពនេះអាចសន្សំរឿងរ៉ាវ ដែលប្រព្រឹត្តទៅក្នុងអតីតជាតិទាំងអស់បានទៀតផង ដោយន័យថា : ចិត្តភាពនេះបានកាន់កាប់រក្សាទុកនូវកម្មដែលសល់ពុំទាន់ឲ្យផលក្នុងជាតិមុននុ៎ះឯង។

ព្រះពុទ្ធសាសនា បានទទួលស្គាល់ថា : មនុស្សស្លាប់ហើយមិនមានរបស់អ្វីសលនៅឡើយ ក្រៅតែអំពីកម្មដែលខ្លួនបានធ្វើ កម្មនេះជាហេតុឲ្យមានកំណើតថ្មីទៀត។ កាលណាបើយើងនិយាយឲ្យស្របគ្នាតាមគតិនៃចិត្តសាស្រ្តនោះ យើងត្រូវនិយាយថា : កម្មដែលនៅសេសសល់អំពីការឲ្យផលនោះ ជាធម្មធាតុមកកកំណើតបានជានិត្តមួយចំណែក ដែលមានមនោសញ្ចេតនាសម្រាប់ដឹងនូវអ្វីៗទាំងអស់បានតែមិនប្រាកដភាពក្នុងរូបរាងថ្មីឡើយ។ ព្រះពុទ្ធបរមគ្រូទ្រង់បញ្ជាក់ថា : វិញ្ញាណដែលកើតក្នុងផ្ទៃមាតានោះ មិនមែនមាននាទីត្រឹមតែឲ្យកំណើតថ្មីប៉ុណ្ណោះទេ គឺមាននាទីជួយទំនុកបំរុងរូបរាងកាយឲ្យចំរើនធំធាត់ឡើងតាមលំដាប់ ដរាបលុះដល់វិញ្ញាណនោះអស់ ពេលដែលត្រូវរីកចំរើនធំធាត់ឡើងតាមលំដាប់ ដរាបលុះដល់វិញ្ញាណនោះអស់ ពេលដែលត្រូវរីកចំរើនវាក៏ស្លាយតួទៅក្នុងទីបំផុត។ វិញ្ញាណដែលបានស៊ីមកហើយនោះ មិនមែនជាអ្វីដទៃ គឺជាចិត្តដែលមិនប្រាកដដោយភាពបានដល់កម្មមួយចំណែកដែលសេសសល់មកអំពីការកំណើតថ្មីនុ៎ះឯង។

ដូច្នេះឃើញថា : មនុស្សយើងចាប់តាំងពីបដិសន្ធិក្នុងផ្ទៃម្តាយ រហូតដល់ថ្ងៃសម្រាលចេញ ចិត្តមួយចំណែកដែលមានមនោសញ្ចេតនាតាមធម្មតានោះសន្សឹមៗរីកចំរើនឡើង ប្រាកដឡើងតាមលំដាប់ ។ តែមានភាពមួយចំណែកទៀត ដែលមានមនោសញ្ចេតនាមិនប្រាកដនៅឡើយនោះ ក៏ជាភាពអែបជ្រកយ៉ាងជ្រៅនៅក្នុងទីជាមួយគ្នានោះដែរ។ ចិត្តភាពនេះនេះសន្សំកម្មក្នុងអតិត

ហើយកម្មនេះក៏សល់នៅពុំទាន់អស់នៅឡើយ សំណល់របស់កម្មនៃចិត្តភាពនេះ មាននាទីបញ្ជាការឲ្យចិត្តភាពដែលប្រាកដតួប្រព្រឹត្តទៅតាមគោលបំណងនៃជីវិតទាំងឡាយ ទាំងក្នុងអតីតជាតិទាំងក្នុងបច្ចុប្បន្នជាតិ តាមអំណាចម្យ៉ាងដែលខាងចិត្តសាស្ត្រហៅថា សេចក្តីត្រូវការដោយមិនដឹងខ្លួន (Unconscious wishes) តាំងពីក្មេងតូចរហូតមកដល់សព្វថ្ងៃនេះ ។

អាស្រ័យហេតុដូចពោលមកនេះ ព្រះពុទ្ធបរមគ្រូរបស់យើង ទើបទ្រង់សំដែងអំពីតម្លៃនៃសមាធិភាវនាថា ជាគុណធម៌អាចធ្វើបុគ្គលអ្នកចំរើនឲ្យបានដឹងច្បាស់នូវហេតុការណ៍ដែលកន្លងទៅហើយ ដឹងដល់សេចក្តីទុក្ខទាំងឡាយសឹងកើតពីកម្មដែលខ្លួនបានធ្វើ ខាងចុងបំផុតអាចធ្វើឲ្យបុគ្គលអ្នកប្រព្រឹត្តរួចផុតចាកកំឡៅនិងជំនឿងាយៗ ថាខ្លួនមានអត្តា។ រួចផុតចាករាគៈ ទោសៈ មោហៈ និងឧបាទានក្ខន្ធ សម្រេចនូវវិមុត្តិសុខ ផុតកងទុក្ខទាំងអស់រួមជាមួយនឹងការអន្ទោលកើតស្លាប់ផង។

វិទ្យាសាស្ត្រទើបតែនឹងបានរកឃើញថាមពលបរមាណូ ដែលយើងបានដឹងឮគ្រប់គ្នាសព្វថ្ងៃនេះ ការល្បងពិសោធរបស់គេក្នុងផ្នែកនេះ អាចនឹងបានជាធាតុមួយជួយគាំទ្រធម្មៈរបស់ព្រះសម្មាសម្ពុទ្ធ ត្រង់ចំណុចដែលស្តីដោយអនិច្ចំ មានន័យថា : អរូបធាតុទាំងអស់មិនទៀង មានចលនាប្រែប្រួលអស់កាលជានិរន្តន៍។

អ្នកប្រាជ្ញចិត្តសាស្ត្រ ក៏បានរកឃើញនូវចំណែករបស់ចិត្ត ដែលចេះដឹងស្គាល់អារម្មណ៍បាន តែមិនប្រាកដដោយភាពថាជារបស់មាននោះដែរ។ ក្នុងអនាគតកាល គេអាចល្បងពិសោធរក "**ការអន្ទោលកើតស្លាប់**" ថាជារបស់មានពិតប្រាកដមិនខានឡើយ។ ដោយអាស្រ័យការពិសោធន៍និងការស្រាវជ្រាវរកសេចក្តីចេះចាំរបស់មនុស្សត្រឡប់ថយទៅក្រោយតាមលំដាប់អាយុ ឬតាមកម្មវិធីនៃចិត្តសាស្ត្រដទៃៗទៀត។ ការពិសោធន៍ "**សេចក្តីអន្ទោលកើតស្លាប់**" តាមល័ខគោលវិជ្ជាគឺជាការមួយអាចកំចាត់ចង់នូវឧបសគ្គក្នុងចំណុចចុងបំផុតដែលជាធាតុមានទំនាស់នឹងធម្មៈនៃពុទ្ធសាសនា នឹងជា

ការផ្តល់ឲ្យនូវសន្តិសុខខាងផ្លូវចិត្តនៃប្រជាជនទាំងឡាយ រួមទាំងជនសម័យថ្មីផង។

□ □

□

# បទទី ១៣

# ស្លាប់ហើយកើតយ៉ាងម៉េច?

*ច្បាប់នៃកម្មនិងការអន្ទោលកើតស្លាប់ ជាធម្មៈសំខាន់បំផុតនៃពុទ្ធសាសនា* ធម្មៈពីរម៉ាត់នេះ មានការដោះស្រាយមកគ្រប់សម័យ តែការស្លាប់ហើយកើតយ៉ាងម៉េច? មិនមានអ្នកណាអាចធ្វើអត្ថាធិប្បាយឲ្យបានច្បាស់លាស់សមហេតុផលឡើយ។ ក្នុងព្រះត្រៃបិដកក៏មិនឃើញមានចម្លើយរបស់ព្រះពុទ្ធបរមគ្រូចំពោះសំណួរនេះចំៗឡើយ។ ក្នុងពេលនោះប្រហែលជាមិនមានអ្នកណាទូលសួរព្រះពុទ្ធអង្គត្រង់ចំណុចថា "**កើតថ្មីយ៉ាងម៉េច?**" ឬមួយមានគេសួរចំចំណុចនេះដែរ តែខ្ញុំរកមិនជួបក៏មិនដឹង។ តែទោះជាយ៉ាងណាក៏គង់មានសំណួរនិងចម្លើយ ដែលទាក់ទងជាមួយនឹងរឿងនេះដោយច្រើនដែរ ដែលមានហេតុផលហុចមកឲ្យគំនិតយើង ក្នុងពេលកំពុងពិចារណារឿងនេះ។

ក្នុងព្រះត្រៃបិដក ខ្ញុំបានជួបសំនួរទាំងឡាយនៃឧបាសក ឧបាសិការនិងភិក្ខុខ្លះបានទូលសួរព្រះសម្ពុទ្ធបរមគ្រូថា : មនុស្សយើងមានវិញ្ញាណឬទេ? វិញ្ញាណនោះមានសភាវៈមាំមួនឬទេ? កម្មឲ្យគុណឲ្យទោសដល់អ្នកប្រព្រឹត្តយ៉ាងណា? ឧបាទានក្ខន្ធមានលក្ខណៈយ៉ាងម៉េច? មនុស្សយើងមានអត្តាពិតប្រាកដឬមិនមានទេ? ក្រៅពីនេះមានសំណួរច្រើនទៀត ដែលសុទ្ធតែជាសំណួរទាក់ទងជាមួយនឹងធម្មៈនៃព្រះបរមសាស្ត្រាចារ្យ ។ ចំពោះសំណួរអស់ទាំងនេះ ព្រះសម្ពុទ្ធទ្រង់ឆ្លើយតបដោយត្រង់ៗក៏មាន ឆ្លើយតបដោយប្រៀបធៀបក៏មាន ដោយព្រះអង្គទ្រង់បញ្ជាក់ថាវិញ្ញាណមាន វិញ្ញាណមិនមានសភាវៈខ្ជាប់ខ្ជួនទេ មិនមានអត្តាខ្លួនប្រាណនៅក្នុងក្ខន្ធប្រាំ ដែលគេប្រកាន់ថាជាសក្កាយៈដោយកម្លៅ។ ការណ៍ពិតជីវិតជាក្រសែប្រកបដោយកម្មមានហេតុផល កម្មកើតមកពីអវិជ្ជាតណ្ហាដែលជាហេតុធ្វើសត្វឲ្យអន្ទោលកើតស្លាប់ក្នុងសង្សារវដ្តជាដរាប លុះអស់អំណាចនៃកម្ម ទើបអស់សេចក្តីកើតស្លាប់។

ក្នុងពេលស្លាប់ ខន្ធទាំង៥ ក៏រលត់អស់ទៅ មិនមានអ្វីឆ្លងទៅកាន់ជីវិតថ្មីទេសូម្បីតែវិញ្ញាណក៏ពុំបានឆ្លងទៅដែរ តែផលរបស់កម្មបញ្ជូនឲ្យទៅកើតទៀតដោយន័យថា កម្មបានសាកបំបៅខន្ធចាស់ឲ្យកើតជាខន្ធថ្មី[១] ឡើងទៀត។

ក្នុងព្រះត្រៃបិដក មានចម្លើយជាច្រើនដែលមានទាក់ទងជាមួយនឹងសំណួរថា "**ស្លាប់ហើយកើតយ៉ាងម៉េច?**" នឹងស្រង់យកមកនិយាយខ្លះ ដូចមានតទៅនេះ :

**១- ក្នុងមិលន្ទបញ្ហា** មាននិយាយយ៉ាងខ្លីថា "**នាមរូប**" បានធ្វើកុសលអកុសល។ កម្មទាំងអស់នេះជាហេតុឲ្យកើតនាមរូបថ្មីឡើងទៀត។

**២- ក្នុងមហាតណ្ហាសង្ខយសូត្រនៃមជ្ឈិមនិកាយ** មានសេចក្តីបញ្ជាក់យ៉ាងច្បាស់ថា : សត្វដែលកើតឡើងបានត្រូវប្រកបដោយ :

ក- បិតានិងមាតារួមសេវនកិច្ច

ខ- មានតាកំពុងមានរដូវបរិបូណ៌

គ- មានគន្ធព្វសត្វ (សត្វចាប់ផ្ទៃ) ទើបជីវិតអាចកើតឡើងបាន។

**៣- ក្នុងមហានិព្វានសូត្រនៃឃីននិកាយ** ព្រះបរមសាស្ត្រាចារ្យរបស់យើងទ្រង់បានធ្វើសេចក្តីអធិប្បាយអំពីបដិច្ចសមុប្បាទ ឲ្យអានន្ទស្តាប់មានសេចក្តីក្នុងចំណុចមួយថា បើវិញ្ញាណមិនចូលកាន់ថង់កូននៃមាតា នាមរូបនឹងកើតយ៉ាងម៉េចបាន បើវិញ្ញាណដែលហូរចូលទៅកាន់សំបុកកូនមាតានោះត្រឡប់ដកខ្លួនចេញមកវិញ កូនក្នុងគ៌ភនោះ នឹងចំរើនធំធាត់បានយ៉ាងណា" ។

**៤- ក្នុងបាយាសិសូត្រនៃទីឃនិកាយ** មានសេចក្តីមួយអន្លើថា : មនុស្សយើងត្រូវមានការអប់កំដៅ ទើបវិញ្ញាណអាចនឹងតាំងនៅបាន។

**៥- ក្នុងកេវដ្តសូត្រនៃទីឃនិកាយ** ព្រះបរមគ្រូទ្រង់តាំងសំណួរថា : ដីទឹក ភ្លើង ខ្យល់ រលត់ក្នុងទីណា? ទ្រង់តបសំណួររបស់ព្រះអង្គថា : រលត់ក្នុងទីព្រះនិព្វាន ដោយអត្ថថាវិញ្ញាណក្នុងគ្រប់ជីវិតទាំងអស់ត្រូវរលត់សូន្យទៅ មិនមានកម្មបញ្ជូនឲ្យទៅកើតថ្មីក្នុងទីណាទៀត ទើបមានឈ្មោះថា **សម្រេចព្រះនិព្វាន។**

**៦- ក្នុងអច្ឆរិយពុទ្ធធម្មសូត្រនៃមជ្ឈិមនិកាយ** ព្រះអានន្ទបានពោលដល់រឿងព្រះសម្ពុទ្ធថា : ព្រះពុទ្ធអង្គទ្រង់បានជ្រាបថា មុននឹងចូលកាន់ផ្ទៃព្រះ

មាតា ព្រះអង្គទ្រង់ធ្លាប់កើតក្នុងសួគ៌វិមាស។ ដូច្នេះ ឃើញថា សត្វដែលនឹងអាចកើតឡើងបាន ត្រូវមានវិញ្ញាណទើបកើតបាន ។

តាមសូត្រដែលពោលមកខាងលើនេះទាំងប៉ុន្មាន មានសេចក្ដីល្មមឲ្យយើងសន្និដ្ឋានប្រកបដោយហេតុផលថា : មនុស្សយើងស្លាប់ហើយត្រូវកើតទៀតយ៉ាងម៉េចនោះហើយ។ ម្យ៉ាងទៀត យើងបានដឹងចាកមិលិន្ទបញ្ហានិងសូត្រដទៃទៀតថា : *វិញ្ញាណរបស់សត្វដែលនឹងមកកើតនោះ មិនមែនជាវិញ្ញាណក្នុងជីវិតមុនៗដោយដាច់ខាត ព្រោះព្រះពុទ្ធអង្គទ្រង់បានដៅបញ្ជាក់រឿយៗថា : ខន្ធ ៥រលត់ទៅរាល់ៗខណៈដែលជីវិតត្រូវរលត់* ។ ដោយហេតុនេះ វិញ្ញាណរបស់សត្វដែលនឹងមកកើតនោះ ត្រូវវិញ្ញាណមួយថ្មី ដែលកើតមកអំពីកម្មចាស់ គឺកើតក្នុងខ្លួនរបស់អ្នកដែលនឹងមកកើតនុ៎ះឯង។ វាជាធាតុកើតចាកអវិជ្ជានិងតណ្ហា ដែលមានមកជាមួយនឹងកម្មចាស់ សឹងជាហេតុនៃសេចក្ដីទុក្ខនិងសេចក្ដីអន្ទោលកើតស្លាប់ ដែលបាននិយាយមកហើយ។

វិញ្ញាណរបស់សត្វដែលនឹងមកកើតនោះ ផ្សេងពីវិញ្ញាណដែលធ្លាប់មានមកក្នុងកាលមុន គឺវិញ្ញាណនេះមានលក្ខណៈសមស្ងួន និងសំណល់របស់កម្មដែលខ្លួនបានកសាងមកនុ៎ះឯង។ វិញ្ញាណនុ៎ះឯងហើយ ដែលចូលមកនៅក្នុងថង់កូនរបស់មាតាហើយសាងនាមរូបឡើងជាថ្មីទៀត។

□ □
□

# បទនី ១៤

# ការរស់នៅក្នុងលទ្ធិខ្លះនិងការគ្រងជីវិត តាមផ្លូវនៃព្រះពុទ្ធសាសនារបស់យើង

សេចក្ដីចំរើនខាងឧស្សាហកម្ម និងការរីកដុះដាលយ៉ាងឆាប់រហ័សនៃវិទ្យាសាស្ត្រ បានធ្វើឲ្យរាជធានីភ្នំពេញរបស់យើង បានក្លាយទៅជាសូន្យកណ្ដាលនៃការគមនាគមន៍មួយយ៉ាងសំខាន់ អាចឲ្យយើងធ្វើការទាក់ទងជាមួយនឹងប្រទេសទាំងអស់ក្នុងពិភពលោកបានយ៉ាងស្រួល ហើយប្រើវេលាត្រឹមតែរាប់ម៉ោងនិងថ្ងៃប៉ុណ្ណោះ។

ក្នុងមួយថ្ងៃៗ ប្រទេសយើងមានយន្តហោះច្រើនគ្រឿង ច្រើនខ្សែចុះចតក្នុងរាជធានី។ យន្តហោះទាំងនោះ បានដឹកនាំជនបរទេសជាគណៈទេសចរគណៈអង្គទូតនិងគណៈប្រតិភូ មកប្រាស្រ័យទាក់ទងការជាមួយនឹងយើង។ ក្រៅពីនេះមានពាណិជ្ជករ និងអ្នកនយោបាយពិសេសគ្រប់ពណ៌សម្បុរ ដែលមានឧបនិស្ស័យមិនគួរឲ្យទុកចិត្ត និងមិនជាទីប៉ងប្រាថ្នារបស់ប្រទេស ក៏បានមកកាន់ប្រទេសយើងដោយច្រើនដែរ។ ក្នុងចំណោមបុគ្គលទាំងអស់នោះ អាចនឹងមានបុគ្គលខ្លះឆ្លៀតឱកាសឃោសនាផ្សាយគំនិតរបស់ខ្លួន ដឹកនាំឲ្យប្រជាជាតិយើងធ្វើការបដិវត្តន៍នូវរបៀបគ្រប់គ្រង ញុះញង់ប្រជាជនឲ្យស្អប់ខ្ពើមការបែងជាន់វណ្ណៈ។ គេទាំងឡាយខ្លះមុខជានឹងព្យាយាមធ្វើឲ្យប្រជាជាតិអស់ជំនឿក្នុងធម្មៈនៃពុទ្ធសាសនា អស់សេចក្ដីទៀងត្រង់ស្លូតបូតដែលធ្លាប់មានចំពោះប្រទេស ពោលដោយសង្ខេប គឺគេព្យាយាមដកឫសគល់នៃជីវិត ដែលយើងធ្លាប់រស់រួមគ្នាអស់កាលច្រើនសតវត្សរ៍ជាមួយនឹងព្រះពុទ្ធសាសនា ឲ្យរលាយស្លាយទៅ។ ការដុតកំដៅខាងផ្លូវចិត្តដែលគេធ្លាប់ធ្វើមកហើយក្នុងប្រទេសនានានោះ គឺជាវត្ថុបំណងរបស់គេ គេធ្វើឲ្យកាន់តែលំបាកតឹងតែងដល់

ការរក្សារបៀបស្ងប់រៀបរយខាងក្នុងប្រទេសរបស់យើង ដែលធ្លាប់មានកេរ្តិ៍ឈ្មោះលេចឮថា ជាប្រទេសសុខស្ងប់ប្រកបដោយសេចក្តីជ្រះថ្លារីករាយយ៉ាងត្រចះត្រចង់។

កាលណាយើងត្រូវឈមមុខចំពោះគ្រោះថ្នាក់ដូចនេះ ការជាចាំបាច់ដែលយើងត្រូវធ្វើ គឺឃុំគ្រងសតិសម្បជញ្ញៈរបស់ខ្លួនឲ្យបានរឹងប៉ឹង គឺត្រូវឈមមុខចំពោះការពិតដោយប្រើគំនិតយ៉ាងល្អិតល្អន់ និងប្រើបញ្ញាយ៉ាងសុខុមពិចារណាមើលហេតុការណ៍ទាំងនោះឲ្យបានជិតដល់។ គ្រោះល្អណាស់ដែលប្រទេសយើង មិនមែនត្រឹមតែជាប្រទេសនៅក្នុងថ្នាក់ឧត្តម សម្បូរណ៍ដោយសម្បត្តិធម្មជាតិដែលជាចាំបាច់ដល់ជីវិតប៉ុណ្ណោះទេ។ តែជាប្រទេសដែលប្រជាជាតិមានជំនឿយ៉ាងខ្លាំងក្លាក្នុងព្រះពុទ្ធសាសនា ហើយជំនឿយ៉ាងបរិសុទ្ធទៀតផង។ យើងត្រូវបានអប់រំហ្វឹកហាត់មករឿយៗ មិនឲ្យជឿក្នុងវត្ថុផ្សេងៗយ៉ាងងាយ សូម្បីតែធម្មៈរបស់ព្រះសម្ពុទ្ធឯង ក៏ត្រូវជឿដោយត្រិះរិះពិចារណាជាមុន យើងត្រូវបានអប់រំឲ្យច្រើនតុល្យពិនិត្យរបស់ខ្លួនក្នុងការសំរេចនូវជំនឿ យោសនិកនៃពុទ្ធសាសនា រំលឹកឲ្យយើងដាក់ជំនឿក្នុងធម្មៈនៃពុទ្ធសាសនា នៅក្រោមសេចក្តីពិចារណារបស់យើង រំលឹកឲ្យជឿធម្មៈតាមសេចក្តីពិត មិនមែនឲ្យជឿតាមពាក្យឃោសនាក្លែងបន្លំទេ។ ក្នុងឋានៈនៃខ្លួនយើង ជាពុទ្ធសាសនិកពិតៗ យើងត្រូវសម្លឹងមើលអនាគតឲ្យបានយ៉ាងវែងឆ្ងាយ យើងត្រូវមើលឲ្យខ្ពស់ហួសពាក្យបោកបញ្ឆោតនានា សឹងពួកលទ្ធិនានាបានឃោសនាយ៉ាងពិរោះ ហើយយើងអាចនឹងវិនិច្ឆ័យដោយខ្លួនឯងថា : នៅក្នុងលទ្ធិទាំងនោះមានអ្វីខ្លះជាចំណែកល្អនិងមានអ្វីខ្លះជាចំណែកអាក្រក់។

ចំណែកពុទ្ធសាសនិកជើងចាស់ ក៏មិនគួរនឹងសម្រេចសេចក្តីថាលទ្ធិណាមានសភាពសមគួរនិងមិនសមគួរដល់ជនពួកណាមួយៗទេ។ តែយើងត្រូវរលឹកឃើញរឿយៗថា គោលសំខាន់របស់លទ្ធិខ្លះនោះ មានសេចក្តីទំនាស់នឹងវិថីរបស់ជីវិតនៃពុទ្ធសាសនិក ហើយមានឧត្តមគតិផ្ទុយគ្នាពីឧត្តមគតិនៃពុទ្ធសាសនារបស់យើង។ ដូច្នេះយើងមិនអាចលើកយកលទ្ធិណាមួយ មកប្រតិបត្តិបានទេ ប្រសិនបើលទ្ធិទាំងនោះនៅតែខ្វែងយោបល់គ្នាដោយរបបគ្រប់គ្រង។

ព្រោះអ្វី? ព្រោះជំនឿរបស់យើងក៏បានចាក់ឫសយ៉ាងជ្រៅទៅក្នុងពុទ្ធធម៌ថា "ធ្វើល្អបានល្អ ធ្វើអាក្រក់បានអាក្រក់" ជាស្រេចទៅហើយ។ ចំណែកលទ្ធិទាំងឡាយខ្លះ ដែលយើងធ្លាប់ដឹងមកសុទ្ធសឹងជាលទ្ធិពុំមានមនុស្សធម៌យ៉ាងធំទូលាយ ដូចពុទ្ធសាសនារបស់យើងទេជាពិសេសមានលទ្ធិខ្លះបង្រៀនឲ្យគ្រប់គ្រងប្រទេស ដោយប្រើកម្លាំងបង្ខាប់យ៉ាងទារុណក៏មាន។

ឧត្តមគតិនៃលទ្ធិខ្លះត្រូវការឲ្យមនុស្សគ្រប់គ្នា មានគ្រឿងឧបភោគបរិភោគគ្រប់គ្រាន់ ត្រូវការឲ្យមនុស្សមានជីវភាពខ្ពស់ ដើម្បីឲ្យសម្រេចផលតាមឧត្តមគតិនោះគេត្រូវធ្វើការតាមកម្មវិធីតទៅនេះគឺ :

១- បង្រៀនឲ្យស្អប់ខ្ពើមការបែងជាន់វណ្ណៈ ញុះញង់ឲ្យស្អប់ជនដែលសន្សំទ្រព្យទុកជាប្រយោជន៍ផ្ទាល់ខ្លួន វត្ថុបំណងនៃលទ្ធិខ្លះ គឺដឹកនាំអ្នកក្រខ្សត់ទូទៅឲ្យធ្វើការបដិវត្តន៍ទំលាក់របបចាស់ ។ ឧត្តមគតិរបស់គេ គឺធ្វើការបដិវត្តន៍ទូទៅក្នុងពិភពលោក គ្រប់គ្រងពិភពលោកនៅក្រោមអំណាចបញ្ជាការ នៃប្រទេសដែលបានធ្វើការបដិវត្តន៍មុនគេ ។

២- លទ្ធិខ្លះ ត្រូវការបោសសំអាតសាសនាទាំងអស់ មិនថាជាសាសនាជាសាសនាណា គេថាសាសនាផ្សេងៗមនុស្សបូរាណបង្កើតឡើងសម្រាប់មនុស្សទន់ខ្សោយ និងមនុស្សមានចិត្តទ្បេះទ្បោះរវើរវាយប៉ុណ្ណោះ។ គេបញ្ជាក់យ៉ាងច្បាស់ថានេះមិនមានសីលធម៌ខ្ពង់ខ្ពស់ មិនមានសេចក្តីប្រព្រឹត្តល្អចំពោះមនុស្សជាតិយ៉ាងប្រសើរវិសេស មិនមានការស្នេហាកិត្តិយសនៃមនុស្សគ្រប់កាលសម័យ មិនមានគុណធម៌អ្វីមុខគួរឲ្យសរសើរក្នុងមនុស្សជាតិ ក្រៅអំពីសេចក្តីប៉ងប្រាថ្នាធ្វើឲ្យមនុស្សរស់នៅក្នុងលោកបច្ចុប្បន្នមួយមុខប៉ុណ្ណោះ ។ លទ្ធិនេះ មិនព្រមឲ្យកិត្តិយសដល់មនុស្សដែលមានគុណធម៌ខាងផ្លូវចិត្ត មិនយកចិត្តទុកដាក់ចំពោះសេចក្តីព្យាយាមលះបង់កិលេសដើម្បី សម្រេចនិព្វាន និងមិនចូលចិត្តដល់ការធ្វើឲ្យកើតបញ្ញាយ៉ាងស្រួចស្រាល់ក្នុងធម្មៈនៃ ពុទ្ធសាសនារបស់យើង។

៣- ពលរដ្ឋគ្រប់ប្រភេទ ត្រូវបានគេបង្ខាប់ឲ្យធ្វើការតាមកម្លាំងសមត្ថភាពក្នុងមុខការរៀងរាល់ខ្លួន កម្មករទាំងអស់នោះត្រូវបានចែកចេញជា ពួកៗ

ដូចជាពួកកសិករ ពួកឧស្សាហករ ពួកវិញ្ញាណករ ។ល។ រដ្ឋមានអំណាចខ្ពង់ខ្ពស់បំផុតរដ្ឋប្រើឲ្យពួកកម្មករទាំងអស់នោះ ធ្វើការយ៉ាងមិនមានត្រាប្រណីផលិតផលរបស់កម្មករ ត្រូវប្រគល់ឲ្យរដ្ឋទាំងអស់ កម្មករម្នាក់ៗត្រូវបានទទួលកំរៃត្រឹមតែចិញ្ចឹមជីវិតរបស់ប៉ុណ្ណោះ ឬក៏បានប្រាក់ខែតាមដែលរដ្ឋកំណត់ឲ្យច្រើនតិចតាមកម្លាំងសមត្ថភាពនិងកម្លាំងធន់ទ្រាំប្រកបការងារ។ ជនទាំងឡាយនឹងសន្សំទ្រព្យសម្បត្តិ ផ្ទះសំបែងទីដីទុកសម្រាប់ប្រើប្រាស់ផ្ទាល់ខ្លួនពុំបាន ក្នុងពេលធ្វើការនិងពេលរស់នៅប្រចាំថ្ងៃរដ្ឋធ្វើការពិនិត្យត្រួតត្រាយ៉ាងតឹងរឹង។

៤- ដើម្បីឲ្យកិច្ចការប្រព្រឹត្តទៅបានយ៉ាងដាច់ខាត រដ្ឋបានចាត់តាំងឲ្យមានតម្រួតសម្ងាត់យ៉ាងច្រើន ប្រតិបត្តិការនៃតម្រួតសម្ងាត់នៅក្រោមអំណាចត្រួតត្រាយ៉ាងដាច់ខាតនៃអ្នកកាន់អំណាច ពលរដ្ឋម្នាក់ៗមិនមានសេរីភាពនឹងចាត់ចែងការរស់នៅតាមគំនិតរបស់ខ្លួនឡើយ មិនមានទាំងអស់សូម្បីតែគំនិតរបស់ខ្លួននោះត្រឹមត្រូវតាមហេតុផលក៏ដោយ ក្រៅតែពីយកគំនិតនោះទៅបូជារដ្ឋ។ ការរស់នៅក្នុងរដ្ឋនោះ គឺមនុស្សទាំងអស់គ្នាត្រូវធ្វើការ ធ្វើតាមបន្ទាត់ដែលគេបានគូសឲ្យ រដ្ឋកាន់ខ្ជាប់នូវអំណាចខ្ពស់បំផុត។ មនុស្សម្នាក់ៗត្រូវធ្លាក់ខ្លួនជាទាសកររបស់រដ្ឋ ជនណាល្មើសនៃអង្គការលទ្ធិនោះ ត្រូវបានផ្តន្ទាទោសយ៉ាងធ្ងន់ ជនល្មើសខ្លះអាចត្រូវបញ្ជូនទៅធ្វើការយ៉ាងធ្ងន់ក្នុងទីណាមួយ។

កាលបើដូច្នេះ យើងអាចស្ដីបានថា លទ្ធិនេះមានឫសគល់នៅជាមួយនឹងលទ្ធិវត្ថុនិយមយ៉ាងខ្លាំងក្លា លទ្ធិនេះចោមវាយសាសនា ជិះជាន់កាក់ខាំងសេរីភាពរបស់មនុស្សខាងផ្លូវគំនិត និងសេរីភាពខាងជំនឿក្នុងសាសនាបង្រៀនមនុស្សឲ្យស្អប់ខ្ពើមជាន់វណ្ណៈ ព្យាយាមបង្គាប់ឲ្យមនុស្សទាំងអស់ទទួលរៀបចំការបដិវត្តន៍ទូទៅក្នុងពិភពលោក ។ របៀបរស់នៅយ៉ាងនេះ នឹងស្រួលឬមិនស្រួល សូមឲ្យអ្នកអានពិចារណាហើយជ្រើសរើសយកដោយខ្លួនឯងចុះ។

ចំណែកព្រះពុទ្ធសាសនា មិនមានប្រាថ្នានឹងជិះជាន់ឬបៀតបៀនសេរីភាពផ្ទាល់ខ្លួននៃមនុស្សទេ។ ផ្ទុយទៅវិញ ព្រះពុទ្ធសាសនាជួយទំនុកបំរុងឲ្យ

មនុស្សព្យាយាមជំរះចិត្តរបស់ខ្លួនឲ្យស្អាតបរិសុទ្ធ សាងសេចក្ដីចំរើននិងគុណសម្ប័ទនានាខាងផ្លូវចិត្តរបស់ខ្លួន ដើម្បីសេចក្ដីសុខចំរើនក្នុងជីវិតនេះនឹងជីវិតក្នុងនិព្វាន។ ពុទ្ធសាសនាបង្រៀនឲ្យមនុស្សមានសេចក្ដីអត់ធន់ជាមួយនឹងធម្មជាតិ បង្រៀនឲ្យប្រើសេចក្ដីស្នេហាទៅក្នុងផ្លូវសុចរិតទៀងត្រង់ បង្រៀនមិនឲ្យស្អប់ខ្ពើមគ្នា មិនឲ្យរើសថាអ្នកណាកាន់សាសនាណា មានជាតិជាអ្វី មានភាសាយ៉ាងម៉េច មានវណ្ណៈយ៉ាងណាមានពេលផ្សេងគ្នាឬដូចគ្នា ។ល។ បង្រៀនសត្វលោកឲ្យស្រឡាញ់គ្នា តាមល័ខគោលដែលថា អ្នកណាធ្វើល្អបានល្អ អ្នកណាធ្វើអាក្រក់នឹងបានអាក្រក់ ធម្មធាតុគ្រប់យ៉ាងជាអនិច្ចំ ជាទុក្ខំ និងជាអនត្តា។ មនុស្សម្នាក់ៗត្រូវតែធ្វើការ ធ្វើការឲ្យបានច្រើន ធ្វើការដោយតស៊ូ ធ្វើការដោយធន់ទ្រាំ មិនត្រូវធ្វើខ្លួនឲ្យចុះចាញ់សង្គ្រាមធម្មជាតិ សង្គ្រាមការងាររវាងមនុស្សគ្នាឯង។ល។ ដើម្បីលាភយសទ្រព្យធនដែលជាចាំបាច់ដល់ជីវិតមនុស្ស និងដើម្បីជួយស្រោចស្រង់មនុស្សទន់ខ្សោយដែលគ្នារស់នៅក្នុងពិភពលោក ជាមួយនឹងខ្លួន។ តែមនុស្សម្នាក់ៗមិនត្រូវភ្លេចខ្លួនថា ទ្រព្យធនលាភយលមិនអាចបំរើសេចក្ដីសុខរបស់ខ្លួនអស់កាលជានិរន្តន៍បានឡើយ ធម្មធាតុដែលសំខាន់បំផុតរបស់ជីវិត គឺការប្រព្រឹត្តល្អ ការស្រឡាញ់សេចក្ដីយុត្តិធម៌ ការស្នេហាចំពោះពេសបុរសស្ត្រីដោយសេចក្ដីបរិសុទ្ធិ និងការផ្សាយមេត្តាចិត្តចំពោះសត្វទាំងឡាយក្នុងពិភពលោក។

ក្នុងលទ្ធិខ្លះ មានសេចក្ដីផ្ដាច់ការយ៉ាងដាច់ខាត ដែលគេចាត់ទុកថាជាការចាំបាច់សម្រាប់ធ្វើការបោសសំអាតលទ្ធិទំនាស់ឲ្យអស់ទៅ ក្នុងពុទ្ធសាសនាយើងឥស្សរភពផ្ទាល់ខ្លួនមនុស្សជារបស់ចាំបាច់ សម្រាប់ប្រតិបត្តិធម៌ទៅនិព្វាន។ ពួកជនក្នុងលទ្ធិខ្លះ មានជំនឿក្នុងការបដិវត្តន៍ តែពុទ្ធសាសនិកមានជំនឿក្នុងការបដិរូបដើម្បីសាងរបបសង្គមថ្មី។ ពួកលទ្ធិខ្លះធ្វើការសម្រេចដោយសម្របសម្រួលលួងលោក។ ពួកលទ្ធិខ្លះបដិវត្តលទ្ធិនយោបាយចាស់ដោយប្រើកម្លាំងបាយ ប្រកបដោយសេចក្ដីឃោរឃៅ។ តែព្រះពុទ្ធបរមគ្រូទ្រង់បដិវត្តលទ្ធិសាសនាចាស់ដោយប្រើកម្លាំងប្រាជ្ញាញាណ ប្រកបដោយមេត្តាធម៌។

ប្រទេសយើងតាំងខ្លួនជាអព្យាក្រិត មានរបបគ្រប់គ្រងប្រជាធិបតេយ្យ

មានបុគ្គលជាប្រធានាធិបតីនៅក្រោមបទបញ្ញត្តិនៃរដ្ឋធម្មនុញ្ញ សឹងសម្តែងឲ្យឃើញថាយើងពេញចិត្តរស់នៅតាមបែបប្រជាធិបតេយ្យដ៏បរិសុទ្ធ។ ក្នុងខណៈណាដែលលទ្ធិប្រជាធិបតេយ្យមូលធននិយមស្តាំបំផុត និងលទ្ធិប្រជាធិបតេយ្យសង្គមនិយមឆ្វេងផុត កំពុងមានការប៉ះទង្គិចគ្នាយ៉ាងខ្លាំងក្លា។ យើងសង្ឃឹមថាការរស់នៅតាមបន្ទាត់នៃព្រះពុទ្ធសាសនារបស់យើងនេះ នឹងអាចធ្វើឲ្យប្រជាជាតិយើងមានសីលធម៌កាន់តែច្រើនឡើង មានចិត្តប្រកបដោយមនុស្សធម៌កាន់តែប្រសើរឡើង មានភាពនិងមានលក្ខណៈជាមនុស្សកាន់តែរឹងប៉ឹងលើសដើម គឺមានតែគុណធម៌ខាងផ្លូវចិត្តទាំងអស់នេះទេ ដែលអាចធ្វើការតទល់នឹងការឃោសនាបោកបន្លំរបស់លទ្ធិនានាបាន។

ធម្មជាតុដែលយើងត្រូវគិតឲ្យច្រើនបំផុតនោះ គឺប្រទេសយើងជាប្រទេសមានសេចក្តីចំរើនរុងរឿងបំផុតក្នុងអតីតកាល ប្រទេសយើងធ្លាប់មានអំណាចក្នុងជ្រោយសុវណ្ណភូមិ ប្រជាជាតិរបស់យើងធ្លាប់មានសេរីភាពខាងផ្លូវគំនិត ខាងផ្លូវជំនឿខាងផ្លូវជ្រើសអាជីវកម្ម ។ល។ យើងធ្លាប់មានសាមគ្គីធម៌នៅជុំវិញយុត្តិធម៌នៃប្រជាជាតិ យើងធ្លាប់ធ្វើការ យើងធ្វើការបានច្រើន យើងធ្វើការប្រកបដោយសេចក្តីអត់ធន់ យើងធ្វើការប្រកបដោយសេចក្តីក្លាហាន។ ប្រាសាទថ្មនិងវត្ថុបុរាណទាំងអស់ក្នុងប្រទេស យើងសាងឡើងដោយកម្លាំងសាមគ្គីរបស់ជាតិ ដោយលទ្ធិរបស់ជាតិសុទ្ធៗ គឺព្រះពុទ្ធសាសនានេះឯង មិនមែនដោយលទ្ធិទាំងឡាយដទៃទៀយ។

ក្នុងបច្ចុប្បន្នកាលនេះ ប្រទេសយើងក៏បានឯករាជ្យហើយ នយោបាយអព្យាក្រិត្យក៏យើងបានធ្វើហើយ ការគ្រប់គ្រងរដ្ឋតាមរបបសេរីប្រជាធិបតេយ្យក៏យើងបានធ្វើអស់ហើយដែរ។ ករណីកិច្ចរបស់យើង គឺនាំគ្នាធ្វើការទាំងអស់ធ្វើឲ្យបានច្រើនៗទាំងអស់គ្នា ធន់ក្នុងការងារទាំងអស់គ្នា តស៊ូក្នុងការងារទាំងអស់គ្នា ក្លាហានក្នុងការងារទាំងអស់គ្នា។ តែប៉ុណ្ណេះប្រទេសយើងក៏បានចំរើនរុងរឿងដូចសម័យព្រេងនាយទៅហើយ។ ការអែអង់ចាំខ្ចីលទ្ធិគេមកប្រើ ចាំជឿតែលទ្ធិគេនិងការដេកគងថ្ងាសចាំឲ្យលទ្ធិគេយកលុយមកឲ្យចាយនោះ មិនមែនជាការចាំបាច់របស់យើងឡើយ។

# បទទី ១៥

# សង្គមនិយមតាមរបបនៃពុទ្ធសាសនា និងសង្គមនិយមតាមរបបនៃលទ្ធិខ្លះ

សេចក្តីពិត ពីបូរាណកាលមក មនុស្សល្ងង់ខ្លៅ មនុស្សទន់ខ្សោយ និងមនុស្សទុគ៌ត ពុំមានឱកាសបានទទួលសេចក្តីភាពបរិបូរណ៍ទេ។ ក្នុងវេលាជាមួយគ្នានេះ ប្រជាជាតិណាដែលទន់ខ្សោយ មិនមានសមត្ថភាពរឹងប៉ឹង ក៏មិនអាចបានទទួលសេរីភាព សមភាពនិងភាតរភាពជាមួយនឹងប្រជាជាតិខ្លាំងពូកែសូម្បីបន្តិចបន្តួចឡើយ។

របបសង្គមជិះជាន់នេះ បានក្លាយជាធម្មតាមួយចាក់ឫសនៅក្នុងគំនិតរដ្ឋបុរស ទស្សនៈវិទូ និងសាស្ត្រាចារ្យសំខាន់ៗទាំងឡាយរៀងៗមក។ ក្នុងផ្លូវប្រវត្តិសាស្ត្រគេបានរកឃើញគំនិតថ្លៃថ្នូរនៃអស់លោកទាំងនោះ ដែលខំប្រឹងដោះស្រាយបញ្ហានៃសេរីភាពរបស់មនុស្សឲ្យបានច្បាស់លាស់ មិនមានឈប់ឈរ រដ្ឋបុរសនិងសសាស្ត្រាចារ្យខ្លះបានស្វែងរកសន្តិសុខ សុភមង្គលនិងជីវភាពថ្លៃថ្នូរជូនប្រជាពលលោក ដោយទឹកចិត្តប្រកបដោយមេត្តាធម៌យ៉ាងទូលំទូលាយ។ ការសាងពិភពលោកឲ្យបានប្រកបដោយសន្តិភាព ចេះតែមានអ្នកនិយាមធ្វើអស់កាលជាប់មិនដាច់ប្រសិនបើសាកលចក្រវាឡនៅតែមានមនុស្សនៅអាស្រ័យ។

## របបសង្គមសាស្ត្រសាកល តាមទស្សនៈនៃគ្រីស្តសាសនា

តាមសេចក្តីយល់ចូលចិត្តរបស់គ្រីស្តសាសនិកថា : ព្រះជាម្ចាស់នៃសួគ៌ព្រះអង្គទ្រង់បង្កើតពិភពលោក ទ្រង់សាងមនុស្សឲ្យនៅលើផ្ទៃនៃពិភពជំនួសព្រះអង្គ ។ ដោយអាស្រ័យហេតុនេះ មនុស្សទើបជាសត្វថ្លៃថ្នូរបំផុតក្នុង

បណ្ដាសត្វទាំងឡាយ។ មនុស្សប្រកបដោយអំណាចខាងផ្លូវចិត្តនិងផ្លូវបញ្ញា និងជាអ្នកមានសមត្ថភាពអាចរក្សានូវភារៈធំដុះរបស់ខ្លួនឲ្យព្រះអង្គបាន ព្រមទាំងមានអំណាចសក្ដិសិទ្ធិលើវត្ថុធាតុនៅជុំវិញខ្លួនផង។ គេទាំងឡាយអាចរចនាវត្ថុធាតុទាំងនោះឲ្យមានប្រយោជន៍ដល់ខ្លួនបាន តាមសេចក្ដីត្រូវការរបស់គេ គ្រីស្ដសាសនិកជនដែលមានសន្ដានចិត្តល្អមានឧត្តមគតិខាងផ្លូវចិត្ត គេខំប្រឹងជាអតិបរមាដើម្បីស្វែងរកនូវសុខសន្តិភាពដោយពឹងផ្អែកលើជំនួយ របស់ព្រះជាម្ចាស់ ព្រមជាមួយនឹងសេចក្ដីព្យាយាមរបស់ខ្លួន ហើយគេមានសង្ឃឹមថាពិភពលោកនេះនឹងមានស្ថានភាពល្អ ដោយកម្លាំងគ្រងរក្សារបស់ព្រះជាម្ចាស់ និងសេចក្ដីព្យាយាមរបស់គេទាំងឡាយ។

របបសង្គមសាស្ត្របែបនេះ មិនមែនមានតែក្នុងវិញ្ញាណនៃគ្រីស្ដសាសនិកប៉ុណ្ណោះទេ។ តែក្នុងវិញ្ញាណនៃឥស្លាមសាសនិកនិងហិណ្ឌូសាសនិក ក៏មានរបបសង្គមសាស្ត្រដូច្នេះដែរ។

# ព្រះពុទ្ធបរមគ្រូរបស់យើង

ចំណែកព្រះបរមសាស្ដាចារ្យរបស់យើង ព្រះអង្គទ្រង់បង្រៀនថា "មិនមានប្រយោជន៍អ្វីនឹងទៅអង្គុយគិតថា : ពិភពលោកនេះត្រូវសាងឡើងដោយអ្នកណាទេព្រោះគំនិតនេះវាមិនមែនជាផ្លូវនាំឲ្យកើតបញ្ញាជាន់ខ្ពស់ វាមិនមែនជាវិជ្ជាដែលចាំបាច់ឲ្យមនុស្សបានទទួលនូវសេរីភាពយ៉ាងខ្ពង់ខ្ពស់ និងមិនមែនជាកុសលោបាយអាចធ្វើឲ្យមនុស្សរួចផុតចាកសេចក្ដីទុក្ខបានដល់នូវ បរមសុខគឺនិព្វានឡើយ" បរមគ្រូរបស់យើងព្រះអង្គទ្រង់បង្រៀនមនុស្ស ឲ្យចេះដឹងនូវសេចក្ដីពិតរបស់ធម្មជាតិ ដែលកើតមានឡើងនៅចំពោះមុខ ទ្រង់បង្រៀនត្រឹមតែរបៀបណាដែលជាចាំបាច់ដល់ជីវិតប៉ុណ្ណោះ។ មេរៀនរបស់ព្រះអង្គមានសេចក្ដីថា "សាកលចក្រវាឡស្ថិតនៅក្រោមសភាពដូរផ្លាស់ គឺធម្មធាតុទាំងអស់វានៅក្នុងចំណុះនៃច្បាប់របស់កម្ម ដែលសត្វក្នុងពិភពលោកមិនអាចនឹងគេច

ផុត” ព្រះបរមសាស្ត្រាចារ្យទ្រង់ពុំបានបដិសេធការកើតមាននៃព្រះជាម្ចាស់ ឬទេវតា ឥន្ទព្រហ្មលើសួគ៌វិមានទេ។ តែព្រះអង្គទ្រង់ដៅបញ្ជាក់ឲ្យឃើញថា អ្នកទាំងនោះក៏ជាបុគ្គលរស់នៅចំណុះកម្មរបស់ខ្លួន អ្នកទាំងនោះមានជោគជតាឡើងចុះទៅតាមកម្លាំងនៃកម្ម ក្នុងកាលណាគេទាំងឡាយបានប្រើកម្មអាក្រក់ល្អអស់ហើយ ក្នុងកាលនោះខ្លួនគេក៏បានជាមនុស្សសេរី លែងរស់នៅក្រោមច្បាប់នៃកម្មទៀតហើយ។

សត្វគ្រប់ប្រភេទកើតមកមានភាពលក្ខណៈខុសៗគ្នា តើដំណើរមិនដូចគ្នាមកពីអ្វី? បញ្ហានេះ យើងនឹងឆ្លើយថា : មកពីការចាត់ចែងរបស់ព្រះជាម្ចាស់ទាំងអស់អង្គ ការចាត់ចែងរបស់មាតាបិតានិងសេចក្ដីប៉ងប្រាថ្នារបស់ខ្លួននៃមនុស្សម្នាក់ៗ ក៏ត្រូវមិនអស់ព្រោះថា ធម្មជាតុទាំងឡាយជាព្រះអាទិទេពក្ដី ជាមាតាបិតាក្ដី ជាចំណង់របស់មនុស្សយើងក្ដី មិនត្រូវឲ្យមានលក្ខណៈថោកទាបលក្ខណៈឆ្កួតលេលា លក្ខណៈល្ងង់ខ្លៅ ។ល។ សោះឡើយ។ ដូច្នេះបញ្ហានេះយើងនឹងដោះស្រាយផ្អែកទៅលើអ្វីខុសអំពីកម្ម ឃើញថារកទ្វារចេញមិនរួចទេ។ យោបល់ពុទ្ធសាសនាថា : ការផ្លែកគ្នានៃមនុស្សទាំងឡាយមកអំពី "**កម្ម**" មនុស្សមិនដូចគ្នាដោយលក្ខណៈនានា ក៏មកតែអំពី "**កម្ម**" របស់ខ្លួន "**កម្ម**" រចនាមនុស្ស "**កម្ម**" ធ្វើឲ្យមនុស្សមានការវិវត្តន៍ផ្លែកៗ ដូចជាការវិវត្តន៍របស់សត្វគ្រប់ប្រភេទ និងពូជរុក្ខជាតិនានានោះដែរ។

ព្រះពុទ្ធបរមគ្រូទ្រង់គូសដៅ ឲ្យឃើញបុព្វហេតុនៃសេចក្ដីផ្លែកគ្នារបស់មនុស្សហើយទ្រង់ប្រាប់ឲ្យមនុស្សតស៊ូយកជ័យជំនះ កុំចុះចាញ់កម្ម កុំបណ្ដោយឲ្យជីវិតប្រព្រឹត្តទៅតាមយថាកម្ម តាមធម្មជាតុនៅជុំវិញខ្លួន មនុស្សម្នាក់ៗត្រូវប្រយុទ្ធឲ្យឈ្នះកម្មអាក្រក់ដោយកម្លាំងកម្មល្អ អប់រំចិត្តរបស់ខ្លួនឲ្យមានមេត្តាករុណា ឲ្យមានគុណធម៌ល្អ លះបង់លែងធ្វើបាបជនដទៃ។ សេចក្ដីប្រព្រឹត្តនេះ អាចធ្វើឲ្យមនុស្សបានទទួលនូវសេចក្ដីសុខចំរើន បានសម្រេចនូវសន្តិភាពជាស្ថាពរមិនខានឡើយ។

តែលទ្ធិគ្រប់គ្រងខ្លះគេនិយាយថា : មនុស្សយើងជាផលិតផលនៃធម្ម

ធាតុដែលមាននៅជុំវិញខ្លួននៃមនុស្ស ក្នុងខ្លួននៃមនុស្សយើងមិនមានអ្វីថ្លៃថ្នូរ គួរឲ្យសង្គមជនរាប់អានទេ ក្រៅពីកម្លាំងចិត្តតស៊ូដើម្បីរស់នៅស្រួល។ ពួកគេបានប្រើអំណាចនិងសេចក្ដីឆ្លៀវឆ្លាតជាពិសេស ដើម្បីសម្រេចនូវការគ្រប់គ្រងត្រួតត្រានិងផលប្រយោជន៍ផ្ទាល់ខ្លួនរបស់គេ។ គេយល់ឃើញថា : សេចក្ដីទុក្ខលំបាកកើតមកអំពីធម្មធាតុនៅជុំវិញជនជាន់ទាប គឺមានមូលហេតុអំពីរបបនាយទុក (លទ្ធិមូលធននិយម) របបនេះធ្លាក់នៅក្នុងដៃជនពួកតិចពិតមែន តែវាបានធ្វើឲ្យមានសេចក្ដីលំបាកដល់ជនភាគច្រើន ។ ដូច្នេះរបបនាយទុន ទើបជារបបនាំឲ្យមានភ័យដល់របបសង្គមថ្មី។ ហេតុនេះទើបគេនាំគ្នាធ្វើការបដិវត្តន៍បំបាត់របបនាយទុន និងដើម្បីការពារសង្គមថ្មី កុំឲ្យមានការវិលត្រឡប់ថយក្រោយ។

ពួកសង្គមថ្មីមានគំនិតថា : ការផ្លាស់ប្ដូរភាវៈជុំវិញខ្លួនមនុស្ស ត្រូវធ្វើដោយការបដិវត្តន៍ គឺកាច្រានរំលំរដ្ឋាភិបាលគ្រប់របប ដើម្បីរំដោះប្រជាជាតិឲ្យផុតចាកសេចក្ដីទុក្ខលំបាក និងដើម្បីធ្វើឲ្យប្រជាជាតិមានឋានៈជីវភាពខ្ពស់ខ្ពស់មានសុភមង្គលទ្វេឡើង។ គោលបំណងរបស់គេនេះមានន័យថា : **គេត្រូវការបដិវត្តន៍ពិភពលោក ត្រូវការដឹកនាំពិភពលោក ។ ទ្រព្យសម្បត្តិទាំងអស់ជារបស់រដ្ឋ បុគ្គលជាប្រមុខនៃការបដិវត្តន៍ ត្រូវកាន់អំណាចខាងនយោបាយដោយដាច់ខាត ។**

ពួកថ្មីរៀបចំសង្គមជនដោយអាស្រ័យពឹងផ្អែកលើវត្ថុតែម្យ៉ាង មិនបានពឹងផ្អែកលើធម៌ទេ។ គឺគេគិតធ្វើយ៉ាងម៉េចឲ្យតែមនុស្សយើងបានរស់នៅស្រួល មានបច្ច័យ៤ បរិភោគប្រើប្រាស់គ្រប់គ្រាន់ គេមិនបានគិតគូរដល់ធម្មធាតុគឺចិត្តនិងធម៌ដែលជាអរូបធាតុ ជាគ្រឿងពឹងផ្អែកនៃវិញ្ញាណរបស់មនុស្សទាំងឡាយឡើយ។ បានសេចក្ដីថារបស់រស់នៅថ្មី គេបំរើរូបកាយមនុស្ស គេពុំបានចំរើចិត្តវិញ្ញាណរបស់មនុស្សឡើយ។ គេទាំងឡាយមិនត្រូវការឲ្យមានសាសនាទាំងអស់ គេយកបូជនីយស្ថានសម្រាប់សាសនាជារបស់រដ្ឋ ដោយគេយល់ថាធម្មៈរបស់សាសនាមានធាតុទំនាស់នឹងកិច្ចការរបស់សង្គម។ សាសនាហាមឃាត់

មិនឲ្យប្រជាជាតិធ្វើការបដិវត្តន៍ដោយអាវុធ ជាសិទ្ធិដែលមនុស្សទាំងអស់គ្នាត្រូវមានក្នុងការបដិវត្តន៍នៃសង្គម។

នៅក្នុងប្រទេសថ្មី គេបិទព្រំដែនដោយរបាំងដែកយ៉ាងជិតឈឹង ដើម្បីកុំឲ្យប្រជាជនមានឱកាសដកកទៅទាក់ទងជាមួយនឹងប្រទេសសេរី ប្រជាធិបតេយ្យទាំងឡាយបាន។ របាំងដែកនេះបានរាំខាំងប្រជាជាតិ មិនឲ្យដឹងនូវសេចក្ដីពិតប្រាកដជាមួយនឹងប្រទេសខាងក្រៅ។ អ្នកនៅខាងក្រោយរបាំងដែកនោះមានសិទ្ធិត្រឹមតែផ្ទៀងត្រចៀកស្ដាប់បញ្ញាថៅហ្វាយរបស់ខ្លួន ពួកគ្នាត្រូវរឹតត្បិតឲ្យនៅក្នុងវិន័យយ៉ាងតឹង ត្រូវបិទភ្នែកមិនឲ្យដឹងហេតុការណ៍ទាំងអស់ដោយសេរី គេឲ្យដឹងបានត្រឹមតែហេតុការណ៍ណាដែលមិនទំនាស់នឹងឧត្ដមគតិរបស់លទ្ធិ។ ពួកគេបានបោសសំអាតនូវវត្ថុធាតុគ្រប់បែបយ៉ាង ដែលជាភក់ជាបន្លានៃសមភាព ហើយគេទុកដាក់ឲ្យជនគ្រប់វណ្ណៈរស់នៅក្នុងរណ្ដាប់ស្មើគ្នា គេរំលំតំណែងផ្សេងៗអស់។ គេធ្វើឲ្យសង្គមមានសមភាពក៏ពិតមែនហើយ តែវាក្លាយទៅជាសមភាពដែលប្រកបទៅដោយសេចក្ដីស្រេចឃ្លាន ប្រកបដោយទោមនស្សវេទនា គឺគេបន្ថយកំរិតឋានៈជីវភាពប្រជាជាតិឲ្យទាបចុះមកជាទីបំផុត តាមដែលគេអាចធ្វើបាន។ មានពេលខ្លះគេបន្ថយកំរិតជីវភាពយ៉ាងទាបបំផុតនោះចុះមកមួយកំរិតទៀត លុះត្រាតែជីវភាពនៃមនុស្សធ្លាក់ចុះក្នុងសភាពសែនវេទនា សែនធន់ទ្រាំ។ ក្នុងពេលនោះគេបាននាំយករបបមូលធននិយមនៃរដ្ឋមកប្រើជំនួសរបបមូលធននិយមនៃបុគ្គល។ ពួកគេបានលើកលែងប្រើអំណាចប្រាក់ក្នុងការតំលើងអំណាចក្នុងប្រទេសរបស់ខ្លួន ហើយលើអំណាចសិទ្ធិដាច់ខាតនៃបុគ្គលជាប្រមុខនៃការបដិវត្តន៍មកប្រើជំនួស គឺអំណាចខាងផ្ដន្ទាទោសមនុស្ស អំណាចខាងបង្គាប់ឲ្យមនុស្សធ្វើការ អំណាចខាងបញ្ជូនអ្នកប្រឆាំងនឹងលទ្ធិទៅទុកក្នុងបន្ទាយឃុំខាំងកម្មករ។

គេឃើញបានយ៉ាងច្បាស់ថា ពួកថ្មីបាននាំយក "**គំលានអំណាច**" មកប្រើជំនួស "**គំលានប្រាក់**" គឺគេផ្លាស់ពី "**របបមូលធននិយម**" មកជា "**របបឃ្លានអំណាចនិយម**" ។

នៅក្នុងប្រទេសសេរីប្រជាធិបតេយ្យ ពលរដ្ឋចង់រាប់អានសាសនាអ្វីក៏បានចង់ប្រើជំនឿទៅក្នុងលទ្ធិណាក៏បាន ចង់កាន់ទំនៀមទំលាប់បែបណាក៏បាន។ រដ្ឋាភិបាលទំនុកបំរុងអ្នករាប់អាន អ្នកជឿ អ្នកកាន់ តាមការគួរ។ ពលរដ្ឋម្នាក់ៗមានសិទ្ធិជ្រើសរើសរបបរស់នៅរបស់ខ្លួនតាមចិត្តស្ម័គ្រ ជាជីវភាពនយោបាយក្តី ជាជីវភាពសេចក្តីកិច្ចក្តី ជាជីវភាពវប្បធម៌ក្តី ។ល។ ស្រេចនឹងឃើញថាគួរ។ ពលរដ្ឋដែលស្ម័គ្រចិត្តធ្វើកម្មករ ត្រូវបានតម្លៃឈ្នួលពេញទី បើកម្មករមិនពេញចិត្តនឹងនាយជួលរបស់ខ្លួន ឬមិនពេញចិត្តនឹងមុខងារដែលគេបានប្រគល់ឲ្យខ្លួនធ្វើ កម្មករអាចលាឈប់ ឬអាចនឹងនិយាយបំភ្លឺនាយជួយរបស់ខ្លួនឲ្យឃើញចិត្តឃើញថ្លើមគ្នាដោយសេរី ឬបើកម្មករមានគ្នាច្រើនអាចនឹងប្រើវិធីការពារផលប្រយោជន៍របស់ខ្លួនដោយកូដកម្ម នឹងដោយប្តឹងឧទ្ធរណ៍ដល់តុលាការរដ្ឋក៏បាន។ តែក្នុងប្រទេសថ្មី ពលរដ្ឋម្នាក់ៗមិនមានសេរីភាពជ្រើសរើសសិទ្ធិសម្រាប់ប្រើផ្ទាល់ខ្លួន ក្រៅពីសិទ្ធិដែលរដ្ឋបានប្រគល់ឲ្យ។ កិច្ចការរាល់យ៉ាងគ្រប់គ្រងដោយឧត្តមគតិនៃលទ្ធិនិងបទបញ្ជានៃ បុគ្គលអ្នកដឹងនាំ ។

# បទទី១៦

# សង្គមនិយមបែបប្រជាធិបតេយ្យខាងពុទ្ធសាសនាមានយ៉ាងម៉េចខ្លះ ?

សំនួរនេះ ខ្ញុំសូមឆ្លើយដោយអាងសូត្រមួយ ក្នុងទីឃនិកាយ សូត្រនេះស្ដីដោយធម្មកថារបស់ព្រះបរមសាស្ត្រាចារ្យ ដែលព្រះអង្គទ្រង់បានសំដែងចំពោះសិង្គាលមាណព ដោយទ្រង់បានដៅបញ្ជាក់អំពីការរស់នៅក្នុងសង្គម ហើយទ្រង់អធិប្បាយវែកញែកដល់របបសង្គមនិយម តាមទស្សនៈរបស់ព្រះអង្គដូចមានសេចក្ដីសង្ខេបតទៅនេះ :

**• "ជាដំបូង ពុទ្ធសាសនិកជនទាំងឡាយគប្បីវៀរចាកអំពើ ៤យ៉ាង (កម្មកិលេស) គឺ :**

១- សម្លាប់ជីវិតរបស់គេ

២- លួចទ្រព្យសម្បត្តិរបស់គេ

៣- ក្បត់សេចក្ដីស្នេហារបស់គេ

៤- ពោលពាក្យកុហក " ។

**• វៀរចាកប្រព្រឹត្តធម៌ឬច្បាប់ប្រកបដោយអគតិ ៤ យ៉ាងគឺ :**

១- លំអៀងចិត្តព្រោះស្រឡាញ់រាប់អាន

២- លំអៀងចិត្តព្រោះស្អប់

៣- លំអៀងចិត្តព្រោះល្ងង់

៤- លំអៀងចិត្តព្រោះខ្លាច។

**• វៀរចាកទំហើដែលធ្វើឲ្យខ្លួន ថោកទាបខាតបង់ទ្រព្យសម្បត្តិ (អបាយមុខ) ៦ យ៉ាង គឺ :**

១- ផឹកទឹកស្រវឹងនិងសេពគ្រឿងញៀន

២- ដើរលេងយប់

៣- ដើរមើលល្បែង

៤- លេងល្បែងភ្នាល់គ្នា

៥- យកមនុស្សអាក្រក់ជាភឿន

៦- ខ្ជិលធ្វើការងារ។

• **បុត្តធីតាគប្បីគោរពប្រតិបត្តិមាតាបិតា ដោយករណីយ៍ ៥ យ៉ាងគឺ :**

១- លោកបានចិញ្ចឹមយើងមកហើយ គប្បីចិញ្ចឹមលោកវិញ

២- បំរើលោកដោយធ្វើកិច្ចការជំនួស

៣- រក្សាវង្សត្រកូលល្អរបស់លោក

៤- ប្រព្រឹត្តខ្លួនឲ្យជាមនុស្សល្អគួរទទួលមត៌ក

៥- កាលណាលោកអនិច្ចកម្មទៅ ត្រូវធ្វើបុណ្យឧទ្ទិសផលជូន។

• **មាតាបិតាគប្បីអនុគ្រោះកូនដោយករណីយ៍ ៥ យ៉ាងគឺ :**

១- ហាមធ្វើការងារអាក្រក់

២- ដឹកនាំឲ្យធ្វើការងារល្អ

៣- ទំនុកបំរុងឲ្យសិក្សាវិជ្ជានានា

៤- រកស្វាមីភរិយាឲ្យតាមការគួរ

៥- កាលណាដល់ពេលគួរហើយប្រគល់មត៌កឲ្យ។

• **អាចារ្យគប្បីអនុគ្រោះសិស្សដោយករណីយ៍ ៥ យ៉ាង គឺ :**

១- អប់រំឲ្យបានល្អ

២- បង្រៀនឲ្យបានចេះដឹង

៣- បង្រៀនឲ្យអស់ដើងមិនលាក់វិជ្ជា

៤- លើកតំកើងសិស្សឲ្យប្រាកដ ច្បាស់លាស់ក្នុងទីប្រជុំជន

៥- ការពារកេរ្តិ៍ឈ្មោះសិស្ស និងធ្វើឲ្យសិស្សស្រឡាញ់រាប់អានគ្នា។

• **សិស្សគប្បីគោរពប្រតិបត្តិអាចារ្យដោយករណីយ៍ ៥ យ៉ាងគឺ :**

១- ដោយក្រោកឡើងទទួលដំណើរចូលនិងជូនដំណើរចេញ

២- ដោយចូលខ្លួនទៅជិតដើម្បីបំរើ

៣- ដោយយកចិត្តទុកដាក់ស្តាប់ឱវាទ

៤- ដោយទំនុកបំរុងផ្គងផ្គើមគ្រប់មធ្យោបាយ

៥- ដោយគោរពយ៉ាងស្មោះអស់ពីចិត្តក្នុងពេលរៀន។

• **បុរសជាស្វាមីគប្បីប្រតិបត្តិភរិយារបស់ខ្លួន ដោយករណីយ៍ ៥ យ៉ាងគឺ:**

១- ដោយរាប់អានលើកតំកើងថាជាភរិយាពិតៗ

២- ដោយមិនប្រមាថមើលងាយ

៣- ដោយមិនគប្បីក្បត់ចិត្តស្នេហា (មានស្ត្រីដទៃទៀត)

៤- ដោយប្រគល់ឲ្យនូវឥស្សរភាពក្នុងគ្រួសារ

៥- ដោយឲ្យគ្រឿងសំអាង និងគ្រឿងតែងកាយ។

• **ស្ត្រីជាភរិយាគប្បីប្រតិបត្តិស្វាមីរបស់ខ្លួន ដោយករណីយ៍ ៥យ៉ាងគឺ :**

១- ចាត់ចែងការងារក្នុងផ្ទះឲ្យបានល្អ

២- សង្គ្រោះញាតិខាងស្វាមីឲ្យបានសមរម្យ

៣- មិនប្រព្រឹត្តក្បត់ចិត្តស្នេហា (មានបុរសដទៃទៀត)

៤- រក្សាឲ្យគង់នូវទ្រព្យសម្បត្តិដែលស្វាមីរកបានមក

៥- ខំធ្វើកិច្ចការទាំងពួងក្នុងគ្រួសារ។

• **កុលបុត្រគប្បីទំនុកបំរុងមិត្រដោយករណីយ៍ ៥ យ៉ាងគឺ:**

១- ដោយចែកប្រយោជន៍ឲ្យ

២- ដោយនិយាយពាក្យពិរោះ

៣- ដោយប្រព្រឹត្តប្រយោជន៍ឲ្យ

៤- ដោយភាវៈជាបុគ្គលមានខ្លួនស្មើៗគ្រប់វេលា

៥- ដោយមិនក្លែងពោលពាក្យឲ្យខុសពីសេចក្តីពិត។

• **មិត្តគប្បីអនុគ្រោះកុលបុត្រដោយករណីយ៍ ៥យ៉ាងគឺ:**

១- រក្សាខ្លួនមិត្តដែលជាអ្នកមានសេចក្តីប្រមាទហើយ

២- រក្សាទ្រព្យសម្បត្តិរបស់មិត្តដែលជាអ្នកមានសេចក្តីប្រមាទហើយ
៣- ក្នុងកាលមានអាសន្នយកខ្លួនធ្វើជាទីពឹងពំនាក់ឲ្យ
៤- មិនលះបង់ចោលគ្នាក្នុងគ្រាមានវិបត្តិ
៥- រាប់អានគ្នារហូតដល់វង្សញាតិរបស់មិត្ត។

• **ធនបតីគប្បីទំនុកបំរុងកម្មករដោយករណីយ៍ ៥ យ៉ាងគឺ:**

១- ចាត់ចែងការងារឲ្យធ្វើតាមគួរដល់កម្លាំងនៃសមត្ថភាព
២- ឲ្យអាហារនិងតម្លៃឈ្នួលឲ្យបានធួនល្មម
៣- រក្សាព្យាបាលយ៉ាងជិតដល់ក្នុងពេលមានជម្ងឺ
៤- ឲ្យរង្វាន់ជាពិសេសក្នុងកាលម្តងៗ
៥- អនុញ្ញាតឲ្យឈប់ធ្វើការតាមកាលតាមសម័យ។

• **កម្មករគប្បីប្រតិបត្តិធនបតី ដោយករណីយ៍ ៥ គឺ :**

១- ក្រោកឡើងធ្វើការមុនធនបតិ
២- ទទួលទានដំណេកក្រោយធនបតិ
៣- កាន់យកតែរបស់ណាដែលធនបតិបានឲ្យ
៤- ធ្វើការរបស់ធនបតិ ប្រកបដោយសេចក្តីប្រឹងប្រែងខ្នះខ្នែង
៥- ជួយទ្រទ្រង់នូវគុណសម្ប័ទល្អរបស់ធនបតិ។

• **កុលបុត្រគប្បីប្រតិបត្តិសមណព្រាហ្មណ៍ ដោយករណី ៥ យ៉ាងគឺ:**

១- គោរពយ៉ាងជិតដល់ដោយកាយកម្ម
២- គោរពយ៉ាងជិតដល់ដោយវចីកម្ម
៣- គោរពយ៉ាងជិតដល់ដោយមនោកម្ម
៤- គោរពដោយបើកទ្វារផ្ទះ គឺឲ្យចេញចូលតាមពេលដ៏គួរ
៥- គោរពដោយសេចក្តីសង្គ្រោះខាងបច្ចយាហារ។

• **សមណព្រាហ្មណ៍គប្បីទំនុកបំរុងកុលបុត្រ ដោយករណីយ៍ ៦យ៉ាងគឺ:**

១- ការពារមិនឲ្យធ្វើសេចក្តីអាក្រក់
២- ឲ្យតំកល់ខ្លួននៅក្នុងសេចក្តីល្អ

៣- អនុគ្រោះដោយទឹកចិត្តល្អ

៤- ឲ្យបានស្តាប់ធម៌ដែលមិនធ្លាប់បានស្តាប់

៥- បំភ្លឺធម៌ដែលធ្លាប់បានស្តាប់ហើយ ឲ្យកាន់តែចូលចិត្តច្បាស់ឡើង

៦- ប្រាប់ផ្លូវសម្រាប់ដើរទៅកាន់សេចក្តីសុខចំរើន។

ករណីយ៍ទាំងអស់នេះ ជារបៀបរស់នៅ តាមល័ខគោលនៃពុទ្ធសាសនា ជាឧត្តមការសម្រាប់ប្រស្រ័យទាក់ទងគ្នាក្នុងសង្គមមនុស្សលោក ។ តាមរបៀបនេះសមាជិកនៃសង្គមជនមានករណីយ៍ ទទួលខុសត្រូវផ្ទាល់ចំពោះរបៀបចាត់ការនិងវិន័យរបស់សង្គម។ ជនគ្រប់វណ្ណៈ អាចរួមរស់នៅជាមួយគ្នាក្រុបកដោយសេចក្តីសុខចំរើន ដោយករណីត្រឹមតែពីចេះគោរពគ្នា ចេះធ្វើប្រយោជន៍ឲ្យគ្នានឹងគ្នា ដោយបរិមាណស្មើៗគ្នា។ របបនេះជារបបសង្គមប្រជាធិបតេយ្យដ៏បរិសុទ្ធ ជារបបដែលប្រជាជាតិអាចប្រតិបត្តិបាន ជារបបសម្រាប់ប្រមូលមនុស្សសម្រាប់ធ្វើប្រយោជន៍ឲ្យមនុស្សគ្រប់ពួក ទោះជាមនុស្សនោះមានជំនឿក្នុងវត្ថុណា រស់នៅក្នុងលទ្ធិណា កាន់សាសនាណា មានវណ្ណៈជាអ្វី មានសញ្ជាតិយ៉ាងណាក៏ដោយ។ របបនេះជារបបមានមកសម្រាប់បំពេញវត្ថុបំណងរបស់មនុស្សអ្នកស្នេហាជាតិ ស្នេហាលទ្ធិ ស្នេហាសាសនា ស្នេហាទំនៀមទំលាប់ ។ល។ ជារបបដែលអាចប្រព្រឹត្តទៅបានគ្រប់កាលសម័យ។ ពុទ្ធសាសនាបានដាស់តឿនមនុស្សលោកថា មុននឹងធ្វើអ្វីទាំងអស់ត្រូវស្វែងរកបញ្ញាសិន បានបញ្ញាហើយត្រូវធ្វើការ ធ្វើការបានផលចិញ្ចឹមខ្លួនឯងគ្រប់គ្រាន់ហើយ ត្រូវជួយសង្គ្រោះជនដទៃ។ ខ្ពស់ជាងនេះទៅទៀត ព្រះបរមសាស្ត្រាចារ្យទ្រង់រំលឹកថា មនុស្សម្នាក់ៗត្រូវរៀបចំខ្លួនឲ្យមានសន្តិភាពខាងផ្លូវចិត្តមុននឹងរៀបចំឲ្យមានសន្តិភាព ខាងក្នុងរូបកាយឬខាងវត្ថុ។ ម្យ៉ាងទៀត ព្រះបរមគ្រូទ្រង់បានបញ្ជាក់ថា : មនុស្សម្នាក់ៗត្រូវចេះធ្វើជាចៅហ្វាយលើខ្លួនឯង ត្រួតត្រាខ្លួនឯង ស្តីបន្ទោសខ្លួនឯង ដោះស្រាយនូវបញ្ហាដែលចោទឡើងដោយខ្លួនឯង។ បណ្តុះមេត្តាករុណាធម៌ឲ្យដុះជ្រៅទៅក្នុងចិត្ត រៀនអាណិតអ្នកដទៃឲ្យច្រើន។ ធ្វើដូច្នេះទើបអាចនឹងដឹកនាំពិភពលោក ឲ្យដើរទៅកាន់ភាគរភាពនៃរបបប្រជាធិបតេយ្យពិតប្រាកដបាន។

សេចក្ដីនេះ ដៅឲ្យឃើញថា ដរាបណាពួកលទ្ធិសំភារៈនិយម នៅតែមានចិត្តពោរពេញដោយសេចក្ដីឃោរឃៅ ល្មោភអំណាច ដរាបនោះការបដិវត្តន៍ដ៏កំណាចកម្ពៅរបស់គេនោះ នឹងដុះត្រាំនៅក្នុងចិត្តរបស់គេ ហើយពួកគេ ក៏នឹងមិនបានជួបនូវសន្តិភាពនៅខាងក្នុងដួងវិញ្ញាណរបស់គេឡើយ។ ការដឹកនាំប្រជាជាតិក្នុងភិភពលោក ឲ្យរាប់អានលទ្ធិសំភារៈនិយមដោយលុបបំបាត់នូវវណ្ណៈ ។ល។ ឬដោយលើកស្ទួយមូលធនិក។ល។ ដោយនិយមប្រើកម្លាំងណាមួយនោះ មិនអាចនឹងធ្វើឲ្យអ្នកស្រឡាញ់សេចក្ដីពិត ស្រឡាញ់សេរីភាព ស្រឡាញ់យុត្តិធម៌ចុះចូលបានឡើយ។

# បទទី ១៧

# ការស្ថាបនាជីវិតតាមបន្ទាត់នៃពុទ្ធសាសនា

ដើម្បីឲ្យបានងាយស្រួល ដល់ការរស់នៅក្នុងលោកបច្ចុប្បន្ន មនុស្សម្នាក់ៗត្រូវខំប្រឹងធ្វើការអស់ពីកម្លាំង ដែលធម្មជាតិបានផ្តល់ឲ្យ ។ ពុទ្ធសាសនាបានសំដែងបញ្ជាក់ថា : **ប្រយោជន៍សុខចំរើនក្នុងជីវិតបច្ចុប្បន្ន កើតឡើងដោយសម្បទា ៤ យ៉ាងគឺ** :

**១- ឧដ្ឋានសម្បទា** សម្បទាគឺសេចក្តីព្យាយាមធ្វើការ

**២- អារក្ខសម្បទា** សម្បទាគឺការថែរក្សា

**៣- កល្យាណមិត្តា** ភាពជាបុគ្គលមានការរាប់អានគ្នាល្អ

**៤- សមជីវិតា** ភាពជាបុគ្គលរស់នៅស្មើៗ។

ពាក្យថា "**សេចក្តីព្យាយាមធ្វើការ**" ដែលលោកប្រើសព្ទថា "**ឧដ្ឋាន**" នោះមានសេចក្តីថា "**ជំហរខ្ពស់**" ដោយន័យថា អ្នកធ្វើការត្រូវតែធ្វើចិត្តរបស់ខ្លួនឲ្យខ្ពស់ជាងធម្មជាតិ ធន់ទ្រាំជាងធម្មជាតិ ពូកែជាងធម្មជាតិ ក្លាហានជាងធម្មជាតិ តស៊ូយកឈ្នះធម្មជាតិ ដោយសំនូយ៉ាងខ្ពស់ដែលបានបណ្តុះរួចក្នុងចិត្តនៃអាត្មា ។ "**ធម្មជាតិ**" ក្នុងទីនេះ មិនមែនសំដៅយកត្រឹមតែទឹក ដី ភ្លើង ខ្យល់ ។ល។ ប៉ុណ្ណោះទេ គឺសំដៅដល់មនុស្ស សត្វ និងព្រឹត្តិការណ៍របស់មនុស្សសត្វផង ។ ដូច្នេះ សេចក្តីព្យាយាម គឺការតស៊ូយកជោគជ័យអំពីធម្មជាតិនោះ គឺយកជ័យអំពីមនុស្សសត្វនិងព្រឹត្តិការណ៍នានានៃមនុស្សសត្វផង។ ព្រះពុទ្ធសាសនាទ្រង់ណែនាំថា : នាទីនៃអ្នកធ្វើនេះ ត្រូវតែភ្លេចធម្មជាតិទាំងអស់នេះគឺ ស្រេក ឃ្លាន ក្តៅ ត្រជាក់ ពេលព្រឹក ពេលល្ងាច ពេលភ្លៀង ខ្យល់ សេចក្តីនឿយហត់សេចក្តីឈឺចាប់ត្រឹមតែបន្តិចបន្តួច ការកំសាន្តដែលមិនមែនជាចាំបាច់ ។ល។ នាទីនៃអ្នកធ្វើការត្រូវលះបង់នូវកម្លាច ដែលកើតមកអំពីមនុស្សគ្រប់ឋានៈ និងសត្វសាហាវគ្រប់ប្រភេទ ដោយប្រើចិត្តក្លាហានពុះពារប្រកប

ដោយយឿឧត្តមគតិថា "ជាមនុស្សដូចគ្នា គេធ្វើអ្វីកើត ខ្លួនអញក៏ត្រូវខំប្រឹងធ្វើឲ្យកើតដូចគេ... ជាសត្វវាហ៊ានកម្លាអញ អញក៏ហ៊ានកម្លាវា" អ្នកធ្វើការត្រូវកុំវាថយនឹងព្រឹត្តិការណ៍ដែលកើតមានម្តងៗក្នុងពិភពលោក ទោះជាចលនានៃជម្ងឺឆ្លងក្តី ចលនានៃសង្គ្រាមក្តី ចលនានៃធម្មជាតិពុំប្រក្រតីក្តី។ល។ អ្នកធ្វើត្រូវកុំរងចាំជោគវាសនា កុំរង់ចាំសេចក្តីស្រោចស្រង់អំពីព្រះអាទិទេព កុំរង់ចាំជំនួយអំពីពួកទេព។ ចំពោះជោគវាសនា យើងត្រូវដឹងថាមិនមានអ្នកណាអាចទាយបានទេ។ តែពុទ្ធសាសនា បានប្រាប់យើងថា : *បុគ្គលមានបុណ្យបានធ្វើមកហើយអំពីអតីតជាតិនោះ រមែងកើតមកបានស្រួលក្នុងបច្ចុប្បន្នជាតិនេះ ចុះបើខ្លួនយើងកើតមកវាមិនបានស្រួលទៅហើយ តើយើងរង់ចាំអ្វីទៀត។ ចំពោះព្រះអាទិទេពទោះណាជាព្រះអង្គមានព្រះវិញ្ញាណល្អ ប្រកបដោយមេត្តាករុណា តែព្រះអង្គក៏មិនអាចនឹងជួយសង្គ្រោះមនុស្ស ដែលពុំព្រមជួយខ្លួនឯងបានឡើយព្រះអង្គទ្រង់ជួយសង្គ្រោះមនុស្សមានជោគវាសនាជាមុន ចំណែកមនុស្សគ្មានភ័ព្វវាសនាត្រូវទុកសង្គ្រោះជាក្រោយ។* បញ្ហានេះ ត្រូវចោទឡើងថា : បើដូច្នេះព្រះអាទីទេពព្រះអង្គមិនសង្គ្រោះសត្វដោយរើសមុខទៅហើយឬ ? មិនមែនដូច្នោះទេព្រះពុទ្ធបរមគ្រូយើង ព្រះអង្គទ្រង់ទេសនាយ៉ាងច្បាស់ថា : មនុស្សទាំងអស់គ្នាមានខ្លួនជាទីពឹងរបស់ខ្លួន មានខ្លួនជាទីរលឹករបស់ខ្លួន ខ្លួនធ្វើល្អបានល្អ ខ្លួនធ្វើអាក្រក់បានអាក្រក់ ។ អំពើអាក្រក់ល្អរបស់មនុស្សនេះហើយ ដែលពុទ្ធសាសនាហៅថា "**បុណ្យបាប**" បុណ្យបាបនេះហើយ ដែលហៅថា ""**ភ័ព្វវាសនាអាក្រក់ល្អ**" របស់មនុស្ស។ មនុស្សធ្វើល្អមានជោគវាសនាបានជួបនឹងព្រះ ព្រះលោកសង្គ្រោះមនុស្សនោះ ដោយការងារល្អរបស់គេអំពាវនាវឲ្យព្រះអង្គសង្គ្រោះ។ ចំណែកមនុស្សធ្វើការអាក្រក់ ពុំបានធ្វើការល្អជាមនុស្សគ្មាវាសនាល្អ ព្រះអង្គពុំអាចសង្គ្រោះបានទេ ព្រោះខ្លួនគេពុំព្រមពឹងខ្លួនឯង ពុំព្រមគិតគូរដោះស្រាយបញ្ហាខ្លួនឯង ពុំព្រមធ្វើការខ្លួនឯង តាមសេចក្តីជាស់តឿនរបស់ព្រះអង្គ។ មនុស្សបែបនេះលោកឲ្យឈ្មោះថា "**បទបរមៈ**" មានន័យថា "**មនុស្សមានវាសនាស្ទួត**" ។ ដូច្នេះដើម្បីឲ្យព្រះសង្គ្រោះ យើង

ត្រូវខំប្រឹងធ្វើការល្អឲ្យបានច្រើន ឲ្យខ្លួនយើងមានវាសនាបរិបូណ៌ ទើបគួរដល់ការសង្គ្រោះរបស់ព្រះអង្គ។ ចំពោះពួកទេពក៏ដូចគ្នានឹងព្រះអង្គដែរ ពួកទេពតាមរឿងក្នុងព្រះពុទ្ធសាសនាដល់បុគ្គលពួកមួយ មានស័ក្តិធំមានឫទ្ធិអំណាចច្រើន។ បុគ្គលពួកនេះ ជួយសង្គ្រោះតែមនុស្សណាមានជោគវាសនាច្រើន : មានគុណធម៌ខ្ពស់ ចំណែកមនុស្សមិនមានវាសនា ឬមានវាសនាត្រឹមតែបន្តិចបន្តួច ពួកទេពពុំបានជួយសង្គ្រោះទេ។ ពួកទេពបំរើតែមនុស្សណាសម្បូណ៌ជោគវាសនា សម្បូណ៌គុណធម៌ខ្ពស់ខុសមនុស្សធម្មតា គឺជោគវាសនារបស់មនុស្សនោះទេ ដែលស្រែកហៅពួកទេពឲ្យចូលមកជួយសង្គ្រោះ មិនមែនសម្លេងធម្មតានៃមនុស្សយើងទេ បើជាសម្លេងនៃមនុស្ស ក៏គឺមនុស្សមានជោគវាសនា មានយុត្តិធម៌ខ្ពស់បំផុតនុ៎ះឯង ទើបពួកទេពយកត្រចៀកស្តាប់។

ក្រៅពីនេះ មានជនមួយពួកទៀត ជាអ្នកធ្វើការល្អ ធ្វើការដោយមានសេចក្តីអត់ធន់ ធ្វើការដោយក្លាហាន ធ្វើការដោយមានសេចក្តីតស៊ូ មានសុចរិតយុត្តិធម៌នៅគ្រប់មុខការដែលខ្លួនធ្វើ ជនពួកនេះច្រើនមានពួកទេពជួយសង្គ្រោះ ព្រោះទេពអស់ទាំងនោះយល់ឃើញថា : មនុស្សពួកនេះហើយ ដែលអាចធ្វើឲ្យពិភពលោកបានប្រកបដោយសន្តិភាព។ ចំណែកអ្នកខ្ជិលធ្វើការ ឬអ្នកធ្វើការរវើរវាយ ឬធ្វើការប្រកបដោយសេចក្តីទុច្ចរិត ឬអ្នកដែលដេកតែបួងសួងបន់ស្រន់ ឲ្យពួកទេពជួយសង្គ្រោះខ្លួននោះ ពួកទេពពុំដូចពោលមកនេះច្រើនណាស់ ព្រោះហឫទ័យនៃព្រះក្តីចិត្តរបស់មនុស្សយើងក្តី មិនសូវជាខុសគ្នាប៉ុន្មានទេ។ នៅក្នុងលោកយើងនេះមនុស្សទ័លក្រខំប្រឹងរៀនវិជ្ជា ខំប្រឹងរកទ្រព្យ ខំប្រឹងប្រតិបត្តិការតាមនាទីប្រកបដោយសេចក្តីអត់ធន់ មានចិត្តក្លាហាន មានការតស៊ូប្រកបដោយមនុស្សធម៌។ ជនពួកនេះ តែងបានទទួលសេចក្តីសង្គ្រោះពីមនុស្សគ្នាឯងជាចៅហ្វាយនាយ ឬជាមិនសម្លាញ់ ឬជាបងប្អូន។ល។ ព្រោះគេអាណិតមនុស្សដែលមានជីវិតជាអ្នកតស៊ូជាអ្នកពឹងខ្លួនឯង ជាអ្នកចេះដោះស្រាយបញ្ហាជីវិតរបស់ខ្លួន។ ឯជនមានឥរិយាបថផ្ទុយពីនេះ គេមិនឈឺក្បាល គេមិនយកភ្នែកមើល គេមិនខ្វីអាណិត មិនខ្វីជួយសង្គ្រោះទេ។ តែពួកជនសប្បុរសមានព្រះពុទ្ធបរមគ្រូជាដើម លោកនៅតែអាណិតមនុស្សខ្ជិល

មនុស្សដេកបន់ស្រន់ មិនមនុស្សធ្វើការផ្សងព្រេងនោះដែរ ប៉ុន្តែសេចក្តីអាណិត នេះ ក្លាយទៅជាសេចក្តីអាណិតធម្មតាដែលតែងតែមានក្នុងសន្តានចិត្តនៃជន សប្បុរសប៉ុណ្ណោះ បើអស់លោកទាំងនោះ ពុំអាចជួយសង្គ្រោះមនុស្សណាដែល មិនពឹងខ្លួនឯងបានឡើយ។

លក្ខណៈនៃជនអ្នកធ្វើការមានច្រើនយ៉ាង ក្នុងទីនេះស្រង់មកនិយាយខ្លះ ចំពោះតែគោលធំៗមានដូចនេះ :

១- ធន់អាកាសក្តៅ

២- ធន់អាកាសត្រជាក់

៣- ធន់សម្រេក

៤- ធន់គំលាន

៥- ធន់ពេលថ្ងៃ

៦- ធន់ពេលយប់

៧- ធន់ព្រឹត្តិការណ៍នានាក្នុងលោក

៨- ធន់សត្វសាហាវបៀតបៀន

៩- ធន់សត្វល្អិតចាក់រុក

១០- ធន់ការដណ្តើមប្រជែងរបស់មនុស្សដទៃ

១១- ធន់សេចក្តីនឿយហត់ ។ល។

ពាក្យថា "**ថែរក្សា**" ដែលលោកប្រើសព្ទថា "**អារក្ខ**" មានសេចក្តីថា រក្សា ដោយដិតដល់ រក្សាដោយហ្មត់ចត់ គឺរក្សាទុកមិនឲ្យបាត់បង់ រក្សាទុកមិនឲ្យខូច ខាត។ មនុស្សម្នាក់ៗកាលណាបើបានធ្វើការប្រកបដោយសេចក្តីព្យាយាម យ៉ាងមោះមុតនោះហើយ គេមុខជានឹងមានវិជ្ជា មានទ្រព្យ មានមុខងារ មាន មុខតំណែង។ល។ ទ្រព្យសម្បត្តិទាំងអស់ ទោះជារូបធនក្តី អរូបធនក្តី ដែល អាចនឹងគង់វង្សគត់មត់បានអាស្រ័យដោយ "**ការរក្សា**" ដូច្នេះ មនុស្សម្នាក់ៗ មិន មែនមានករណិយ៍ត្រឹមតែប្រឹងរៀនប្រឹងរកប៉ុណ្ណោះទេ គឺមានករណិយ៍ថែរក្សា ទុកដាក់យ៉ាងញឹកល្អិតផង ប្រុងប្រយ័ត្នតទប់នឹងអន្តរាយដែលនឹងកើតមានមក

លើទ្រព្យសម្បត្តិផងទើបមានឈ្មោះថាជាបុគ្គលដល់ព្រមដោយ អារក្ខសម្បទា។

លក្ខណៈនៃជនថៃរក្សា លក្ខណៈនោះមានច្រើនក្នុងទីនោះ ស្រង់មកនិយាយខ្លះចំពោះតែគោលធំៗមានដូចនេះ :

១- ទ្រព្យណាដែលបាត់បង់ទៅ គេរកឲ្យឃើញវិញ

២- វត្ថុណាបាក់បែក គេជួយជុលឡើងវិញ

៣- ចាត់ការប្រើប្រាស់ ឲ្យល្មមត្រឹមតែរស់

៤- តមវៀរអាបាយមុខ ៤ ប្រការ (ល្បែង បុរស ស្ត្រី ល្បែងស៊ីផឹកល្បែងភ្នាល់ ល្បែងត្រូវជើងភឿនបនខ្ជះខ្ជាយ)។

ពាក្យថា "**ភាពជាបុគ្គលមានការរាប់អានគ្នាល្អ**" ដែលលោកប្រើសព្ទថា "**លក្ខណមិត្តតា**" ស័ព្ទនេះមានន័យថា : រាប់អានគ្នាក្នុងឋានៈជាប្រជាសត្វលោករស់នៅក្រោមបទបញ្ញត្តិនៃធម្មជាតិដូចគ្នា ទាំងអស់គ្នាសុទ្ធតែមានសេចក្តីប្រែប្រួលទៅតាមព្រឹត្តិការណ៍នៃធម្មជាតិ (អនិច្ចំ) មានជីវិតរស់នៅដោយសេចក្តីធន់ទ្រាំ (ទុក្ខំ) មានខ្លួនតែជារបស់សោះសូន្យ (អនត្តា) ។ បើតាមព្រឹត្តិការណ៍នៃធម្មជាតិនិងព្រឹត្តិការណ៍ជីវិតមនុស្ស វត្ថុទាំងពីរនេះ មានលក្ខណៈត្រូវគ្នាគឺប្រែប្រួលធន់ ទ្រាំ ទ្រោមស្លាយ ពុទ្ធសាសនាហៅចលនានេះថា "**អនិច្ចំ ទុក្ខំ អនត្តា**" ប្រែថា **ជីវិតមនុស្សរស់នៅបានដោយការតស៊ូ** ។ មនុស្សទាំងឡាយមានការចាំបាច់ត្រូវរាប់អានគ្នាដោយល្អ រាប់អានគ្នាដោយស្មោះត្រង់ ព្រោះមនុស្សម្នាក់ៗ ទោះជាខ្លួនមានវិជ្ជា មានទ្រព្យ មានកិត្តិយស ។ល។ ច្រើនដល់ប៉ុន្មាន ធំដល់ប៉ុនណាកម្លាំងមួយភាគនេះ មិនអាចប្រយុទ្ធតទប់នឹងគ្រោះថ្នាក់ដែលកើតអំពីធម្មជាតិ គ្រោះថ្នាក់ដែលកើតអំពីសង្គ្រាម គ្រោះថ្នាក់ដែលកើតអំពីអមនុស្ស ។ល។ បានឡើយ។

ដូច្នេះករណិយ៍របស់មនុស្សមួយចំណែកទៀត ដែលត្រូវរាប់ចូលក្នុងចំណែកទី ១ និងទី ២ គឺការសាងកម្លាំង និងការស្ងួនគ្រងកម្លាំងនោះ គឺចំណែកទី ៣ បានដល់ការរាប់រកគ្នានេះឯង។ ដើម្បីធ្វើការរាប់រកគ្នាឲ្យកាន់តែ

មានតុល្យភាពល្អឡើងនោះ ជាដំបូងមនុស្សយើងត្រូវរំពឹងគិតដល់មនុស្សភាពថា : មនុស្សទាំងអស់ខុសគ្នាដោយជាតិត្រកូល-សម្បុរ វណ្ណៈ ឋានៈ ភាសា ។ល។ ក៏ពិតមែន តែមនុស្សទាំងអស់ត្រូវគ្នាដោយសេចក្ដីប្រាថ្នា ចង់បានសុខ ចង់បានចំរើន ចង់បានទ្រព្យ ចង់បានវិជ្ជា ចង់បានជួបជុំគ្នីគ្នា ចង់រស់នៅយូរ ។ល។ បន្ទាប់មកត្រូវរំពឹងគិតដល់ "**ត្រៃលក្ខណ៍**" គឺ "**អនិច្ចំ ទុក្ខំ អនត្តា**" ដែលជាលក្ខណៈប្រចាំប្រាណរបស់មនុស្សទាំងឡាយក្នុងសាកលពិភពលោក ដែលមិនមានមនុស្សណាម្នាក់អាចចៀសបាន។ កាលណាយើងបានរំពឹងគិតដូចនេះរឿយៗ ខ្លួនយើងក៏មានចិត្តទោរទន់ អាណិតមនុស្សដែលមានសេចក្ដីប៉ងប្រាថ្នាត្រូវគ្នា មានគ្រោះថ្នាក់ដោយធម្មជាតិដូចគ្នា។ សេចក្ដីអាណិតនេះហើយដែលជាបុព្វហេតុនាំឲ្យយើងរាប់អានគ្នាដោយល្អបាន ប្រសិនណាបើក្នុងសង្គមយើងមានមនុស្សណាម្នាក់ឬច្រើននាក់មានចរិយាមិនល្អ មានចិត្តប្រកបដោយអមនុស្សធម៌នោះ យើងគ្រប់គ្នាក្នុងសង្គមត្រូវព្រួតគ្នាជួយអប់រំ ជួយដុះខាត់អធ្យាស្រ័យ មនុស្សនោះឲ្យបានល្អឡើង ការរាប់អានដោយយល់មុខ ស្អប់ខ្ពើមដោយរើសមុខ មិនមែនជាករណិយ៍គួរឲ្យយើងធ្វើទេសន្តិសុខយ៉ាងខ្ពង់ខ្ពស់មិនអាចកើតមានបានក្នុងសង្គម ដែលមានមនុស្សអាក្រក់នៅរួមជាមួយផងទេ។ មានតែការរាប់រកគ្នា ចង់បាច់គ្នាឲ្យបានមូល មិត្រស្និទ្ធស្នាលប៉ុណ្ណោះទេ ដែលអាចធ្វើឲ្យសង្គមយើងបានប្រកបដោយសេចក្ដីសុខចំរើនតាមលំដាប់ តាំងពីគ្រួសារមួយ ភូមិស្រុកមួយ ដំបន់មួយ ប្រទេសមួយ រហូតដល់ពិភពលោកទាំងមូល តាមទំហំនិងបរិមាណនៃសេចក្ដីរាប់អានរបស់យើង ច្រើនតិចតួចធំនោះឯង។

លក្ខណៈនៃជនអ្នករាប់អានគ្នាល្អ លក្ខណៈនេះមានច្រើន ក្នុងទីនេះស្រង់យកតែលក្ខណៈសំខាន់ខ្លះមកនិយាយ មានដូចនេះ :

១- ជាបុគ្គលឲ្យនូវរបស់ដែលគេឲ្យបានដោយក្រ

២- ជាបុគ្គលជួយធ្វើនូវការដែលគេលំបាកនឹងជួយ

៣- ជាបុគ្គលអត់ឲ្យនូវទោស ដែលគេលំបាកនឹងអត់

៤- ជាបុគ្គលទទួលនូវសេចក្តីទុក្ខមុនគេ

៥- ជាបុគ្គលទទួលនូវសេចក្តីសុខក្រោយគេ។

ពាក្យថា "**ភាពជាបុគ្គលរស់នៅស្មើៗ**" ដែលលោកប្រើសព្ទថា "**សមជិវតា**" សព្ទនេះមានន័យថា រស់នៅត្រឹមតែរស់ រស់នៅដោយសំចៃ រស់នៅដោយសន្តោសតាមធម្មតា មនុស្សយើងទាំងខំប្រឹងរៀនវិជ្ជាខំប្រឹងរកទ្រព្យ ដើម្បីប្រើប្រាស់ស៊ីចាយឲ្យបានសប្បាយ នេះជាសេចក្តីពិតតាមតណ្ហានៃមនុស្សជាតិ។ តែបើទាំងអស់គ្នាប្រព្រឹត្តដូច្នេះ មើលទៅទ្រព្យសម្បត្តិនៃធម្មជាតិ ដែលធម្មតាមានសាងឡើងសម្រាប់បំរើមនុស្សលោកនោះ នឹងពាយស្លាយអស់ជាមិនខាន។ ដូច្នេះ ពាក្យថា "**សមជីវិតា**" ដែលប្រែថារស់នៅស្មើៗនោះ មិនមែនមានន័យថា ស្មើនឹងកម្លាំងវិជ្ជាស្មើនឹងបរិមាណទ្រព្យ ស្មើនឹងបរិមាណមុខងារ ស្មើនឹងបរិមាណមុខតំណែង។ល។ ដែលយើងនិយមនិយាយគ្នាថា រកបានតិចចាយតិច រកបានល្មមចាយល្មម រកបានច្រើនបាយច្រើននេះទេ។

"**សមជីវិតា**" ក្នុងទីនេះ មានន័យថា "**រស់នៅត្រឹមតែរស់**" ដូចបានពោលមកហើយ។ ដើម្បីចូលចិត្តងាយក្នុងរឿងនេះ ខ្ញុំសូមឲ្យអ្នកអានពិនិត្យដល់គោលបំណងនៃពុទ្ធភាសិតក្នុងសម្បទាទី១ ទី២ និងទី៣ ដែលស្តីអំពីការរក ការទុកដាក់ និងការប្រមូលមិត្ត។ ខ្ញុំសូមបញ្ជាក់ន័យរបស់ពាក្យក្នុងចំណុចនេះថា : ជាមនុស្សត្រូវតែខំប្រឹងធ្វើការឲ្យច្រើន ដើម្បីឲ្យមានរូបធននិងវិញ្ញាណធនច្រើន ត្រូវចេះទុកដាក់វត្ថុច្រើននោះឲ្យគង់ ត្រូវរកមធ្យោបាយប្រមូលមិនឲ្យបានច្រើន សេចក្តីបញ្ជាក់នេះខ្ញុំមិនមែនធ្វើឡើងដោយអារម្មណ៍របស់ខ្ញុំទេ គឺខ្ញុំធ្វើឡើយដោយមានសំអាងលើអក្សរពីរតួគឺ "ឧ" "អា" និងពាក្យមួយបទគឺ "កល្យាយ" អក្សរនិងពាក្យនេះក្នុងភាសាបាលី បើនៅខាងដើមសព្ទណា នឹងធ្វើឲ្យសព្ទនោះមានគុណភាពខ្ពស់ខុសធម្មតា ដូច "គច្ឆតិ" ប្រែថា "ទៅ" មាន "ឧ" នៅដើម សម្រេចរូបជា "**ឧគច្ឆតិ**" ប្រែថា "**ហោះ**" ។ "នន្ទ" ប្រែថា "រីករាយ" មាន"អា" នៅដើម សម្រេចរូបជា "**អានន្ទ**" ប្រែថា "**រីករាយច្រើន**" "មិត្ត" ប្រែថា

"រាប់អាន" មាន "កល្យាយ" នៅដើម សម្រេចរូបជា "**កល្យាណមិត្ត**" ប្រែថា "**រាប់អានល្អ**" ។

បំណងពុទ្ធភាសិតក្នុងសម្បទា ៣ ខាងដើមនោះ ចង់និយាយថា "រកឲ្យទាល់តែបាន" "រក្សាឲ្យទាល់តែគង់" "រាប់អានគ្នាឲ្យកាន់តែកើត" តែចំពោះ "សមជីវិតា" ត្រូវយកសេចក្ដីថា "រស់នៅត្រឹមតែរស់" ក្នុងភោគទ្រព្យដែលខ្លួនមាន ទោះតិចក្ដី ល្មមក្ដី ច្រើនក្ដី ។ ដែលខ្ញុំកាន់យកសេចក្ដីយ៉ាងនេះ ដើម្បីឲ្យសមតាមបំណងព្រះពុទ្ធសាសនា គ្រប់ចំណុចនៃទ្រឹស្ដីដែលជាប់ទាក់ទងជាមួយនឹងជីវិតមនុស្ស។

ទ្រឹស្ដី "**ទាន សីល ភាវនា**" ជាទ្រឹស្ដីសាធារណៈ ទ្រឹស្ដីនេះ កើតឡើងដោយបំណងរបស់ព្រះពុទ្ធបរមគ្រូ ចង់ឲ្យអ្នកមានកម្លាំងនិងអ្នកខ្សោយរស់នៅជាមួយគ្នាបាន ព្រោះមនុស្សយើងទោះជាយ៉ាងណា ក៏មិនអាចសាងកម្លាំងឲ្យស្មើគ្នាបានទេ។ ព្រះអាទិទេពក្ដី ធម្មជាតិ កម្មផលក្ដី លោកបង្កើតមនុស្សឡើងដោយមានឆន្ទៈយ៉ាងណា យើងទាំងឡាយគិតមិនចេញទេ បញ្ហារូបកាយសខ្មៅខ្ពស់ទាបស្គមធាត់តូចធំអាយុវែងអាយុខ្លីរោគតិចរោគច្រើន ។ល។ បានកើតជាពាក្យនិយាយប្រកបដោយបុច្ឆនសញ្ញា (?) នេះរបស់យើង។ ព្រះពុទ្ធបរមគ្រូទ្រង់ចង់លុបបំបាត់នូវបុច្ឆនសញ្ញានេះ ដោយទ្រង់ខំប្រឹងប្រមូលសមត្ថភាពទាំងអស់មកឆ្លើយសំនួរនេះលទ្ធផលបានសម្រេចខ្លះដែរ។ តែនៅមានច្រើនណាស់មិនអាចនឹងឲ្យព្រះអង្គលុបចោលនូវសញ្ញាពាក្យសួរនេះ បានឡើយ។ ក្នុងទីបំផុត ព្រះអង្គទ្រង់បបួលឲ្យមនុស្សយើងរស់នៅជាមួយគ្នាដោយទាន សីល ភាវនាមិនជិះជាន់គ្នាដោយប្រើកម្លាំងទ្រព្យ យកទ្រព្យមកសង្គ្រោះគ្នាហៅថា "ទាន" មិនជិះជាន់គ្នាដោយប្រើកម្លាំងទ្រព្យ យកទ្រព្យមកសង្គ្រោះគ្នាហៅថា "ទាន" មិនជិះជាន់គ្នាដោយប្រើកម្លាំងអំណាចនៃយសស័ក្តិ នៃជាតិនៃវណ្ណៈ ។ល។ យកកម្លាំងនៃអំណាចទាំងអស់នេះមកសង្គ្រោះគ្នា ហៅថា "សីល" មិនជិះជាន់គ្នាដោយប្រើកម្លាំង ចិត្តលំអៀងប្រកបដោយសេចក្ដីស្អប់ស្រឡាញ់ សេចក្ដីភ័យខ្លាច សេចក្ដីល្ងង់ខ្លៅ។ល។ យកចិត្តប្រកបដោយមេត្តា

ករុណា មុទិតា ឧបេក្ខា មកសង្គ្រោះគ្នាហៅថា "ភាវនា" តាមបំណងនៃព្រះពុទ្ធសាសនា ត្រង់ចំណុចនេះឃើញថា មនុស្សយើងត្រូវតែខំប្រឹងរកទ្រព្យឲ្យបានទុកដាក់ទ្រព្យឲ្យគង់ រាប់អានគ្នាឲ្យកើត រស់នៅជាមួយគ្នាឲ្យបាន ។ ដូច្នេះ "សមជីវិតា" ដែលប្រែថា "រស់នៅត្រឹមតែរស់" និង "កល្យាមិត្តតា" ដែលប្រែថា "រាប់អានគ្នាឲ្យកើត" នោះជាការបកស្រាយសមតាមបំណង់នៃពុទ្ធសាសនាហើយ។ ចំពោះយោបល់នៃជនខ្លះ ដែលបកស្រាយ "សមជីវិតា" ថា "រស់នៅស្មើនឹងកម្លាំងទ្រព្យ" "រាប់អានតែមនុស្សណាល្អ" នោះយោបល់នេះគឺជាយោបល់ផ្ទាល់ខ្លួន មិនមែនជាយោបល់នៃពុទ្ធសាសនាទេ ព្រោះពុទ្ធសាសនាដឹកនាំឲ្យមនុស្សជួយសង្គ្រោះគ្នា ឲ្យមនុស្សលះបង់សេចក្ដីសប្បាយផ្ទាល់ខ្លួន ឲ្យមនុស្សរួមរស់នៅជាមួយគ្នា ឲ្យមនុស្សធ្វើបុណ្យទាន ឲ្យមនុស្សធ្វើពលិកម្មនានា ចុះបើយើងរស់នៅស្មើនឹងកម្លាំងទ្រព្យ យើងរស់នៅតែម្នាក់ឯង គឺអ្នកមានទ្រព្យតិចប្រើប្រាស់តិច អ្នកមានទ្រព្យល្មមប្រើប្រាស់ល្មម អ្នកមានទ្រព្យចច្រើនប្រើប្រាស់ច្រើននោះ ទ្រព្យសម្បត្តិរបស់យើងក៏ចេះតែអស់ទៅ កម្លាំងរបស់យើងក៏ចេះតែទន់ខ្សោយទៅតាមលំដាប់ តើពលិកម្មគ្រប់យ៉ាងដែលយើងត្រូវធ្វើ និងគ្រោះថ្នាក់គ្រប់យ៉ាងដែលយើងត្រូវការពារនោះ នឹងទៅជាយ៉ាងណា? ។

ពាក្យថា "រស់នៅត្រឹមរស់" មិនមែនមានន័យថា "រស់នៅដោយត្រដាបត្រដួស" ទេ គឺរស់នៅដោយប្រើប្រាស់ទ្រព្យសម្បត្តិគ្រប់គ្រាន់ តាមសេចក្ដីត្រូវការរបស់ជីវិត។ ខាងចំរើនសុខភាព គេប្រើជីវាហារឲ្យគ្រប់គ្រាន់ គឺគេប្រើទ្រព្យសម្បត្តិដោយប្រតិបត្តិតាមក្បួនអានម័យ។ ខាងកំសាន្តសប្បាយ គេលៃលកឲ្យល្មមសមគួរ គេមិនឲ្យដាច់បង់ទ្រព្យសម្បត្តិច្រើនទៅលើគ្រឿអាហារ គ្រឿងភេសជ្ជៈ គ្រឿងសំលៀកបំពាក់។ល។ ដែលមិនជាចាំបាច់ដល់ជីវិត។ គេសំចៃទ្រព្យសម្បត្តិដោយប្រតិបត្តិតាមក្បួនសេដ្ឋកិច្ច(Ecomnomice Politique) គឺគេប្រិតប្រៀបប្រើប្រាស់វត្ថុផ្សេងៗឲ្យល្មមតែនឹងសេចក្ដីត្រូវការរបស់ជីវិត ។ គេស្លៀកពាក់ត្រឹមតែមួយប្រដាប់ ពីរប្រដាប់ គេមិនឲ្យមានគ្រឿងប្រដាប់ស្លៀកពាក់ (ខោ-អាវ) ច្រើនពេកនាំងឲ្យខាតលុយកាក់ ហើយយូរៗទៅប្រើប្រាស់មិន

កើត ដោយវាចង្អៀតឬវាផុយរហែកទៅ។ គេបរិភោគអាហារត្រឹមតែមួយចំអែត គេមិនឲ្យមានអាហារសេសសល់សម្រាប់ចាក់ចោល គេនៅផ្ទះត្រឹមតែមួយខ្នង គេមានរថយន្តត្រឹមតែមួយគ្រឿង គេមានគ្រែដេកត្រឹមតែមួយប្រដាប់។ល។ គេមានតែល្មមប្រើ ល្មមបរិភោគ គេមិនឲ្យមានរបស់សល់ចោលឡើយ។

ការ "រស់នៅត្រឹមតែរស់" នេះ ខាងពុទ្ធសាសនាលោកហៅថា "បុគ្គលមានសេចក្តីសន្តោស" គឺមានសេចក្តីស្កប់ចិត្តក្នុងវត្ថុត្រឹមតែល្មមប្រើប្រាស់បាន។ សេចក្តីសន្តោសមានច្រើន ក្នុងទីនេះសូមស្រង់មកនិយាយត្រឹមតែ ៤:

១- សន្តោសក្នុងគ្រឿងស្លៀកពាក់

២- សន្តោសក្នុងគ្រឿងបរិភោគ

៣- សន្តោសក្នុងទីសេនាសនៈ

៤- សន្តោសក្នុងគ្រឿងភេសជ្ជៈ។

កាលណាយើងរស់នៅក្នុងបច្ចុប្បន្ន បានស្រួលហើយ សេចក្តីហួងហែងក៏រមែងកើតមានឡើងដល់ជីវិតរបស់យើង យើងចង់ឲ្យការរស់នៅក្នុងអនាគតបានស្រួលដូចក្នុងបច្ចុប្បន្ននេះ ឬចង់ឲ្យអនាគតរបស់យើង មានសេចក្តីថ្លៃថ្នូរជាងបច្ចុប្បន្ននេះទៅទៀត។ ដោយអាស្រ័យចំណង់នេះ ពុទ្ធសាសនាទើបណែនាំយើងឲ្យប្រកបសម្បទា សម្រាប់ជីវិតអនាគតមួយជាន់ទៀត។ **សម្បទាសម្រាប់ផ្តល់វាសនានៃមនុស្សក្នុងអនាគតមាន ៤ យ៉ាងគឺ :**

**១- សទ្ធាសម្បទា** ធ្វើខ្លួនឲ្យដល់ព្រមដោយជំនឿ

**២- សីលសម្បទា** ធ្វើខ្លួនឲ្យដល់ព្រមដោយសីល

**៣- ចាគសម្បទា** ធ្វើខ្លួនឲ្យដល់ព្រមដោយការបរិច្ចាគ

**៤- បញ្ញាសម្បទា** ធ្វើខ្លួនឲ្យដល់ព្រមដោយបញ្ញា។

ពាក្យ "ធ្វើខ្លួនឲ្យដល់ព្រមដោយជំនឿ" "ជំនឿ" សម្លេងពុទ្ធសាសនាថា "សទ្ធា" សទ្ធាដៅយកគុណធម៌ ចំណែកមួយសម្រាប់លាងសំអាតនូវអសទ្ធាដែលធ្វើឲ្យមនុស្សយើងមិនមានជំនឿ ក្នុងធម្មជាតុ ៤ យ៉ាងគឺ :

ក- កម្មអាក្រក់ល្អ

ខ- ផលនៃកម្មអាក្រក់ល្អ

គ- គតិនៃកម្មអាក្រក់ល្អ

ឃ- សេចក្ដីត្រាស់ដឹងនៃព្រះពុទ្ធបរមគ្រូ។

ពាក្យថា "**ធ្វើខ្លួនឲ្យដល់ព្រមដោយសីល**" សីលក្នុងទីនេះ ដៅយក កល្យាណសីលចំណែកមួយ សម្រាប់លាងសំអាតចរិយាអាក្រក់របស់មនុស្ស លោក ចែកជា ៤ ប្រភេទគឺ :

**១- និច្ចសីល**

**២- ឧបោសថសីល**

**៣- អតិរេកសីល**

**៤- អាជីវដ្ឋមកសីល៕**

ពាក្យថា "**ធ្វើខ្លួនឲ្យដល់ព្រមដោយការបរិច្ចាគ**" "បរិច្ចាគ" សព្ទនេះបាន ដល់ការលះបង់ទ្រព្យសម្បត្តិ ដែលជាប្រយោជន៍ខាងការបំរើជីវិតរបស់ខ្លួន ឲ្យ ជាប្រយោជន៍ដល់ជីវិតអ្នកដទៃ ឲ្យជាប្រយោជន៍មនុស្សលោក ឲ្យជាប្រយោជ-ន៍ដល់អង្គការសន្តិភាព ជាពិសេសអង្គការរដ្ឋដែលស្របគ្នានឹងអង្គការពុទ្ធ សាសនា ត្រង់ផ្នែកសង្គ្រោះមនុស្សដោយមិនមានល័ខខ័ណ្ឌ។ ការបរិច្ចាគនេះ ពុទ្ធសាសនាលោកចែកជា ២ ប្រភេទគឺ :

១- បរិច្ចាគចំពោះបុគ្គល ឬចំពោះអង្គការដែលធ្លាប់រាប់អានធ្លាប់ចុះចូល ឬធ្លាប់ប្រាស្រ័យទាក់ទង

២- បរិច្ចាគចំពោះមនុស្សទូទៅ ឬចំពោះអង្គការរដ្ឋ អង្គការសាសនានិង អង្គការមនុស្សធម៌ទូទៅ។

ពាក្យថា "**ធ្វើខ្លួនឲ្យដល់ព្រមដោយបញ្ញា**" "បញ្ញា" សព្ទនេះ ដោយ សេចក្ដីថា "ការដឹងទូទៅ" ដោយន័យថា "វិជ្ជាសម្រាប់ស្រាវជ្រាវរកសេចក្ដីខុស ត្រូវ ឬរកសេចក្ដីពិតរបស់ធម្មៈ ឬរបស់ធម្មជាតិ ។ **បញ្ញានេះពុទ្ធសាសនាលោក ចែកចេញជា ២ ប្រភេទគឺ :**

**១- លោកិយបញ្ញា** បញ្ញាសម្រាប់ប្រើខាងផ្លូវលោកសុទ្ធ និងផ្លូវលោកដែលមានទាក់ទងជាមួយនឹងធម៌

**២- លោកុត្តិបញ្ញា** បញ្ញាសម្រាប់ប្រើខាងផ្លូវធម៌សុទ្ធ ដែលញែកចេញដាច់ដោយឡែកអំពីផ្លូវលោក។

សម្បទាសម្រាប់ផ្តល់វាសនាអនាគតនេះ ខ្ញុំមិនស្រង់យកមួយៗមកធ្វើអត្ថាធិប្បាយរែកញែកក្នុងសៀវភៅនេះទេ ព្រោះសម្បទាផ្នែកនេះ ខ្ញុំបាននិយាយមកខ្លះហើយក្នុងខាងដើម ត្រង់បទដែលពោលអំពីកម្មនិងទ្រឹស្តីនៃទាន សីល ភាវនា ប្រសិនបើសេចក្តីអធិប្បាយរបស់ខ្ញុំត្រឹមប៉ុណ្ណេះ នៅតែមិនល្មមដល់ការបកស្រាយរបស់អ្នកអាននោះ សូមពិនិត្យមើលក្នុងសៀវភៅឯទៀតផងចុះ។ ព្រោះសៀវភៅដែលស្តីដល់សម្បទាផ្នែកនេះ ក៏មានច្រើនណាស់ដែរហើយក្នុងប្រទេសយើង។

ក្នុងលំដាប់នេះ ខ្ញុំនឹងនិយាយអំពី **បរមត្ថសម្បទា** តទៅ។ បរមត្ថសម្បទា *ជាសម្បទាមួយដែលពុទ្ធបរិស័ទគួរបំពេញឲ្យបានច្រើន ព្រោះសម្បទានេះ មានការទាក់ទងដល់សេចក្តីពិតនៃជីវិតរបស់មនុស្សផង នៃវត្ថុធាតុនៅជុំវិញខ្លួននៃមនុស្សផង។ ពិសេសជាងនេះទៅទៀត គឺសម្បទានេះហើយដែលព្រះសម្មាសម្ពុទ្ធជាប្រមុខនៃសាសនារបស់យើង ព្រះអង្គទ្រង់រកឃើញផ្ទាល់ខ្លួន មិនបានកែប្រែចេញពីយោបល់ចាស់ និងមិនបានបដិវត្តចេញចាកលទ្ធិណា ឬទស្សនវិជ្ជាណា ឬសាសនាណាមួយសោះឡើយ ។*

កាលណាគេរស់នៅក្នុងលោកនេះយូរៗទៅគេរមែងមានសេចក្តី ធុញទ្រាន់ណាយដល់ជីវិតដែលជាទីស្នេហា ដល់វត្ថុធាតុដែលមាននៅជុំវិញនៃជីវិតរបស់គេ ព្រោះធម្មធាតុទាំងអស់នេះឋិតនៅក្នុងចលនាដដែលៗដូចៗគ្នា គឺ "*ចលនាប្រែប្រួល ចលនាធន់ទ្រាំ ចលនាបែកធ្លាយ*" ។ ដោយអាស្រ័យធុញទ្រាន់របស់សត្វទាំងឡាយនេះហើយ ទើបពុទ្ធសាសនាសំដែងចេញនូវបរមត្ថសម្បទាមួយទៀត។ បំណងរបស់ពុទ្ធសាសនាក្នុងរឿងនេះ គឺត្រូវការឲ្យមនុស្ស

គ្រប់គ្នាស្គាល់ភាពដទៃ ក្រៅពីភាពដែលខ្លួនធ្លាប់ស្គាល់មកហើយ។ ភាពដទៃនេះ លោកឲ្យឈ្មោះថា "**បរមត្ថសច្ចៈ**" ឬ "**បរមត្ថសម្បទា**" **សម្បទាផ្នែកនេះពុទ្ធសាសនាលោកចែកចេញជា ៤ យ៉ាងគឺ** :

**១- ទុក្ខសច្ចៈ** សេចក្តីពិតនៃទុក្ខ

**២- ទុក្ខសមុទសច្ចៈ** សេចក្តីពិតនៃហេតុរបស់ទុក្ខ

**៣- ទុក្ខនិរោធសច្ចៈ** សេចក្តីពិតនៃសេចក្តីរលត់ទុក្ខ

**៤-ទុក្ខនិរោធគាមិនីបដិបទាសច្ចៈ** សេចក្តីពិតនៃផ្លូវប្រតិបត្តិទៅកាន់សេចក្តីរលត់នៃទុក្ខ។

ពាក្យថា "**ទុក្ខសច្ចៈ**" ដោយអត្ថថា "**សេចក្តីពិតនៃចលនាធន់ទ្រាំ**" មានន័យថា ធម្មធាតុទាំងអស់ ទោះជារូបធាតុក្តី អរូបធាតុក្តី មានចលនាធន់ទ្រាំជានិច្ចកាល ។ ក្នុងពេលណាធាតុទាំងនោះអស់ចលនាធន់ទ្រាំ ក្នុងពេលនោះធាតុទាំងនោះក៏ប្រែក្លាយខុសពីសភាពដើមរបស់វាទៅ។ ឯចលនាធន់ទ្រាំនេះ ក៏ប្រែក្លាយទៅជាចលនាបែកធ្លាយទៅវិញ មនុស្សយើងបានឲ្យឈ្មោះចលនានេះថា "**សេចក្តីស្លាប់**" ។

ពាក្យថា "**ទុក្ខសមុទយសច្ចៈ**" ដោយអត្ថថា "*សេចក្តីពិតនៃការតាក់តែងបំណងដើម្បីចលនាធន់ទ្រាំ*" មានន័យថា សភាវៈធម្មតាទាំងអស់ ទោះជារូបសភាវៈក្តីអរូបសភាវៈក្តី មានចលនាតាក់តែងបំណងរបស់ខ្លួនដើម្បីចលនាធន់ទ្រាំ ដោយមានកម្លៅនៅក្នុងគំនិតថា ចលនានេះជាចលនាស្រួលងាយ។

ពាក្យថា "ទុក្ខនិរោធសច្ចៈ" ដោយអត្ថថា "*សេចក្តីពិតនៃចលនានាំចេញនូវចលនាធន់ទ្រាំ*" មានន័យថា ធម្មធាតុទាំងឡាយ ទោះជារូបធាតុក្តី អរូបធាតុក្តីរមែងមានគូប្រតិកិរិយា គឺបើមានចលនាធន់ទ្រាំ (ទុក្ខៈ) និងមានចលនាស្រួលងាយ (សុខៈ)។

ពាក្យថា "**ទុក្ខនិរោធគាមិនីបដិបទាសច្ចៈ**" ដោយអត្ថថា "*សេចក្តីពិតនៃផ្លូវប្រតិបត្តិដើម្បីរំដោះនូវចលនាធន់ទ្រាំ*" មានន័យថា ធម្មធាតុទាំងឡាយទោះជារូបធាតុក្តី អរូបធាតុក្តី ដែលជាគូប្រតិកិរិយានឹងគ្នានោះ បើកាលណាគ្មានផ្លូវ

ប្រតិបត្តិយ៉ាងពិតប្រាកដតាមហេតុផលទេនោះ ក៏មិនអាចទាត់ចោលនូវគូប្រតិកិរិយាម្ខាងទៀតបានឡើយ ។

ការវែកញែកបរមត្ថសម្បទាដោយសេចក្ដីខ្លីៗនេះ ខ្ញុំដឹងច្បាស់ថា អ្នកអានពិតជាពុំសូវយល់ទេ ។ ប៉ុន្តែធ្វើម៉េចបើបរមត្ថធម៌ជាធម៌ជ្រៅសែនជ្រៅ វែងសែនវែងហើយក្នុងសៀវភៅនេះ ខ្ញុំក៏មិនត្រូវការឲ្យមានទំព័រច្រើនហួសពេលផង។ ដូច្នេះដើម្បីឲ្យពួកយើងអ្នកកាន់ពុទ្ធសាសនា បានបំពេញបរមត្ថសម្បទាដូចសម្បទាឯទៀតដែរនោះ។ ខ្ញុំមិនឃើញមានផ្លូវឯណា ក្រៅអំពីផ្លូវសិក្សាបរមត្ថធម៌ឲ្យបានច្រើន ហើយឲ្យបានយល់អត្ថន័យដោយជ្រៅជ្រះផង គឺមានតែផ្លូវមួយនេះទេ ដែលធ្វើឲ្យការស្រាវជ្រាវឬការបំពេញបរមត្ថសម្បទារបស់យើង បានសម្រេចផលដោយឆាប់រហ័ស។

ម្យ៉ាងទៀតខ្ញុំដឹងដោយស្មានថា : អ្នកអានមុខជាចង់ឃើញនូវអ្វីមួយដើម្បីធ្វើជាស្ពាននៃគំនិតរបស់ខ្លួន បើពិតដូចនេះមែន ខ្ញុំសូមបញ្ជាក់ថា : ធម្មជាតុដែលជាស្ពាននៃគំនិតរបស់យើងមានច្រើន តែយើងកុំទាន់អាលដឹងច្រើនពេក ព្រោះកាដឹងព្រមគ្នាតែម្ដង ជាការនាំឲ្យខួរក្បាលរបស់យើងនឿយហត់ណាស់។ មុនដំបូងបង្អស់ យើងត្រូវរំពឹងគិតដល់សុភាសិតខាងវិទ្យាសាស្ត្រមួយបទថា *"អ្នកស្គាល់នូវវត្ថុធាតុណាជាយ៉ាងណា មិនមែនវត្ថុធាតុនោះជាយ៉ាងនោះ ដូចអ្នកបានស្គាល់នោះទេ តែអ្នកដែលស្គាល់នូវវត្ថុធាតុនោះថាជាយ៉ាងនោះ ក៏ព្រោះតែខ្លួនអ្នកក៏ជាមនុស្សយ៉ាងនោះដែរ"* បន្ទាប់មកត្រូវរំពឹងគិតដល់សុភាសិតនៃពុទ្ធសាសនាមួយបទថា *"អ្នកស្គាល់រុក្ខជាតិ តិណជាតិ ទេវជាតិ សត្វជាតិ ។ល។ ជាយ៉ាងណាមិនមែនជាតិទាំងអស់នោះជាយ៉ាងនោះ ដូចអ្នកស្គាល់នោះទេ តែអ្នកដែលស្គាល់ធម្មជាតិទាំងអស់នោះថា ជាយ៉ាងនោះ ក៏ព្រោះតែខ្លួនក៏ជាមនុស្សយ៉ាងដូច្នោះដែរ"* ។

ការចេះដឹងរបស់យើង ដែលជាមនុស្សធម្មតានិងការចេះដឹងរបស់អ្នកវិទ្យាសាស្ត្រផ្សេងគ្នា យើងស្គាល់វត្ថុធាតុមួយបែបថាជាទឹកសម្រាប់ងូតផឹក តែអ្នកវិទ្យាសាស្ត្រ ស្គាល់វត្ថុដែលនេះថាជាវត្ថុផ្សំ គឺមានធាតុអុកស៊ីហ្សែន និងអ៊ីដ្រូសែនប្រកបចូលគ្នា។ យើងស្គាល់គ្នាយើងថាជាមនុស្ស ជាសត្វ ។ល។ តែ

ពុទ្ធសាសនាខាងបរមត្ថស្គាល់ធម្មធាតុដដែលនេះថា ជាធាតុផ្សំ (ដី ទឹក ភ្លើង ខ្យល់ អាកាស វិញ្ញាណ) ។ យើងស្គាល់ដីសម្រាប់ដាំដំណាំ ទឹកសម្រាប់ងូត ផឹក ភ្លើងសម្រាប់ចំអិនបាយ ខ្យល់សម្រាប់ប្រាណអាកាសបង្កើតបានជាវត្ថុធាតុត្រជាក់ ថាជាបឋវីធាតុ អាបោធាតុ តេជោធាតុ វាយោធាតុ។ តែពុទ្ធសាសនាខាងបរមត្ថស្គាល់ថា បឋវី អាបោ តេជោ វាយោ ជាធាតុមើលមិនឃើញដោយភ្នែក ចាប់ពាល់មិនបានដោយដៃធម្មតាទេ។

បរមត្ថធម៌ក្នុងពុទ្ធសាសនា ត្រង់ចំណុចដែលស្ដីដោយរូបមានការវែកញែកបឋវីធាតុ អាបោធាតុ តេជោធាតុ វាយោធាតុ មួយៗមាន ៤ គឺ :

**១- លក្ខណៈបឋវី :** បានដល់សភាវៈធាតុ ដែលមាននៅក្នុងចន្លោះភាពរឹង និងភាពទន់ ឬរាវ និងខាប់

**២- សសម្ភារបឋវី :** បាលដល់សក់ រោម ឆ្អឹង សាច់ ។ល។ ដែលមាន នៅក្នុងរូបកាយមនុស្ស សត្វ

**៣- អារម្មណ៍បឋវី :** បានដល់ដី ដែលគេដាក់ក្នុងភាជនៈណាមួយដើម្បីធ្វើជាអារម្មណ៍របស់ចិត្ត នៃជនអ្នកចំរើនកម្មដ្ឋាន

**៤- សម្មតិបឋវី :** បានដល់ផែនដី សម្រាប់ធ្វើស្រែចំការជាដើម។

*ក្នុងបណ្ដាធាតុដីទាំង ៤ នេះ មានតែលក្ខណៈបឋវីមួយទេ ដែលលោកសង្គ្រោះចូលក្នុងបរមត្ថធម៌។ ចំណែកធាបោធាតុ តេជោធាតុ វាយោធាតុ ក៏ចែកជា ៤ ដូចគ្នា គឺគ្រាន់តែដកពាក្យ "បឋវី" ចេញអំពីសព្ទ "លក្ខណៈ" សសម្ភារៈអារម្មណៈ សម្មតិ ហើយដាក់ពាក្យថា "អាបោ តេជោ វាយោ" ចូលមកក៏ជាការស្រេច។* ឯសេចក្ដីវិញ ត្រូវកាន់យកដំណើរនៃធាតុទាំងឡាយនោះទៅក៏ទុកជាការស្រេចដូចគ្នាដែរ។ ការវែកញែកអំពីរឿងធាតុមកប៉ុណ្ណោះនេះ ខ្ញុំគ្មានបំណងអ្វីក្រៅអំពីឲ្យអ្នកអានទាំងឡាយស្គាល់ថា *ពុទ្ធសាសនារបស់យើងជាអភិបរមត្ថទស្សនវិជ្ជាមួយខាងផ្លូវរូប។* ចំណែកខាងផ្លូវចិត្តវិញ្ញាណវិញ ពុទ្ធសាសនាយើងក៏បានវែកញែកហើយកិនលំអិតតាមលក្ខណៈ តាមអាការៈ

តាមថាមពល ។ល។ ប្រហែលៗគ្នានឹងរូបដែរ ។ តាមការសង្កេតរបស់ខ្ញុំឃើញថា *ពុទ្ធសាសនាជាវិទ្យាសាស្ត្រផង ជាទស្សនវិជ្ជាផង ជាចិត្តសាស្ត្រផង ជាតក្កសាស្ត្រផង ។ល។ បើដូច្នេះ ការរស់នៅរបស់យើង តាមផ្លូវពុទ្ធសាសនា គឺជាការរស់នៅយ៉ាងខ្ពស់ជាងរបបរស់នៅដទៃៗ ព្រោះពុទ្ធសាសនា បានធ្វើការវែកញែករូបធាតុ និងអរូបធាតុយ៉ាងល្អិតជ្រាលជ្រៅ បានបញ្ជាក់ឲ្យឃើញនូវចលនានៃរូបធាតុនិងអរូបធាតុទាំងអស់នោះយ៉ាងច្បាស់លាស់ណាស់ ល្មមឲ្យយើងយកមកប្រើខាងរចនារៀបចំរូបធម៌និង អរូបធម៌ ឲ្យបានជាប្រយោជន៍ដល់ជីវិតគ្រប់ៗគ្នា ។*

## ហេតុអ្វី ទើបយើងត្រូវរស់នៅតាមរបបព្រះពុទ្ធសាសនា ?

ដោយហេតុថា មិនមានផ្លូវណាដទៃអាចធ្វើឲ្យយើងបានសម្រេចនូវអមតធម៌ដ៏ជាកំពូលនៃសេចក្តីពិត ព្រោះហេតុនោះ ទើបយើងត្រូវរស់នៅជាមួយនឹងពុទ្ធសាសនា ដោយខំសិក្សាឲ្យបានចូលចិត្តសេចក្តីដោយខ្លួនឯង ហើយខំប្រតិបត្តិតាមសេចក្តីពិតនោះ ដរាបដល់បានសម្រេចផល ដើម្បីធ្វើជីវិតឲ្យបានដល់នូវកំពូលនៃសេចក្តីពិតនោះ ដរាបដល់បានសម្រេចផល ដើម្បីធ្វើជីវិតឲ្យបានដល់នូវកំពូលនៃសេចក្តីដៅរបស់ពុទ្ធសាសនាយើង។ យើងទាំងឡាយត្រូវដឹងថា : សេចក្តីស្ទាត់ជំនាញខាងសភាវៈដ៏ពិតប្រាកដរបស់ជីវិតនោះហើយដែលអាចដឹកនាំជីវិតឲ្យបានល្អ អាចធ្វើឲ្យជីវិតបានដល់នូវចំណុចនៃការត្រាស់ដឹងដោយខ្លួនឯង មិនចាំបាច់មានអ្នកដទៃមកជួយផងឡើយ។

ធម្មៈរបស់ព្រះពុទ្ធបរមគ្រូ មានបំណងចង់ឲ្យមនុស្សធ្វើចៅហ្វាយនាយលើខ្លួនឯង បង្គាប់ខ្លួនឯង ប្រើខ្លួនឯង ពឹងខ្លួនឯង គោរពខ្លួនឯង ស្រឡាញ់ខ្លួនឯង ធ្វើការខ្លួនឯង។ល។ ព្រោះទំហើដូចនេះ ព្រះពុទ្ធបរមគ្រូទ្រង់ធ្លាប់ល្បងពិសោធមកលទ្ធផលគឺបានត្រាស់ដឹងជាព្រះពុទ្ធជាតិមកហើយ។

ពុទ្ធសាសនារបស់យើងបានបង្រៀនរឿយៗ នូវវិធីបណ្តុះបណ្តាលខាងផ្លូវចិត្តនិងកម្មវិធីអប់រំបន្ទំនិស្ស័យនៃមនុស្សជាតិ ដោយចាត់ទុកកម្មវិធីនេះថាជា

ឫសគល់ដ៏សំខាន់ និងជាការចាំបាច់ក្នុងការរចនាជីវិតនៃមនុស្ស ឲ្យចំរើនរុងរឿង។

*មេរៀនទាំងឡាយនៃពុទ្ធសាសនា ជាទស្សនវិជ្ជានៃកម្មនិយម* (Philosiphy of Activities) *មិនមែនជាទស្សនវិជ្ជានៃសេចក្ដីផ្សងព្រេងទេ គឺជាពុទ្ធទស្សនវិជ្ជាដែលពោរពេញទៅដោយសេចក្ដីដាស់តឿនយ៉ាង ក្បោះក្បាយឲ្យមនុស្សធ្វើការដើម្បីប្រយោជន៍សុខចំរើនខ្លួនឯង និងដើម្បីសុភមង្គលនៃសង្គមជន។*

ដើម្បីរស់នៅជាមួយគ្នា ប្រកបដោយសេចក្ដីសុខសាន្ត ពុទ្ធសាសនាបានប្រាប់ឲ្យមនុស្សគ្រប់គ្នារលឹកដល់ករណីយ៍ដែលត្រូវប្រតិបត្តិខ្លួនឯង និងករណីយ៍ដែលត្រូវប្រតិបត្តិចំពោះបុគ្គលដទៃ ដោយឲ្យមេរៀនខាងរួមរស់រួមប្រាស្រ័យទាក់ទងគ្នាយ៉ាងទូលំទូលាយ គឺរវាងមាតាបិតា ជាមួយនឹងបុត្រ អាចារ្យជាមួយនឹងសិស្ស ភរិយាជាមួយនឹងស្វាមី មិត្រជាមួយនឹងមិត្រ ធនបតិជាមួយនឹងកម្មករ សមណព្រហ្មណ៍ជាមួយនឹងឃរាវាស គប្បីមានទំនុកបំរុងគ្នាយ៉ាងណាខ្លះ ។ មេរៀននេះហើយ ដែលចាក់ជាឫសគល់យ៉ាងសំខាន់នាំឲ្យកើតមេត្រីចិត្តសាមគ្គីភាពនិងសេចក្ដីគោរពរាប់អានគ្នាច្រើនជាងប្រើមេរៀន "ព្រះតេជៈ" (Force) ដែលមនុស្សមុនពុទ្ធសម័យបានប្រើមក។ មេរៀនទាំងឡាយនេះ មាននៅក្នុង**សិង្គាលោវាទសូត្រ** ដែលខ្ញុំបាននិយាយមកហើយខាងផ្នែកស្ដីដោយសង្គមនិយម។

ក្នុងប្រទេសដែលប្រជាជាតិមានសេចក្ដីរាប់រកគ្នា មានមេត្រីចិត្តចំពោះគ្នានឹងគ្នា និងមានមនុស្សធម៌ប្រចាំសន្ដានដូចនេះ គោលបំណងសំខាន់បំផុតមិនមែនជាអ្វីដទៃក្រៅអំពី ស្វែងរកសេចក្ដីសុខជូនមនុស្សជាតិឡើយ។ រដ្ឋកើតមានឡើងដើម្បីប្រជាជាតិ សង្គមនិងសុភមង្គលនៃមនុស្សជាតិ មិនមែនមានឡើងដើម្បីជិះជាន់មនុស្សទេ។ ការទាក់ទងរវាងមនុស្សនឹងរដ្ឋ មិនមែនជាការធ្វើដោយសេចក្ដីខ្លាចដោយការសម្លឹងយកប្រយោជន៍ផ្ទាល់ខ្លួន ដោយការកំហែងសង្កត់សង្កិនឡើយ។ របបគ្រប់គ្រងដូចនេះ អាចកើតមានបានចំពោះតែក្នុងប្រទេសសេរីប្រជាធិបតេយ្យទាំងឡាយ ដូចយ៉ាងប្រទេសយើងដែល

ប្រជាជនរួមរស់នៅជាមួយគ្នា ដោយប្រើវឌ្ឍធម៌ខាងផ្លូវចិត្ត ជាគ្រឿងប្រមូលផ្តុំនូវមេត្រីភាព និងផ្សាយមេត្តាករុណាចិត្តដល់គ្នានឹងគ្នា តាមមេរៀននៃពុទ្ធសាសនានុ៎ះឯងៗ

ពាក្យថា "**សង្គមឬសង្គមនិយម**" ដែលខ្ញុំសរសេរក្នុងសៀវភៅនេះ គឺខ្ញុំចង់និយាយឲ្យគេចូលចិត្តថា មនុស្សទាំងឡាយដែលមានជីវិតរស់នៅក្នុងលោកនេះ នឹងនៅដាច់ឡែកម្នាក់ៗតាមទំនើងខ្លួនឯងពុំបាន ព្រោះយើងមានហេតុការណ៍ចាំបាច់តម្រូវឲ្យនៅរួមគ្នា ជាពួក ជាបន ជាសមាគម ជាជាតិ ។ល។ កុំថាឡើយតែមនុស្សយើង សូម្បីតែរុក្ខជាតិឈើព្រៃ ក៏វាចូលចិត្តរស់នៅតាមបន ដុះឡើងតាមពួករបស់វា។ ចំណែកសត្វតិរច្ឆានក៏មានការរស់នៅជាបន។ យើងធ្លាប់ឃើញត្រីនៅក្នុងទឹក វាហែលទៅណាមកណាតាមហ្វូងរបស់វា បក្សីក្នុងអាកាសវាហើរទៅណាមកណាតាមហ្វូងរបស់វា ពួកសត្វល្អិតមានស្រមោចជាដើម ក៏វាចូលចិត្តរស់នៅក្នុងហ្វូងក្នុងបនរបស់វា វាទៅណាមកណាម្តងៗ វានាំគ្នាដើរជាក្បួនជាថៃវមាន ខ្សែវែងៗ សត្វម្រឹគក៏មានហ្វូងមានបនដែលគេនិយមហៅថាហ្វូងឆ្កែព្រៃ ហ្វូងជ្រូកព្រៃ ហ្វូងក្របីព្រៃ ខ្លោងដំរីព្រៃ ។ល។ ការរួមរស់នៅជាមួយគ្នា ជាការចាំបាច់សម្រាប់ជាតិ គណៈ ហ្វូង បន ខ្លោង ។ល។ ព្រោះមនុស្សតែម្នាក់ ឬសត្វតែមួយក្បាល ពុំអាចប្រយុទ្ធតទប់នឹងគ្រោះថ្នាក់ ដែលបណ្តាលមកពីធម្មជាតិអំពីមនុស្សពួកដទៃ ឬអំពីហ្វូងសត្វដទៃបានទេ។ ក្នុងសង្គមមនុស្សក្តី ក្នុងសង្គមសត្វក្តី គេតែងរៀបចំឲ្យមានវិន័យមានច្បាប់ សម្រាប់ធ្វើឲ្យការរស់នៅនោះ ប្រព្រឹត្តទៅក្នុងរបៀបរៀបរយ។ ពិសេសជាងនេះទៅទៀត គឺគេអប់រំគ្នាឲ្យមានសីលធម៌ និងមនុស្សធម៌ ដើម្បីធ្វើឲ្យសង្គមបានប្រសើរថ្លៃថ្នូរប្រកបដោយអារ្យធម៌ខ្ពង់ខ្ពស់ដែលជាទីដៅចុងបំផុតនៃជីវិតរបស់មនុស្សលោក។ មនុស្សឬសរូបណាប្រព្រឹត្តល្មើសបទបញ្ញត្តិនៃសង្គមមនុស្សសត្វពួកនោះត្រូវទោសដោយបណ្តេញចេញ ឬដោយធ្វើទណ្ឌកម្មណាមួយ តាមការគួរដល់កំហុសរបស់ខ្លួន។ តែបើមនុស្សណាឬសត្វណាមានសេចក្តីប្រព្រឹត្តរៀបរយ មានសីលធម៌ល្អ មានសេចក្តីឈឺឆ្អាលយកចិត្តទុកដាក់ធ្វើការ

ឲ្យសង្គមបានចំរើន សង្គមក៏រាប់អានលើកតំកើងអ្នកនោះជាវិរបុរសរបស់ជាតិ ឬរបស់ពួកគណៈ។

កាលយើងចូលចិត្តថា : សង្គមគឺការរួមរស់នៅជាមួយគ្នា ជាពួកគណៈ ឬជាប្រជាជាតិយ៉ាងនេះហើយ យើងក៏នឹងអាចដឹងថា : ព្រះពុទ្ធសាសនាមានប្រយោជន៍ដល់សង្គមយ៉ាងណាខ្លះ។ ដើម្បីឲ្យបានចូលចិត្តដល់រឿងនេះភ្លាមៗ ខ្ញុំសូមឲ្យអ្នកអាននឹកថយទៅក្រោយវិញ នឹងបានចូលចិត្តជាមិនខាន ព្រោះខ្ញុំបាននិយាយមកហើយក្នុងវគ្គដែលស្តីអំពីសង្គមនិយម តាមរបបព្រះពុទ្ធសាសនា។ នៅក្នុងឃ្លានេះ ខ្ញុំសូមកញ្ជាក់ជាថ្មីទៀត ដើម្បីឲ្យសេចក្តីបានខ្លីងាយចាំ។ ហើយមានន័យធំទូលាយស្រួលធ្វើវិចារណញ្ញាណ ក្នុងពុទ្ធធម៌ទាំងអស់តែម្តង។ តាមការស្រាវជ្រាវរបស់ខ្ញុំឃើញថា មេរៀនដែលពុទ្ធសាសនាបានបង្កើតឡើង ដើម្បីរកសេចក្តីសុខស្ងប់ រកពន្លឺត្រចេះត្រចង់ ឲ្យជីវិតមនុស្សនោះមានច្រើនណាស់។ តែបើបំព្រួញឲ្យតិចមក មានត្រឹមតែពីរប៉ុណ្ណោះទេ គឺទី១ "**សិក្ខានៃសីលធម៌**" ទី២ "**សិក្ខានៃវិបស្សនាធម៌**" តាមគោលបំណងនៃមេរៀននេះ។ ខ្ញុំអាចបញ្ជាក់បានថា : ពុទ្ធសាសនាត្រូវការឲ្យមនុស្សយើង រៀនរស់នៅជាមួយគ្នា ចាប់តាំងពីរៀនដេក រៀនដើរ រៀនអង្គុយ រៀនឈរ រៀននិយាយ រៀនស្នេហា ។ល។ ក្នុងបណ្តាមេរៀនទាំងឡាយរាប់ពាន់ ខ្ញុំសូមស្រង់យកតែមេរៀនមួយ គឺរៀនស្នេហាមកអធិប្បាយវែកញែកក្នុងទីនេះ ។ អ្នកអានទាំងអស់គ្នាមុខជាចង់ដឹង ថាតើខ្ញុំមានបំណងយ៉ាងណាបានជាខ្ញុំរាប់អានមេរៀននេះជាងគេ។ ខ្ញុំសូមឆ្លើយថា : *បានជាខ្ញុំស្រឡាញ់មេរៀននេះជាងគេ ព្រោះខ្ញុំស្រឡាញ់យុវជនយុវនារីរបស់ជាតិ របស់សាសនាយើង ព្រោះគេទាំងឡាយជាអនាគតរបស់ប្រទេស។ ខ្ញុំត្រូវការចង់ឲ្យគេទាំងអស់គ្នា រស់នៅក្នុងសេចក្តីស្នេហាមួយយ៉ាងបរិសុទ្ធ ប្រកបដោយសេចក្តីថ្លៃថ្នូរនិងប្រកបដោយឧត្តមគតិយ៉ាងខ្ពស់ ដែលអាចចាត់ទុកថាជាឋានសួគ៌នៃជីវិតរបស់គេបាន នៅក្នុងពិភពលោកនៃមនុស្សនេះ។*

ពុទ្ធសាសនារបស់យើង មិនមែនត្រឹមតែមិនពេបជ្រាយឲ្យគូស្នេហា ប៉ុណ្ណោះទេ។ តែពុទ្ធសាសនាបានទាំងជួយគាំទ្រ និងជួយសរសើរលើកទឹកចិត្ត ដល់គូស្នេហាទាំងនោះទៀតផង ប្រសិនបើស្នេហារបស់គេបានដើរទៅក្នុងផ្លូវ ត្រូវ។ ក្នុងពុទ្ធដំណើរទៅកាន់ផ្ទះអនាថបណ្ឌិកសេដ្ឋីក្នុងពេលមួយនោះ ព្រះអង្គ បានឮសម្លេងជេរប្រមាថមើលងាយស្វាមីនៃស្ត្រីម្នាក់ ជាកូនរបស់ម្ចាស់ផ្ទះនោះ ។ ព្រះអង្គទ្រង់បានក្រើនរំលឹកហើយឲ្យមេរៀនថា : *សេចក្ដីស្នេហាគេមិនមែន យកមកប្រើត្រឹមតែក្នុងនាទី ឬក្នុងករណីយ៍ជាប្ដីប្រពន្ធតាមប្រពៃណីខាងផ្លូវ កាមប៉ុណ្ណោះទេ ការពិសេសជាងនេះទៅទៀត គឺគេប្រើជាអាហាររបស់ជីវិត ទៀតផង ។* ដោយមានគេចោទសួរអំពីរឿងនេះ ព្រះអង្គទ្រង់ឆ្លើយថា : *សេចក្ដីស្នេហាបើគេលះបង់បានជាការល្អណាស់ ព្រោះសេចក្ដីស្នេហានេះ វានាំឲ្យ បង់ខាតពេលវេលារបស់ជីវិតច្រើនណាស់។* ប៉ុន្តែបើគេលះបង់ពុំបានទេ គេ ត្រូវតែសិក្សានូវបច្ចេកទេសនៃសេចក្ដីស្នេហានោះឲ្យបានជ្រៅជ្រះ មុននឹងខ្លួន ដែលចូលទៅកាន់វិមាននៃសេចក្ដីស្នេហា។ *មេរៀនទាំងឡាយដែលអ្នកស្នេហា ត្រូវចេះនោះ មានច្រើនណាស់ តែក្នុងទីនេះ ខ្ញុំសូមស្រង់យកតែមេរៀនធំៗ ដែលខាងប្ដីត្រូវរៀនឲ្យបានប្រាំមាត្រិកា ខាងប្រពន្ធត្រូវរៀនឲ្យបានប្រាំមាត្រិកា ដូចតទៅ។*

**មេរៀនខាងប្តីមាន ៥ យ៉ាងគឺ :**

១- ស្វាមីគប្បីសិក្សាថា *"អញនឹងស្រឡាញ់រាប់អានលើកតម្កើងនូវស្ត្រីជា ប្រពន្ធរបស់អាត្មាអញឲ្យទាល់តែបាន ទោះណាជាមានឧបសគ្គយ៉ាងណាក៏ ដោយ។*

២- ស្វាមីគប្បីសិក្សាថា *"អញនឹងមិនប្រមាថមើលងាយស្ត្រីជាប្រពន្ធ របស់អញឡើយ ទោះជានាងធ្វើឲ្យអញទាស់ចិត្ត យ៉ាងណាក៏ដោយ"* ។

៣- ស្វាមីគប្បីសិក្សាថា *"អញនឹងមិនប្រព្រឹត្តក្បត់ស្នេហាដែលខ្លួនអញ ស្ម័គ្រចិត្ត ព្រមប្រគល់សេចក្ដីស្នេហានេះទៅឲ្យប្រពន្ធរបស់អាត្មាអញ ក្នុងថ្ងៃ បង្ហើយនៃមង្គលការ ទោះជាមាននារីណាប្រលោម ឬប្រើកម្លាំងណាមួយក៏*

*ដោយ"* ។

៥- ស្វាមីគប្បីសិក្សាថា *"អញនឹងរៀបចំឲ្យប្រពន្ធអញ មានប្រដាប់តាក់តែងកាយ តាមដែលអញយល់ឃើញថាល្អ និងតាមសេចក្តីត្រូវការរបស់នាង ទោះជាអ្នកណាថាម៉េចក៏ដោយ"* ។

**មេរៀនខាងប្រពន្ធមាន ៤ យ៉ាងគឺ :**

១- ភរិយាគប្បីសិក្សាថា *"ខ្លួនអញនឹងចាត់ចែងការដែលគ្រួសាររស់នៅជាមួយគ្នា ត្រូវធ្វើឲ្យបានល្អពិសេស ដើម្បីសុភមង្គលគ្រប់ទិវារាត្រីកាល ទោះជាទំហើនេះមានសេចក្តីលំបាកតឹងតែងយ៉ាងណាក៏ដោយ"* ។

២- ភរិយាគប្បីសិក្សាថា *"ខ្លួនអញនឹងធ្វើសេចក្តីគារវៈរាប់អាន ព្រមជាមួយដោយសេចក្តីសង្គ្រោះដល់ញាតិមិត្តជិតខាងនៃស្វាមីរបស់អញ ដោយសេចក្តីស្និទ្ធស្នាលជាទីបំផុត ទោះជាមានអ្នកណាមករាំងរាយ៉ាងណាក៏ដោយ"* ។

៣- ភរិយាគប្បីសិក្សាថា *"ខ្លួនអញនឹងមិនប្រព្រឹត្តក្បត់ចិត្តស្នេហារបស់ស្វាមីដោយមិននាំយកសេចក្តីស្នេហារបស់ខ្លួនទៅបូជាបុរសដទៃ ដោយដាច់ខាត ទោះជាបុរសណាលួងលោមចែចង់ដោយប្រើឥរិយាបថទន់ភ្លន់ តាមផ្លូវចិត្តសាស្ត្រក្តី ឬព្រលោមចែចង់ដោយប្រើកម្លាំងអំណាចណាមួយ មានអំណាចទ្រព្យជាដើមក្តី"* ។

៤- ភរិយាគប្បីសិក្សាថា *"ខ្លួនអញនឹងខំប្រឹងឲ្យអស់ពីសមត្ថភាពដើម្បីរក្សាទុកនូវទ្រព្យសម្បត្តិរបស់គ្រួសារ និងការពារនូវស្ថិរភាពរបស់គ្រួសារ មិនឲ្យបាត់បង់រលំរលាយទៅ ដោយប្រើមធ្យោបាយទាំងអស់ណា ដែលខ្លួនអញអាចធ្វើទៅកើត "* ។

៥- ភរិយាគប្បីសិក្សាថា *"ខ្លួនអញនឹងប្រឹងប្រែងធ្វើកិច្ចការបំរើគ្រួសារដោយការយកចិត្តទុកដាក់ជាទីបំផុត ដើម្បីធ្វើឲ្យគ្រួសាររបស់អញមានជំហររឹងប៉ឹង តាមសមត្ថភាពដែលអញអាចធ្វើបាន"* ។

បុរសស្ត្រីកាលបើបានអនុវត្តមេរៀនទាំងអស់នេះ ទៅលើគូជីវិតស្នេហារបស់ខ្លួនហើយ សេចក្តីស្នេហារបស់គេឈ្មោះថា បានឈានមួយជំហានទៅរក

វឌ្ឍនភាពនៃសេចក្ដីស្នេហាហើយ។ *តែសេចក្ដីស្នេហានេះ មិនទាន់បានចាក់ឫស មាំមួននៅឡើយទេ ព្រោះសេចក្ដីស្នេហាបែបនេះ ជាធម្មតាឋិតនៅក្នុងនាទី គឺបុរសស្ត្រីនេះ បានបូជាស្នេហារបស់ខ្លួនទៅវិញទៅមក សំអាងទៅលើនាទីជាប្ដីប្រពន្ធ សំអាងទៅលើករណិយ៍ដែលបានធ្វើដល់គ្នានឹងគ្នាតែប៉ុណ្ណោះ ។ សេចក្ដីស្នេហាមានសភាពដូចនេះនឹងត្រូវលោយបាត់បង់ទៅវិញដោយអាស្រ័យហេតុពីរប្រការគឺ :*

*១- ដោយសេចក្ដិប្រតិបត្តិមិនដិតដល់ក្នុងនាទី ឬក្នុងករណិយ៍ណាមួយរបស់គូស្នេហាម្នាក់ៗ ឬទាំងពីរនាក់*

*២- ដោយមានបុរសស្ត្រីដទៃ ដែលមានសេចក្ដីខ្លាំងពូកែខាងផ្លូវចិត្តសាស្ត្រមកជ្រៀតជ្រែក។*

ពុទ្ធសាសនា ដែលមានធម្មៈទាក់ទងជាមួយនឹងសេចក្ដីស្នេហាបានដៅបញ្ជាក់ថា *ស្នេហាកើតឡើងដោយឆាប់រហ័សដែរប្រសិនបើសេចក្ដីស្នេហានោះគេមិនមានចងដោយចំណងចិត្តសាស្ត្រ ។* ដូច្នេះបុរសស្ត្រីដែលជាម្ចាស់នៃសេចក្ដីស្នេហា ដែលត្រូវការធ្វើឲ្យសេចក្ដីស្នេហារបស់ខ្លួនមានសេចក្ដីឋិតថេរខ្ជាប់ខ្ជួននោះ គប្បីសិក្សាវិជ្ជាប្រើចិត្ត ឬចិត្តសាស្ត្រ ជាពិសេសគឺចិត្តសាស្ត្ររវាងពេស[(១)] ឲ្យបានច្រើន ហើយត្រូវយកវិជ្ជានោះមកប្រើបន្ថែមលើសេចក្ដីស្នេហាតាមនាទីនោះទៀតចុះ ។ តាមក្បួនចិត្តសាស្ត្រនេះ មានសេចក្ដីពិស្ដាពេក ខ្ញុំមិនអាចលើកយកមកនិយាយក្នុងសៀវភៅនេះបាន តែខ្ញុំក៏អាចចង្អុលគោលនិងបញ្ជាក់ន័យខ្លះ ដូចមានតទៅ ។

តាមសេចក្ដីពិតចិត្តសាស្ត្រ មិនមែនកើតឡើងដោយសិក្សាតាមក្បួនតែម៉្យាងទេចិត្តសាស្ត្រជាធម្មជាតុមានស្រាប់ នៅក្នុងប្រាណនៃមនុស្សយើងនេះខ្លះដែរ។ ប្រជាជាតិចិន ដែលគេធ្វើជាអ្នកលក់ដូរបានប្រសើរជាងជាតិដទៃនោះមកពីគេមានចិត្តសាស្ត្រពីកំណើតខ្លះ ចិត្តសាស្ត្រកើតឡើងក្នុងបច្ចុប្បន្នតាមការនៅអាស្រ័យរូបរួមជាមួយគ្នាខ្លះ និងចិត្តសាស្ត្រកើតឡើងដោយរៀនតាមក្បួន

---

(១) "ពេស" ធ្លាប់ប្រើមកថា "ភេទ" ក្នុងទីនេះប្រើថា ពេសវិញ សំដៅយកអវយវៈដែលធ្វើឲ្យបុរសស្ត្រីផ្លែកគ្នា។

ខ្លះ។ ក្នុងក្បួនសេដ្ឋកិច្ចបាននិយាយថា *"ជនណាមិនមានសេចក្តីញញឹមស្រស់នៅលើបបូរមាត់អស់កាលជានិរន្តរ៍ ជននោះមិនត្រូវបើកផ្ទះលក់ទំនិញទេ"* ។ ខាងក្បួនពុទ្ធសាសនាមាននិយាយថា *"ជនណាមិនមានសេចក្តីញញឹមស្រស់សរាយនៅគ្រប់ឥរិយាបថទាំងអស់ ឬមិនមានចិត្តនឹងន ជននោះមិនអាចធ្វើទានឲ្យមានផលច្រើនទេ ។* បើតាមន័យនេះឃើញថា : ចិត្តសាស្ត្រ គឺចិត្តរបស់មនុស្សយើង ដែលគេបានហ្វឹកហាត់អប់រំឲ្យចេះប្រើអាការៈ ប្រើឥរិយាបថ ប្រើកាយវិការ វចីវិការផ្លែកៗ ដើម្បីទាក់ទាញអារម្មណ៍អ្នកដទៃ ឲ្យចូលមកនៅក្នុងសេចក្តីបំណងរបស់គេ ឬដើម្បីធ្វើអ្នកដទៃឲ្យស្រឡាញ់រាប់អានគេ។ ដូច្នេះ បុគ្គលណា ដែលមិនបានប្រើចិត្តសាស្ត្រ បុគ្គលនោះមិនអាចធ្វើការទាក់ទងជាមួយបុគ្គលដទៃបានល្អឡើយ ទោះជាការស្នេហាក្តីការអាជីវកម្មនានាក្តី ។ល។

*ការជាចាំបាច់ដែលគូជីវិតស្នេហា ត្រូវធ្វើដល់គ្នានឹងគ្នានោះ គឺការប្រើចិត្តសាស្ត្រផ្សំជាមួយនឹងមុខការទាំងអស់។ ជាមួយនឹងការផ្ទះ មានការបោសសំអាតផ្ទៃនាប ការគត់បោកសំលៀកបំពាក់ ការធ្វើម្ហូបអាហារ ការទទួលភ្ញៀវ ។ល។ ភរិយាត្រូវធ្វើដោយថ្នាក់ថ្នម ប្រកបដោយឥរិយាបថទន់ភ្លន់ ចេះថ្នមដៃក្នុងពេលលូកចាប់វត្ថុផ្សេងៗ ចេះសម្រាលជើងក្នុងពេលដើរ ចេះបន្ទន់សម្លេងក្នុងពេលត្រូវនិយាយ ចេះធ្វើទឹកមុខស្រស់ស្រាយក្នុងពេលងាកមុខចំស្វាមី ។ល។* ការផ្ទុយពីនេះនារីមានចិត្តសាស្ត្រគឺ[១] មិនធ្វើឡើយ។ *មានស្ត្រីខ្លះចង់ទាញចិត្តស្វាមីឲ្យបំរើសេចក្តីស្នេហារបស់ខ្លួន ដោយសម្រស់នៃរូបកាយធម្មជាតិ ដោយឥទ្ធិពលនៃភោគទ្រព្យរបស់ត្រកូល របស់ទាំងអស់នេះតាមក្បួនចិត្តសាស្ត្រសំដែងថា មិនមែនជាវត្ថុធាតុសម្រាប់ធ្វើឲ្យសេចក្តីស្នេហាមានកម្លាំងបានទេ គឺជាវត្ថុធាតុសម្រាប់ធ្វើឲ្យសេចក្តីស្នេហាមានកម្លាំងអន់ខ្សោយចុះទៅរាល់ៗនាទី ព្រោះសម្រស់រូបកាយធម្មជាតិក្តីភោគទ្រព្យក្តីដែលគេប្រើដោយមិនបានផ្សំលាយជាមួយចិត្តសាស្ត្រនោះ យូរៗទៅនឹងធ្វើឲ្យគូស្នេហាធុញទ្រាន់ពុំខាន។*

(១) គឺធ្លាប់ប្រើមកថា "គេ" ក្នុងទីនេះប្រើថា គឺ វិញ ព្រោះតួសព្វនាមជា ឥត្ថិលិង្គ បើមិនប្រើ គឺ ប្រើនាងវិញក៏បាន។

បុគ្គលមានចិត្តសាស្ត្រ គេអាចយកសម្រប់រូបកាយធម្មជាតិ និងភោគទ្រព្យរបស់គ្រួសារ មករចនាជាមួយនឹងវត្ថុវិទ្យាសាស្ត្រ ធ្វើឲ្យរូបកាយរបស់គេមានលំអនិងមានសម្រស់ឆ្លែកៗ នឹងធ្វើឲ្យវត្ថុប្រើប្រាស់របស់គេមានទំរង់សមសួន និងមានរសជាតិឆ្ងាយ់ពិសារាល់ៗពេល។ *សេចក្តីស្នេហារបស់គេក៏មានកម្លាំងទ្វេឡើងជាលំដាប់ចំពោះរឿងស្នេហានេះ ពុទ្ធសាសនាថា កើតឡើងដោយហេតុ ២ យ៉ាងគឺ :*

*១- ដោយគូស្វាមីភរិយានេះ ធ្លាប់រួមសេចក្តីស្នេហាជាមួយគ្នា ដោយសេចក្តីបរិសុទ្ធក្នុងបុព្វជាតិ*

*២- ដោយធ្លាប់រាប់អានគ្នា ឬធ្លាប់ប្រាស្រ័យទាក់ទងការងារជាមួយគ្នាក្នុងបច្ចុប្បន្ន។*

ចំណុចនៃពុទ្ធសាសនាត្រង់នេះ បញ្ជាក់ឲ្យយើងឃើញថា សេចក្តីស្នេហាដែលគេទាក់ភ្ជាប់ ដោយឥទ្ធិពលនៃចិត្តសាស្ត្រក្នុងអតីតជាតិ ជាសេចក្តីស្នេហាមានកម្លាំងខ្លាំងបំផុត អាចទាញគូស្នេហាឲ្យមកជួយគ្នាក្នុងបច្ចុប្បន្នបាន។ ឯសេចក្តីស្នេហាដែលគេទាក់ភ្ជាប់ដោយឥទ្ធិពលទាំងឡាយ មានឥទ្ធិពលនៃត្រកូលនិងទ្រព្យសម្បត្តិជាដើមនោះ ពុំអាចចងភ្ជាប់សេចក្តីស្នេហារវាងគ្នានឹងគ្នាពីជាតិនេះទៅជាតិមុខបានទេ។ បើយ៉ាងពូកែណាស់ បានត្រឹមតែមួយជីវិតក្នុងជាតិនេះប៉ុណ្ណោះ។ តែដែលគេបានឃើញជារឿយៗមកហើយនោះ គូស្នេហាបែបនេះច្រើនតែបោះបង់ចោលគ្នាក្នុងជីវិតបច្ចុប្បន្ននេះផង។ ចំណែកមាតាបិតាដែលមានទីជាអ្នករកស្វាមីភរិយាឲ្យកូននោះ តាមសេចក្តីណែនាំនៃពុទ្ធសាសនាថា : ត្រូវរើសរកឲ្យមានតុល្យភាពដោយយោវង្សត្រកូល ទ្រព្យសម្បត្តិ ។ល។ ជំរើសនេះ មិនមែនប្រយោជន៍អ្វី ក្រៅពីការពារមិនឲ្យស្វាមីភរិយាទាំងគូនេះណាមួយ យកកម្លាំងទ្រព្យសម្បត្តិគោត្តត្រកូលមកប្រើជាមធ្យោបាយជិះជាន់សង្កត់សង្កិនគ្នា ដែលជាហេតុនាំឲ្យសេចក្តីស្នេហាមានសេចក្តីប្រេះឆាក្នុងអនាគតប៉ុណ្ណោះ ប្រសិនបើគេយល់ឃើញថាមិនជាអ្វីទេ មិនបាច់ជ្រើសរើសក៏បាន។ ស្នេហាដោយសេចក្តីសន្តោស ក៏ជាមេរៀនមួយរបស់ពុទ្ធសាសនាដែរ ក្នុងមេរៀននេះបានចែងថា សេចក្តីស្នេហាបើគេប្រើប្រាស់ដោយគ្មានសេចក្តី

សន្តោស (គ្មានសំចៃ) គឺគេចេះតែប្រើតាមអារម្មណ៍របស់គេ។ គេមិនខ្វីរវល់គិតគូរដល់អារម្មណ៍នៃគូជីវិតស្នេហា ដើម្បីឲ្យដឹងថា តើគូស្នេហានោះ មានសេចក្តីស្កប់អារម្មណ៍នឹងចលនាស្នេហារបស់ខ្លួនឬទេ ឬមួយគេប្រើសេចក្តីស្នេហាហួសព្រំដែន គឺគេប្រើទៅលើបុរសស្រ្តីដទៃ គេមិនមានសេចក្តីក្រែងចិត្តគូជីវិតរបស់គេ។ ការប្រើសេចក្តីស្នេហាប្រាសចាកសេចក្តីសន្តោសដូចនេះ គូស្នេហាមិនអាចត្រងរក្សានូវសេចក្តីស្នេហារបស់ខ្លួនបានទេ។ ដូច្នេះ *បុរសស្រ្តីគួរតែប្រព្រឹត្តសន្តោសក្នុងស្វាមីក្នុងភរិយារបស់ខ្លួន គឺធ្វើយ៉ាងណាឲ្យសេចក្តីស្នេហាមានតុល្យភាពមានសេចក្តីបរិសុទ្ធ ដែលពុទ្ធសាសនាចាត់ទុកថាជា "***ព្រហ្មចរិយធម៌***" គឺជាចរិយាថ្លៃថ្នូរមួយក្នុងផ្នែកសីលធម៌ ។*

សេចក្តីស្នេហា ដែលកើតមានឡើងនៅក្នុងលក្ខណៈចំពោះត្រឹមតែពេស គឺ អវយវៈកំបាំងរបស់បុរសស្រ្តីដែលជាអណ្តូង ជាទីញ៉ាំងអារម្មណ៍ស្នេហាឲ្យកើតឡើងនោះ ជាសេចក្តីស្នេហាមានរសជាតិជូរចត់ណាស់ ជាសេចក្តីស្នេហាតែលតោលឃ្លេងឃ្លោងមិនមានកម្លាំងរឹងប៉ឹងទេ។ ម្ចាស់ស្នេហាចង់ប្រើក៏ប្រើទៅ មិនចង់ប្រើក៏បោះបង់ចោលទៅ ព្រោះសេចក្តីស្នេហានេះ កើតឡើងព្រោះតែពេស មិនមែនកើតឡើងដោយមេត្រីចិត្តទេ អ្នកប្រាជ្ញខាងសត្វសាស្រ្តបាននិយាយថា : *សេចក្តីស្នេហាចំពោះពេសនេះ មានច្រើនក្នុងចំណោមសត្វតិរច្ឆាន ជាពិសេសគឺមានច្រើនក្នុងចំណោមសត្វសុនខ។ ពួកសត្វនេះ វាមានត្រឹមតែសេចក្តីស្នេហា តែវាមិនមានសេចក្តីអាណិតគ្នាទេ កាលណាវាមានសេចក្តីស្នេហា វាក៏ស្នេហាគ្នាវាទៅ កាលណាវាលែងត្រូវការ វាក៏ដេញខាំគ្នាភ្លាមទៅ ការទំនុកបំរុងគូស្នេហា មិនមានក្នុងពួកសត្វទាំងឡាយនេះទេ។* ដោយព្រះពុទ្ធសាសនា ជាសាសនាសម្រាប់ជីវិតទូទៅ ទោះជាសាសនានេះមិនបានដឹកនាំឲ្យគេស្នេហាគ្នាតាមផ្លូវកាម។ ប៉ុន្តែបើគេស្នេហាគ្នា សាសនានេះក៏បានជួយណែនាំឲ្យគេស្នេហាគ្នាដោយមនុស្សធម៌ គឺគូស្នេហាមិនត្រូវស្នេហាគ្នាតែត្រឹមពេសប៉ុណ្ណោះទេ ត្រូវមានសេចក្តីស្នេហាដល់រូបកាយចិត្តវិញ្ញាណនិងវត្ថុធាតុនៅជុំវិញរូបមនុស្ស ដែលខ្លួនស្នេហានោះផង។ ពុទ្ធសាសនាត្រូវការឲ្យមនុស្សរស់នៅក្នុងសេចក្តីស្នេហា ប្រកបដោយមនុស្សធម៌ ដូចខ្ញុំបាននិយាយ

ក្នុងខាងដើមហើយ។ ដូច្នេះ *បុរសស្ត្រីម្នាក់ៗ បើនឹងនាំជីវិតរបស់ខ្លួនចូលទៅកាន់ពិធីមង្គលការនោះ គប្បីយកមេរៀនស្នេហាទាំងអស់មកពិចារណា បកស្រាយឲ្យបានជ្រៅជ្រះមុនសិន កុំអាលប្រញាប់ប្រញាល់តាមកម្លាំងស្នេហាបង្ខំ ព្រោះថាជីវិតស្នេហាត្រូវបានឡើងកាន់ឋានសួគ៌ ក៏ព្រោះស្នេហាប្រកបដោយមនុស្សធម៌ ជីវិតស្នេហាត្រូវបានធ្លាក់ចុះឋាននរកក៏ព្រោះស្នេហាប្រកបដោយស្នេហាអមនុស្សធម៌ហ្នឹងឯង ។ ស្នេហាដោយបង្ខំចិត្ត ស្នេហាដោយសម្លឹងទ្រព្យសម្បត្តិ ។ល។ ជាស្នេហាអកុសល។ ស្នេហាដោយស្មោះស្ម័គ្រ ស្នេហាដោយមនុស្សធម៌ ។ល។ ជាកុសលស្នេហា។*

សិក្ខានៃសីលធម៌ ដែលខ្ញុំបាននិយាយមកនេះ មិនបានពិស្តារទេ តែមានគោលនិងអត្ថន័យ ល្មមឲ្យអ្នកអានធ្វើអត្ថាធិប្បាយដោយខ្លួនឯងបានហើយ ។ ក្នុងលំដាប់នេះ ខ្ញុំនឹងលើកយក **សិក្ខានៃវិបស្សនាធម៌** មកនិយាយតទៅ តែដោយវិបស្សនាធម៌នេះ មានសេចក្តីពិស្តារណាស់ផង មានអត្ថសេចក្តីជ្រាលជ្រៅណាស់ផង ខ្ញុំនឹងនិយាយត្រឹមតែបន្តិចបន្តួច ឃើញថាមិនអាចឲ្យអ្នកអានចេះដឹងបានទេ ។ ដូច្នេះ អ្នកអានសូមយកគម្ពីរព្រះត្រៃបិដក និងសៀវភៅដទៃៗទៀតមកសិក្សាផងចុះព្រោះសៀវភៅផ្នែកនេះក្នុងប្រទេសខ្មែរយើងមានច្រើនណាស់ហើយ។ ក្នុងទីនេះខ្ញុំសូមបញ្ជាក់ត្រឹមតែសព្ទថា សិក្ខានៃវិបស្សនាធម៌ និងតួយ៉ាងនៃបុគ្គលខ្លះ ដែលបានសម្រេចមគ្គផលដោយសិក្ខានៃវិបស្សនាធម៌នេះប៉ុណ្ណោះ។ "**សិក្ខានៃវិបស្សនា**" ដោយសេចក្តីថា *ធម៌សម្រាប់សិក្សាឲ្យឃើញនូវវត្ថុធាតុទាំងអស់ក្នុងលោក តាមផ្លូវបញ្ញា ដោយន័យថាបុគ្គលអ្នកមើលឃើញលោក ផ្ទុយពីការឃើញលោកនៃមនុស្សធម្មតា។* បុគ្គលពួកនេះមានច្រើន តែដែលពិសេសជាងគេគឺ ព្រះពុទ្ធបរមគ្រូនុ៎ះឯង។

*ព្រះពុទ្ធអង្គ កាលដើមឡើយទ្រង់ឃើញលោកដូចគេឯងដែរ តែក្រោយមកទ្រង់សិក្សាស្រាវជ្រាវយ៉ាងខ្លាំង ក្នុងទីបំផុតនៃការសិក្សានេះ ព្រះអង្គទ្រង់មើលឃើញលោក ប្រកបដោយសច្ចៈ ៤ ប្រការ (ទុក្ខៈ សមុទយៈ និរោធៈ មគ្គៈ) ដោយអំណាចការឃើញថ្មីនេះ ព្រះអង្គក៏បានលះបង់ស្នេហាចាស់ចោលអស់ទៅ ហើយទ្រង់ប្រើប្រាស់សេចក្តីស្នេហាថ្មី ដែលជាសេចក្តីស្នេហាមានរស*

*ជាតិមិនចេះប្រែប្រួល គឺ ព្រះនិព្វានហ្នឹងឯង ។*

សេចក្ដីទាំងឡាយដែលខ្ញុំបានសរសេរនេះ ដៅឲ្យឃើញថា : *ការរស់នៅរបស់យើងជាមួយនឹងព្រះពុទ្ធសាសនា វាជាការចាំបាច់របស់យើង ព្រោះសាសនានេះជាសាសនាវិទ្យាសាស្ត្រផង ជាទស្សនវិជ្ជាផង។* ចំណែកពួកជនមួយ ដែលមានយោបល់ថា : ពុទ្ធសាសនាមិនគួរឲ្យពលរដ្ឋខ្មែរ រស់នៅជាមួយបានទេ ព្រោះពុទ្ធសាសនាមានកិច្ចការ មានវត្ថុបំណង មានបទបញ្ញត្តិ និងមានឧត្ដមគតិដូចនេះគឺ :

១- ហាមឃាត់នូវរបរអាជីវកម្មខ្លះ នាំឲ្យប្រជាជាតិមានមុខរបររកស៊ីតិច

២- កុលបុត្រខ្មែរបួសច្រើនពេកខាតមនុស្សធ្វើការដើម្បីជា ប្រយោជន៍របស់ជាតិ

៣- មានវត្តអារាមច្រើនពេក ខាតធនធានរបស់ប្រទេស

៤- ដឹកនាំមនុស្សឲ្យទៅនៅឋានសួគ៌ មិនបានដឹកនាំមនុស្សធ្វើការងារក្នុងជាតិនេះ ដើម្បីប្រយោជន៍ដល់ជាតិ

៥- អប់រំមនុស្សឲ្យផ្អែកខ្លួនលើព្រេងសំណាង ដែលជាហេតុមួយនាំឲ្យមនុស្សខ្ជិលធ្វើការ

៦- បង្រៀនមនុស្សឲ្យលះបង់សេចក្ដីស្នេហារវាងភេទ[១] ដែលធម្មជាតិបានរៀបចំស្រេចមកហើយ។

យោបល់នៃជនពួកនេះ ជាយោបល់កើតឡើងតាមអារម្មណ៍ មិនមែនកើតឡើងដោយវិចារណញ្ញាណ ផ្អែកទៅលើវត្ថុបំណងដ៏ពិតប្រាកដនៃពុទ្ធសាសនាឡើយ។ ការណ៍ពិត ពុទ្ធសាសនារបស់យើង ជាសាសនាមួយ មានល័ខគោលធម៌សម្រាប់ទ្រទ្រង់នូវសេចក្ដីរស់នៅរបស់រូបធាតុ និងអរូបធាតុទាំងអស់ ទោះជាមនុស្សក្ដីសត្វតិរច្ឆានក្ដី ធម្មជាតិក្ដី ប្រសិនបើមានបំណងចង់រស់នៅក្នុងរបបការងារណាចង់ដាក់ជំនឿទៅក្នុងលទ្ធិណា ចង់គោរពរាប់អានសាសនាណា។ល។ ស្រេចហើយនឹងបំណងរបស់ខ្លួន ពុទ្ធសាសនាពុំបានហាមឃាត់ទេ ។ ពុទ្ធសាសនា មាននាទីត្រឹមតែជួយបំភ្លឺ បញ្ហាជីវិតរបស់មនុស្ស

ទាំងឡាយ ដូចជាបញ្ហាស្នេហា បញ្ហាសុខភាព បញ្ហាប្រកបអាជីវកម្ម។ល។ នឹងជួយធ្វើកល្យាយអន្តរាគមន៍ក្នុងកិច្ចការទាំងឡាយណា ដែលគេធ្វើរំលោភ ហួសព្រំដែន នៃសិទ្ធិដែលខ្លួនគេត្រូវមាន ដូចសិទ្ធិរស់នៅ សិទ្ធិចងច្បាប់ សិទ្ធិប្រតិបត្តិច្បាប់។ល។ យើងមានសេរីភាពខាងស្នេហាមែន តែសេចក្តីស្នេហារបស់យើងត្រូវនៅក្នុងព្រំដែននៃច្បាប់ ព្រំដែននៃសេចក្តីយល់ព្រមអំពីមនុស្សដែលយើងស្នេហា ឧទាហរណ៍ : យើងមានភ្នែកសម្រាប់មើល សម្រាប់ឃើញរូប តែបើរូបដែលយើងត្រូវការមើលនោះ គេមិនត្រូវការឲ្យយើងមើល យើងក៏មិនត្រូវមើលដែរ។ ចំពោះបញ្ហាមើលនោះ ខាងផ្លូវសេរីភាពយើងចេះតែមើលបាន មិនទាន់ជាខុសត្រូវអ្វីទេ តែខាងផ្លូវសីលធម៌វិញនោះ មានការមិនសមរម្យច្រើនដែរ ព្រោះមានយុវជនខ្លះ សម្លឹងមើលយុវនារីដែលដើរតាមផ្លូវសាធារណៈ ឬអង្គុយក្នុងទីប្រជុំជនក្នុងកន្លែងណាមួយ ដោយប្រើឥរិយាបថខុសធម្មតាខ្លាំងពេក ទាល់តែយុវនារីនោះ កើតមានសេចក្តីអៀនខ្មាស់ដើរមិនរួចឬអង្គុយមិនកើតក៏មាន។ *ដើម្បីជីវិតរបស់យើងរស់នៅក្នុងសេចក្តីសុខស្ងប់នោះមនុស្សម្នាក់ៗមុននឹងធ្វើការអ្វីមួយ ត្រូវមានស្មារតីនៅក្នុងការនោះ មិនត្រូវធ្វើដោយគ្មានស្មារតី ឬធ្វើតាមបែបអារម្មណ៍របស់ខ្លួនទេ គឺត្រូវធ្វើតាមអារម្មណ៍របស់អ្នកដទៃដែលជាគូកម្មរបស់ខ្លួនយើងនោះផង។*

ពុទ្ធសាសនា មិនបានបង្រៀនឲ្យមនុស្សបិទភ្នែក ត្រចៀក ច្រមុះ អណ្តាត កាយទេ តែពុទ្ធសាសនាបង្រៀនឲ្យសង្រួមភ្នែក ត្រចៀក ច្រមុះ អណ្តាត កាយ ភ្នែកត្រូវមើលតែរូបណាដែលគួរមើល ឬមើលឲ្យតិច ឬមើលឲ្យខ្លី ត្រចៀកត្រូវស្តាប់តែសម្លេងណាដែលគួរស្តាប់ ឬស្តាប់ឲ្យតិច ច្រមុះត្រូវថើបតែថ្កាល់ណាដែលគួរឲ្យថើប ឬវត្ថុណាដែលគួរថើប ឬថើបឲ្យតិច អណ្តាចត្រូវនិយាយតែពាក្យណាគួរនិយាយ ត្រូវបរិភោគតែរសជាតិណាដែលគួរបរិភោគ ឬនិយាយឲ្យតិចបរិភោគឲ្យតិច កាយត្រូវធ្វើតែការងារដែលគួរធ្វើ ឬចាប់កាន់តែរូបណាដែលម្ចាស់គេយល់ព្រមផងប៉ុណ្ណោះ។ *កាលណាមនុស្សយើងបានសង្រួមឥន្ទ្រីយ៍តាមសេចក្តីណែនាំនៃពុទ្ធសាសនា ត្រង់ចំណុចនេះ ការរស់នៅក្នុងសង្គមរបស់យើង ក៏រមែងបានសុខស្រួល អារ្យធម៌របស់ជាតិយើង ក៏បាន*

*រីកដុះដាលយ៉ាងរហ័សទៅក្នុងពិភពលោក ។*

យោបល់ថា : ពុទ្ធសាសនាហាមឃាត់នូវអាជីវកម្មប្រភេទខ្លះនោះ ក្នុងចំណុចនេះ ខ្ញុំយល់ឃើញថា គ្រប់ជីវិតទាំងអស់ក្នុងសាកលចក្រវាឡ មិនមែនត្រូវការត្រឹមតែរស់ប៉ុណ្ណោះទេ តែត្រូវការធ្វើឲ្យសេចក្តីរស់នៅរបស់ខ្លួនមានវឌ្ឍនភាពមានសេចក្តីថ្លៃថ្នូរផង។ ដើម្បីឲ្យជីវិតទាំងអស់បានរស់នៅស្រួលតាមសេចក្តីប៉ងប្រាថ្នារបស់ម្ចាស់ជីវិត *ពុទ្ធសាសនារំពឹងថា ជំនួញប្រាំប្រការគឺ : ជំនួញមនុស្ស ជំនួញសត្វសម្រាប់ធ្វើអាហារ ជំនួញអាវុធចំបាំង ជំនួញសុរា ជំនួញថ្នាំពុល* ជំនួញទាំងអស់នេះ បើអាចវៀរបង់ចបានជាការល្អណាស់ ព្រោះជំនួញប្រភេទនេះប៉ះពាល់ដល់សេរីភាពនៃជីវិត ដល់សុខភាពនៃរូបកាយ និងដល់ស្មារតីនៃមនុស្សជាតិដែលជាទីស្រឡាញ់រាប់អានគ្រប់ៗគ្នា ។ ម៉្យាងទៀតជំនួញទាំង ៥ នេះ បើតាមការបកស្រាយរបស់ខ្ញុំឃើញថា :

**ជំនួញមនុស្ស** បានកន្លងសម័យហើយជំនួញប្រភេទនេះ ច្បាប់អន្តរជាតិក៏បានបញ្ញត្តជាស្រេចហើយដែរ មិនមែនតែពុទ្ធសាសនារបស់យើងមួយទេ។

**ជំនួញសត្វ** សម្រាប់ធ្វើអាហារនៅមានសព្វថ្ងៃ ជំនួញប្រភេទនេះ ប្រសិនបើជីវិតរបស់យើងមានការចាំបាច់ត្រូវរស់នៅដោយសាច់សត្វ ហើយប្រទេសរបស់យើងក៏មានសេចក្តីត្រូវការ នឹងបង្កើនសេដ្ឋកិច្ចដោយមុខរបរផ្នែកនេះ ការចាំបាច់នឹងសេចក្តីត្រូវការនេះ យើងនឹងវៀរបង់ពុំបានទេ យើងត្រូវតែឆ្លៀតត្រឹមតែ ចិញ្ចឹមនឹងឆ្លៀតធ្វើជំនួញទឹកដោះសត្វ ជំនួញរោមសត្វ ជំនួញសត្វស្លាប ជំនួញ កន្ទុយសត្វ។ល។ តាមការដែលអាចលៃលកទៅបាន ព្រោះជំនួញបែបនេះ ក្នុងជាន់ពុទ្ធសម័យ ក៏មានគេធ្វើច្រើនណាស់ដែរ ជាពិសេស មហាឧបាសិកាវិសាខាជាព្រះអរិយសាវកាទៅហើយ ក៏នាងនៅចិញ្ចឹមគោលក់ទឹកដោះដែរ។

**ជំនួញអាវុធចំបាំង** ក្នុងបច្ចុប្បន្នកាលនេះក៏នៅមានគេធ្វើតែជំនួញប្រភេទនេះ កំពុងត្រូវចោទថាជាជំនួញចក្រព័ត្រនិយម និងអាណានិគមនិយម សព្វថ្ងៃនេះអង្គការនៃមនុស្សធម៌(អង្គការសហប្រជាជាតិ) ក៏បានបើកឲ្យមាន

សន្និសិទមួយហៅថា"សន្និសិទបន្ថយសញ្ញាវុធចំបាំង"ដែរហើយ តើមានអ្នកណាខ្លះ ដែលមិនដឹងថាសកម្មភាពនិងចលនានៃអង្គការនេះ បានប្រព្រឹត្តទៅស្រប ជាមួយនឹងការណែនាំនៃពុទ្ធសាសនារបស់យើង។

**ជំនួញសុរា** ចំពោះជំនួញប្រភេទនេះ ក៏ត្រូវលើកមកចោទក្នុងបញ្ហាសង្គមនឹងបញ្ហាសុខភាពនៃប្រជាជនគ្រប់ៗប្រទេស។ ប្រទេសខ្លះថាត្រូវបិទមិនឲ្យមានប្រទេសខ្លះថាត្រូវឲ្យមានសុរាយ៉ាងតិចបំផុត ប្រទេសខ្លះថាត្រូវធ្វើសុរាឲ្យខ្សោយឬឲ្យមានកំដៅតិច ដើម្បីកុំឲ្យខូចសុខភាពប្រជាជាតិ។ ម្យ៉ាងទៀតវត្ថុស្រវឹងនេះមិនមែនមានត្រឹមតែសុរាទេ អាភៀននិងគ្រឿងត្រាំងទៀតៗ ក៏សង្គ្រោះចូលក្នុងធាតុដែលជាគ្រឿងស្រវឹងគ្រឿងញៀននេះដែរ ។ ចំពោះអាភៀនមួយមុខនេះ រដ្ឋបានធ្វើច្បាប់ហាមឃាត់មិនឲ្យអ្នកជំនួញលក់ មិនឲ្យប្រជាជាតិទិញជក់ទេ។ ចំណែកខាងសុរា រដ្ឋមិនបានហាមឃាត់ទេ តែរដ្ឋក៏មិនមែននៅស្ងៀមព្រងើយបោះបង់ចោលនូវចំណោទនេះក្នុងអនាគតឡើយ។

**ជំនួញថ្នាំបំពុល** ចំពោះជំនួញប្រភេទនេះ រដ្ឋបានហាមប្រាមមិនឲ្យលក់មិនឲ្យផឹកជាស្រេចទៅហើយ ដែលនៅមានខ្លះនោះ គឺមានតែក្នុងអង្គការរបស់រដ្ឋ មានអង្គការពេទ្យជាដើមប៉ុណ្ណោះ។ *ដូច្នេះឃើញថាជំនួញ ៥ យ៉ាងនេះ មិនមែនមានតែអង្គការនៃពុទ្ធសាសនាទេ ដែលថាមិនល្អដល់ជីវិតមនុស្ស តែអង្គការរដ្ឋក៏ថាមិនល្អដូចគ្នាដែរ។* ចំពោះជំនួញពីរបីខាងក្រោយ ខ្ញុំយល់ថា : ប្រសិនរដ្ឋក្តី ជីវិតប្រជាជាតិក្តី បានការចាំបាច់លើរបរទាំងអស់នេះ ក៏អាចធ្វើបានដែរ ។ ខាងសុរាយើងត្រូវធ្វើសុរាឲ្យវាខ្សោយ ឲ្យមានកំដៅតិច ឬកែសុរាឲ្យមកជាភេសជ្ជៈ ដោយធ្វើយ៉ាងណាឲ្យវត្ថុនេះមានរសជាតិស្រវឹងយ៉ាងតិចបំផុត ដើម្បីឲ្យខុសពីសព្ទថា "សុរា" ព្រោះសព្ទនេះ បើតាមអត្ថថា "ភ្លៀវភ្លាក្អេងក្អាង"។ល។ បើតាមន័យថា "ធ្វើអ្នកផឹកឲ្យមានស្មារតីវង្វេងវាយ" ឬបើមិនធ្វើដូចនេះទេ និងលក់វត្ថុដើមរបស់សុរាមានអង្ករនិងស្ករជាដើមក៏បាន ។ ពុទ្ធសាសនាមិនបានហាមឃាត់មិនឲ្យប្រើសុរាទេតែឲ្យប្រើយ៉ាងតិចបំផុត គឺឲ្យលាយចូលជាមួយគ្រឿងអាហារ ឬគ្រឿងភេសជ្ជៈដោយចំនួនតិចជាអតិបរមា

ដើម្បីត្រឹមតែបំបាត់ក្លិនឆ្អាបក្លិនផ្អមប៉ុណ្ណោះ ហើយក្នុងគ្រឿងអាហារឬគ្រឿងភេសជ្ជៈនោះ កុំឲ្យប្រាកដដោយពណ៌ឬដោយក្លិនសុរា។ ខាងគ្រឿងអាវុធវិញ យើងធ្វើអាវុធកាប់ឈើក៏បាន ធ្វើចបប៉ែលត្រាក់ទ័រ ។ល។ ឈូសឆាយដីក៏បាន ឬលក់វត្ថុដើមសម្រាប់ធ្វើអាវុធដូចជាដែកជាដើមក៏បាន។ ខាងថ្នាំបំពុលយើងអាចលក់នូវវត្ថុដើមនៃគ្រឿងពុល ដូចជាគ្រាប់ស្លែង សំបកស្លាក់ ឬសកន្ទួតជាដើមបាន។ បើតាមន័យនេះ ឃើញថា : ពុទ្ធសាសនារបស់យើងមិនបានអនុញ្ញាតឲ្យលក់នូវវត្ថុធាតុដែលជាសត្រូវរបស់ជីវិត តែអនុញ្ញាតឲ្យលក់នូវធាតុដែលមានគុណប្រយោជន៍ដល់ជីវិត។

យោបល់ថា **កុលបុត្រខ្មែរបួសច្រើនខាតមនុស្សធ្វើការ មានវត្តអារាមច្រើនខាតធនធានរបស់ប្រទេសៗ** ក្នុងចំណុចនេះ ប្រសិនបើយើងគិតឲ្យដិតដល់ទៅនោះឃើញថាមិនច្រើនហួសបរិមាណទេ។ តាមការសង្កេតរបស់ខ្ញុំដែលបានធ្វើមកហើយនោះ កូនខ្មែរបួសមានចំនួនមិនដល់ម្នាក់ក្នុងភាគរយទេ តែបើយើងកំណត់ចំនួនថាកូនខ្មែរបួសម្នាក់ក្នុងភាគរយ មួយពាន់នាក់នឹងមានអ្នកបួស ១០ នាក់ មួយហ្មឺននាក់នឹងមានអ្នកបួស ១០០នាក់ មួយសែននាក់នឹងមានអ្នកបួស ១០០០នាក់ មួយលាន់នាក់នឹងមានអ្នកបួស ១០ ០០០នាក់ប៉ុណ្ណោះទេ។ ចំណែកវត្តអារាមក្នុងប្រទេសខ្មែរយើងសព្វថ្ងៃនេះ មានមិនដល់ ៥០០០ទេ រួមទាំងវត្តសម្រាប់គណសង្ឃមហានិកាយ ទាំងវត្តសម្រាប់គណសង្ឃធម្មយុត្តិកនិកាយ។ តែបើយើងកំណត់ចំនួនវត្តឲ្យមាន ៥០០០ ហើយបែងចែកស្មើគ្នានោះ ពលរដ្ឋខ្មែរក្នុងមួយពាន់នាក់មានវត្តធ្វើបុណ្យត្រឹមត្រូវតែមួយទេ។ ចំនួនអ្នកបួសនិងចំនួនវត្តមានបរិមាណប៉ុណ្ណោះឃើញថាមិនទាន់ច្រើនហួសពេកទេ ព្រោះមានកន្លែងខ្លះ ប្រជាជាតិគ្មានទាំងវត្តធ្វើបុណ្យផង ដែលថាគ្មាននេះ មិនមែនដៅសេចក្ដីថាប្រទេសខ្មែរយើងមិនមានវត្តទេគឺដៅសេចក្ដីថាមានវត្តនៅឆ្ងាយពេក មិនអាចនឹងទៅធ្វើបុណ្យបាន ប្រសិនបើអង្គការរដ្ឋ ឬអង្គការសាសនា ចាត់ចែងធ្វើឲ្យមានវត្តក្នុងដំបន់ដែលគ្មានវត្ត ដោយដកយកវត្តខ្លះពីកន្លែងណាដែលមានវត្តច្រើនពេក ទៅដាក់ក្នុងកន្លែងនោះ ឃើញ

ថាជាការគាប់ប្រសើរណាស់ ព្រោះវត្តនឹងមិនកើតឡើងទៀត ដែលជាហេតុនាំឲ្យដាច់បង់ថវិកាគ្រួសារ ឬថវិកាជាតិ។

ម្យ៉ាងទៀត ការសាងវត្តក្នុងអនាគតកាល យើងមិនត្រូវចេះតែដេញជើងគ្នាយកឈ្នះចាញ់ខាងល្អជាងគ្នានោះទេ អ្នកណាក្រក៏ធ្វើតាមក្រ អ្នកណាមានធ្វើតាមមានទៅ ព្រោះបុណ្យកុសលមិនមែនត្រូវវាស់ដោយខាតលុយកាក់ទេ គឺត្រូវវាស់ដោយចិត្តជ្រះថ្លាបញ្ញាឃើញត្រូវប៉ុណ្ណោះ។ *តាមឧត្តមគតិនៃពុទ្ធសាសនា អ្នកបួសមិនត្រូវស្វែងរកសេចក្តីរុងរឿងដោយសាងវត្តទេ ផ្ទុយទៅវិញគឺត្រូវស្វែងរកសេចក្តីរុងរឿងដោយសាងចិត្តវិញ្ញាណ អ្នកបួសម្នាក់ៗត្រូវរស់នៅត្រឹមតែរស់ដើម្បីបំរើសង្គមប្រជាជាតិដោយសិក្ខានៃសីលធម៌ និងសិក្ខានៃវិបស្សនាធម៌ប៉ុណ្ណឹងបានហើយ។* តាមឧត្តមគតិនៃពុទ្ធសាសនាដដែល អ្នកបួសមិនមែនមានកិច្ចការត្រឹមតែបួសដើម្បីរស់នៅជាមួយសង្គម ដោយគ្មានការសិក្សាវែកញែករកសេចក្តីខុសត្រូវក្នុងធម្មវិន័យដើម្បីដឹកនាំខ្លួនឲ្យបានល្អ នោះទេ ជាអ្នកបួសត្រូវតែធ្វើខ្លួនឲ្យបានជាអ្នកបួស គឺជួយខ្លួនឯងឲ្យបានចេះដឹងនូវវិជ្ជាពុទ្ធសាសនាដោយជ្រៅជ្រះ ប្រតិបត្តិខ្លួនឲ្យបានល្អ លះបង់នូវទំនៀមទំលាប់ខ្លះ ដែលនាំឲ្យមានសេចក្តីសៅហ្មងដល់ធម្មៈនៃពុទ្ធសាសនាជួយបង្រៀនអ្នកដទៃឲ្យស្គាល់នូវសីលធម៌ និងវិបស្សនាធម៌ ជួយគាំទ្រកិច្ចការរដ្ឋដែលទាក់ទងជាមួយនឹងកិច្ចការនៃពុទ្ធសាសនា។ កាលណាយើងកាន់ពុទ្ធសាសនាក៏បានទទួលនូវសេចក្តីចំរើន សេដ្ឋកិច្ចរបស់ជាតិក៏មិនទន់ខ្សោយ អារ្យធម៌របស់ប្រទេសដែលចងភ្ជាប់ជាមួយនឹងអារ្យធម៌នៃពុទ្ធសាសនា នឹងបានលូតលាស់ដុះដាល់ដល់គំនួសចុងបំផុតជាពុំខានឡើយ។

យោបល់ថា**ពុទ្ធសាសនា គិតតែដឹកនាំមនុស្សឲ្យទៅនៅឋានសួគ៌ មិនគិតដឹកនាំមនុស្សដោយធ្វើការខាងនោះ** ។ យោបល់នេះ ក៏កើតមានឡើងតែតាមអារម្មណ៍តាមសេចក្តីល្ងង់ខ្លៅរបស់ជនពួកខ្លះប៉ុណ្ណោះ។ ការណ៍ពិត ពុទ្ធសាសនា មិនដែលបានដឹកនាំមនុស្សណាម្នាក់ឲ្យទៅនៅឋានសួគ៌ម្តងណាទេ។ ព្រហ្មណសាសនិកគេអួតសរសើរឋានសួគ៌ គេបបួលគ្នាទៅនៅឋានសួគ៌ ដើម្បីបានបំរើព្រះរបស់គេដែលគេថាគង់នៅក្នុងឋានសួគ៌ គេថាឋានសួគ៌សប្បាយ

មានរបស់របរប្រើប្រាស់ស្រាប់ៗ មានប្រពន្ធច្រើនៗ អ្នកណាបានទៅនៅមិនត្រឡប់មកវិញទេ។ ចំណែកខាងពុទ្ធសាសនា ព្រះបរមគ្រូរបស់យើងទ្រង់បង្រៀនថា ឋានសួគ៌មានទុក្ខទោសដែរ អ្នកទៅនៅក្នុងឋានសួគ៌ ក៏នៅក្នុងអំណាចនៃចលនាប្រែប្រួល (អនិច្ចំ) នៃចលនាធន់ទ្រាំ (ទុក្ខំ) នៃចលនាបាក់បែក (អនត្តា) ក្នុងទីបំផុតព្រះអង្គទ្រង់បញ្ជាក់ថា មានតែការលះបង់ចោលនូវឋានសួគ៌ប៉ុណ្ណោះទេ ដែលចាត់ថាជាការបានសម្រេចនូវសេចក្តីសុខដ៏ខ្ពង់ខ្ពស់បំផុត។ ព្រះយោបល់របស់ព្រះសម្មាសម្ពុទ្ធក្នុងចំណុចនេះ មិនមានអ្នកប្រាជ្ញណា ទោះជាខាងទស្សនវិជ្ជាក្តី ខាងវិទ្យាសាស្ត្រក្តីអាចទាក់ចោលបានទេ ព្រោះយោបល់នេះ មានមូលដ្ឋាននៅលើសេចក្តីពិត គឺសច្ចធម៌៤ ប្រការ ដែលព្រះអង្គទ្រង់រាវរកឃើញដោយសិក្ខានៃវិបស្សនា។ រាល់ពេលដែលទ្រង់ប្រកាសសច្ចៈ ព្រះអង្គពុំដែលលះបង់ចោលនូវសច្ចធម៌នេះទេ គឺព្រះអង្គតែងតែប្រាប់ថា លោកទាំងអស់ជាទុក្ខ សេចក្តីទុក្ខកើតពីតណ្ហា និព្វានជាបរមសុខ មគ្គ ៨ ជាផ្លូវដើរទៅនិព្វាន។ ឋានសួគ៌តាមដែលគេស្គាល់ថា សម្បូណ៌សេចក្តីសុខ ព្រោះកន្លែងនោះ មានប្រពន្ធច្រើន មានកាមទិព្វកើតឡើងឯងៗសម្រាប់បំរើឲ្យពួកទេព គឺគួរឲ្យព្រះអង្គបបួលយើងឲ្យទៅនៅទីនោះដែរឬទេ? បើធម្មទេសនារបស់ព្រះអង្គបានដៅឲ្យឃើញថា សេចក្តីទុក្ខកើតពីកាមតណ្ហានោះទៅហើយ ។ យោបល់ខ្ញុំថា ពុំមែនព្រះអង្គបបួលទេ តែជាធម្មតានៃមនុស្សយើងដែលធ្លាប់នៅក្នុងស្រុកបរិភោគកាម រមែងចង់ទៅនៅក្នុងស្រុក ដែលមានកាមសម្រាប់ប្រើប្រាស់ទៀត។ ចំណង់នេះនាំឲ្យពុទ្ធសាសនាលំបាកក្នុងការបង្រៀនជាខ្លាំង ដោយមិនដឹងគិតលៃលកយ៉ាងណាឲ្យគេចូលចិត្តថា លោកទាំងអស់ជាទុក្ខតាមកំរិតនៃសច្ចធម៌ ។ ដើម្បីពុះពារនូវសេចក្តីលំបាកនេះ ពុទ្ធសាសនាមិនមានមធ្យោបាយណា ក្រៅពីមធ្យោបាយចាក់បណ្តោយតាមចំណង់។ ដូច្នេះ ទើបពុទ្ធសាសនាត្រូវនិយាយថា *"បើអ្នកណាចង់បានសេចក្តីសុខ ត្រូវខំប្រឹងធ្វើបុណ្យ ធើឲ្យបានរឿយៗ ហើយឲ្យមានសេចក្តីជ្រះថ្លាពេញចិត្តចំពោះបុណ្យរបស់ខ្លួនផង បុណ្យនឹងនាំសេចក្តីសុខមកឲ្យជាពុំខាន។* សេចក្តីសុខក្នុងទីនេះ ព្រោះសេចក្តីសុខកើតពីបុណ្យ ហើយបុណ្យក៏មានច្រើនថ្នាក់ច្រើនជាន់ទៅ

ទៀត។ អ្នកធ្វើបុណ្យចង់បានសេចក្តីសុខបែបណា ស្រេចហើយតែខ្លួនស្រឡាញ់។ តែពុទ្ធសាសនាបានប្រើសព្ទមួយថា "ប៉ុន្តែ" នៅក្នុងចន្លោះប្រយោគដែលនិយាយអំពីអនិសង្សទាន សីល ភាវនា ដូចជាប្រយោគថា "*អ្នកធ្វើបុណ្យទាននឹងបានទៅនៅខានសួគ៌ ដែលខ្លួនអ្នកបានដឹងឮ ដែលខ្លួនអ្នកចង់បាន "ប៉ុន្តែ" ឋានសួគ៌គឺនៅមានទុក្ខមានទោស ព្រោះឋានសួគ៌នៅមានខន្ធ៥ ដែលជាប្រភពនៃទុក្ខ។* យើងអាល័យតែនឹកសប្បាយនឹងឋានសួគ៌ យើងក៏ស្តាប់ពាក្យ "ប៉ុន្តែ" នោះមិនទាន់ ឬមួយស្តាប់ទាន់ តែវាឮគេអួតខ្លាំងពេក ក៏ចង់ទៅនៅសាកល្បងមើល។

ឋានសួគ៌ជាកន្លែងស្រវឹងកាម គឺស្រវឹងប្តីប្រវឹងប្រពន្ធ ស្រវឹងសប្បាយស្រវឹងខ្ជិល។ល។ មិនមែនជាទីដៅនៃពុទ្ធសាសនារបស់យើង ដែលជាសាសនាមួយមានធម្មៈសម្រាប់តស៊ូរកសេចក្តីពិតរបស់ធម្មជាតិ រកផ្លូវចេញចាកទុក្ខទាំងអស់ក្នុងសាលកពិត។ បើយើងចង់ទៅនៅក៏ទៅចុះ តែយើងកុំថាព្រះបរមគ្រូរបស់យើងបបួលយើងឲ្យទៅនៅឋានសួគ៌ឡើយ។

យោបល់ថា : ពុទ្ធសាសនាប្រៀនមនុស្សឲ្យអាងភ័ព្វវាសនា ដែលជាហេតុនាំឲ្យមនុស្សខ្ជិលធ្វើការនោះ ខ្ញុំមិនចាំបាច់និយាយម្តងទៀតទេ ព្រោះខ្ញុំបាននិយាយមកហើយថា : *ពុទ្ធសាសនារបស់យើងជាទស្សនវិជ្ជានៃកម្មនិយម គឺជាសាសនាបង្រៀនមនុស្សឲ្យធ្វើការ ពុំដែលបង្រៀនមនុស្សឲ្យដេកផ្សងព្រេងម្តងណាឡើយ។* តែមនុស្សមានភ័ព្វវាសនា រមែងមានកំណើតល្អ រមែងធ្វើការឆាប់បានសម្រេចផល។ ព្រះបរមគ្រូរបស់យើងមិនមែនមានភារកិច្ចត្រឹមតែក្រើនរំលឹក ឲ្យមនុស្សខំប្រឹងធ្វើការប៉ុណ្ណោះទេ ព្រះអង្គថែមទាំងបានដៅបញ្ជាក់ថា សេចក្តីទុក្ខរបស់មនុស្សដែលនឹងអស់ទៅបាន ក៏ដោយសារតែសេចក្តីព្យាយាមរបស់មនុស្សទាំងឡាយ។ ដូច្នេះឃើញថា ពុទ្ធសាសនារបស់យើងមិនមែនជាសាសនារំលាយសេចក្តីទុក្ខ នឹងសាងសេចក្តីសុខ ដោយការផ្សងព្រេងទេ ។ តែមនុស្សកំជិលចេះតែនាំគ្នាដេកផ្សងព្រេងលុះធ្លាក់ខ្លួនទៅជាមនុស្សក្រខ្សត់ ក៏តាំងចោទទុព្វសាសនាថា បង្រៀនខ្លួនឲ្យដេកផ្សងព្រេងទៅវិញ។

យោបល់ថា : **ពុទ្ធសាសនាបង្រៀនមនុស្សឲ្យលះបង់នូវសេចក្តីស្នេហា ដែលធម្មជាតិបានរចនាតាក់តែងជាស្រេចមកហើយ ឲ** យោបល់នេះបើពិចារណាតាមនិស្ស័យសន្តាននៃមនុស្សអ្នកបរិភោគកាមឃើញថាត្រូវដែរ តែបើពិចារណាតាមពុទ្ធភាសិតត្រង់ចំណុចទាំងឡាយ មានចំណុចថា *"សេចក្តីសោកក្រៀមក្រំរមែងកើតមកអំពីកាមគឺសេចក្តីស្នេហា"* ជាដើមនោះ យើងមិនគួររិះគន់ពុទ្ធសាសនា ក្នុងបទណែនាំឲ្យលះបង់នូវសេចក្តីស្នេហាទេ។ ម្យ៉ាងទៀត ការណែនាំឲ្យលះបង់នូវសេចក្តីស្នេហារបស់មនុស្សនៃពុទ្ធសាសនានោះក៏មិនមែនទាន់ឲ្យលះបង់សេចក្តីស្នេហាគ្រប់ប្រភេទទាំងអស់កាលណា។ ជាដំបូង ឲ្យលះបង់នូវសេចក្តីស្នេហា ដែលពុំមានសេចក្តីបរិសុទ្ធ គឺបង្រៀនឲ្យមនុស្សចេះរៀបចំសេចក្តីស្នេហារបស់ខ្លួនឲ្យបានល្អ ឲ្យជាសេចក្តីស្នេហាប្រកបដោយមនុស្សធម៌ ។ បន្ទាប់មក បង្រៀនឲ្យយកសេចក្តីស្នេហាសម្រាប់ធម្មជាតិទៅដូរយកសេចក្តីស្នេហាមួយថ្មីទៀត ដែលធម្មជាតិពុំបានរចនាតាក់តែង គឺ **សេចក្តីស្នេហាក្នុងមគ្គផលនិព្វាន** ។ ដើម្បីឲ្យយល់ច្បាស់នូវមេរៀននេះ អ្នកអានត្រូវរំពឹងគិតដល់សេចក្តីស្នេហាក្រខ្វក់ និងសេចក្តីស្នេហាបរិសុទ្ធដែលមនុស្សក្នុងអតីតកាល បានប្រព្រឹត្តមកហើយថាតើសេចក្តីស្នេហាទាំងអស់នោះឲ្យសេចក្តីសុខទុក្ខដល់អ្នកប្រព្រឹត្តយ៉ាងណាខ្លះ។ ចំពោះបញ្ហានេះ អ្នកនិពន្ធខាងរឿងប្រលោមលោក វណ្ណកម្មខាងអក្សរសាស្រ្តជាតិ វណ្ណកម្មខាងសាសនារឿងព្រេងគឺរឿងដែលកើតឯងតៗគ្នា សុទ្ធតែបានបញ្ជាក់ពីចំបាំងស្នេហាចំបាំងក្បត់ចិត្ត។ល។ ដោយលើកយកតួឯកស្នេហាមួយៗ មកធ្វើអត្ថាធិប្បាយវែកញែកយ៉ាងពិស្តារហើយក្នុងទីបំផុតរឿងមួយៗ សុទ្ធតែបានប្រាប់កំហុសនៃសេចក្តីស្នេហាក្រខ្វក់ ហើយបានសរសើរសេចក្តីស្នេហាបរិសុទ្ធ ព្រមជាមួយនឹងសេចក្តីតឿនក្រើនឲ្យមនុស្សរៀបចំសេចក្តីស្នេហាឲ្យមានតុល្យភាព ជាមួយគូស្នេហារបស់ខ្លួន និងឲ្យបានប្រកបដោយយុត្តិធម៌ជាមួយនឹងគូស្នេហាទូទៅ។ ដូច្នេះឃើញថា ពុទ្ធសាសនារបស់យើងមិនមែនបង្រៀនឲ្យគេលះបង់នូវសេចក្តីស្នេហាទេ តែបង្រៀនឲ្យគេរៀបចំសេចក្តីស្នេហាធម្មតា ដើម្បីប្រើប្រាស់នូវ

សេចក្ដីស្នេហាធម្មតា ដើម្បីប្រើប្រាស់នូវសេចក្ដីស្នេហាមួយទៀត ដែលជាសេចក្ដីស្នេហាខ្ពស់បំផុត ដែលជីវិតរបស់មនុស្សចេះតែនឹកសង្ឃឹមទុកថា ថ្ងៃណាមួយខ្លួននឹងបានដើរទៅដល់ជាពុំខាន។

ពុទ្ធសាសនា ជាអង្គការសួនគ្រងជីវិតមនុស្ស។ ដូច្នេះមុននឹងឲ្យសៀវភៅនេះចប់ ខ្ញុំសូមអំពាវនាវដល់អ្នកអានឲ្យពិចារណាឡើងវិញ នូវសេចក្ដីទាំងអស់ដែលខ្ញុំបានសរសេរមកហើយ ដើម្បិបានងាយស្រួលកាន់តែច្រើន ដល់ការប្រមូលផ្ដុំនូវស្មារតី សេចក្ដីចងចាំនិងសេចក្ដីសល់នោះ ខ្ញុំសូមឲ្យអ្នកអានហាត់សិក្សាតាមមេរៀនដូចតទៅនេះ :

**ជាមួយនឹងការរស់នៅក្នុងបច្ចុប្បន្ន** អ្នកអានគប្បីសិក្សាថា "*អញត្រូវធ្វើការឲ្យច្រើន អញនឹងធ្វើការដោយសេចក្ដីអត់ធន់ ក្លាយហានពុះពារ អញមិនចុះចាញ់ធម្មជាតិ មិនចុះចាញ់មនុស្សគ្នាឯង អញត្រូវថែរក្សាទុកដាក់នូវផលិតផលការងារទាំងអស់ អញនឹងមិនខ្លាចព្រឹត្តិការណ៍ប្រែប្រួលណាៗទាំងអស់ អញត្រូវការពារផលប្រយោជន៍ ដែលកើតឡើងហើយមិនឲ្យវិនាសបាត់បង់ទៅដោយប្រើគ្រប់មធ្យោបាយដែលខ្លួនអញអាចរកបាន អញត្រូវប្រមូលមនុស្សទាំងអស់ឲ្យរួមរស់នៅជាមួយគ្នាដោយល្អ ដើម្បីជាកម្លាំងសម្រាប់តទប់នូវគ្រោះកាចគ្រប់យ៉ាង អញត្រូវប្រើប្រាស់ទ្រព្យសម្បត្តិឲ្យតិច គឺអញរស់នៅត្រឹមតែរស់មិនរស់នៅដើម្បីសប្បាយ នៅក្នុងកណ្ដាលពួកមនុស្ស ដែលមានសេចក្ដីទុក្ខលំបាក អញត្រូវបរិច្ចាគទ្រព្យសម្បត្តិដល់អង្គការមនុស្សធម៌នានាដែលគេបង្កើតឡើង ដើម្បីសេចក្ដីសុខចំរើននៃមនុស្សលោក* " ។

**ជាមួយនឹងការរស់នៅក្នុងអនាគតជាតិ** អ្នកអានគប្បីសិក្សាថា "*អញត្រូវរៀបចំខ្លួនឲ្យជាបុគ្គលមានជំនឿក្នុងកម្មនិងផលរបស់កម្ម អញត្រូវធ្វើខ្លួនឲ្យជាមនុស្សមានសីលល្អ មានចរិយាថ្លៃថ្នូរ មានមារយាទសមរម្យ អញត្រូវចាយទ្រព្យសម្បត្តិធ្វើបុណ្យទាន ដើម្បីឲ្យមានបារមីធម៌សម្រាប់អាត្មា អញត្រូវសិក្សារៀនសូត្រឲ្យច្រើនដើម្បីឲ្យមានប្រាជ្ញាវៃឈ្លាស សម្រាប់ដោះស្រាយបញ្ហាកម្មនានា ដែលចោទមកលើខ្លួននៃអាត្មា។*

**ជាមួយនឹងការរស់នៅខ្ពស់បំផុត** អ្នកអានគប្បីសិក្សាថា *"អញត្រូវស្គាល់នូវសេចក្តីទុក្ខសម្រាប់មនុស្ស សត្វ ធម្មជាតិ និងត្រូវកំណត់ចាំនូវសេចក្តីទុក្ខនេះគ្រប់កាល អញត្រូវលះបង់នូវតណ្ហា (ការវាតពង្រីកនូវចំណង់) របស់មនុស្ស សត្វ ធម្មជាតិ ដែលជាហេតុនាំឲ្យកើតនូវសេចក្តីទុក្ខ អញត្រូវធ្វើការពិចារណាវែកញែករកនូវសេចក្តីសុខខ្ពស់បំផុត ដែលអ្នកប្រាជ្ញឲ្យឈ្មោះថា ជាសេចក្តីសុខមិនមានប្រែប្រួល អញត្រូវដើរទៅរកសេចក្តីសុខខ្ពស់បំផុតនោះតាមមគ្គ ៨ ប្រការដែលព្រះពុទ្ធបរមគ្រូទ្រង់បានរកឃើញ "* ។

**ជាមួយនឹងវិទ្យាសាស្ត្រ** អ្នកអានគប្បីសិក្សាថា *"អញត្រូវរៀនវិជ្ជាវែកញែកធម្មជាតិ (វិទ្យាសាស្ត្រ) ឲ្យបានចេះដឹងច្បាស់លាស់ ដើម្បីធ្វើធម្មជាតិឲ្យមានប្រយោជន៍ដល់ជីវិតមនុស្ស ព្រោះពុទ្ធសាសនារបស់អញ បានបង្រៀនឲ្យស្គាល់នូវធម្មជាតិដោយការសិក្សាស្រាវជ្រាវវែកញែក អញត្រូវរាប់អានស្រឡាញ់វិទ្យាសាស្ត្រព្រោះវិជ្ជាផ្នែកនេះ ព្រះពុទ្ធបរមគ្រូរបស់អញ បានរកឃើញហើយបានប្រកាសថា រាល់ៗរូបធាតុរមែងមានចលនា គឺចលនាប្រែប្រួល (អនិច្ចំ) ចលនាធន់ទ្រាំ (ទុក្ខំ) ចលនាដូរផ្លាស់ (អនត្តា)"* ។

**ជាមួយនឹងទស្សនវិជ្ជា** អ្នកអានគប្បីសិក្សាថា *"អញត្រូវរៀនទស្សនវិជ្ជាឲ្យបានចេះដឹងជ្រៅជ្រះ ព្រះពុទ្ធសាសនារបស់អ្បានប្រាប់ឲ្យសម្រេចនូវសេចក្តីខុសត្រូវដោយផ្លូវបញ្ញា គឺមុននឹងដាក់ជំនឿទៅក្នុងធម្មធាតុណាមួយ ថាជាធម្មធាតុល្អ អាក្រក់យ៉ាងណាៗនោះ ត្រូវសិក្សាវែកញែកឲ្យបានល្អិតល្អន់ និងត្រូវធ្វើការស្រាវជ្រាវពិនិត្យលើធម្មជាតិទាំងអស់ ដោយបញ្ញាយ៉ាងស្រួចស្រាល់ មិនមែនបង្រៀនឲ្យឃើញលោកតាមក្បួនតម្រា ឬទំនៀមទំលាប់ឡើយ"* ។

**ជាមួយនឹងនិច្ចសីល** អ្នកអានគប្បីសិក្សាថា *"អញត្រូវរៀនរស់នៅជាមួយនឹងជីវិតនៃមនុស្សផងគ្នា ដោយមិនបៀតបៀនជីវិតគេ មិនធ្វើជីវិតគេឲ្យស្លាប់ អញត្រូវយកចំណង់របស់អាត្មាអញ គឺបើអញចង់រស់នៅយូរយ៉ាងណា ខ្លួនគេទាំងឡាយក៏ចង់រស់នៅយូរយ៉ាងនោះដែរ អញត្រូវរៀនរស់នៅជាមួយនឹងទ្រព្យសម្បត្តិនៃមនុស្សផងគ្នា ដោយមិនឆោកបោកលួចលាក់ទ្រព្យសម្បត្តិអ្នកដទៃ*

*មិនធ្វើទ្រព្យសម្បត្តិអ្នកដទៃឲ្យវិនាសអន្តរាយ ដោយសេចក្ដីព្យាយាមបំផ្លិចបំផ្លាញរបស់អាត្មាអញ អញត្រូវយកសេចក្ដីស្រឡាញ់របស់គេ មកប្រៀបធៀបនឹងសេចក្ដីស្រឡាញ់របស់អាត្មាអញគឺបើអញស្រឡាញ់ទ្រព្យសម្បត្តិរបស់អញយ៉ាងណា គេក៏ស្រឡាញ់ទ្រព្យសម្បត្តិរបស់គេយ៉ាងនោះដែរ អញត្រូវរៀនរស់នៅជាមួយសេចក្ដីស្នេហានៃមនុស្សផងគ្នា ដោយមិនលួចសហាយស្មន់ជាមួយនឹងប្រពន្ធអ្នកដទៃ ឬស្ត្រីកំណាន់អ្នកដទៃ ឬស្វាមីនៃស្ត្រីដទៃ ឬបុរសកំណាន់នៃស្ត្រីដទៃ ឬកំហែងចែចង់ ស្ត្រីដែលគឺមិនមានចិត្តព្រមព្រៀងផង ឬទំលាយព្រហ្មចារីយ៍របស់ស្ត្រី ដែលគ្នាខំថែរក្សាយ៉ាងបរិសុទ្ធ អញត្រូវយកចិត្តរបស់គេមកប្រៀបធៀបនឹងចិត្តរបស់អញ គឺបើអញស្រឡាញ់ប្រពន្ធកូនរបស់អញយ៉ាងណា គេក៏ស្រឡាញ់កូនប្រពន្ធរបស់គេយ៉ាងនោះដែរ អញមិនត្រូវក្បត់សេចក្ដីស្នេហា ដែលអញបានបូជាប្រពន្ធអញជាស្រេចហើយនោះទេ ។*

**បើអ្នកអានជាស្ត្រីវិញ** ក៏ត្រូវរៀនដូចបុរសដែល ឆ្លែកគ្នាតែត្រង់ពាក្យថា "ជាមួយប្រពន្ធអ្នកដទៃ" មកជា "ប្ដីអ្នកដទៃវិញ" *អញត្រូវរៀនរស់នៅជាមួយនឹងមនុស្សផងគ្នា ដោយមិនពោលពាក្យកុហក ពាក្យជេរប្រទេច ពាក្យញុះញង់បំបែកបំបាក់ ពាក្យរោយរាយឥតប្រយោជន៍ អញត្រូវយកចំណង់របស់គេមកប្រៀបធៀបនឹងចំណង់របស់អញ គឺបើអញមានបំណងចង់ឮពាក្យពិរោះប្រកបដោយខ្លឹមសារយ៉ាងណា គេក៏មានបំណងចង់យ៉ាងនោះដែរ អញត្រូវរៀនរស់នៅជាមួយនឹងមនុស្សផងគ្នា ដោយធ្វើខ្លួនរបស់អាត្មាឲ្យមានសតិសម្បជញ្ញៈយ៉ាងខ្ពង់ខ្ពស់ មានចរិយាយ៉ាងថ្លៃថ្នូរ គឺមិនផឹកសុរាឲ្យខ្លាំងជ្រុលពេក ឬមិនផឹកសោះដោយយកអធ្យាស្រ័យរបស់អ្នកដទៃ មកប្រៀបធៀបនឹងអធ្យាស្រ័យរបស់អញ គឺបើអញមិនចូលចិត្តនឹងកិរិយាមាត់ឡូឡាមួយអន្លើដោយ ការប្រព្រឹត្តឥរិយាបថខុសប្រក្រតី នៃជនអ្នកផឹកសុរាយ៉ាងណា គេក៏មិនចូលចិត្តដូចអាត្មាអញដែរ" ។*

**ជាមួយនឹងអដ្ឋសីល** អ្នកអានគប្បីសិក្សាថា "*អញនឹងរស់នៅជាមួយនឹងព្រហ្មចរិយធម៌ គឺការប្រព្រឹត្តធម៌ប្រសើរ ធម៌មិនមានគូឲ្យអស់យប់មួយថ្ងៃមួយ អញត្រូវតែរស់នៅជាមួយនឹងធម៌នេះឲ្យបាន ដោយឧត្តមគតិរបស់អញថា*

*ជីវិតតែជ្រក់ជ្រេញក្នុងសេចក្តីស្នេហាគ្រប់ពេលទាំងអស់ សេចក្តីស្នេហាវានឹងក្លាយទៅជាគ្រឿងញៀនរបស់ជីវិត ការញៀនសេចក្តីស្នេហាវាអាចនឹងធ្វើឲ្យតមៈធម៌ដែលអាត្មាអញត្រូវប្រព្រឹត្ត ដើម្បីសេចក្តីស្នេហាខ្ពស់បំផុត មានកម្លាំងថយចុះតាមលំដាប់ជាមិនខាន អញនឹងរស់នៅដោយការមិនបរិភោគអាហារក្នុងពេលវិកាល (ពេលថ្ងៃជ្រេពីត្រង់) អស់មួយថ្ងៃនឹងមួយយប់ អញនឹងមិនមើលរបាំ ស្តាប់ចំរៀនស្តាប់ភ្លេងក្នុងយប់មួយថ្ងៃមួយ អញនឹងមិនតាក់តែងកាយដោយគ្រឿងសំអាង និងគ្រឿងសំរើបក្នុងយប់មួយថ្ងៃមួយ អញនឹងមិនដាក់កាយដោយគ្រឿងសំអាង និងគ្រឿងសំរើបក្នុងយប់មួយថ្ងៃមួយ អញនឹងមិនដាក់កាយសម្រេចដំណេកលើទីខ្ពស់ហួសប្រមាណក្នុងយប់មួយថ្ងៃមួយ ដើម្បីធ្វើឲ្យជីវិតរបស់អញមានសេរីភាពក្នុងការស្វែងរកសេចក្តីរស់នៅមួយថ្មី ទៀតដែលជាសេចក្តីរបស់នៅក្រៅអំណាចនៃតណ្ហា និងដើម្បីរំដោះនូវសេចក្តីញៀនរបស់ជីវិត ដោយការតមរៀររបស់អាត្មាអញនេះ" ។*

**ជាមួយនឹងអតិរេកសីល**[១] ឧបាសកឧបាសិកា ឬសាមណេរគប្បីសិក្សាថា "*អញនឹងមិនរស់នៅជាមួយនឹងមាសប្រាក់ តែអញនឹងរស់នៅជាមួយនឹងបច្ច័យ (គ្រឿងសំលៀកបំពាក់ គ្រឿងអាហារ ទីសេនាសនៈ គ្រឿងភេសជ្ជៈ) ។ ឧត្តមគតិរបស់អញ គឺរស់នៅដោយសន្តោសក្នុងបច្ច័យ ៤ នឹងវៀរបង់នូវការសន្សំប្រាក់មាសដើម្បីលើកខ្លួនធ្វើជានាយទុនតាមរបបនៃ លទ្ធិមូលធននិយម" ។*

**ជាមួយនឹងចតុប្បារិសុទ្ធិសីល** ភិក្ខុគប្បីសិក្សាថា : *អញនឹងរស់នៅជាមួយនឹងសិក្ខាបទក្នុងបាតិមោក្ខ តាមសេចក្តីស្ម័គ្ររបស់អញ ដែលបានប្តេជ្ញាថានឹងប្រព្រឹត្តតាមដរាបដល់ជីវិតផ្ទុស គឺអញនឹងមិនប្រព្រឹត្តធម៌គូ គឺសេធមេថុនកម្ម អញនឹងមិននៅក្នុងទីកំបាំងភ្នែកត្រចៀកជាមួយនឹងស្ត្រី អញនឹងមិនចាប់កាន់រូបកាយស្ត្រីដោយសេចក្តីស្នេហា ឬដោយមានបំណងដើម្បីសំរាលនូវសេចក្តីស្នេហា អញនឹងមិនទទួលកាន់មាសប្រាក់ ឬសន្សំមាសប្រាក់ទុកដាក់*

(១) ក្នុងឧបោសថសីល ត្រូវដកយកសិក្ខាបទក្នុងនិច្ចសីលមកបំពេញ
ក្នុងអតិរេកសីល ត្រូវយកសិក្ខាបទ ក្នុងឧបោសថសីលមកបំពេញ

*ដើម្បីធ្វើខ្លួនជាមួយអ្នកមាន អញនឹងមិនជីកដីមិនគួរជីក អញនឹងមិនកាប់ដើមឈើរស់ ឬចាំងជំរះនូវស្មៅស្រស់ ។ល។* **ក្នុងឥន្ទ្រីយ៍សំវរសីល** *អញនឹងសង្រួមនូវឥន្ទ្រីយ៍ ៦ ឲ្យបានល្អភ្នែករបស់អញមើលឲ្យតិចឬមើលឲ្យខ្លី ឬមើលតែរបស់ណាដែលគួរមើល ត្រចៀករបស់អញស្តាប់ឲ្យតិច ឬស្តាប់តែសម្លេងណាដែលគួរស្តាប់ ច្រមុះរបស់អញថើបឲ្យតិចឬថើបតែរបស់ណាដែលគួរឲ្យថើប ឬថើបត្រឹមតែឲ្យដឹងនូវក្លិនយ៉ាងណាៗក្នុងពេលដែលមានសេចក្តីសង្ស័យកើតឡើង អណ្តាតរបស់អញលិឍភក្សឲ្យតិចគឺ ចាប់កាន់តែរបស់ណាដែលគួរលិឍភក្សកាយរបស់អញចាប់កាន់ប៉ះពាល់ឲ្យតិចនឹក ឬនឹកតែអារម្មណ៍ល្អ* **ក្នុងអាជិវបារិសុទ្ធិសីល** *អញនឹងរស់នៅដោយសេចក្តីបរិសុទ្ធិ គឺរស់នៅដោយកម្លាំងស្មង (បិណ្ឌបាត) អញនឹងរស់ដោយបច្ច័យ ដែលកើតឡើងដោយការប្រព្រឹត្តនូវអនេសនៈនិងបាបធម៌ អញនឹងរស់នៅដោយអតិរេកលាភដែលព្រះពុទ្ធបរមគ្រូទ្រង់អនុញ្ញាត អញនឹងរស់នៅដោយអានិសង្សនៃសុចរិតធម៌ដែលខ្លួនអញបានប្រព្រឹត្ត ក្នុងបច្ច័យសន្និស្សិតសីល អញនឹងប្រើប្រាស់បច្ច័យ ៤ ឲ្យល្មមត្រឹមតែរស់ អញនឹងមិនរស់នៅដើម្បីអួតគេដោយអាយុវែង អញនឹងមិនរស់នៅដើម្បីអួតគេដោយចំណេះវិជ្ជា អញនឹងមិនរស់នៅដើម្បីអួតគេដោយសេចក្តីថ្កើងថ្កាននៃជីវិត អញនឹងរស់នៅដើម្បីប្រព្រឹត្តនូវព្រហ្មចរិយធម៌ អញនឹងរស់នៅដើម្បីបំរើនូវឧត្តមគតិនៃពុទ្ធសាសនា ដែលខ្លួនអញស្រឡាញ់ប៉ុណ្ណោះ" ។*

**ជាមួយនឹងមនុស្សគ្រប់សញ្ជាតិ** អ្នកអានគប្បីសិក្សាថា *អញនឹងរស់នៅជាមួយមនុស្សគ្មានទ្រព្យ ដោយធ្វើទាន អញនឹងជួយទំនុកបំរុងមនុស្សខ្សត់ខ្សោយអញនឹងជួយទំនុកបំរុងអង្គការសាសនា។ អញនឹងរស់នៅជាមួយនឹងមនុស្សគ្មានអំណាច ដោយការរក្សាសីល អញនឹងមិនប្រើកម្លាំងស័ក្តិយសសង្កត់សង្កិនមនុស្សទន់ខ្សោយ អញនឹងបំរើមនុស្សទន់ខ្សោយដោយអំណាចណាមួយ ដែលខ្លួនអញមាន។ អញនឹងរស់នៅជាមួយនឹងមនុស្សផ្សេងជាតិផ្សេងភាសា ផ្សេងវណ្ណៈ។ល។ ដោយចិត្តប្រកបដោយមេត្តា ករុណា មុទិតា និងឧបេក្ខា អញស្រឡាញ់គេ អាណិតគេ ចិត្តច្រណែនគេ និងសម្លឹងមើលគេដោយគតិយ៉ាងខ្ពស់គឺតាំងចិត្តឲ្យគេបានសេចក្តីសុខ ឲ្យគេប្រាសចាកសេចក្តី*

*ទុក្ខរបស់គេ ឲ្យគេបានសម្រេចនូវបំណងទាំងអស់ណា ដែលខ្លួនគេចង់បាន"។*

**ជាមួយនឹងសេរីភាព** អ្នកអានគប្បីសិក្សាថា *"ពុទ្ធសាសនារបស់យើងជាសាសនាមានមកសម្រាប់បំរើសេរីភាពរបស់មនុស្ស សត្វ និងធម្មជាតិ ឲ្យមនុស្សម្នាក់ៗមានសេរីភាពរៀបចំការរស់នៅរបស់ខ្លួនក្នុងជីវិតបច្ចុប្បន្នផង ឲ្យរៀបចំជោគវាសនាសម្រាប់ជីវិតអនាគតផង ឲ្យរៀបចំបារមីធម៌ដើម្បីដឹកនាំជីវិតឲ្យបានដល់ទីដៅចុងក្រោយបំផុត គឺព្រះនិព្វានផង ឲ្យសត្វគ្រប់ពួកមានសេរីភាពក្នុងសេចក្តីប៉ងប្រាថ្នាគ្រប់យ៉ាងរបស់វា ឲ្យធម្មជាតិទាំងអស់មានសេរីភាពក្នុងការលូតលាស់ដុះដាល តាមការលៃលកនៃសង្ខតធាតុ។ ពុទ្ធសាសនាមិនដែលបានហាមឃាត់មនុស្សណាម្នាក់ មិនឲ្យប្រើសេរីភាពរបស់គេឡើយ តែពុទ្ធសាសនាមិនអាចនឹងលះបង់នូវសេចក្តីណែនាំ សូមឲ្យគេប្រើសេរីភាពនៅក្នុងល័ខខ័ណ្ឌនៃមនុស្សធម៌ គឺធ្វើយ៉ាងណាកុំឲ្យសេរីភាពទាំងសងខាងប៉ះទង្គិចគ្នាប៉ុណ្ណោះ។*

**ជាមួយនឹងនយោបាយគ្រប់គ្រងរដ្ឋ** ពលរដ្ឋគប្បីសិក្សាថា *"ពុទ្ធសាសនារបស់យើងមិនមែនជាអង្គការនយោបាយទេ តែជាអង្គការនៃមនុស្សធម៌ ពុទ្ធសាសនាបានណែនាំអ្នកកាន់អំណាចគ្រប់គ្រងរដ្ឋ ទោះជាអំណាចខាងនិតិបញ្ញត្តិ ខាងនីតិប្រតិបត្តិក្តី ខាងតុលាការក្តី ឲ្យតម្កល់ខ្លួននៅក្នុងទសពិធរាជធម៌[១] ១០គឺ :*

១-**ទានំ** ការសង្គ្រោះដោយទ្រព្យនូវបុគ្គលម្នាក់ៗ ដែលបានធ្វើការបំរើរដ្ឋដោយស្មោះ និងដោយយកចិត្តទុកដាក់

២- **សីលំ** ការរក្សាមារយាទរបស់ខ្លួន ឲ្យមានរៀបរយនិងឲ្យមានសេចក្តីថ្លៃថ្នូរ

---

(១) ទសពិធរាជធម៌ មិនមែនជាធម៌សម្រាប់តែអង្គព្រះមហាក្សត្រគ្រងរាជ្យទ្រង់ប្រព្រឹត្តទេ បុគ្គលឯក្រៅអំពីអង្គព្រះមហាក្សត្រ តែជាអ្នកកាន់អំណាចរបស់រដ្ឋ ក៏ត្រូវប្រព្រឹត្តធម៌នេះដែរ ព្រោះរាជសព្ទនៅក្នុងទីនេះ ពុំមែនដោយយកតែអំណាចស្តេចគ្រប់គ្រងរាជ្យទេ ប្រធានាធិបតី ព្រះអង្គម្ចាស់ឬបុគ្គលទាំងឡាយណាដែលកាន់អំណាចគ្រប់គ្រងរដ្ឋក្នុងផ្នែកណាមួយ ទោះបីផ្នែកតូចក្តីក៏ត្រូវសង្គ្រោះចូលក្នុងសព្ទរាជនេះដែរ។

៣- **បរិច្ចាគ:** ការបរិច្ចាគទ្រព្យឲ្យជាប្រយោជន៍ដល់អង្គការសាធារណៈនានា

៤- **អាជ្ជវ:** ការធ្វើខ្លួនឲ្យមានអធ្យាស្រ័យស្លូតត្រង់

៥- **មទ្ទវ:** ការធ្វើខ្លួនឲ្យមានអធ្យាស្រ័យទន់ភ្លន់

៦- **តបំ** ព្យាយាមកំចាត់បង់នូវសេចក្ដីអាក្រក់របស់ខ្លួនឲ្យបាន

៧- **អក្កោធ:** មិនមានសេចក្ដីក្រេវក្រោធ

៨- **អវិហឹសា** មិនមានសេចក្ដីបៀតបៀនមនុស្សឥតកំហុស

៩- **ខន្តិ** មានសេចក្ដីអត់ធន់ (អំណត់)

១០- **អវិរោធនំ** មិនមានការប្រព្រឹត្តបំពានលើច្បាប់។

**ចំពោះឋានសួគ៌និងឋាននរក** យើងគប្បីសិក្សាថា "*ពុទ្ធសាសនារបស់យើងពិតមែនតែមិនមានបំណងឲ្យមនុស្សរស់នៅក្នុងឋានសួគ៌។ តែពុទ្ធសាសនា ក៏បាននិយាយអំពីឋានសួគ៌ដូចសាសនាដទៃទាំងឡាយដែរ។ ការស្ដីដល់ឋានសួគ៌នៃពុទ្ធសាសនា មិនមែនជាការចង់បន្លំមនុស្សទេ តែជាការចង់ឲ្យមនុស្សស្គាល់ឋានទាំងអស់នោះតាមប្រពៃណីដែលគេធ្លាប់ស្គាល់ ចង់ឲ្យគេឃើញថា ពុទ្ធសាសនាក៏បានស្គាល់ឋានសួគ៌ដូចគេដែរ ចុងក្រោយបង្អស់គឺចង់ប្រាប់នូវសេចក្ដីពិត ដែលមាននៅក្នុងឋានសួគ៌។* ក្នុងចំណុចថា ឋានសួគ៌នៅឯណានោះ ប្រសិនបើយើងចង់ឆ្លើយសំនួរនេះ យើងត្រូវលើកដល់ការចែកភពនៃពុទ្ធសាសនាដែលបានបញ្ជាក់ថាកាមភពមាន១១ គឺមនុស្សមួយ សួគ៌៦ជាន់ អបាយភូមិ ៤ ភពទាំង១១នេះ ជាលំនៅនៃសត្វបរិភោគកាម។ ក្នុងភពទាំង១១ នេះ លោកចែកចាពីរគឺ : មនុស្សលោកមួយ សួគ៌ ៦ជាន់ ជាសុគតិភព។ អបាយភូមិ ៤ ជាទុគ្គតិភពបើតាមន័យនេះ ស្រុកមនុស្សយើងក៏ជាឋានសួគ៌មួយដែរ សត្វតិរច្ឆានក៏ជាកំណើតនៃអបាយភូមិដែរ។ ដូច្នេះ ដើម្បីកុំឲ្យវានឿយគំនិតរបស់យើងក្នុងរឿនេះពេកយើងត្រូវស្គាល់ត្រឹមតែឋានសួគ៌មួយ នៅក្នុងលោកនៃមនុស្ស និងឋាននរកមួយនៅក្នុងលោកនៃសត្វតិរច្ឆាន តែប៉ុណ្ណឹងក៏បានណាស់ទៅហើយ។ *ចំណែកឋានសួគ៌នរកក្រៅពីនេះ វាមិនមែនជាឋាន*

*មានការចាំបាច់ដល់ជីវិតយើងប៉ុន្មានទេ។* កាលណាពួកអ្នកប្រាជ្ញខាងស្រាវជ្រាវនៃចក្រវាឡ គេរកឃើញពិភពលោកថ្មីទៀតនោះឋានសួគ៌និងឋាននរកនឹងប្រែមកជាវត្ថុធាតុ ដែលយើងត្រូវស្គាល់ក្នុងពេលនោះហើយ។ ម្យ៉ាទៀត យើងត្រូវដឹងថា ពិភពលោកដែលយើងនៅសព្វថ្ងៃនេះ មានដីធំ មានភ្នំច្រើន មានសមុទ្រទឹកសាប មានសមុទ្រទឹកប្រៃ មានសមុទ្រទឹកកក មានសមុទ្រខ្សាច់ មានដីដែលទើបនឹងក្លាយមកអំពីទឹកកក មានភ្លើងដែលប្រកបដោយកំដៅយ៉ាងខ្លាំងនៅក្នុងដី ។ល។ បញ្ហាចោទឡើងថា : មនុស្សជាតិដែលនៅក្នុងទឹកកក នៅក្នុងសមុទ្រខ្សាច់ នៅលើដីដែលទើបនឹងក្លាយមកអំពីទឹកកក នៅលើដីដែលទើបនឹងមានភ្នំភ្លើងផ្ទុះឡើង និងជាឋាននរកក្នុងពិភពលោកយើងនេះបានឬទេ? យ៉ាងណាក៏ដោយចុះ យើងត្រូវកុំភ្លេចថា : *ពុទ្ធសាសនារបស់យើងលោកសរសើរកំណើតរបស់មនុស្ស (កិច្ឆោមនុស្សបដិលាភោ) បង្រៀនមនុស្សឲ្យរស់នៅជាមួយគ្នា បង្រៀនមនុស្សធ្វើចំបាំងវាយលុកទ័ពកិលេសតណ្ហាដើម្បីដឹកនាំជីវិតទៅនៅក្នុងស្ងប់គឺនិព្វាន នេះហើយដែលជាមុខការសំខាន់បំផុតរបស់ពុទ្ធសាសនា ដែលយើងត្រូវធ្វើភ្លាមៗ " ។*

**ជាមួយនឹងនិព្វាន** ពុទ្ធសាសនិកគប្បីសិក្សាថា : *"និព្វានជាគុណធម៌មួយខ្ពស់បំផុត ដែលពុទ្ធសាសនារបស់យើងបានធ្វើការដោះស្រាយច្រើនឥតគណនា។ តែនិព្វានដែលព្រះពុទ្ធបរមគ្រូរបស់យើងបានរកឃើញ បានធ្វើអត្ថាធិប្បាយពន្យល់យើងមកហើយនោះ មិនមែនមានន័យថាសូន្យទេ គឺមានន័យថាដូរផ្លាស់ធម្មជាតិ។ អ្នកចង់បាននិព្វាន ត្រូវខំប្រឹងហាត់រៀនសាងកម្លាំងចិត្តរបស់ខ្លួនឲ្យខ្លាំងពូកែ ឲ្យឈ្នះសេចក្តីស្នេហាតាមធម្មជាតិ ឲ្យឈ្នះសេចក្តីសៅហ្មងដែលតាក់តែងឡើងដោយធម្មជាតិ ខាងចុងបំផុតគឺធ្វើឲ្យធម្មជាតិទាំងអស់នៅក្នុងអំណាចនៃសេចក្តីបង្គាប់របស់ខ្លួន រៀបចំធម្មជាតិឲ្យបានល្អបរិសុទ្ធទៅតាមអំណាចរបស់ខ្លួន លទ្ធផលក្រោយបង្អស់ គឺយើងបានប្រើប្រាស់នូវធម្មជាតិមួយថ្មីទៀត ដែលបានផ្លាស់មកពីធម្មជាតិទាំងឡាយនុ៎ះឯង ហ្នឹងហើយនិព្វាន" ។*

មេរៀនទាំងអស់ដែលខ្ញុំបាននិយាយមកនេះ ក្នុងមេរៀននិមួយៗពុំមានសេចក្តីពិស្តារទេ ហើយពុំបានគ្រប់មេរៀនផង តែខ្ញុំមានសេចក្តីសង្ឃឹមថា អ្នកអានគង់យល់បាននូវវត្ថុបំណងនិងឧត្តមគតិរបស់ព្រះពុទ្ធសាសនាយើង ហើយ។ ក្នុងទីបំផុតនេះ ខ្ញុំសូមប្រមូលឡើងវិញនូវគំនិតខ្លះរបស់ខ្ញុំ ព្រមមួយអន្លើដោយសេចក្តីជាស់តឿនខ្លះ ដែលត្រូវខ្ញុំធ្វើជាមួយនឹងអ្នកអាន ដូចមានតទៅនេះ ៖

១- **ព្រះពុទ្ធសាសនា** *ពុំដែលបានបង្ខំអ្នកណាម្នាក់ឲ្យជឿធម្មៈ ឬឲ្យប្រព្រឹត្តធម្មៈដោយប្រើកម្លាំងទេ*

២- **ព្រះពុទ្ធសាសនា** *ពុំបានបបួលអ្នកណាម្នាក់ឲ្យទៅនៅឋានសួគ៌ ប្រសិនណាបើចិត្តគេមិនចង់ទៅ*

*៣-* **ព្រះពុទ្ធសាសនា** *ពុំដែលបានយល់ព្រមជាមួយនឹងមនុស្សណាម្នាក់ ដែលបានធ្វើនូវទំហឺអាក្រក់ ហើយមកសូមសេចក្តីយល់ព្រម*

*៤-* **ព្រះពុទ្ធសាសនា** *ពុំដែលបានភ្លេចនូវតួនាទីរបស់ខ្លួន ក្នុងការដឹកនាំមនុស្សឲ្យធ្វើសេចក្តីល្អ និងពុំដែលខានសរសើរមនុស្សណា ដែលបានប្រព្រឹត្តនូវអំពើល្អឡើយ*

*៥-* ***ព្រះពុទ្ធសាសនា*** *ពុំដែលបានធ្វើឲ្យមនុស្សណាម្នាក់លះបង់ចោលនូវបំណងរបស់ខ្លួនឡើយ ប្រសិនបើគេមិនបានសូមឲ្យជួយគិតគូរ។*

ប្រជាជាតិខ្មែរយើង គួរតែនាំគ្នាដោះស្រាយនូវបញ្ហាជីវិតរបស់ខ្លួន ឲ្យស្របតាមបំណងនិងឧត្តមគតិនៃពុទ្ធសាសនា *ជាដំបូងគឺយើងត្រូវស្រាយបញ្ហាជីវិតក្នុងផ្លូវបច្ចុប្បន្ន បន្ទាប់មកត្រូវស្រាយបញ្ហាជីវិតខាងផ្លូវអនាគត ចុងបំផុតស្រាយបញ្ហាជីវិតខាងផ្លូវនៃនិព្វាន។* យើងត្រូវមានសេចក្តីអត់ធន់ក្លាហានអង់អាច យើងត្រូវតស៊ូយកឈ្នះធម្មជាតិ ឈ្នះសត្វ ឈ្នះមនុស្សគ្នាឯង ឈ្នះព្រឹត្តិការណ៍នានាដែលជ្រៀតជ្រែកចូលមក ដោយការតស៊ូរបស់យើងប្រកបដោយសេចក្តីយុត្តិធម៌។ ក្នុងពិភពលោកបច្ចុប្បន្ននេះ មនុស្សជាតិកំពុងតែដណ្តើមប្រជែងគ្នាធ្វើការ ដើម្បីជីវិតរបស់ខ្លួនបានរស់នៅស្រួល។ នៅក្នុងស្រុកសង្គម

និយមឆ្វេងផុត មានភាសិតក្រើនរំលឹកឲ្យមនុស្សធ្វើការថា "*កនយើងត្រូវធ្វើការទាំងអស់គ្នា កនយើងត្រូវចែកការងារគ្នាធ្វើ តាមកម្លាំងនៃរូបកាយ និងតាមកម្លាំងសមត្ថភាពនៃខួរក្បាល អ្នកណាធ្វើការបានច្រើនអ្នកនោះត្រូវបានស៊ីច្រើន អ្នកណាអ្នកធ្វើការតិចអ្នកនោះត្រូវបានស៊ីតិច អ្នកណាពុំបានធ្វើការសោះអ្នកនោះត្រូវបានអត់*" ។

**ក្នុងប្រទេសខ្មែរយើង** *ប្រជាជាតិគ្រប់វណ្ណៈ គ្រប់ពណ៌សម្បុរ គួរតែបំបែកគ្នាធ្វើការតាមសមត្ថភាព អ្នកខ្លះលក់ដូរ អ្នកខ្លះធ្វើជាងសំណង់ អ្នកខ្លះធ្វើក្បួនតម្រា អ្នកខ្លះធ្វើគ្រូបង្រៀន អ្នកខ្លះធ្វើការកសិកម្ម អ្នកខ្លះចិញ្ចឹមសត្វដើម្បីប្រើកម្លាំងដើម្បីលក់រោម ដើម្បីលក់ទឹកដោះ និងដើម្បីអ្វីៗទៅទៀត ប្រសិនបើអាចនឹងធ្វើបាន។ល។ កាលណាយើងព្រមព្រៀងគ្នាធ្វើការ ធ្វើការតាមសមត្ថភាពនៃរូបកាយធ្វើការតាមសមត្ថភាពនៃចិត្តវិញ្ញាណនោះ ខ្ញុំយល់ថាមនុស្សយើងគ្រប់វណ្ណៈ គង់ធ្វើការបានទាំងអស់គ្នាគ្មានសល់មនុស្សណាម្នាក់ទេ ប្រសិនបើគេមានចិត្តស្រឡាញ់ការ ចង់ធ្វើការ ជាគ្រហស្ថត្រូវធ្វើការរបស់គ្រហស្ថ ជាអ្នកបួសត្រូវធ្វើការរបស់អ្នកបួស។* **ចំពោះអ្នកបួស** ខ្ញុំបាននិយាយមកម្តងហើយថា *អ្នកបួសមិនមែនមានករណីយ៍ ត្រឹមតែបួស ត្រឹមតែឆាន់ ត្រឹមតែសឹង ត្រឹមតែកាន់ទំនៀមទំលាប់ប្រពៃណី ត្រឹមតែអាយុវស្សា។ល។ ប៉ុណ្ណោះទេ គឺមានករណីយ៍ត្រូវខំប្រឹងរៀននូវវិជ្ជានៃពុទ្ធសាសនា ឬវិជ្ជាលោក ដែលត្រូវប្រើជាមួយនឹងវិជ្ជានៃពុទ្ធសាសនា ឲ្យបានចេះដឹងជ្រៅជ្រះ ហើយត្រូវធ្វើការឃោសនាពន្យល់ឲ្យមនុស្សស្គាល់បញ្ហាជីវិតដោយទេសនាក្តី ដោយបង្រៀនក្តី ដោយធ្វើសន្និសិទក្តី ដោយសរសេរតម្រាក្បួនខ្នាតក្តី ។ល។ ប្រសិនបើអ្នកបួសរូបណាមិនមានសមត្ថភាព នឹងធ្វើការអស់ទាំងនោះបានទេ អ្នកបួសនោះត្រូវធ្វើការដោយកម្លាំងរូបកាយ មានការលើសែងកាប់គាស់ចូកចាំងជាដើម ទាំងការផ្ទាល់ខ្លួន ទាំងការរបស់សង្គមមនុស្ស ។ វិន័យមិនបានហាមមិនឲ្យភិក្ខុធ្វើការទេ តែវិន័យហាមមិនឲ្យភិក្ខុធ្វើការណាដែលវិន័យបានហាម។*

វិន័យត្រង់ចំណុចនេះ យើងត្រូវបកស្រាយថា : *បំណងរបស់វិន័យ ត្រូវ*

*ការឲ្យភិក្ខុទាំងអស់ធ្វើការជាប្រាកដ ប្រសិនបើវិន័យមិនមានបំណងឲ្យភិក្ខុធ្វើការទេវិន័យនឹងមិនហាមភិក្ខុមិនឲ្យជីកត្រឹមតែដីសើម ជំរះស្មៅស្រស់ កាប់ឈើរស់ប៉ុណ្ណោះទេ វិន័យនឹងហាមភិក្ខុមិនឲ្យជីកដីក្រៀម ជំរះស្មៅស្ងួត កាប់ឈើងាប់ទាំងអស់ស្រេចតែម្តង។ វិន័យមិនបានហាមភិក្ខុមិនឲ្យធ្វើការងារទេ តែវិន័យបានហាមភិក្ខុមិនឲ្យធ្វើការបំរើត្រកូល ក្នុងបំណងថាឲ្យត្រកូលដែលខ្លួនបំរើនោះ គេមកបំរើខ្លួនវិញ ឬចង់ឲ្យគេសងកម្លាំងរបស់ខ្លួនដោយបច្ច័យទាំងឡាយ មានបិណ្ឌបាតបច្ច័យជាដើម។* វិន័យក្នុងចំណុចនេះ យើងត្រូវបកស្រាយថា ភិក្ខុនឹងធ្វើការបំរើត្រកូលមួយៗក្តី បំរើសង្គមជាតិក្តី បំរើសង្គមមនុស្សទូទៅក្តី បានទាំងអស់ ប្រសិនបើភិក្ខុធ្វើដោយសេចក្តីសង្គ្រោះ ដោយមិនសម្លឹងអាមិស ដោយមិនទារយកសំណងអំពីគេ។

**បើតាមបំណងវិន័យ** ដែលខ្ញុំបានបកស្រាយមកនេះឃើញថា *ភិក្ខុមួយរូបៗត្រូវតែធ្វើការ បើធ្វើការនេះមិនកើត ត្រូវធ្វើការនោះ ជីកដីសើមមិនបាន ជីកដីក្រៀម ជំរះស្មៅស្រស់មិនបាន ជំរះស្មៅស្ងួត កាប់ឈើរស់មិនបាន កាប់ឈើងាប់ធ្វើយ៉ាងណាទាល់តែបាន ព្រោះការងារមិនមែនត្រឹមតែជាវត្ថុធាតុសម្រាប់ធ្វើឲ្យមនុស្សរស់នៅប៉ុណ្ណោះទេ គឺជាវត្ថុធាតុមានតម្លៃសម្រាប់ខ្លួនមនុស្សម្នាក់ៗផង មានតម្លៃសម្រាប់ពិភពលោកដែលជាលំនៅរបស់មនុស្សទាំងអស់គ្នាផង។*

ទ្រឹស្តីនៃពុទ្ធសាសនា ត្រង់ចំណុចដែលស្តីដោយ "**បុព្វេកតបុញ្ញតា**" មានសេចក្តីថា "**បុគ្គលមានបុណ្យបានធ្វើមកហើយអំពីដើម**" នឹងបានសេចក្តីសុខចំរើនក្នុងកាលឥឡូវនេះនោះ យើងមិនត្រូវបកស្រាយថា សាសនានេះបង្រៀនមនុស្សឲ្យដេកផ្សងព្រេងចាំបុណ្យជួយខ្លួនទេ គឺត្រូវបកស្រាយថា បុណ្យនឹងជួយទំនុកបំរុងអ្នកមានបុណ្យ ឲ្យធ្វើការឆាប់បានសម្រេចផល។ ដូច្នេះ ខ្មែរយើងទាំងអស់គ្នាត្រូវខំប្រឹងធ្វើការតាមនាទីរៀងៗខ្លួន នៅក្នុងវត្ថុបំណង និងឧត្តមគតិតែមួយ គឺដំបូងត្រូវធ្វើខ្លួនឲ្យអស់នូវសេចក្តីទុក្ខធម្មតា ឲ្យបាននូវសេចក្តីសុខធម្មតា។ បន្ទាប់មកត្រូវលះបង់សេចក្តីសុខធម្មតា សេចក្តី

សុខមិនពិត ចុងបំផុតត្រូវធ្វើខ្លួនឲ្យបានដល់នូវបរមសុខ គឺសេចក្តីសុខពិតប្រាកដ ដែលហៅថា "**និព្វាន**" ។ តាមសេចក្តីពិត "**និព្វាន**" ខ្ញុំមិនយល់ថាបានសម្រេចដោយសេចក្តីខ្ជិលច្រអូសទេ គឺបានសម្រេចដោយសេចក្តីឧស្សាហ៍ ដែលមនុស្សម្នាក់ៗបានធ្វើការបំរើជីវិតរបស់ខ្លួន និងជីវិតរបស់បុគ្គលដទៃចប់ស្រេចហើយនុ៎ះឯង។ និព្វានដែលគេបានដោយចប់ការងារនោះគឺជានិព្វានរបស់ព្រះសម្មាសម្ពុទ្ធ ក្នុងថ្ងៃបានត្រាស់ដឹងនូវសម្មាសម្ពោធិញ្ញាណ និង (**ឧប្បាទិសេសនិព្វាន**) " ។ និព្វានដែលបានក្នុងថ្ងៃជីវិតក្នុងបច្ឆិមជាតិនៃព្រះអរហន្តទាំងឡាយ មានព្រះពុទ្ធជាដើមហៅថា "**អនុប្បាទិសេសនិព្វាន**" ។ និព្វានដែលគេបានក្នុងពេលកំពុងប្រតិបត្តិការជិតនឹងចប់ គឺជានិព្វានរបស់ព្រះអរិយបុគ្គលថ្នាក់ទាបនិងថ្នាក់កណ្តាលហៅថា "**មគ្គនិព្វាន**" ។ ចំណែកខាងមនុស្សធម្មតាដែលកំពុងកសាងសព្វថ្ងៃនេះ ពុំទាន់បានសម្រេចនូវនិព្វានទាំងអស់នោះទេ ប៉ុន្តែគេគង់នឹងបានសម្រេចនូវនិព្វានដែលខ្ញុំឲ្យឈ្មោះថា "**និព្វានដើម្បី**" នោះដែរ។ ដូចម្តេចហៅថា "**និព្វានដើម្បី**" សំនួរនេះ បើយើងចង់ឆ្លើយ យើងត្រូវរំលឹកដល់អត្ថបទនៃនិព្វាន ដែលអ្នកប្រាជ្ញនៃពុទ្ធសាសនាទាំងឡាយបានពណ៌នាថា "**មទនិម្មទនោ**" និព្វានជាគុណធម៌ញាំញីនូវសេចក្តីស្រវឹង "**បិបាសវិនយោ**" និព្វានជាគុណធម៌ដកចេញនូវសេចក្តីអាល័យ "**វដ្តុបច្ឆេទនោ**" និព្វានជាគុណធម៌កាត់ផ្តាច់នូវវដ្ត គឺកិលេសជាគ្រឿងញុំាងសត្វឲ្យវិលវល់កើតចាស់ឈឺស្លាប់ "**តណ្ហក្ខយោ**" និព្វានជាទីអស់ទៅនៃតណ្ហា "**វិរាគោ**" និព្វានជាទី ប្រាសចាករាគ "**និរោធោ**" និព្វានជាទីរំលត់បង់នូវគ្រឿងសៅហ្មង "**និព្វានំ**" និព្វានជាគុណធម៌នាំចេញនូវគ្រឿងជំពាក់របស់ធម្មជាតិទាំងអស់។

និព្វានគេមិនអាចស្គាល់បាន ដោយមេទន្ទេញទេ តែគេអាចស្គាល់បានដោយធ្វើការពិសោធន៍តាមទន្ទេញ ប្រៀបបាននឹងអ្នកសិក្សាវិទ្យាសាស្ត្រ ដែលពុំអាចស្គាល់បាននូវធាតុអាតូម (បរមាណូ) ដោយមេទន្ទេញទេ តែគេអាចស្គាល់បានដោយការធ្វើពិសោធន៍តាមមេទន្ទេញ។ ដូច្នេះ អ្នកចង់បាននិព្វានខាងក្រោយដែលបានចាំអត្ថនៃនិព្វានហើយ ត្រូវប្រតិបត្តិតាមអត្ថទាំងអស់នោះ

ហើយត្រូវធ្វើការពិសោធន៍ក្នុងចិត្តរបស់ខ្លួនដើម្បីដឹងថា : និព្វាននាំឲ្យបាននូវសេចក្តីសុខស្ងប់យ៉ាងពិសេសមែនឬទេ? ។ តាមការពិនិត្យរបស់ខ្ញុំ ខ្ញុំពុំដែលបានឃើញមនុស្សណាម្នាក់ បានសេចក្តីសុខស្រួល ដោយមានត្រឹមតែប្តីប្រពន្ធ ឪពុកម្តាយ ទ្រព្យសម្បត្តិយសសក្តិ ។ល។ ប៉ុណ្ណោះទេ។ តែខ្ញុំឃើញគេមានសេចក្តីសុខស្រួល ដោយគេចេះប្រើសេចក្តីស្នេហារបស់គេឲ្យមានសេចក្តីបរិសុទ្ធ គេចេះគោរពឪពុកម្តាយរបស់គេ គេមិនប្រើកម្លាំងទ្រព្យសម្បត្តិយសសក្តិជិះជាន់អ្នកដទៃ។ នៅក្នុងលោកនេះអ្នកណាក៏សឹងតែបានដឹងហើយថា ចំបាំងតែងកើតឡើងអំពីសេចក្តីស្នេហា ដែមមនុស្សម្នាក់ៗបានប្រព្រឹត្តឲ្យហួសព្រំដែន សេចក្តីស្នេហាក្នុងទីនេះ មិនមែនដៅយកត្រឹមតែសេចក្តីស្នេហាក្នុងបុរសស្ត្រីប៉ុណ្ណោះទេ គឺដៅសេចក្តីស្នេហាក្នុងវត្ថុធាតុទាំងឡាយ ទោះជាវត្ថុធាតុនោះមានជីវិតក្តី មិនមានជីវិតក្តី ។ ម្យ៉ាងទៀតពាក្យថាស្នេហានេះ ជាគូនឹងពាក្យពីរម៉ាត់ទៀតគឺ "**រាគៈ**" និង "**តណ្ហា**" ពាក្យទាំងអស់នេះមានសម្លេងខុសគ្នា តែមានសេចក្តីត្រូវគ្នា គឺចំណង់ក្នុងផ្លូវកាមនេះឯង។ ពុទ្ធសាសនារបស់យើងបានបង្រៀនយើងថា "**តណ្ហាជាហេតុនៃទុក្ខ**" មេរៀននេះ មិនមានអ្នកណាអាចបដិសេធបានទេ *ព្រោះតណ្ហាដែលគេប្រើឲ្យហួសព្រំដែន ឬដែលគេប្រើដោយគ្មានសំចៃនោះ រមែងតែងនាំឲ្យមានទុក្ខ។ បើតណ្ហានោះមានតិចក៏ទុក្ខ បើមានល្មមក៏ទុក្ខល្មម បើមានច្រើនក៏ទុក្ខច្រើន។* អ្នកអានទាំងឡាយគប្បីដឹងថា *ចំបាំងរវាងព្រះរាមនឹងក្រុងរាបក្តី ចំបាំងរវាងព្រះឥន្ទនឹងសេចក្តីសុរក្តី សង្គ្រាមលោកលើទី ១ ក្តី សង្គ្រាមលោកលើកទី២ ក្តី។ល។ សង្គ្រាមទាំងអស់នេះ សុទ្ធតែកើតឡើងដោយតណ្ហា គឺការលួចប្រពន្ធកូនគេ ការពង្រីកអំណាចនៃសេចក្តីកិច្ច និងការស្វែងរកប្រភេទនៃអាណានិគមរបស់ប្រទេសមហាអំណាចទាំងឡាយ ។ល។ ក្នុងអនាគតកាល គេអាចទាយបានថា : នឹងមានចំបាំងថ្មីកើតឡើងទៀត ដោយការផ្សាយអំណាចនៃលទ្ធិនយោបាយ និងការផ្សាយអំណាចនៃលទ្ធិសេដ្ឋកិច្ច ទាំងពីរយ៉ាងនេះ យ៉ាងណាមួយជាមិនខានឡើយ។*

ដូច្នេះ ការរស់នៅជាមួយនឹងព្រះពុទ្ធសាសនារបស់យើង មិនមែនជាការ

ខុសទេ ប្រសិនណាយើងចង់បានសេចក្តីសុខពិតមែន ព្រោះគោលបំណងនិងឧត្តមគតិនៃពុទ្ធសាសនា មិនមានអ្វីក្រៅពីធ្វើមនុស្សឲ្យរស់នៅបានស្រួល ហើយដែលមនុស្សគ្រប់គ្នាក៏តែងតែចង់បានដូច្នេះដែរ។ ដើម្បីសម្រេចនូវបំណងនេះ មនុស្សម្នាក់ៗនឹងធ្វើការដើម្បីរស់នៅក្នុងផ្លូវណាក៏បាន តែត្រូវកុំភ្លេចថា *ខ្លួនយើងទាំងអស់គ្នា មិនមែនត្រូវការត្រឹមតែសេចក្តីសុខប៉ុណ្ណោះទេ គឺចង់បានសេចក្តីស្ងប់ផង បើដូច្នេះមុខងាររបស់យើង មិនមែនមានត្រឹមតែធ្វើការឲ្យកើតទេ តែត្រូវធ្វើការឲ្យបានផលល្អផង ។ មានតែការល្អទេ ដែលអាចធ្វើមនុស្សឲ្យបានសេចក្តីសុខ ព្រមមួយអន្លើដោយសេចក្តីស្ងប់ សេចក្តីសុខគេរកបានដោយងាយ តែសេចក្តីស្ងប់គេមិនងាយនឹងរកបានទេ។ ទ្រព្យសម្បត្តិបានដោយផ្លូវទុច្ចរិត ស្នេហាបានដោយបង្ខំ ស្វាមីភរិយារៀនមង្គលការដោយមានសេចក្តីស្នេហាមិនស្មើគ្នា ឬមិនមានសេចក្តីស្នេហាទាំងសងខាង ធ្វើទានចង់បានទ្រព្យ ឬចង់បានកេរ្តិ៍ឈ្មោះ រក្សាសីលចង់បានយសស័ក្តិ ឬចង់ឲ្យគេអួតខ្លួនថាជាមនុស្សល្អ ភាវនាធម៌ចង់ឃើញឋានសួគ៌ ឬចង់ទៅនៅឋានព្រហ្ម ទាំងអស់នេះបានផលត្រឹមតែសេចក្តីសុខពុំបានសេចក្តីស្ងប់ទេ ។*

**ពួកយើងពុទ្ធសាសនិក** *ត្រូវរកទ្រព្យដោយកម្លាំងរបស់ខ្លួន មិនបៀតបៀនអ្នកដទៃ រកគូស្នេហាដោយស្ម័គ្រចិត្ត ចូលកាន់មង្គលការដោយចិត្តស្នេហា មិនមែនដោយសម្លឹងឃើញទ្រព្យសម្បត្តិយសស័ក្តិខ្វាងៗ ធ្វើទានដោយចិត្តមេត្តា ដោយសេចក្តីសង្គ្រោះ រក្សាសីលដោយចិត្តករុណា ដោយសេចក្តីគោរពមនុស្សជាតិភាវនាធម៌ដោយចិត្តសប្បុរស ដោយនឹកថាសូមឲ្យមនុស្សទាំងអស់បានសេចក្តីសុខចំរើនដូចៗគ្នា ។* កាលណាយើងធ្វើទានដូចនេះ យើងនឹងបានសេចក្តីសុខស្ងប់ដែលខ្ញុំឲ្យឈ្មោះថា "**និព្វាន**" តែពុំមែនជានិព្វានរបស់ព្រះអរហន្តទាំងឡាយទេ គឺជា "**និព្វានដើម្បី**" នុះឯង។ "**និព្វានដើម្បី**" មានន័យថា *និព្វានដែលបានសម្រេចក្នុងជីវិតបច្ចុប្បន្ន ដោយមកពីគេធ្វើការអ្វីៗ គេធ្វើដើម្បីនិព្វាន គឺគេរកទ្រព្យសម្បត្តិដើម្បីនិព្វាន គេរកយសស័ក្តិដើម្បីនិព្វាន ។ល។* "**និព្វានដើម្បី**" នេះគឺជាជណ្តើរនៃនិព្វានរបស់ព្រះអរហន្ត ។ និព្វានរបស់ព្រះ

អរហន្តនេះហើយ ដែលជាទីដៅចុងក្រោយបង្អស់នៃពុទ្ធសាសនារបស់យើង។ ដូច្នេះគ្នាយើងទាំងអស់គប្បីរស់នៅជាមួយនឹងពុទ្ធសាសនា តាមរបៀបដែលខ្ញុំបាននិយាយមកហើយនោះចុះប្រសិនណាបើយល់ឃើញថា : *ការដោះស្រាយបញ្ហាជីវិតតាមរបៀបនេះ ល្អជាងរបៀបទាំងឡាយ ដែលពិភពលោកកំពុងធ្វើសព្វថ្ងៃនេះ* ។

# ចប់

□ □
□